PESTECH



Leaping forward sustainably

# ENERGISING GROWTH SUSTAINABLY

ANNUAL REPORT 2022




## ការបង្កើនថាមពលប្រកបដោយនិរន្តរភាព

ក្របសៀវភៅក្នុងឆ្នាំនេះ បង្ហាញពីការប្តេជ្ញាចិត្តយ៉ាងអង់អាច តាមរយៈរូបភាពរបស់កីឡាករមួយរូបដែលហក់លោតផុតរនាំងឧបសគ្គនិងការឆ្លុះបញ្ចាំងពីភាពរហ័សរហួននិងកម្លាំងដែលត្រូវការដើម្បីយកឈ្នះបញ្ហាទាំងឡាយនៅក្នុងឆ្នាំនេះ។ ខ្សែបន្ទាត់ដ៏មានថាមពលទាំងនោះបង្ហាញពីតម្រូវការកាន់តែច្រើននៃល្បឿនក្នុងប្រតិបត្តិការឌីជីថលតាមរយៈការផ្សារភ្ជាប់ទៅនឹងសមត្ថភាពឌីជីថល។ ពណ៌ខៀវរាងប្រផេះប្តូរទៅជា ពណ៌ទឹកក្រូចដ៏មានអំណាច និងពណ៌ក្រហមដែលតំណាងឲ្យក្រុមហ៊ុន PESTECH បង្ហាញពីសមត្ថភាពក្នុងការប្រមូលផ្តុំយុទ្ធសាស្ត្រយ៉ាងឆាប់រហ័សដើម្បីដាក់ចេញជាសកម្មភាព។

## លើកទី ៣ កិច្ចប្រជុំមហាសន្និបាត

ថ្ងៃព្រហស្បតិ៍ ទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២

១០.០០ ព្រឹក

បន្ទប់ប្រជុំស្វីតលេខ៤ ជាន់ទីពីរ
សណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ
ផ្ទះលេខ៥៥ ផ្លូវ១៧៨ សង្កាត់ ជ័យជំនះ
១២២០៦ រាជធានីភ្នំពេញ កម្ពុជា

# នៅក្នុងរបាយការណ៍នេះ









### ចក្ខុវិស័យ

០១ ទស្សនវិស័យ និង បេសកកម្ម
០២ ព័ត៌មានហិរញ្ញវត្ថុសង្ខេប
០៣ ក្រាហ្វិកអំពីហិរញ្ញវត្ថុ
០៤ សមាសភាពក្រុមប្រឹក្សាភិបាល
០៦ សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល
០៧ សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

### ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

០៨ អត្តសញ្ញាណរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ
០៩ ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ
១៤ ស្ថានភាពទីផ្សារ
១៥ ស្ថានភាពប្រកួតប្រជែង
១៥ ផែនការអនាគត
១៥ កត្តាហានិភ័យ

### ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

២១ លទ្ធផលនៃការដំណើរការធុរកិច្ច
២១ រចនាសម្ព័ន្ធប្រាក់ចំណូល

### ផ្នែកទី ៣ - ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

២២ រចនាសម្ព័ន្ធគ្រប់គ្រង
២២ សមាសភាពក្រុមប្រឹក្សាភិបាល
២២ លេខាធិការក្រុមហ៊ុន

### ផ្នែកទី ៤ - ព័ត៌មានអំពីការជួញដូរនិងភាគហ៊ុនិករបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

២៣ ព័ត៌មានអំពីមូលបត្រ
២៣ ថ្លៃ និងបរិមាណការជួញដូរមូលបត្រ
២៣ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់
២៣ ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

### ផ្នែកទី ៥ - របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

២៤ របាយការណ៍សវនកម្មលើការត្រួតពិនិត្យផ្ទៃក្នុង

# នៅក្នុង របាយការណ៍នេះ

## ផ្នែកទី ៦ - របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ


២៤ របាយការណ៍ហិរញ្ញវត្ថុ


## ផ្នែកទី ៧ - ព័ត៌មានអំពីប្រតិបត្តិការនានាដែលពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍


៨៨ ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥% ឡើងទៅ

៨៨ ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់

៨៨ ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកដែលពាក់ព័ន្ធនឹងការទិញ/លក់ទ្រព្យសកម្ម និងសេវាកម្ម

៨៨ ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនយ៉ាងតិច ៥% ឡើងទៅ

៨៨ ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ បុត្រសម្ព័ន្ធ ឬ ក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

៨៨ ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធនឹងបុគ្គលធ្លាប់ជាអភិបាល

៨៨ ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គការ មិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត ក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ

៨៨ ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ


## ផ្នែកទី ៨ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង


៨៩ ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

៨៩ កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ

៨៩ ការប្រែប្រួលសំខាន់ៗនៅក្នុងការលក់ និងប្រាក់ចំណូល

៩០ ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ

៩០ ផលប៉ះពាល់នៃអតិផរណា

៩០ គោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល


## ផ្នែកទី ៩ - ព័ត៌មានដែលចាំបាច់ផ្សេងទៀតការការពារវិនិយោគិន (ប្រសិនបើមាន)


៩១ ព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន

៩២ ហត្ថលេខារបស់អភិបាលក្រុមហ៊ុន

៩៣ ឧបសម្ព័ន្ធ៖របាយការណ៍ស្តីពីអភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំដែលបានកំណត់ដោយអគ្គនាយកនៃ ន.ម.ក។




# ព័ត៌មាន
# អំពីក្រុមហ៊ុន

## ចក្ខុវិស័យ

ភាពឋិតថេរប្រកបដោយសង្គតិភាព
និងគុណសម្បត្តិបន្ថែម
ក្នុងភាពជាអ្នកស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ
អគ្គិសនីប្រកបដោយចីរភាព

## បេសកកម្ម

**ប្រសិទ្ធិភាព** ក្នុងការបំពេញភារកិច្ចនិងផ្តល់សេវាកម្មនានាជូនអតិថិជនក្នុងនិងក្រៅតំបន់។

**ប្រសិទ្ធផល** ក្នុងការដឹកនាំការងារនិងសេវាកម្មដើម្បីទទួលបាននូវលទ្ធផលជាអតិបរមាក្នុងរយៈពេលដ៏ខ្លី។

**ឧត្តមភាព** ដែលផ្តល់ជូនអតិថិជនលើសពីបរិមាណ និងគុណសម្បត្តិបន្ថែមដល់ការវិនិយោគរបស់ពួកគាត់។

# ទិន្នន័យ
# ហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ឆ្នាំ ២០២២ (លានរៀល) | ឆ្នាំ ២០២១ (លានរៀល) | ឆ្នាំ ២០២០ (លានរៀល) |
|---|---|---|---|---|
| ស្ថានភាពហិរញ្ញវត្ថុ | | | | |
| ទ្រព្យសកម្មសរុប | | ១ ២០២ ២៨២ | ១ ១៦៦ ៨៨២ | ១ ០១៦ ១១២ |
| បំណុលសរុប | | ១ ០៩២ ២៦៦ | ១ ០៧២ ៩៨៥ | ៩៤៦ ១៥៥ |
| មូលធនសរុប | | ១១០ ០១៦ | ៩៣ ៨៩៧ | ៦៩ ៩៥៧ |
| ចំណេញ (ខាត) | | | | |
| ចំណូលសរុប | | ២១៦ ៣៥៥ | ២៧៣ ៦២៨ | ២០៣ ០១៤ |
| ចំណេញមុនបង់ពន្ធ | | ៥ ៤៨៣ | ១០ ០៨៨ | ៣៧ ៧៧៦ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | ២ ៤៧០ | ៥ ៩៨០ | ២៩ ៤៤៣ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ១៨ ១០៤ | ១១ ៦៦២ | ១៣ ៣២៥ |
| អនុបាតហិរញ្ញវត្ថុ | | | | |
| អនុបាតសាធនភាព | | ១,៦៨% | ២,៤០% | ៧,៤៣% |
| អនុបាតសាធនភាព (ប្រាក់កម្ចីទូទៅ)* | | ១៥,៩៥% | ៤៩,៩៣% | ២០៣,៨៧% |
| អនុបាតបំណុលធៀបនឹងមូលធន | | ៩,៩៣ | ១១,៤៣ | ១៣,៥២ |
| អនុបាតបំណុលធៀបនឹងមូលធន (មិនរួមបញ្ចូលកម្ចីរយៈពេលវែង)** | | ០,៤០ | ០,២២ | ០,២៤ |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ០,៩៣ | ០,៩០ | ០,២៨ |
| | អនុបាតចរន្តលឿន | ០,៩២ | ០,៨៨ | ០,២៤ |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | ០,២១% | ០,៥១% | ២,៩០% |
| | អនុបាតចំណេញធៀបនឹងមូលធន | ២,២៥% | ៦,៣៧% | ៤២,០៩% |
| | អនុបាតគម្លាតចំណេញភាព | ១,១៤% | ២,១៩% | ១៤,៥០% |
| | អនុបាតគម្លាតចំណេញដុល | ១៧,៥៦% | ១៦,៣៤% | ៣៨.០២% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | ៣២,៩៦ រៀល | ៧៥,៨៦ រៀល | ៤១៤,៨៦ រៀល |
| អនុភាពលទ្ធភាពបង់ការប្រាក់ | | ០,៧៩ | ១,២២ | ២,៣៩ |

* កម្ចីទូទៅរួមមាន ឥណទានបង្វិល និងឥណទានវិបារូបន៍ ដោយមិនរាប់បញ្ចូលលក្ខខណ្ឌកម្ចីរយៈពេលវែងដែលធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេល ដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គិសនីកម្ពុជា។

** លក្ខខណ្ឌកម្ចីរយៈពេលវែងសំដៅទៅលើការខ្ចីដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេល ដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គិសនីកម្ពុជា។

# ក្រាហ្វិកអំពីព័ត៌មាន
# ហិរញ្ញវត្ថុសង្ខេប

## ចំណូលសរុប និងចំណេញដុល
## សម្រាប់ ឆ្នាំ២០២២




## ការរួមចំណែកចំណេញមុនបង់ការប្រាក់ និងពន្ធតាមផ្នែក
## សម្រាប់ ឆ្នាំ២០២២




## ការប្រមូលតាមផ្នែកសម្រាប់
## ឆ្នាំ២០២២



# សមាសភាព
# ក្រុមប្រឹក្សាភិបាល

**ជាវ អានសាន**

អភិបាលឯករាជ្យ

**PAUL LIM PAY CHUAN**

ប្រធានក្រុមប្រឹក្សាភិបាល



**HAN FATT JUAN**
អភិបាលប្រតិបត្តិ/នាយកប្រតិបត្តិ

**LIM AH HOCK**
អភិបាលប្រតិបត្តិ

**CHARLES TAN PU HOOI**
អភិបាលប្រតិបត្តិ



# សេចក្តីថ្លែងរបស់
# ប្រធានក្រុមប្រឹក្សាភិបាល

## ភាគហ៊ុនិកជាទីរាប់អាន



PAUL LIM PAY CHUAN
ប្រធានក្រុមប្រឹក្សាភិបាល

សូមអរគុណដល់ភាគហ៊ុនិកដែលបានចូលរួមជាមួយខ្ញុំក្នុងឆ្នាំហិរញ្ញវត្ថុទីបីរបស់ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ("**ផថខ**") ជាក្រុមហ៊ុនដែលបានចុះបញ្ជីលក់មូលបត្រ នៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ("**ផ.ម.ក**") ។

ការជំរុញការអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលនៅប្រទេសកម្ពុជាត្រូវបានទ្រទ្រង់បានយ៉ាងល្អប្រសើរពេញមួយឆ្នាំហិរញ្ញវត្ថុកន្លងទៅ។ ការអភិវឌ្ឍន៍លើវិស័យនេះជាបន្តបន្ទាប់ជួយផ្តល់ទំនុកចិត្តដ៏ច្បាស់លាស់មួយ ដល់វិស័យឧស្សាហកម្មសម្រាប់ការរីកលូតលាស់នៃសក្តានុពលនាពេលអនាគតចំពេលដែលមានបញ្ហាប៉ះពាល់ដល់វិស័យឧស្សាហកម្មនាពេលថ្មីៗនេះ។

ថ្វីត្បិតការរំពឹងទុកជារួមសម្រាប់ការអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលក្នុងតំបន់នៅតែបន្តភាពវិជ្ជមាន ផលប៉ះពាល់អវិជ្ជមានដ៏រាំរ៉ៃបង្កឡើងពីភាពមិនប្រាកដប្រជានៃស្ថានភាពភូមិសាស្ត្រនយោបាយ ការឡើងចុះនៃ តម្លៃទំនិញ ការកើនឡើងនៃអត្រាការប្រាក់ និងភាពស្មុគស្មាញនៃការរៀបចំភស្តុភារជាអកុសលបាននាំលទ្ធផលគួរឲ្យព្រួយបារម្ភដល់ដំណើរការរបស់ក្រុមហ៊ុនក្នុងអំឡុងពេលឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្ន។

ជាលទ្ធផល ពួកយើងមានការរំពឹងប្រកបដោយភាពសុទិដ្ឋិនិយមតែនៅតែប្រយ័ត្នប្រយែងទៅលើលទ្ធផលនាឆ្នាំហិរញ្ញវត្ថុខាងមុខនេះដោយគិតគូរពីឧបសគ្គខាងក្រៅដែលអាចបន្តនាំមកនូវបញ្ហាប្រឈមឆ្ពោះទៅរកប្រតិបត្តិការរបស់ក្រុមហ៊ុន។ ក្នុងន័យនេះ គណៈគ្រប់គ្រងបច្ចុប្បន្នកំពុងបន្តការត្រួតត្រាលើតម្លៃនិងការចំណាយតាមរយៈការពិនិត្យលើទិដ្ឋភាពសំខាន់ៗនៃប្រតិបត្តិការដើម្បីកំណត់ពីផ្នែកនៃការកែលម្អដែលអាចធ្វើទៅបានដើម្បីបង្កើនស្ថានភាពលំហូរសាច់ប្រាក់ទាំងមូលនាពេលអនាគត។

ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានរៀបរាប់នៅក្នុងសេចក្តីថ្លែងការណ៍ប្រចាំត្រីមាសមុនរបស់យើងគ្រឿងម៉ាស៊ីនរបស់ **ផថខ** ត្រូវបានរៀបចំនិងត្រៀមខ្លួនរួចជាស្រេចដើម្បីទប់ទល់នឹងស្ថានការដ៏តឹងរ៉ឹងនេះ។ ពួកយើងនៅតែបន្តប្តេជ្ញាក្នុងការអនុវត្តគម្រោងឲ្យទាន់ពេលវេលា។ មិនតែប៉ុណ្ណោះ យើងមានកាតព្វកិច្ចពេញលេញក្នុងការ បម្រើអតិថិជនរបស់យើងជាមួយនឹងការខិតខំប្រឹងប្រែងដ៏ល្អបំផុតនិងផ្តល់សេវាកម្មដែលអាចទុកចិត្តបាន។

នៅក្នុងទិដ្ឋភាពនៃការអភិវឌ្ឍន៍អាជីវកម្ម គណៈគ្រប់គ្រងនឹងដឹកនាំឆ្ពោះទៅរកភាពជោគជ័យក្នុងការបញ្ចប់គម្រោងជាមួយនឹងលំហូរសាច់ប្រាក់វិជ្ជមាននិងប្រាក់ចំណេញសមហេតុផលដើម្បីបង្កើតផលប័ត្រដែលមានសុខភាពល្អសម្រាប់ជាប្រយោជន៍ដល់ភាគហ៊ុនិករបស់យើង។ ដោយផ្អែកលើគោលការណ៍ដែលមានចែង ក្រុមហ៊ុននឹងអាចជ្រើសរើសគម្រោងទាំងឡាយណាដែលស្របទៅតាមតម្រូវការដែលបានគ្រោងទុករបស់យើងដោយមិនមានការរាំង ឬដាក់កម្រិតលើការអនុវត្តគម្រោងនាពេលខាងមុខនេះ។

ទន្ទឹមនឹងនេះ យើងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូនិងភាគហ៊ុនិករបស់យើងគឺ Maschinenfabrik Reinhausen ("MR") នៃប្រទេសអាឡឺម៉ង់ដើម្បីបន្តបង្កើនចំណេះដឹងផ្នែកបច្ចេកទេសសម្រាប់ក្រុមវិស្វកររបស់យើងនៅក្នុងប្រទេសកម្ពុជាដោយជម្រុញការពង្រឹងសមត្ថភាពដើម្បីបម្រើឲ្យកាន់តែប្រសើរឡើងនូវទីផ្សារក្នុងតំបន់ក្នុងតណ្ឌចិនជាពិសេសក្នុងវិស័យដែលពាក់ព័ន្ធនឹងការផ្តល់សេវាប្រតិបត្តិការនិងថែទាំសម្រាប់ហេដ្ឋារចនាសម្ព័ន្ធថាមពលនៅកម្ពុជានិងជុំវិញតំបន់ផងដែរ។

យើងសូមថ្លែងអំណរគុណដល់ភាគហ៊ុនិកដ៏ស្មោះស្ម័គ្ររបស់យើង អតិថិជនដែលបន្តគាំទ្រ អ្នកផ្គត់ផ្គង់ដ៏មាន ទំនុកចិត្ត និងជាចុងក្រោយបុគ្គលិករបស់យើងដែលខិតខំប្រឹងប្រែងក្នុងការជួយជ្រោមជ្រែងក្រុមហ៊ុនឆ្ពោះទៅរក ការរីកចម្រើនបន្ថែមទៀតនៅក្នុងឆ្នាំហិរញ្ញវត្ថុខាងមុខនេះ។

សូមអរគុណ។

Ir. Paul Lim Pay Chuan
ប្រធានក្រុមប្រឹក្សាភិបាល
កាលបរិច្ឆេទ៖ ២១ កញ្ញា ២០២២

# សេចក្តីថ្លែង
# របស់នាយកប្រតិបត្តិ



HAN FATT JUAN
អភិបាលប្រតិបត្តិ/នាយកប្រតិបត្តិ

ភាគហ៊ុនិកជាទីគោរពរាប់អាន!

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ("**ផថខ**") បានឆ្លងកាត់បញ្ហាដ៏លំបាកនៅក្នុងឆ្នាំហិរញ្ញវត្ថុ២០២២។

ក្នុងអំឡុងពេលឆ្នាំហិរញ្ញវត្ថុនេះ ព្រឹត្តិការណ៍សកល ដែលមិនគួរឲ្យកើតឡើងបានធ្វើឲ្យលទ្ធផលការងាររបស់ក្រុមហ៊ុន មានការថយចុះគួរឲ្យកត់សម្គាល់។ គួរឲ្យសោកស្តាយ ដំណើរការផ្នែកហិរញ្ញវត្ថុមិនសូវល្អជាហេតុធ្វើឲ្យក្រុមការងាររបស់យើងខិតខំប្រឹងប្រែងនិងយកចិត្តទុកដាក់កាន់តែខ្លាំងក្នុងការបញ្ចប់គម្រោងឲ្យទាន់ពេលវេលា កំណត់ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុកន្លងមក។

យើងបានសម្រេចបញ្ចប់គម្រោងមួយចំនួនក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុនេះ ខណៈពេលដែលបន្តកិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការធានាបន្ថែមទៀតដើម្បីចូលខ្លួនក្នុងវិស័យថាមពលកកើតឡើងវិញជាពិសេសដំណោះស្រាយថាមពលពន្លឺព្រះអាទិត្យនៅលើដំបូលសម្រាប់អាជីវកម្មក្នុងស្រុក។ ក្នុងន័យនេះ យើងរំពឹងថា **ផថខ** នឹងចូលរួមកាន់តែសកម្មក្នុងដំណោះស្រាយបង្កើតថាមពលកកើតឡើងវិញដើម្បីបម្រើបំពេញតម្រូវការធនធានថាមពលប្រកបដោយនិរន្តរភាពក្នុងប្រទេស ខណៈដែលចំនួនវិនិយោគិនបរទេសកាន់តែច្រើនបានឈានជើងចូលមកព្រះរាជាណាចក្រកម្ពុជាដើម្បីទាញយកគោលនយោបាយមិត្តភាពអាជីវកម្មរបស់ខ្លួន ទីតាំងភូមិសាស្រ្ត យុទ្ធសាស្រ្ត និងស្ថានភាពអាជីវកម្មដែលកំពុងតែរីកចម្រើនយ៉ាងឆាប់រហ័ស។

គណៈគ្រប់គ្រងក៏កំពុងសម្លឹងមើលការអភិវឌ្ឍន៍បន្ថែមទៀតលើការចូលរួមរបស់យើងក្នុងប្រតិបត្តិការនិងសេវាថែទាំ ("O&M") នៃទ្រព្យសកម្មរបស់ហេដ្ឋារចនាសម្ព័ន្ធថាមពលនៅក្នុងប្រទេសកម្ពុជា។ ការពង្រឹងសមត្ថភាពក្រុមបុគ្គលិក O&M ដែលមានជំនាញរបស់យើងក្នុងការគ្រប់គ្រងពេញលេញពីមួយថ្ងៃទៅមួយថ្ងៃនៃប្រព័ន្ធបញ្ជូនថាមពលនិងរោងចក្រផលិតថាមពលអគ្គិសនីពីរ៉ុលតាក យើងនឹងទាញយកចំណុចខ្លាំងដែលមានស្រាប់របស់យើងដើម្បីផ្តល់ជូននូវសេវាកម្ម O&M ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងឧត្តមភាពដល់ម្ចាស់ទ្រព្យសកម្មនៅកម្ពុជា។

ក្នុងន័យនេះ យើងនឹងអាចបង្កើតអាជីវកម្មវិជ្ជមានលំហូរសាច់ប្រាក់ឡើងវិញ ខណៈពេលដែលការស្វែងរកគម្រោងផលិតថាមពលបៃតងដើម្បីបង្កើតទិសដៅដ៏រីកចម្រើនមួយសម្រាប់ក្រុមហ៊ុនក្នុងគោលដៅរក្សា និរន្តរភាពក្នុងរយៈពេលវែងនាពេលអនាគត។
សូមអរគុណ។



Han Fatt Juan

អភិបាលប្រតិបត្តិ/នាយកប្រតិបត្តិ

កាលបរិច្ឆេទ៖ ២១ កញ្ញា ២០២២

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# បុគ្គលចុះបញ្ជីលក់មូលបត្រ

### ក.　　អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | **ផេសថិក (ខេមបូឌា) ម.ក** |
| ជាអក្សរឡាតាំង | PESTECH (CAMBODIA) |
| លេខកូដស្តង់ដា | KH១០០០១៩០០០៩ |
| និមិត្តសញ្ញា | **ផថក** |
| អាសយដ្ឋាន | អគារលេខ ៣៥ ជាន់ទី១០ ផ្លូវម៉ៅសេទុង ភូមិ ៩ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | +៨៥៥ ២៣ ៨៨២ ១០៥ |
| លេខទូរសារ | +៨៥៥ ២៣ ៨៨២ ១០៦ |
| គេហទំព័រ | www.pestech.com.kh |
| អ៊ីមែល៖ | info@pestech.com.my |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០០៩៥៧ ចុះថ្ងៃទី៥ កុម្ភៈ ឆ្នាំ២០១០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាប័ណ្ណអាជីវកម្ម | ៣២៦ ប្រក.ជនស.អសណ ចេញដោយ ជនស ចុះថ្ងៃទី ២០ ធ្នូ ឆ្នាំ២០១៨ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៧១/២០ គ.ម.គ/ស.ស.រ ចុះថ្ងៃទី ២២ កក្កដា ឆ្នាំ២០២០ ចេញដោយ គណៈកម្មការមូលបត្រកម្ពុជា (បច្ចុប្បន្នជា និយ័តករមូលបត្រកម្ពុជា "នមក") |
| ឈ្មោះបុគ្គលតំណាងក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក | លោក Paul Lim Pay Chuan |

ដំបូងឡើយ **ផថខ** ត្រូវបានគេស្គាល់ថាជាក្រុមហ៊ុនឈ្មោះ **ថាវីរ៍-ផេសថិក ខេវី លីមីធីត** ដែលបានបង្កើតឡើងនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ជាក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិតនៅប្រទេសកម្ពុជា។ **ផថខ** បានចុះបញ្ជីនាមករណ៍បច្ចុប្បន្ននៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣។

**ផថខ**បានប្តូរពីក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិតទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ ដែលអនុម័តដោយក្រសួងពាណិជ្ជកម្ម និងបានដាក់នាមការណ៍បច្ចុប្បន្នដើម្បីជួយសម្រួលដល់ការចុះបញ្ជីនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក)។

**ផថខ** គឺជាក្រុមហ៊ុនបច្ចេកវិទ្យាថាមពលអគ្គិសនីរួមបញ្ចូលគ្នា។ យើងចូលរួមយ៉ាងសំខាន់ក្នុងការផ្តល់នូវវិស្វកម្ម ប្រព័ន្ធថាមពលដ៏ទូលំទូលាយ និងដំណោះស្រាយបច្ចេកទេសសម្រាប់ ការរចនា ការផ្គត់ផ្គង់ ការសាងសង់ ការដំឡើង ការដាក់ឲ្យដំណើរការអនុស្ថានីយ៍ HV និង EHV បណ្តាញបញ្ជូន HV និង EHV ព្រមទាំងប្រព័ន្ធ ខ្សែចម្លងក្រោមដីសម្រាប់បញ្ជូន ចែកចាយអគ្គិសនី ការជួយដូរគ្រឿងបន្លាស់ ឧបករណ៍ថាមពលដែលមាន កម្មសិទ្ធិ និងមិនមានកម្មសិទ្ធិ។

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# បុគ្គលចុះបញ្ជីលក់មូលបត្រ

**ផថខ**
ផេសថិក
(ខេមបូឌា)
ម.ក

**១០០%**
PESTECH
(Myanmar)
Limited

ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមាននាមករណ៍ PESTECH (Myanmar) Limited ("PML") បានចុះបញ្ជីនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រោមច្បាប់ក្រុមហ៊ុនរបស់ប្រទេសមីយ៉ាន់ម៉ា។ សកម្មភាពចម្បងរបស់ក្រុមហ៊ុន PML គឺផ្តល់ជូននូវប្រព័ន្ធវិស្វកម្មសំណង់រចនានិងតំឡើងសេវាកម្មពាក់ព័ន្ធនឹង ឧស្សាហកម្មថាមពល។

**៦០%**
PESTECH
Hinthar
Corporation

PESTECH Hinthar Corporation Limited ("PHC") ជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលកាន់កាប់ភាគហ៊ុនចម្បងក្នុងក្រុមហ៊ុន PESTECH (Myanmar) បានចុះបញ្ជីនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រោមច្បាប់ក្រុមហ៊ុនរបស់ប្រទេសមីយ៉ាន់ម៉ា។ សកម្មភាពចម្បងរបស់ក្រុមហ៊ុន PHC គឺបង្កើតហេដ្ឋារចនាសម្ព័ន្ធនៃវិស័យ ថាមពល និងលើកកម្ពស់ផ្នែកថាមពល ដូចជាការផលិតថាមពល ការបញ្ជូនថាមពលនិងការចែកចាយ

**៩០%**
PESTECH
Microgrid
Company

ក្រុមហ៊ុន PESTECH Microgrid Corporation Limited ("PMC") ជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលកាន់កាប់ភាគហ៊ុន ចម្បងក្នុងក្រុមហ៊ុន PHC បានចុះបញ្ជីនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រោមច្បាប់ក្រុមហ៊ុននៃប្រទេសមីយ៉ាន់ម៉ា។ សកម្មភាពចម្បងរបស់ក្រុមហ៊ុន PMC គឺផ្តល់ប្រព័ន្ធមីក្រូក្រាហ្វិច និងហេដ្ឋារចនា សម្ព័ន្ធថាមពលផ្សេងទៀតដល់តំបន់ជនបទក្នុងប្រទេសមីយ៉ាន់ម៉ា។

## ខ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ

**ផថខ** បានចាប់ផ្តើមប្រតិបត្តិការពាណិជ្ជកម្មនៅ ឆ្នាំ២០១០ ពេលដែលយើងទទួលបានកិច្ចសន្យាពាក់ព័ន្ធនឹងការសាងសង់អនុស្ថានីយ៍ HV និងបណ្តាញបញ្ជូន HV រវាងបណ្តាញបញ្ជូនពីភាគខាងជើងនៃទីក្រុងភ្នំពេញទៅបណ្តាញកំពង់ចាមនៅកម្ពុជា (គម្រោងភាគខាងជើងនៃទីក្រុងភ្នំពេញ-កំពង់ចាម) ពីក្រុមហ៊ុន ខេមបូឌាន ទ្រែនមីសិន លីមីធីត។ គម្រោងនេះពាក់ព័ន្ធនឹងការរចនា ការសាងសង់ ការសាកល្បង និងការដាក់ឲ្យដំណើរការនៃបណ្តាញបញ្ជូនសៀគ្វីពីរ ដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល ប្រវែងប្រហែល ១១០ គីឡូម៉ែត្រ ពីភាគខាងជើងនៃទីក្រុងភ្នំពេញទៅកំពង់ចាម រួមជាមួយការអភិវឌ្ឍន៍លើអនុស្ថានីយ៍ចំនួន ពីរ (២) ឲ្យកាន់តែប្រសើរ។

**ផថខ** បានបញ្ចប់គម្រោងភាគខាងជើងនៃទីក្រុងភ្នំពេញ-កំពង់ចាមដោយជោគជ័យនិងប្រគល់គម្រោងនេះទៅឲ្យម្ចាស់ ក្រុមហ៊ុន ខេមបូឌាន ទ្រែនមីសិន លីមីធីត ក្នុងឆ្នាំ២០១៣។ គម្រោងនេះគឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយសម្រាប់ **ផថខ** ដោយហេតុថាគម្រោងនេះបានបញ្ចប់ក្នុងរយៈពេលប្រាំបី (៨) ខែមុនកាលកំណត់។





# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# បុគ្គលចុះបញ្ជីលក់មូលបត្រ



លើសពីនេះទៅទៀត ក្នុងឆ្នាំ២០១២ **ផថខ** ទទួលបានកិច្ចសន្យាពី EDC ពាក់ព័ន្ធនឹងការសាងសង់បណ្តាញបញ្ជូនដែលមានតង់ស្យុង ១១៥ គីឡូវ៉ុល ពីអនុស្ថានីយ ២៣០/១១៥ គីឡូវ៉ុល របស់ក្រុមហ៊ុន Cambodia Power Grid Co., Ltd ("CPG") ទៅអនុស្ថានីយ៍បណ្តាញអគ្គិសនី ១១៥/២២ គីឡូវ៉ុល របស់ក្រុមហ៊ុន Trans mission Lines Co., Ltd ("CPTL") នៅខេត្តបាត់ដំបងដែលមានប្រវែង ០.៩៧ គីឡូម៉ែត្រ។ គម្រោងនេះរួមមានការរចនា វិស្វកម្ម ការផ្គត់ផ្គង់ និងការដំឡើងបណ្តាញបញ្ជូនហើយបានបញ្ចប់នៅខែសីហា ឆ្នាំ២០១២។

នៅឆ្នាំ២០១៤ **ផថខ** បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន អាទ្បិចឧបករើរេសិន ជាអង្គភាពអាជីវកម្មពហុវិស័យនៃកម្ពុជាទាក់ទងនឹងការរចនា វិស្វកម្ម ការដំឡើង ការធ្វើតេស្ត និងការដាក់ឲ្យដំណើរការគម្រោងភាគខាងលិចនៃទីក្រុងភ្នំពេញ-ក្រុងព្រះសីហនុសម្រាប់៖

- បណ្តាញបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល ពីភាគខាងលិចនៃទីក្រុងភ្នំពេញ-ក្រុងព្រះសីហនុ និង
- គម្រោងពង្រីកអនុស្ថានីយ ២៣០/១១៥/២២ គីឡូវ៉ុល។

គម្រោងនេះពាក់ព័ន្ធនឹងការសាងសង់បណ្តាញបញ្ជូនចម្ងាយប្រមាណ ១៩៨ គីឡូម៉ែត្រ ដែលបញ្ជូនអគ្គិសនីពី រោងចក្រថាមពលក្នុងតំបន់ក្រុងព្រះសីហនុមកទីក្រុងភ្នំពេញ។ គម្រោងនេះពាក់ព័ន្ធនឹងការធ្វើឲ្យអនុស្ថានីយ៍ស្ទឹងហាវកាន់តែប្រសើរឡើងរួមជាមួយនឹងបណ្តាញបញ្ជូនថ្មីចំនួន ពីរ (២) ដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល តភ្ជាប់ទៅអនុស្ថានីយ៍ភាគខាងលិចនៃទីក្រុងភ្នំពេញតាមរយៈបណ្តាញបញ្ជូនថ្មីដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល ដែលគ្រោងនឹងសាងសង់ក្រោមគម្រោងនេះ។







# ព័ត៌មានទូទៅពាក់ព័ន្ធនឹង បុគ្គលចុះបញ្ជីលក់មូលបត្រ

នៅឆ្នាំ២០១៥ **ផថខ** បានចុះកិច្ចសន្យាជាមួយ ក្រុមហ៊ុន ដាយ អឺម៉ិន ផៅវ័រ លីមីធីត ដើម្បីអនុវត្តគម្រោងកំពង់ចាម-ក្រចេះ។ គម្រោងនេះពាក់ព័ន្ធនឹងការរចនា វិស្វកម្ម ការធ្វើតេស្ត ការដំឡើង និងការដាក់ឲ្យដំណើរការនូវកុងតាក់ដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល នៅអនុស្ថានីយ៍កំពង់ចាមដែលមានស្រាប់ អនុស្ថានីយ៍ក្រចេះ ២៣០/២២ គីឡូវ៉ុលថ្មី និងតភ្ជាប់បណ្ដាញបញ្ជូនដែលមានប្រវែង ១២៥ គីឡូម៉ែត្រ ពីអនុស្ថានីយ៍កំពង់ចាមទៅអនុស្ថានីយ៍ក្រចេះ។ **ផថខ** បានបញ្ចប់គម្រោងដោយជោគជ័យនៅក្នុងខែតុលា ឆ្នាំ២០១៧។





បន្ថែមពីលើនេះ ក្នុងអំឡុងឆ្នាំដដែល **ផថខ** បានបញ្ចប់គម្រោងមួយនៅ Sarawak ប្រទេសម៉ាឡេស៊ីដែល **ផថខ** បានផ្ដល់សេវាកម្មគ្រប់គ្រងគម្រោង និងសេវាគ្រប់គ្រងសំណង់ស៊ីវិលសម្រាប់ការសាងសង់អនុស្ថានីយ៍ ២៧៥ គីឡូវ៉ុល/៣២ គីឡូវ៉ុល និង ១៣២ គីឡូវ៉ុល/១១ គីឡូវ៉ុល ("គម្រោង Sarawak")។

ក្រោយមកទៀត នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ មានការធ្វើវិសោធនកម្មលើកិច្ចសន្យាដែលធ្វើជាមួយ ក្រុមហ៊ុន អាឡិច ឧបភើរេសិន កាលពីមុន ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវលក្ខណៈពិសេសនៃគម្រោងភាគខាងលិចនៃទីក្រុងភ្នំពេញ-ក្រុងព្រះសីហនុ។ វិសោធនកម្មនៃកិច្ចសន្យានេះរួមមាន ការរចនាវិស្វកម្ម ការដំឡើង ការធ្វើតេស្ត និងការដាក់ឲ្យដំណើរការនូវ៖

- បណ្ដាញបញ្ជូនសៀគ្វីពីរដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល ប្រវែងប្រហែល ៥០ គីឡូម៉ែត្រ ពីអនុស្ថានីយ៍ ស្ទឹងហាវទៅចំការហ្លួង និង
- បណ្ដាញបញ្ជូនសៀគ្វីពីរដែលមានតង់ស្យុង ៥០០ គីឡូវ៉ុល ប្រវែងប្រហែល ១៤០ គីឡូម៉ែត្រ ពីចំការហ្លួងទៅអនុស្ថានីយ៍បែកចានថ្មីដែលបានស្នើសុំ។

នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ **ផថខ** បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ស្នេថេក សម្រាប់គម្រោងសៀមរាប-ឧត្ដរមានជ័យក្នុងតម្លៃចរចាចំនួន ២៦ លានដុល្លារអាមេរិក។ គម្រោងនេះពាក់ព័ន្ធនឹងការអភិវឌ្ឍន៍បណ្ដាញ បញ្ជូនតង់ស្យុង ១១៥ គីឡូវ៉ុល ពីសៀមរាបទៅឧត្ដរមានជ័យ អនុស្ថានីយ៍ឧត្ដរមានជ័យ ១១៥/២២ គីឡូវ៉ុល និងអនុស្ថានីយ៍បែកចាន ២៣០/២២ គីឡូវ៉ុល។ គម្រោងនេះត្រូវបានបញ្ចប់នៅ ខែមករា ឆ្នាំ២០២០។





# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# បុគ្គលចុះបញ្ជីលក់មូលបត្រ

ថ្វីត្បិតជំងឺរាតត្បាតបានកើតឡើងក្នុងឆ្នាំ២០២០ក៏ពិតមែន **ផថខ** បានលៃលកបញ្ចប់គម្រោងអនុស្ថានីយបញ្ជូន អូរខ្វាវ ២៣០/១១ គីឡូវ៉ុល សម្រាប់គម្រោងរ៉ែមាសអូរខ្វាវបានមុនពេលកំណត់។ គម្រោងរ៉ែមាសអូរខ្វាវនេះដែរ ផ្តោតលើការអភិវឌ្ឍន៍ជម្រករ៉ែមាសអូរខ្វាវនៅខេត្តមណ្ឌលគិរីភាគខាងកើតនៃប្រទេសកម្ពុជា។





ក្រោយការបញ្ចប់បណ្តាញបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល ភាគខាងលិចនៃក្រុងភ្នំពេញ-ក្រុងព្រះសីហនុ **ផថខ** បានចូលរួមផ្តល់សេវាកម្មប្រតិបត្តិការនិងថែទាំដល់អនុស្ថានីយ៍បណ្តាញបញ្ជូនចំនួនពីរខ្សែនៅស្ទឹងហាវនិងបណ្តាញបញ្ជូនតង់ស្យុង ៥០០ គីឡូវ៉ុល ក្រោមគម្រោងនេះនៅ ឆ្នាំ២០២០។

**ផថខ** ទទួលបានគម្រោងផលិតថាមពលពន្លឺព្រះអាទិត្យទ្រង់ទ្រាយធំដំបូងបង្អស់របស់ខ្លួននៅក្នុងប្រទេសកម្ពុជានៅពេលក្រុមហ៊ុន PESTECH International Berhad កាន់កាប់ភាគហ៊ុន ៩៤% នៅក្នុង ក្រុមហ៊ុន ហ្គ្រីន សីស្តែនណេប៊ល វេនឈ័រ (ខេមបូឌា) ឯ.ក ("GSV") តាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ដែលក្នុងនោះយើងទទួលខុសត្រូវលើផ្នែកវិស្វកម្ម ការផ្គត់ផ្គង់ ការសាងសង់ និងដាក់ដំណើរការបច្ចេកទេស។ GSV ទទួលបានកិច្ចព្រមព្រៀងទិញថាមពលសម្បទានរយៈពេល ២០ ឆ្នាំលើការអភិវឌ្ឍន៍រោងចក្រថាមពលពន្លឺព្រះអាទិត្យខ្នាតធំ ២០ មេហ្គាវ៉ាត់ (ចរន្តផ្ទាល់ ២៤ មេហ្គាវ៉ាត់) នៅក្រុងបាវិត ខេត្តស្វាយរៀង។ គម្រោងថាមពលព្រះអាទិត្យនៅក្រុងបាវិតនេះជាគម្រោងខ្នាតធំដំបូងបង្អស់ដែលធ្វើឡើងដោយ **ផថខ** នៅប្រទេសកម្ពុជាហើយគម្រោងនេះបានដាក់ឲ្យដំណើរការនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២។



# ព័ត៌មានទូទៅពាក់ព័ន្ធនឹង បុគ្គលចុះបញ្ជីលក់មូលបត្រ

## គម្រោងដែលកំពុងដំណើរការបច្ចុប្បន្ន

ដើម្បីជាការធ្វើបច្ចុប្បន្នភាព **ផថខ** កំពុងបន្តអនុវត្តគម្រោងមួយចំនួនដែលខាងក្រោម៖

១. **គម្រោងប្រព័ន្ធបញ្ជូនថាមពលស្ទឹងតាតៃ-ភ្នំពេញ៖** គម្រោងនេះពាក់ព័ន្ធនឹងការរចនាវិស្វកម្ម ការដំឡើង ការធ្វើតេស្ត និងការដាក់ឲ្យដំណើរការខ្សែបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល ប្រហែល ២២០ គីឡូម៉ែត្រ ពីវារីអគ្គិសនីស្ទឹងតាតៃ ទៅទីតាំងអនុស្ថានីយ៍បែកចានថ្មីដែលបានស្នើសុំនៅទីក្រុងភ្នំពេញ រួមទាំងការផ្គត់ផ្គង់ ការដំឡើង និងការតភ្ជាប់បណ្ដាញខ្សែភ្លើង ២៣០ គីឡូវ៉ុល ចំនួន ២ ខ្សែ នៅចំណតទំនប់វារីអគ្គិសនីស្ទឹងតាតៃ។

២. **គម្រោងពង្រីកប្រព័ន្ធបញ្ជូន និងចែកចាយអគ្គិសនីក្នុងរាជធានីភ្នំពេញ ដំណាក់កាលទី២ (I) កញ្ចប់ទី៣ គម្រោងផ្គត់ផ្គង់បណ្ដាញបញ្ជូន និងចែកចាយអគ្គិសនីក្រោមដី៖** នេះជាគម្រោងខ្សែកាបក្រោមដី ២៣០ គីឡូវ៉ុល ដំបូងបង្អស់ដែលធ្វើឡើងដោយ EDC ក្នុងប្រទេសកម្ពុជា ក៏ដូចជាការបណ្ដាក់ទុនជោគជ័យរបស់ ក្រុមហ៊ុន ផេសចិក ក្នុងការនាំចេញការរចនានិងសមត្ថភាពក្នុងការដាក់តម្រៀបខ្សែក្រោមដីតង់ស្យុងខ្ពស់បន្ថែមទៅក្រៅ ប្រទេស។

នៅក្នុងគម្រោងនេះ វិសាលភាពការងាររួមបញ្ចូលការងារទាំងឡាយណាដែលចាំបាច់ក្នុងការសាងសង់ខ្សែកាប ក្រោមដី ២៣០ គីឡូវ៉ុល និង ២២ គីឡូវ៉ុល ក្នុងមូលដ្ឋានបញ្ចប់គម្រោង មានដូចជា ការរចនាប្លង់ ការស្ទង់មតិ ធ្វើផលិតកម្ម ធ្វើតេស្ត ដឹកជញ្ជូន ធានារ៉ាប់រង ដឹកជញ្ជូនដល់ការដ្ឋាន ការដំឡើងដោយសមស្រប ការបណ្ដុះ បណ្ដាល ការរៀបចំការងារការដ្ឋានសម្រាប់៖

- ពីរសៀគ្វី បណ្ដុលមួយចំនួនបីក្នុងសៀគ្វីមួយ ខ្សែស្រោមដែលស្រោមដោយប៉ូលីអេទីឡែន ២៣០ គីឡូវ៉ុល ស្រោមដោយខ្សែចម្លងក្រោមដី ខ្សែកាបអុបទិច ("OFC") ខ្សែកាបរួមគ្នាសម្រាប់ខ្សែចម្លង ខ្សែកាបរួមគ្នាសម្រាប់ OFC ខ្សែចម្លងក្រៅអគារ ឬ ឧស្ម័នស៊ុលហ្វាអេសាហ្វ្លរីដ ("SF6") ជ្រលក់បិទជិត នៅខាងចុង និងគ្រឿងបន្ទាប់បន្សំដែលពាក់ព័ន្ធទាំងឡាយណា ដែលមានប្រវែងប្រហែល ៩ គីឡូម៉ែត្រ នៅចន្លោះទីតាំងដែលបានពង្រីកក្រៅអគាររបស់អនុស្ថានីយ៍ GS5 និង ខាងក្នុង អគារអនុស្ថានីយ៍ មជ្ឈមណ្ឌលជាតិបញ្ជូន ("NCC") ដែលបានដាក់ស្នើ។ ខ្សែកាបដែលស្រោមដោយ ប៉ូលីអេទីឡែន តង់ស្យុង ២៣០ គីឡូវ៉ុល ដែលពាក់ព័ន្ធមានប្រវែងប្រហែល ៥៣,៤៨ គីឡូម៉ែត្រ។
- ការបញ្ចប់កម្រោងសាងសង់ខ្សែកាបចែកចាយអគ្គិសនីក្រោមដីដែលមានតង់ស្យុង ២២ គីឡូវ៉ុល ពីអនុស្ថានីយ៍ NCC ២៣០/១១៥/២២ គីឡូវ៉ុល GIS ថ្មីទៅអនុស្ថានីយ៍ចែកចាយអគ្គិសនីដែលមានស្រាប់ ចំនួន៥ផ្សេងទៀត និង ពីអនុស្ថានីយ៍ទួលគោក GIS ១១៥/២២ គីឡូវ៉ុល ថ្មី ទៅអនុស្ថានីយ៍ចែកចាយ អគ្គិសនីដែលមានស្រាប់ចំនួន៥ផ្សេងទៀត ដែលមានប្រវែងសរុបប្រហែល ១៩ គីឡូម៉ែត្រ។ ខ្សែកាប តង់ស្យុង ២២ គីឡូវ៉ុល សរុបដែលពាក់ព័ន្ធមានប្រវែងប្រហែល ១៩,២៥ គីឡូម៉ែត្រ។

៣. **ការអភិវឌ្ឍន៍ខ្សែបណ្ដាញបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល ពីឧត្តរមានជ័យ ទៅអនុស្ថានីយ៍ប្រព័ន្ធបណ្ដាញ បញ្ជូនអគ្គិសនី ភាគខាងកើតនៃខេត្តសៀមរាប ក្នុងមូលដ្ឋានសាងសង់និងផ្ទេរ**

ធាតុចម្បងក្នុងគម្រោងនេះមានដូចជា វិស្វកម្ម ការផ្គត់ផ្គង់ សាងសង់ និងការធ្វើតេស្តបច្ចេកទេសដូចខាងក្រោម៖

- បណ្ដាញបញ្ជូនសៀគ្វីពីរតង់ស្យុង ២៣០ គីឡូវ៉ុល ដែលមានប្រវែង ៣៥ គីឡូម៉ែត្រ (ខ្សែចម្លង 2xbittern 630mm2) ពីអនុស្ថានីយ៍ប្រព័ន្ធបណ្ដាញបញ្ជូនអគ្គិសនីភាគខាងកើតរបស់ EDC នៅខេត្តសៀមរាប ទៅទីតាំងអនុស្ថានីយ៍របស់ EDC ដែលបានដាក់ស្នើក្បែរព្រលានយន្តហោះថ្មី។
- បណ្ដាញបញ្ជូនសៀគ្វីពីរតង់ស្យុង ២៣០ គីឡូវ៉ុល ដែលមានប្រវែង ១០០ គីឡូម៉ែត្រ (ខ្សែចម្លង 1xbittern 630mm2) ពីទីតាំងអនុស្ថានីយ៍របស់ EDC ដែលបានដាក់ស្នើក្បែរព្រលានយន្តហោះថ្មីទៅស្ថានីយ៍រោងចក្រផលិតធ្យូងថ្មនៅខេត្តឧត្តរមានជ័យ
- មធ្យោបាយតភ្ជាប់នៅរោងចក្រផលិតថាមពល
- ការសាងសង់បណ្ដាញបន្ថែមចំនួនពីរដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល នៅអនុស្ថានីយ៍ប្រព័ន្ធបណ្ដាញបញ្ជូនអគ្គិសនីភាគខាងកើតរបស់ EDC នៅខេត្តក្នុងសៀមរាប

៤. **វិស្វកម្ម ការផ្គត់ផ្គង់ និងការសាងសង់ គម្រោងថាមពលពន្លឺព្រះអាទិត្យលើដំបូលរបស់ ក្រុមហ៊ុន វ៉ាន់កូ អ៊ិនជាសស្រៀល ឯ.ក ដើម្បីសាងសង់ប្រព័ន្ធថាមពលពន្លឺលើដំបូលដែលមានថាមពល ៧៥១ គីឡូវ៉ាត់ភីក**

គម្រោងនេះរួមមាន ការរចនា វិស្វកម្ម ការផ្គត់ផ្គង់ ការផលិត ការសាងសង់ ដំណើរការនៃការដំឡើង ការធ្វើតេស្ត និងបច្ចេកទេសលើប្រព័ន្ធផលិតថាមពលពន្លឺអគ្គិសនីដែលមានថាមពល ៧៥០ គីឡូវ៉ាត់ភីក លើដំបូល សម្រាប់រោងចក្រកាត់ដេរ នៅខេត្តកណ្ដាល ព្រះរាជាណាចក្រកម្ពុជា។

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# បុគ្គលចុះបញ្ជីលក់មូលបត្រ

## គ. ស្ថានភាពទីផ្សារ

កំណើនពិតប្រាកដរបស់កម្ពុជាត្រូវបានព្យាករថានឹងឈានដល់ ៤.៥ ភាគរយនៅ ឆ្នាំ២០២២។ ការព្យាករណ៍កំណើនតិចតួចឆ្លុះបញ្ចាំងពីផលប៉ះពាល់ដែលរំពឹងទុកនៃលក្ខខណ្ឌអវិជ្ជមាននៃវិបត្តិពាណិជ្ជកម្មដែលបណ្ដាលមកពីការកើនឡើងតម្លៃប្រេង ការធ្លាក់ចុះនៃសកម្មភាពពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងប្រទេសចិន ដែលជាដៃគូពាណិជ្ជកម្មដ៏សំខាន់របស់ប្រទេសកម្ពុជា។ បន្ថែមពីលើនេះទៅទៀត ស្ថានភាពសេដ្ឋកិច្ចនៅតែបន្ត អាស្រ័យលើការវិវឌ្ឍរបស់ជំងឺរាតត្បាតកូវីដ ១៩។ អរគុណដល់ការវិវឌ្ឍកម្មវិធីចាក់វ៉ាក់សាំង ការបន្ធូរបន្ថយ បន្ថែមលើវិធានធ្វើដំណើរ ដែលបានបន្តជួយទ្រទ្រង់ដល់ការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ចនិងការងារ។ សកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងការនាំចេញទំនិញកសិកម្មត្រូវបានរំពឹងថានឹងនៅតែរឹងមាំ ដែលរួមចំណែកដល់ ការងើបឡើងវិញនៃសេដ្ឋកិច្ច។ ក្នុងរយៈពេលមធ្យម សេដ្ឋកិច្ចត្រូវបានគេរំពឹងថានឹងមាននិន្នាការត្រឡប់ទៅរកសក្ដានុពលវិញដោយមានកំណើនប្រហែល ៦ ភាគរយ។ ច្បាប់ថ្មីស្ដីពីការវិនិយោគរួមជាមួយនឹងកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរី កម្ពុជា-ចិន ដែលបានអនុម័តថ្មី និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ ត្រូវបានគេរំពឹងថានឹងជម្រុញការវិនិយោគ និងពាណិជ្ជកម្មនៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។ ដូចគ្នានេះដែរ ពាណិជ្ជកម្ម និងការវិនិយោគនឹងត្រូវបានជម្រុញបន្ថែមទៀតនៅពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-សាធារណរដ្ឋកូរ៉េត្រូវបានផ្ដល់សច្ចាប័ន។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់អវិជ្ជមាននៃជំងឺកូវីដ-១៩ លើការងារ និងសុខុមាលភាព ត្រូវបានគេរំពឹងថានឹងបន្តកើតមាន ខណៈដែលវិស័យសេវាកម្ម ជាពិសេសឧស្សាហកម្មធ្វើដំណើរ ទេសចរណ៍ និងបដិសណ្ឋារកិច្ច នៅតែបន្តប្រឈមមុខនឹងបញ្ហាជាបន្តបន្ទាប់។

សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងថា រាជរដ្ឋាភិបាលកំពុងតែឧបត្ថម្ភ ធនជាង១០០ លានដុល្លារដល់អគ្គិសនីកម្ពុជា (EDC) ដើម្បីរក្សាស្ថិរភាពតម្លៃអគ្គិសនី ដោយហេតុជម្លោះ រវាងរុស្ស៊ី និងអ៊ុយក្រែន និងការដាក់ទណ្ឌកម្មសេដ្ឋកិច្ចដោយប្រទេសលោកខាងលិចមួយចំនួនមកលើរុស្ស៊ីបានជម្រុញឲ្យតម្លៃថាមពលនៅលើពិភពលោកហក់ឡើងយ៉ាងខ្លាំងដែលបង្កផលប៉ះពាល់ដល់ប្រទេសទាំងអស់ជុំវិញពិភពលោក។ សម្ដេចនាយករដ្ឋមន្ត្រីបានលើកឡើងពីសារសំខាន់នៃទំនប់វារីអគ្គិសនី និងរោងចក្រថាមពលពន្លឺព្រះអាទិត្យក្នុងការជួយផ្គត់ផ្គង់តម្លៃអគ្គិសនីឲ្យមានស្ថិរភាព ចំពេលមានវិបត្តិថាមពលពិភពលោក។

ក្នុងរយៈពេល២០ ឆ្នាំកន្លងទៅនេះ ប្រព័ន្ធថាមពលរបស់ប្រទេសកម្ពុជាបង្ហាញថាអាចសម្របខ្លួនបានយ៉ាងល្អ។ កាលពីដើមសតវត្សថ្មី ប្រជាជនតែប្រមាណ ១៧ ភាគរយមានប៉ុណ្ណោះដែលមានលទ្ធភាពក្នុងការប្រើប្រាស់ អគ្គិសនី ហើយប្រព័ន្ធបណ្ដាញអគ្គិសនីនៅពេលនោះដំណើរការដោយឥន្ធនៈផូស៊ីលចំនួនបីភាគបួន។ រហូតដល់ ឆ្នាំ២០១៤ ប្រព័ន្ធបណ្ដាញអគ្គិសនីបានប្ដូរទៅដំណើរការដោយទំនប់វារីអគ្គិសនីប្រហែលពីរភាគបី។ នៅក្នុងឆ្នាំ ២០២១ ប្រទេសកម្ពុជាបានរីកចំរើនគួរឲ្យកត់សម្គាល់ដោយអត្រាប្រើប្រាស់អគ្គិសនីមានរហូតទៅដល់ ៩៣ ភាគរយ ហើយកំពុងស្ថិតក្នុងដំណាក់កាលផ្លាស់ប្ដូរមួយទៀត ដោយថាមពលលើសពីពាក់កណ្ដាលទទួលបានពី ឥន្ធនៈផូស៊ីល។ គម្រោងត្រូវបានអនុម័តក្នុងឆ្នាំ២០១៩ ដោយសារបញ្ហាកង្វះថាមពលអគ្គិសនី ដែលជាហេតុបណ្ដាលឲ្យប្រទេសកម្ពុជាត្រឡប់ទៅរកឥន្ធនៈផូស៊ីលវិញ ហើយរំពឹងថានឹងផ្គត់ផ្គង់ថាមពលរហូតដល់ ៧៥ ភាគរយ នៅឆ្នាំ២០៣០។ នៅប្រទេសកម្ពុជា ថាមពលពន្លឺព្រះអាទិត្យនិងខ្យល់គឺជាប្រភពថាមពលថ្មីដែលមាន តម្លៃថោកជាងគេ ហើយតម្លៃលក់ឲ្យ EDC មានចន្លោះពី ៣,៩ សេន ទៅ ៦,៩ សេន ក្នុងមួយគីឡូវ៉ាតម៉ោង ដែលមានតម្លៃទាបជាងថាមពលធ្យូងថ្មដាក់ស្មើដែលមានតម្លៃទិញ ៧,៧ សេន ក្នុងមួយគីឡូវ៉ាតម៉ោង សម្រាប់ រោងចក្រផលិតថាមពលកម្ដៅ ២៤០០ មេហ្គាវ៉ាតនៅឡាមមនិងសេកុង។ បទវិភាគពីក្រុមការងារផ្នែកថាមពល កកើតឡើងវិញរបស់ក្រសួងរ៉ែនិងថាមពល បានបង្ហាញថាជំនួសការសាងសង់ថាមពលថ្មធ្យូងដោយ ថាមពលពន្លឺព្រះអាទិត្យ ខ្យល់ និងទំនប់វារីអគ្គិសនីដែលមិនចេញពីប្រភពចម្បង ក៏ដូចជាការស្ដុកទុកថាមពលថ្ម ដែលដំណើរការឆាប់រហ័ស និង ឧស្ម័នចំហេះម៉ាស៊ីន នឹងធ្វើឲ្យប្រព័ន្ធអគ្គិសនីនៅប្រទេសកម្ពុជាមានតម្លៃថោកជាងមុន និងធានាថានឹងអាចទៅដល់គ្រប់ទីកន្លែង។ ជម្រើសសម្បូរបែបរបស់ថាមពលគឺជាគន្លឹះនាពេល ១០ ឆ្នាំ និង ២០ ឆ្នាំខាងមុខទៀត។ ប្រទេសកម្ពុជាអាចជំនួសការសាងសង់រោងចក្រធ្យូងថ្មដែលគ្មានជំនួយផ្នែក ហិរញ្ញវត្ថុ ដោយការសាងសង់រួមបញ្ចូលគ្នានៃរោងចក្រថាមពលអគ្គិសនី ខ្យល់ វារីអគ្គិសនី ឧស្ម័នចំហេះម៉ាស៊ីន និង ស្ដុកទុក ដើម្បីរក្សាកម្រិតភាគហ៊ុនថាមពលកកើតឡើងវិញឲ្យនៅដូចបច្ចុប្បន្ន នោះគឺពាក់កណ្ដាល។ ភាគហ៊ុនថាមពលកកើតឡើងវិញកាន់តែខ្ពស់នឹងជួយទ្រទ្រង់ការវិនិយោគនិង ប្រតិបត្តិការឧស្សាហកម្មពិភពលោក នៅក្នុងប្រទេសកម្ពុជា ដែលស្ថិតនៅក្រោមសម្ពាធនៃការថយចុះសង្វាក់ផលិតកម្មឧស្ម័នកាបូន។ នៅក្នុងឆ្នាំមុន យីហោសំលៀកបំពាក់អន្តរជាតិធំៗមួយចំនួនបានចាប់ផ្ដើមអាជីវកម្មរបស់ខ្លួននៅប្រទេសកម្ពុជា ដែលក្នុងនោះមានដូចជា H&M, Puma, Adidas, Nike and Gap បានទាមទារភាគហ៊ុនថាមពលកកើតឡើងវិញ កាន់តែខ្ពស់ក្នុងល្បាយប្រភពថាមពល។ ពួកគេបានធ្វើការប្ដេជ្ញានឹងអតិថិជនរបស់ពួកគេលើថាមពលកកើតឡើងវិញនិងអាកាសធាតុ ថាពួកគេនឹងបន្តត្រៀមខ្លួនជាស្រេចលើគម្រោងផលិតប្រព័ន្ធឧស្ម័នកាបូនរបស់កម្ពុជា។

ក្រោមការឧបត្ថម្ភរបស់រាជរដ្ឋាភិបាលអូស្ត្រាលី ប្រព័ន្ធថាមពលឆ្លាតវៃ ហៅកាត់ថា (IES) បានបំពេញកិច្ចការ ស្រាវជ្រាវកាលពីឆ្នាំមុន និងសន្និដ្ឋានថា ប្រទេសកម្ពុជាមានថាមពលពន្លឺព្រះអាទិត្យខ្ពស់រហូតដល់ ៤៤ ជីកាវ៉ាត់ថាមពលខ្យល់ ៦ ជីកាវ៉ាត់ ដែលខ្ពស់ជាងថាមពលដែលកម្ពុជាគ្រោងនឹងត្រូវការនាឆ្នាំ២០៤០ ដែលមានត្រឹមតែ ១៥ ជីកាវ៉ាត់។ កាលពីឆ្នាំ២០១៧ អ្នកជំនាញវិភាគអគ្គិសនីដែលទទួលបានការឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី បានបង្ហាញថា ថាមពលអគ្គិសនីនៅប្រទេសកម្ពុជាអាចទទួលយកថាមពលពន្លឺព្រះអាទិត្យ ពី ១០ ភាគរយ ទៅ ២០ ភាគរយដោយគ្មានបញ្ហានិងរហូតដល់ ៤០ ភាគរយ ដោយមានការគ្រប់គ្រងផលប៉ះពាល់មានដែនកំណត់។ នាពេលបច្ចុប្បន្ន ប្រព័ន្ធបណ្ដាញបញ្ជូនអគ្គិសនីកំពុងមានដំណើរការយ៉ាងល្អ ដែលមានថាមពលពន្លឺព្រះអាទិត្យ ៨ ភាគរយ ប៉ុន្តែភាគហ៊ុនថាមពលនោះបានធ្លាក់ចុះ នៅពេលដែលគម្រោងធ្យូងថ្មកាន់តែមានច្រើនមាននៅលើប្រព័ន្ធអនឡាញ។ ប្រទេសកម្ពុជាមានបទពិសោធន៍យ៉ាងល្អនិងជោគជ័យក្នុងការផលិតថាមពលអគ្គិសនី ចេញពី ថាមពលពន្លឺព្រះអាទិត្យ ចាប់តាំងពីឆ្នាំ២០១៦ នៅពេលដែលថាមពលពន្លឺព្រះអាទិត្យនៅមិនទាន់មានក្នុង ប្រព័ន្ធបណ្ដាញបញ្ជូនអគ្គិសនីរហូតដល់ចុងឆ្នាំមុនដែលមានថាមពលពន្លឺព្រះអាទិត្យរហូតដល់ ០,២៣ ជីកាវ៉ាត់។

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# បុគ្គលចុះបញ្ជីលក់មូលបត្រ

## ឃ. ស្ថានភាពប្រកួតប្រជែង

**ផថខ** ស្ថិតនៅទីតាំងល្អក្នុងទទួលបាននូវអត្ថប្រយោជន៍ពីការកើនឡើងនូវតម្រូវការអគ្គិសនីនៅកម្ពុជា។ ជាមួយនឹងជំនាញបច្ចេកទេសដ៏រឹងមាំផ្នែកវិស្វកម្មប្រព័ន្ធថាមពល **ផថខ** កាន់កាប់គំរូអាជីវកម្មរួមមានផ្នែកបញ្ជូននិងចែកចាយវិស្វកម្មប្រព័ន្ធថាមពលដោយផ្នែក។ ការគ្រប់គ្រងប្រកបដោយបទពិសោធន៍និងស្មារតីលះបង់ផ្តោតលើការរីកលូតលាស់ផ្នែកអាជីវកម្មគឺជាចំណុចខ្លាំងគឺសង្កត់ធ្ងន់លើគុណភាពដែលជាគន្លឹះចាំបាច់ក្នុងការផ្តល់សេវាកម្មផ្សេងៗ។
ឱកាសដើម្បីអនុវត្តគម្រោងថាមពលព្រះអាទិត្យខ្នាតធំសម្រាប់រោងចក្រថាមពលពន្លឺព្រះអាទិត្យក្រុងបាវិតកម្រិត២០ មេហ្គាវ៉ាត់ នឹងផ្តល់ជាឈ្នាន់ដ៏ល្អដើម្បីឲ្យ **ផថខ** អាចចូលរួមក្នុងគម្រោងថាមពលកកើតឡើងវិញ។ ចំណុចនេះក៏ស្របទៅនឹងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលកម្ពុជាក្នុងការស្វែងរកសក្តានុពលថា មពលកកើតឡើងវិញសម្រាប់ប្រទេសផងដែរ។

## ង. ផែនការអនាគត

**ផថខ** មានបំណងបន្តពង្រឹងជំហរទីផ្សាររបស់ខ្លួនលើផ្នែកបញ្ជូននិងចែកចាយថាមពលនៅប្រទេសកម្ពុជានិងបណ្តាប្រទេសនានានៅតំបន់មេគង្គដើម្បីបំពេញតម្រូវការកំណើនថាមពល។ ក្នុងពេលជាមួយគ្នានេះ ការធ្វើពិពិធកម្មវិស្វកម្មប្រព័ន្ធថាមពល និងដំណោះស្រាយបច្ចេកទេសរួមទាំង O&M នៃហេដ្ឋារចនាសម្ព័ន្ធ ថាមពលឲ្យល្អដើម្បី ផ្តល់ជូននូវដំណោះស្រាយថាមពលដ៏ទូលំទូលាយដល់អតិថិជន។

**ផថខ** ខិតខំបញ្ចូលកម្មវិធីអភិវឌ្ឍន៍ប្រកបដោយចីរភាពដោយគិតគូរពីបរិបទសេដ្ឋកិច្ចបរិស្ថានសង្គមនិងអភិបាលកិច្ចក្នុងការអនុវត្តផែនការអាជីវកម្មនាពេលអនាគតរបស់ខ្លួន។កិច្ចប្រឹងប្រែងបានបង្កើតឡើងនៅក្នុងកិច្ចការនវានុវត្តន៍ការស្រាវជ្រាវនិងអភិវឌ្ឍន៍ដើម្បីនាំមកនូវប្រសិទ្ធភាពថាមពលកកើតឡើងវិញតាមរយៈការបង្កើតរោងចក្រថាមពលពន្លឺព្រះអាទិត្យ ប្រព័ន្ធផ្ទុកថាមពល និងប្រព័ន្ធមីក្រូក្រាដ ដើម្បីបង្កើតការផ្តល់ជូនថាមពលកកើតឡើងវិញថ្មីសម្រាប់អ្នកប្រើប្រាស់និងនាំមកនូវការផ្គត់ផ្គង់ថាមពលប្រកបដោយនិរន្តរភាពដល់តំបន់ដាច់ស្រយាលនៅតំបន់មេគង្គ។

## ច. កត្តាហានិភ័យ

### ១. ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់សំដៅលើហានិភ័យពីការប្រែប្រួលនៃអត្រាការប្រាក់នាពេលអនាគតដែលអាចរងឥទ្ធិពលអាក្រក់ដល់ការចំណាយហិរញ្ញប្បទានដល់ក្រុមហ៊ុន។

**ផថខ** មានសមត្ថភាពក្នុងការពង្រីកប្រតិបត្តិការអាជីវកម្មគឺពឹងផ្អែកលើសមត្ថភាពរបស់ខ្លួនក្នុងការបង្កើនហិរញ្ញប្បទានឲ្យបានគ្រប់គ្រាន់ក្នុងទម្រង់នៃការផ្តល់ហិរញ្ញប្បទានបំណុល ខាងក្រៅហិរញ្ញប្បទាន មូលធនឬ លំហូរសាច់ប្រាក់ដែលបង្កើតឡើងពីខាងក្នុង។

ពុំមានផលប៉ះពាល់ជាសារវន្តដល់ការប្រែប្រួលអត្រាការប្រាក់ទៅលើប្រាក់ចំណេញរបស់ក្រុមហ៊ុនជាប្រវត្តិសាស្ត្រឡើយ។ ទោះយ៉ាងណា **ផថខ** បានចុះកិច្ចសន្យាប្តូរអត្រាការប្រាក់ដើម្បីការពារក្រុមហ៊ុនពីការប្រឈមនឹងហានិភ័យអត្រាការប្រាក់លើប្រាក់កម្ចីរបស់ខ្លួន។ កិច្ចសន្យាប្តូរអត្រាការប្រាក់ដែលផ្តល់លទ្ធភាពឲ្យក្រុមហ៊ុនបង្កើនប្រាក់កម្ចីក្នុងអត្រាអណ្តែតទៅជាអត្រាថេរ។

គណៈគ្រប់គ្រងនឹងបន្តវាយតម្លៃហានិភ័យអត្រាការប្រាក់ដោយយកចិត្តទុកដាក់និងកំណត់ពីតម្រូវការក្នុងការចុះកិច្ចសន្យាការពារអត្រាការប្រាក់នាពេលអនាគត។

### ២. ហានិភ័យអត្រាប្តូរប្រាក់

ហានិភ័យនៃការប្តូររូបិយប័ណ្ណរបស់ **ផថខ** កើតឡើងដោយសារប្រតិបត្តិការជារូបិយប័ណ្ណផ្សេងទៀតក្រៅពីប្រាក់ដុល្លារអាមេរិក។

គណៈគ្រប់គ្រងមានបទពិសោធន៍ច្រើនក្នុងការទិញសំភារៈនិង/ឬឧបករណ៍និងតាមដានជានិច្ចនូវនិន្នាការទីផ្សារលើតម្លៃសម្ភារៈនិង/ឬឧបករណ៍ដើម្បីធានាថាការប្រឈមមុខនឹងហានិភ័យ នៃការប្តូរប្រាក់បរទេសត្រូវបានរក្សាក្នុងកម្រិតតិចតួចបំផុត។

ទោះយ៉ាងណាក្តីខាងលើនេះពុំមានការធានាថាការប្រែប្រួលអត្រាប្តូរប្រាក់បរទេសនាពេលអនាគតនឹងមិនជះឥទ្ធិពលអាក្រក់ដល់ដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# បុគ្គលចុះបញ្ជីលក់មូលបត្រ

### ៣. ហានិភ័យផ្នែកឧស្សាហកម្ម ហានិភ័យដែលទាក់ទងនឹងការប្រែប្រួលនៅក្នុងបរិបទជាតិ និងអន្តរជាតិ និងការកែប្រែវិធាន និងបទប្បញ្ញត្តិនានា

#### i. ការពឹងផ្អែកលើតម្រូវការសម្រាប់ការផ្គត់ផ្គង់អគ្គិសនីដែលអាចទុកចិត្តបានមានសុវត្ថិភាព និងពេញលេញ

អតិថិជនរបស់ **ផថខ** ភាគច្រើនជាក្រុមហ៊ុនផ្តល់សេវាកម្មសាធារណៈឧស្សាហកម្មនិងសម្បទានហេដ្ឋារចនាសម្ព័ន្ធថាមពលដែលផ្តល់កិច្ចសន្យាការងារហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីពាក់ព័ន្ធ។ ដូច្នេះដំណើរការអាជីវកម្មត្រូវបានផ្សាភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងល្បឿននៃកំណើនសេដ្ឋកិច្ចសង្គមនៃតំបន់ដែលអាស្រ័យលើតម្រូវការរបស់ប្រជាជាតិនីមួយៗ។

រាល់ឱនភាពនៃការពង្រីកឬការធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធថាមពលមានភាពប្រសើរឡើងនៅក្នុងតំបន់ដែលបណ្តាលមកពីកំណើនសេដ្ឋកិច្ចនិងភាពអវិជ្ជមាននៃសង្គមនឹងរងឥទ្ធិពលដោយចំពោះដល់ប្រតិបត្តិការអាជីវកម្មនិងការរំពឹងទុករបស់ក្រុមហ៊ុន។

នៅបណ្តាប្រទេសភាគច្រើន ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងតំបន់ជាទូទៅនឹងមានតម្រូវការថាម ពលជាមូលដ្ឋានស្របគ្នានឹងកំណើនសេដ្ឋកិច្ច និងសកម្មភាពកំណែទម្រង់លទ្ធភាពប្រើប្រាស់ថាមពលទូទៅ។

ក៏ជាបញ្ហាប្រឈមមួយដែរសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសអភិវឌ្ឍន៍ភាគច្រើនក្នុងការបន្តវិនិយោគនៅក្នុងបណ្តាញអគ្គិសនីដើម្បីផ្តល់នូវការផ្គត់ផ្គង់អគ្គិសនីដែលអាចទុកចិត្តបាននិងមានសុវត្ថិភាពដល់ប្រជាពលរដ្ឋនិងឧស្សាហកម្មរបស់ខ្លួន។ ក្នុងករណីកាត់បន្ថយ **ផថខ** កំពុងខិតខំពង្រីកសេវាកម្មរបស់ខ្លួនឲ្យដល់អ្នកប្រើប្រាស់នៅទូទាំងតំបន់និងទៅកាន់បណ្តាប្រទេសដូចជា ប្រទេសប៉ាពួនូវែលគីនេ ប្រទេសមីយ៉ាន់ម៉ា និងសាធារណៈរដ្ឋកុតឌីវ័រ ដើម្បីធ្វើឲ្យមានភាពចម្រុះសម្រាប់អតិថិជនរបស់ខ្លួន។

#### ii. បម្រែបម្រួលស្ថានភាពនយោបាយសង្គមនិងនិយ័តកម្មនៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃទៀតដែលយើងអាចនឹងដំណើរការនៅទីនោះ

**ផថខ** ងាយនឹងទទួលយកនូវកំណែទម្រង់ស្ថានភាពនយោបាយនិងបទប្បញ្ញត្តិនៅក្នុងប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសដទៃទៀតដែលយើងអាចនឹងដំណើរការនាពេលអនាគត។ ស្ថានភាពមិនល្អនៅក្នុងប្រទេសដែលអាចបណ្តាលឱ្យមានការរំខានជាខ្លាំងដល់សកម្មភាពអាជីវកម្មដូច្នេះនឹងមានផលប៉ះពាល់ដល់ដំណើរការហិរញ្ញវត្ថុនិងប្រាក់ចំណេញ។ ស្ថានភាពទាំងនោះរួមមានជាអាទិ៍បរិយាកាសសេដ្ឋកិច្ចទាំងក្នុងស្រុកនិងជាសាកលនាពេលបច្ចុប្បន្នអតិផរណាលក្ខខណ្ឌឥណទានការដឹកនាំនយោបាយបទបញ្ជានិងគោលនយោបាយរបស់រដ្ឋាភិបាលហានិភ័យសង្គ្រាមវិធីសាស្រ្តហូតពន្ធជាតូបនីយកម្មអស្សាមិករណ៍និងការចរចាឡើងវិញឬការលុបចោលកិច្ចសន្យាដែលមានស្រាប់។

**ផថខ** បានប្រកាន់យកវិធីសាស្រ្តសកម្មនិយមក្នុងការតាមឱ្យទាន់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនយោបាយសង្គមនិងបទប្បញ្ញត្តិនៅក្នុងប្រទេសកម្ពុជាក៏ដូចជាប្រទេសដទៃទៀតដែលយើងអាចធ្វើប្រតិបត្តិការនាពេលអនាគត។

ទោះយ៉ាងណាប្រភេទអាជីវកម្ម និងយុទ្ធសាស្រ្តមិនតម្រូវឱ្យ **ផថខ** ធ្វើការវិនិយោគទុនជាសារវន្តដើម្បីចាត់ចែងអាជីវកម្មឡើយ។ ដោយ **ផថខ** បានរំពឹងថានឹងទទួលរងផលប៉ះពាល់ពីកត្តាអវិជ្ជមានតិចតួចខាងផ្នែកនយោបាយសេដ្ឋកិច្ចសង្គមនិងបទប្បញ្ញត្តិដោយជឿជាក់ថានឹងអាចសម្របខ្លួនទៅនឹងភាពប្រែប្រួលដោយសារតម្រូវការដើមទុនអប្បបរិមានិងការធ្វើភាពចម្រុះក្នុងភូមិសាស្រ្ត។

### ៤. ហានិភ័យផ្នែកប្រតិបត្តិការ

#### i. ហានិភ័យផ្នែកប្រតិបត្តិការប្រចាំថ្ងៃ និងទំហំធានារ៉ាប់រង

ដោយ **ផថខ** បានចូលរួមក្នុងវិស័យឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនី ដូច្នេះសកម្មភាពអាជីវកម្មងាយប្រឈមនឹងហានិភ័យប្រតិបត្តិការ។ ហានិភ័យក្នុងប្រតិបត្តិការប្រចាំថ្ងៃរួមមានហានិភ័យគ្រោះថ្នាក់ភាពរអាក់រអួលក្នុងការផ្គត់ផ្គង់សមាសធាតុសំខាន់ៗការផ្គត់ផ្គង់ឧបករណ៍ប្រើប្រាស់ក៏ដូចជាអគ្គីភ័យ ទឹកជំនន់ និង/ឬ គ្រោះធម្មជាតិ ផ្សេងទៀតដែលអាចបណ្តាលឱ្យមានការរំខាន ឬពន្យារពេលក្នុងការអនុវត្តគម្រោង ហើយក៏អាចបណ្តាលឱ្យខូចខាតដល់សម្ភារៈនិងឧបករណ៍ដែលអាចរំខានដល់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ថែមពីលើនេះ ដោយសារគម្រោងរពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍ធុនធ្ងន់និងគ្រឿងម៉ាស៊ីនដែល **ផថខ** អាចប្រឈមមុខនឹងឧបទ្ទវហេតុឬគ្រោះថ្នាក់នៅការដ្ឋានគម្រោង។

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# បុគ្គលចុះបញ្ជីលក់មូលបត្រ

**ផថខ** ព្យាយាមដាក់កំហិតលើហានិភ័យមួយចំនួនដូចខាងលើតាមរយៈវិធីសាស្រ្តគ្រប់គ្រងហានិភ័យដូចខាងក្រោម៖

(i) ជូនបុគ្គលិកគ្រប់រូបនូវប័ណ្ណសន្យាធានារ៉ាប់រងលើឧប្បទ្ទវហេតុផ្ទាល់ខ្លួន
(ii) ការដ្ឋានគម្រោងត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវផ្នែកសុវត្ថិភាពដែលមានចែងនៅក្នុងអាជ្ញាប័ណ្ណដែលបានចេញដោយអាជ្ញាធរពាក់ព័ន្ធ និងនីតិវិធីការងារផ្ទៃក្នុងដែលបានអនុម័ត។
(iii) បង្កើតនីតិវិធីអនុវត្តគម្រោងផ្ទៃក្នុងនិងការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ដើម្បីធានាបាននូវប្រតិបត្តិការអាជីវកម្មប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។
(iv) ការបណ្ដុះបណ្ដាលនៅខាងក្នុងក្រុមហ៊ុននិងការពន្យល់សង្ខេបអំពីភាពចាំបាច់ផ្នែកសុវត្ថិភាពនិងការប្រើប្រាស់ឧបករណ៍យ៉ាងត្រឹមត្រូវ បានធ្វើឡើងដើម្បីធានាថានិយោជិតទទួលបានការបណ្ដុះបណ្ដាលយ៉ាងសមស្របដើម្បីកាត់បន្ថយហានិភ័យនៃឧប្បទ្ទវហេតុនៅលើការដ្ឋានគម្រោងឲ្យដល់កម្រិតអប្បបរមា។ និង
(v) ធានានូវសម្ភារៈផ្គត់ផ្គង់ពីសហគ្រិនស្របតាមប្រភេទគម្រោង និងសម្ភារៈទាំងនោះត្រូវបានទទួលការធានា គុណភាព។

គម្រោងទាំងអស់មានធានារ៉ាប់រងពេញលេញដើម្បីបង្ការការខូចខាត និងឧប្បទ្ទវហេតុដែលអាចកើតមានឡើង។

### ii. ការបំពេញការងារតាមគម្រោង

ការបំពេញការងាររបស់ **ផថខ** គឺធ្វើឡើងតាមគម្រោង។ សមត្ថភាពនៅក្នុងការបង្កើនកិច្ចសន្យានាពេលអនាគតគឺអាស្រ័យលើក្នុងចំណោមស្ថានភាពដទៃទៀតស្ថានភាពនយោបាយរបស់រដ្ឋាភិបាលនិងសេដ្ឋកិច្ចទូទៅតម្រូវការក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់និងបម្រែបម្រួលនៃលក្ខខណ្ឌធ្វើអាជីវកម្មទូទៅនិងលក្ខខណ្ឌឥណទានទាំងនៅក្នុងប្រទេសនិងនៅក្រៅប្រទេស។

លើសពីនេះទៀត ការបំពេញការងាររបស់ផថខ នៅក្នុងឆ្នាំហិរញ្ញវត្ថុជាក់លាក់មួយអាចពឹងផ្អែកខ្លាំងលើគម្រោងតែមួយគត់និងដំណាក់កាលនៃការអនុវត្តគម្រោងរបស់ខ្លួន។ **ផថខ** ចាត់វិធានការចាំបាច់នានាដើម្បីបង្កើតមូលដ្ឋានអតិថិជនដ៏ទូលំទូលាយមួយនៅក្នុងតំបន់ដោយសារតែសេវានិងផលិតផលរបស់ យើងមានតម្រូវការប្រហាក់ប្រហែលគ្នា នៅគ្រប់ប្រទេសទាំងអស់នៅក្នុងតំបន់។ យើងខិតខំប្រឹងប្រែងធានាឲ្យបាននូវសេចក្ដីពេញចិត្តរបស់អតិថិជន ការថែរក្សាអតិថិជន និងការណែនាំបន្តឲ្យមានកម្រិតខ្ពស់៖

- ស្នើផ្ដល់ដំណោះស្រាយឬសេវាកម្មដែលមានបន្ថែមគុណតម្លៃដល់អតិថិជនរបស់ខ្លួនតាមរយៈបរិក្ខារធ្វើតេស្ដនៅក្នុងក្រុមហ៊ុនដែលមានភាពគ្រប់ជ្រុងជ្រោយសម្រាប់ការដាក់ឲ្យដំណើរការអនុស្ថានីយ៍ និង
- ផ្ដល់ដំណោះស្រាយយ៉ាងសមស្របដល់អតិថិជនដែលមាននៅក្នុងដៃនិងធានាថាអតិថិជនពេញចិត្តនឹងគុណភាពសេវាកម្មគម្រោងនិងការអនុវត្តទាន់ពេលវេលា។

### iii. ហានិភ័យផ្នែកគម្រោង

ប្រាក់ចំណូលរបស់ **ផថខ** ភាគច្រើនមានប្រភពចេញពីគម្រោងដែលបានអនុវត្តកិច្ចសន្យាដោយស្របតាមខចែងនិងលក្ខខណ្ឌមួយចំនួន។ ប្រសិនបើគម្រោងរបស់ខ្លួនមានភាពយឺតយ៉ាវបណ្ដាលមកពីកត្តាផ្សេងៗដែលយើងត្រូវទទួលខុសទៅតាមកិច្ចសន្យានោះជាពិសេសកត្តាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុននោះ **ផថខ** នឹងទទួលខុសត្រូវលើការទូទាត់សំណងព្រាងទុកនិងសំណងខូចខាតដែលបានកំណត់មុនលើការបញ្ឈប់ឬភាពយឺតយ៉ាវនោះ។ ដូច្នេះភាពយឺតយ៉ាវណាមួយអាចជះឥទ្ធិពលដល់លទ្ធភាពនៅក្នុងការបញ្ចប់គម្រោងនិងសម្រេចគោលដៅប្រាក់ចំណូល និងផែនការអាជីវកម្មនៅក្នុងរយៈពេលជាក់លាក់មួយ។ ការលំបាកដែលត្រូវប្រឈមនៅក្នុងការអនុវត្តគម្រោងក៏អាចបណ្ដាលឱ្យមានការចំណាយកើនឡើងកាន់តែខ្ពស់ផងដែរ។ ជាលទ្ធផល ប្រភេទការអភិវឌ្ឍន៍ទាំងនេះអាចមានផលប៉ះពាល់ជាអវិជ្ជមានចំពោះអាជីវកម្មស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលប្រតិបត្តិការ។

ក្រៅពីការលើកឡើងដូចខាងលើគម្រោងរបស់យើងអាចប្រឈមនឹងការលុបចោលការពន្យារពេលឬការកែប្រែកាលវិភាគដែលអាចជះឥទ្ធិពលលើលទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញដែលបានរំពឹងទុក។ លើសពីនេះទៀត ការបញ្ឈប់គម្រោងសំខាន់ៗណាមួយនឹងមានផលប៉ះពាល់ជាអវិជ្ជមានចំពោះ ប្រាក់ចំណូលនាពេលអនាគត។

ចំពោះស្ថានភាពដែលយើងមិនអាចគ្រប់គ្រងបានដូចជាអាកាសធាតុមិនអំណោយផលនិង/ឬទឹកជំនន់ ការពន្យារពេលបែបនោះនឹងត្រូវបានប៉ះប៉ូវដោយអតិថិជនតាមរយៈការពន្យារពេលបញ្ចប់គម្រោង។ លើសពីនេះទៀត ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាជាមួយអតិថិជនភាគច្រើនអតិថិជនអាចស្នើសុំឲ្យមានការកែប្រែព័ត៌មានលម្អិតនៃកិច្ចសន្យាដែលអាចបណ្ដាលមកពីព្រឹត្តិការណ៍មិនបានរំពឹងទុកដែលជះឥទ្ធិពលដល់គម្រោងទាំងនោះ។ ជាទូទៅការទាមទារប្រាក់សម្រាប់ការងារដែលបានធ្វើមុនពេលលុបចោល ឬបញ្ឈប់នឹងបានផ្ដល់ជូនក្នុងកិច្ចសន្យា។

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# បុគ្គលចុះបញ្ជីលក់មូលបត្រ

គម្រោងទាំងអស់គឺផ្អែកលើកិច្ចព្រមព្រៀងតាមកិច្ចសន្យា។ ការលុបចោលនិងការបញ្ឈប់គម្រោងណាមួយ នឹងត្រូវអនុវត្តតាមដោយយោងតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យា។ ជាទូទៅសំណងទាមទារសម្រាប់ការងារដែលបានធ្វើមុនពេលលុបចោលឬបញ្ឈប់បែបនោះនឹងបានផ្តល់ជូននៅក្នុងកិច្ចសន្យា។

លើសពីនេះទៀត **ផថខ** នឹងស្នើសុំយោបល់ផ្នែកច្បាប់មុនពេលចុះកិច្ចសន្យាណាមួយដើម្បីធានាដល់កិច្ចការពារផលប្រយោជន៍របស់ក្រុមហ៊ុន។

### iv. ការពឹងផ្អែកនិងអសមត្ថភាពក្នុងការរក្សានាយកប្រតិបត្តិនិងបុគ្គលិកជាន់ខ្ពស់

**ផថខ** ជឿជាក់ថា ភាពជោគជ័យជាបន្តបន្ទាប់របស់ក្រុមហ៊ុនមួយផ្អែកធំនឹងពឹងផ្អែកលើសមត្ថភាព ភាពអង់អាច និងកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់នាយកប្រតិបត្តិនិងបុគ្គលិកជាន់ខ្ពស់នៅក្នុងការធ្វើទីផ្សារសេវានិងផលិតផលដើម្បីធ្វើឱ្យអាជីវមានភាពរីកចម្រើន។ ក្រុមហ៊ុនបានដឹកនាំដោយអភិបាលដែលមានបទពិសោធន៍ និងគ្រប់គ្រងដោយក្រុមបុគ្គលិកជាន់ខ្ពស់ដែលមានគុណវុឌ្ឍិ ចំណេះដឹង និងបទពិសោធន៍ដ៏ទូលំទូលាយខាងផ្នែកឧស្សាហកម្មនេះ។

ហេតុនេះ ការបាត់បង់អភិបាលនិងបុគ្គលិកជាន់ខ្ពស់ណាម្នាក់ អាចជះឥទ្ធិពលដល់សមត្ថភាពក្នុងការអនុវត្តសកម្មភាពអាជីវកម្មប្រកបដោយប្រសិទ្ធភាព។

ក្រុមប្រឹក្សាភិបាលរបស់យើងទទួលស្គាល់អំពីសារសំខាន់នៃសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការទាក់ទាញ ថែរក្សានាយកប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់តាមរយៈការអនុវត្តយុទ្ធសាស្រ្តផ្នែកធនធានមនុស្សដែលរួមបញ្ចូលកញ្ចប់ប្រាក់បំណាច់ដ៏សមរម្យនិងការចាប់ផ្តើមរៀបចំផែនការបន្តតំណែងសម្រាប់មុខតំណែងសំខាន់ៗ។

លើសពីនេះទៀត **ផថខ** បានអនុវត្តការគ្រប់គ្រងនិរន្តរភាពអាជីវកម្មដើម្បីធានាដល់ដំណើរការអាជីវកម្មដោយ គ្មានការរាំងស្ទះ។ ទោះបីជាយ៉ាងណាក៏ដោយ មិនអាចមានការបញ្ជាក់ថា វិធីសាស្រ្តខាងលើនឹងទទួលបានជោគជ័យនៅក្នុងការ ទាក់ទាញ និងការថែរក្សានាយកប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់របស់យើងនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ជឿជាក់ថា ការបាត់បង់នាយកប្រតិបត្តិ ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់នឹងមានផលប៉ះពាល់ដល់សកម្មភាពអាជីវកម្មក្នុងរយៈពេលខ្លីប៉ុណ្ណោះ។

### v. ភាពពឹងផ្អែកលើក្រុមហ៊ុនពាក់ព័ន្ធនឹង PESTECH International Berhad Group (“PESTECH Group”)

**ផថខ** ពង្រីកខ្លួនតាមរយៈការធ្វើឱ្យមានសមត្ថភាពនិងចំណេះដឹងដល់ក្រុមហ៊ុនពាក់ព័ន្ធផ្សេងទៀតនៅក្នុង PESTECH Group ខណៈដែល **ផថខ** អាចជួយពន្លឿនការលូតលាស់របស់ខ្លួនដោយមានការគាំទ្រពី PESTECH Group ក៏បង្កើតឱ្យមានការពឹងផ្អែកលើផ្នែករបស់ **ផថខ** លើសមត្ថភាពរបស់ក្រុមហ៊ុនពាក់ព័ន្ធផ្សេងទៀតក្នុងការផ្តល់សេវាកម្មដល់អតិថិជនផងដែរ។

ទោះយ៉ាងណា ការពឹងផ្អែកបែបនេះកំពុងផ្តល់អត្ថប្រយោជន៍ដល់ **ផថខ** ទាក់ទងនឹងការពង្រីកវិសាលភាពសេវាកម្មរបស់ **ផថខ** ដល់អតិថិជនរបស់ខ្លួនដោយពង្រឹងសមត្ថភាពនិងការយល់ដឹងពីក្រុមក្នុងស្រុកនិងផ្តល់បន្ថែមតម្លៃដល់អតិថិជនរបស់ខ្លួន។

### vi. ហានិភ័យនៃការប្រើប្រាស់បច្ចេកទេសរបស់តតិយជន

នៅក្នុងដំណើរការនៃការអនុវត្តគម្រោងចាំបាច់ត្រូវប្រើប្រាស់បរិក្ខារ ឬផលិតផលរបស់តតិយជន។ ប្រសិនបើបរិក្ខារឬផលិតផលទាំងនោះមានបញ្ហាគុណភាព **ផថខ** អាចចាំបាច់ត្រូវស្នើសុំជំនួយបច្ចេកទេសពីរោងចក្រដើមដើម្បីជួយដោះស្រាយបញ្ហាទាំងនោះ។ ទោះបីជាតាមធម្មតារោងចក្រមានក្រុមអ្នកជំនាញមួយក្រុមដែលត្រៀមជាស្រេចនៅក្នុងការផ្តល់ជំនួយ នៅក្នុងកាលៈទេសៈទាំងនេះក៏ដោយក៏មិនអាចធានាបានថាជំនួយនោះអាចផ្តល់ជូនបានទាន់ពេល និងប្រកបដោយប្រសិទ្ធផលជានិច្ចឡើយ។

**ផថខ** ធានាថាសមាសធាតុឬបរិក្ខាររបស់តតិយជន មានម៉ាកសញ្ញាដែលមានកំណត់ត្រាតាមដានដែលជឿទុកចិត្តបានលើគុណភាពបរិក្ខារឬផលិតផលរបស់ពួកគេដើម្បីកាត់បន្ថយហានិភ័យលើបញ្ហាគុណភាពដែលកើតឡើង។ លើសពីនេះទៀត ការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់របស់ក្រុមហ៊ុនតម្រូវឲ្យមានការចុះបញ្ជីអ្នកផ្គត់ផ្គង់ការពិនិត្យតាមដានអំពីវឌ្ឍនភាពនិងការត្រួតពិនិត្យនៅតាមរោងចក្រដើម្បីធានាដល់គុណភាពផលិតផលនិងការប្រគល់ជូនទាន់ពេលវេលា។

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# បុគ្គលចុះបញ្ជីលក់មូលបត្រ

### vii. ការពឹងផ្អែកលើអតិថិជនធំៗ

ដោយសារតែប្រាក់ចំណូលទទួលបានជាចម្បងពីគម្រោង **ផថខ** អាចពឹងផ្អែកលើគម្រោងមួយចំនួនដោយតាមរយៈអតិថិជនមួយចំនួននៅក្នុងអំឡុងពេលជាក់លាក់។

**ផថខ** មិនបានរំពឹងទុកថានឹងត្រូវពឹងផ្អែកលើអតិថិជនជាក់លាក់ណាម្នាក់ម្តងហើយម្តងទៀតនោះទេ វាគឺជាលក្ខណៈនៃអាជីវកម្មដែលអាចនឹងត្រូវពឹងផ្អែកលើអតិថិជនជាក់លាក់ណាម្នាក់នៅពេលណាមួយនៅថ្ងៃអនាគត។ ការបាត់បង់អតិថិជនណាម្នាក់ក្នុងចំណោមអតិថិជនទាំងនេះប្រសិនបើពុំមានអតិថិជនថ្មីចូលមកជំនួសទេនោះនឹងជះឥទ្ធិពលជាអវិជ្ជមានចំពោះស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលនៃដំណើរការ ទោះបីជាយ៉ាងណាក៏ដោយក្រុមប្រឹក្សាភិបាលមានទស្សនៈថាហានិភ័យទាំងនេះ នឹងត្រូវបានកាត់ បន្ថយនូវកម្រិតជាក់លាក់មួយតាមរយៈវិធីសាស្ត្រដូចខាងក្រោម៖

- កំណត់ត្រាតាមដានអំពីការផ្តល់ដំណោះស្រាយដែលបន្ថែមគុណតម្លៃនិងសេវាដែលមានគុណភាពល្អបានធានាចំពោះការថែរក្សាអតិថិជននិងការណែនាំបន្ត។ និង
- តាមរយៈការទទួលបានកិច្ចសន្យាកាន់តែច្រើនពីអតិថិជនខុសៗគ្នាហើយតាមរយៈកិច្ចសន្យាទាំងនោះវាបំពេញបន្ថែមឲ្យការងារគម្រោងហើយអាចកាត់បន្ថយការពឹងផ្អែកលើអតិថិជនណាម្នាក់ឲ្យដល់កម្រិតអប្បបរមានាថ្ងៃអនាគត។

លើសពីនេះទៀតក្រុមហ៊ុនបានថែរក្សានិងខិតខំប្រឹងប្រែងបន្តទៀតដើម្បីបំពេញតាមការរំពឹងទុករបស់អតិថិជនតាមរយៈការធ្វើការងារស្របតាមលក្ខខណ្ឌតម្រូវរបស់ពួកគេដើម្បីធ្វើឱ្យគុណភាពសេវាមានភាពល្អប្រសើរឡើងបន្ថែមទៀត។ ទោះបីជាយើងខិតខំប្រឹងប្រែងពង្រីកមូលដ្ឋានអតិថិជនឱ្យកាន់តែទូលំទូលាយក៏ដោយក៏ពុំមានការធានាថាស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការនានារបស់ក្រុមហ៊ុននឹងមិនទទួលរងផលប៉ះពាល់ជាអវិជ្ជមានពីការពឹងផ្អែកលើអតិថិជនធំៗនោះទេ។

### viii. ការពឹងផ្អែកលើអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការអនុម័តពាក់ព័ន្ធផ្សេងទៀតចេញដោយអាជ្ញាធរ និយ័តកម្មផ្សេងៗក្នុងប្រទេសកម្ពុជា

**ផថខ** បានតម្រូវដោយអាជ្ញាធរនិយ័តកម្មនៅក្នុងប្រទេសដែលយើងកំពុងតែដំណើរការអាជីវកម្មនៅទីនោះឱ្យកាន់កាប់អាជ្ញាប័ណ្ណលិខិតអនុញ្ញាត និងការអនុម័តផ្សេងទៀតដូចដែលត្រូវបានតម្រូវដើម្បីដំណើរការអាជីវកម្ម។ ការកំណែទម្រង់ច្បាប់បទប្បញ្ញត្តិនិងគោលនយោបាយរបស់រដ្ឋាភិបាលអាចជះឥទ្ធិពលដល់ដំណើរការជាពិសេសសេចក្តីសម្រេចដែលធ្វើឡើងដោយរដ្ឋាភិបាលឬអាជ្ញាធរនិយ័តកម្មទាក់ទងនឹងការផ្តល់ឬការបន្តអាជ្ញាប័ណ្ណឬលិខិតអនុញ្ញាតអាចរំខានដល់ដំណើរការនិងមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដល់អាជីវកម្មនិងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ទោះបីជាទទួលបានអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការអនុម័តដែលបានតម្រូវរួចរាល់ហើយក៏ដោយ ក៏នៅតែត្រូវទទួលការត្រួតពិនិត្យឡើងវិញជានិច្ចស្របតាមច្បាប់និងបទប្បញ្ញត្តិដែលពាក់ព័ន្ធដែលការអនុវត្តនោះអាចមានកំណែទម្រង់ពីមួយគ្រាទៅមួយគ្រា។

**ផថខ** នឹងបន្តអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានានៅក្នុងប្រទេសដែលកំពុងដំណើរការអាជីវកម្មដោយធានា ថានឹងទទួលការត្រួតពិនិត្យឡើងវិញលើបទប្បញ្ញត្តិ លក្ខខណ្ឌដែលត្រូវបានដាក់ជូន និងសេចក្តីណែនាំ ថ្មីៗជាបន្តបន្ទាប់។ ទោះបីជាយ៉ាងណាក៏ដោយពុំមានការធានាថាកិច្ចខិតខំ

## ៥. ហានិភ័យនៃការមិនដំណើរការ

### i. ហានិភ័យផ្នែកហិរញ្ញវត្ថុរួមបញ្ចូលទាំងហានិភ័យសន្ទនីយភាពនិងហានិភ័យឥណទាន

ហានិភ័យសន្ទនីយភាព

ហានិភ័យផ្នែកហិរញ្ញវត្ថុរួមបញ្ចូលទាំងហានិភ័យសន្ទនីយភាព (liquidity risk) និងហានិភ័យផ្នែកឥណទានហានិភ័យសន្ទនីយភាព (liquidity risk) គឺជាហានិភ័យដែលក្រុមហ៊ុននឹងជួបការលំបាកក្នុងការបង្កើនមូលនិធិដើម្បីបំពេញតាមការសន្យាទូទាត់ប្រាក់ក្នុងរយៈពេលខ្លី។

**ផថខ** ប្រឈមមុខនឹងហានិភ័យសន្ទនីយភាពដោយជាទូទៅយើងពន្យារពេលផ្តល់ឥណទានជូនអតិថិជននិងនៅក្នុងករណីមួយចំនួននឹងទទួលបានការទូទាត់ប្រាក់នៅក្រោយពេលបញ្ចប់ការសាងសង់ប៉ុណ្ណោះ។ ជាលទ្ធផលអាចជាប្រឈមមុខនឹងហានិភ័យសន្ទនីយភាពប្រសិនបើមិនអាចផ្តល់មូលនិធិសម្រាប់ចំណាយ លើការសាងសង់និងការទិញគ្រឿងម៉ាស៊ីនបរិក្ខារសម្រាប់ប្រើប្រាស់នៅក្នុងគម្រោងបានទេនោះ។

**ផថខ** ព្យាយាមរក្សាសាច់ប្រាក់និងសមមូលនៃសាច់ប្រាក់ឲ្យបានគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការនៃទុនបង្វិលក្រោយពេល IPO និងក៏នឹងបន្តរក្សាទំនាក់ទំនងល្អជាមួយស្ថាប័នហិរញ្ញវត្ថុនានាផងដែរ។

# ព័ត៌មានទូទៅពាក់ព័ន្ធនឹង
# បុគ្គលចុះបញ្ជីលក់មូលបត្រ

ក្រុមហ៊ុនក៏នឹងខិតខំប្រឹងប្រែងធ្វើឱ្យគម្រោងការទូទាត់ប្រាក់មានរយៈពេលវែងមានតុល្យភាពនឹងគម្រោងទូទាត់ប្រាក់មានរយៈពេលខ្លីដើម្បីសម្រាលបន្ទុកសន្ទនីយភាពដល់ក្រុមហ៊ុន។

ហានិភ័យផ្នែកឥណទាន

**ផថខ** ប្រឈមមុខនឹងហានិភ័យផ្នែកឥណទានដោយតាមធម្មតាការចេញវិក្កយបត្រជូនអតិថិជនតាមដំណាក់កាលនៃការបញ្ចប់គម្រោងឬផ្អែកតាមលក្ខខណ្ឌទូទាត់ប្រាក់ដែលបានកំណត់នៅក្នុងកិច្ចសន្យាជាមួយអតិថិជន។ លក្ខខណ្ឌទូទាត់ប្រាក់ធម្មតាបានចរចាគ្នាជាមុនរវាងភាគីនៃកិច្ចសន្យា។

ការជះឥទ្ធិពលនៃស្ថានភាពសេដ្ឋកិច្ចអវិជ្ជមានឬភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជនអាចកាត់បន្ថយលទ្ធភាពអតិថិជនក្នុងការទូទាត់ប្រាក់សម្រាប់សេវានានាឬបំពេញកាតព្វកិច្ចនៃកិច្ចសន្យារបស់ពួកគេឬធ្វើឲ្យពួកគេពន្យារពេលទូទាត់ប្រាក់ឬបំពេញកាតព្វកិច្ចទាំងនោះ។ **ផថខ** ពឹងផ្អែកលើអតិថិជនក្នុងការរៃប្រាក់ឲ្យបានទៀងទាត់ពេលវេលា។

**ផថខ** មានការយល់ឃើញថាវិធីសាស្ត្រក្នុងការចេញវិក្កយបត្រគឺស្របតាមស្តង់ដានៃឧស្សាហកម្មនេះ។ អតិថិជនឬអ្នកប្រើប្រាស់ចុងក្រោយភាគច្រើនគឺជាក្រុមហ៊ុនដែលកាន់កាប់ដោយរដ្ឋហើយកន្លងមកទទួលបានការទូទាត់ប្រាក់បានទាន់ពេលវេលា។

ជាទូទៅ **ផថខ** ផ្តល់លក្ខខណ្ឌឥណទានរយៈពេលវែងសម្រាប់តែអតិថិជនប៉ុណ្ណោះនៅខណៈពេលដែលមានការព្រមព្រៀងទូទាត់ប្រាក់ដោយផ្ទាល់ជាមួយអ្នកប្រើប្រាស់ចុងក្រោយដែលជាទូទៅជាក្រុមហ៊ុនផ្តល់សេវាសាធារណៈដែលកាន់កាប់ដោយរដ្ឋ។

### ii. តម្រូវការដើមទុននាពេលអនាគតនឹងតម្រូវឱ្យមានការផ្តល់ហិរញ្ញប្បទានបន្ថែម

យើងអាចចាំបាច់ត្រូវបង្កើនសាច់ប្រាក់បន្ថែមទៀតនាពេលអនាគតតាមរយៈហិរញ្ញប្បទានសាធារណៈឬឯកជនដើម្បីគាំទ្រដល់ភាពរីកចម្រើននៃក្រុមហ៊ុនដើម្បីអនុវត្តការទិញនានាដើម្បីឆ្លើយតបទៅនឹងសម្ពាធនៃការប្រកួតប្រជែងនិង/ឬដើម្បីទិញអាជីវកម្មនិងបច្ចេកវិទ្យាបន្ថែមទៀត។ ពុំមានការធានាថាការបញ្ចូលសាច់ប្រាក់បន្ថែម ប្រសិនបើចាំបាច់នឹងអាចស្វែងរកបានដោយមានលក្ខខណ្ឌអំណោយផលនោះទេ។ លើសពីនេះទៀត ហិរញ្ញប្បទានតាមរយៈបំណុលណាមួយ ប្រសិនបើអាចស្វែងរកបាន អាចមានការយល់ព្រមដែលមានលក្ខណៈរឹតត្បិតដែលអាចដាក់កំហិតលើភាពបត់បែននៃដំណើរការរបស់ក្រុមហ៊ុន។ ប្រសិនបើសាច់ប្រាក់បន្ថែមនោះត្រូវបានបង្កើនតាមរយៈការចេញទ្រព្យម្ចាស់ឬលិខិតូបករណ៍ដែលមានទំនាក់ទំនងនឹងទ្រព្យម្ចាស់នោះប្រាក់ចំណូលរបស់ក្រុមហ៊ុនក្នុងមួយភាគហ៊ុន នឹងត្រូវថយចុះហើយភាគហ៊ុនិកអាចជួបប្រទះការថយចុះនៃការកាន់កាប់ភាគហ៊ុននៃទ្រព្យម្ចាស់របស់ពួកគេនៅ ក្នុងក្រុមហ៊ុន។ លើសពីនេះទៀតទ្រព្យម្ចាស់ ឬលិខិតូបរណ៍ដែលមានទំនាក់ទំនងនឹងទ្រព្យម្ចាស់បែបនោះអាចមានសិទ្ធិភាពអនុគ្រោះ ឬបុព្វសិទ្ធិលើភាគហ៊ុនដែលមានស្រាប់ផងដែរ។ ការខកខានក្នុងការទទួលបានសាច់ប្រាក់គ្រប់គ្រាន់ផ្អែកតាមលក្ខខណ្ឌដែលអាចទទួលយកបាននឹងជះឥទ្ធិពលអវិជ្ជមានខ្លាំងចំពោះអាជីវកម្មភាពប្រកួតប្រជែងនិងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

**ផថខ** ថែរក្សាទំនាក់ទំនងល្អជាមួយស្ថាប័នហិរញ្ញវត្ថុហើយស្របតាមការយល់ឃើញរបស់ក្រុមប្រឹក្សាភិបាលមានសន្ទស្សន៍ដ៏ល្អនៅក្នុងការបង្កើតទំនាក់ទំនងផ្នែកធនាគារជាមួយពួកគេប្រសិនបើមានការចាំបាច់។ លើសពីនេះទៀត ផថខ រំពឹងទុកថាតម្រូវការនៃការបញ្ចូលសាច់ប្រាក់តាមរយៈបំណុលនាពេលអនាគត ភាគច្រើនពាក់ព័ន្ធនឹងគម្រោងដែលមានប្រភពនៃការសងប្រាក់យ៉ាងច្បាស់លាស់។

## ៦. ហានិភ័យផ្នែកបណ្តឹងវិវាទ និងបំណុលអនិមិត្ត

### i. ហានិភ័យផ្នែកបណ្តឹងវិវាទ

**ផថខ** ពុំជាប់ពាក់ព័ន្ធនឹងបណ្តឹងវិវាទណាមួយនៅក្នុងប្រទេសកម្ពុជានោះទេ។ ទោះយ៉ាងណាក៏ដោយក្រុមហ៊ុនអាចមានហានិភ័យនៃបណ្តឹងវិវាទនិងចំណាត់ការក្នុងការអនុវត្តនិយ័តកម្មនានានៅក្នុងដំណើរការធម្មតានៃអាជីវកម្មជាពិសេសពាក់ព័ន្ធនឹងការបំពានលើការយល់ព្រមនៃកិច្ចសន្យាណាមួយលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាននិងការសាងសង់ដែលទាក់ទងនឹងគម្រោងលក្ខខណ្ឌតម្រូវនៃច្បាប់ពន្ធដារនិងច្បាប់ការងារ។

បណ្តឹងវិវាទនិងចំណាត់ការក្នុងការអនុវត្តនិយ័តកម្មណាមួយអាចបង្កការខូចខាតជាសក្តានុពលដល់កេរ្តិ៍ឈ្មោះនិងអាចធ្វើឱ្យក្រុមហ៊ុនត្រូវប្រឈមនឹងទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុបង្វែរចំណាប់អារម្មណ៍ផ្នែកធនធាននិងការគ្រប់គ្រងរបស់យើងចេញពីការធ្វើអាជីវកម្មប្រចាំថ្ងៃនិងជះឥទ្ធិពលអវិជ្ជមានលើកេរ្តិ៍ឈ្មោះក្រុមហ៊ុននិងស្ថានភាពហិរញ្ញវត្ថុ។

### ii. វិវាទសារពើពន្ធ

**ផថខ** មិនមានវិវាទសារពើពន្ធជាមួយអគ្គនាយកដ្ឋានពន្ធដារទេ។

# ព័ត៌មានអំពី
# លទ្ធផលនៃការដំណើរការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គីសនីនិងអនុស្ថានីយ៍គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំឆ្នាំដែលមានទឹកប្រាក់ចំនួន ២០២ ៥០៨ លានរៀល (ឆ្នាំហិរញ្ញវត្ថុ ២០២១៖ ២៦០ ៨៤៥ លានរៀល) ដែលស្មើនឹងប្រមាណ ៩៥,៣% នៃចំណូលសរុប។

បន្ថែមពីលើសេវាកម្ម EPCC ផ្នែកប្រតិបត្តិការនិងសេវាថែទាំ "O&M" មានប្រមាណ ១៣ ៨៤៧ លានរៀល ឬ ៦,៤% នៃចំណូលសរុប (ឆ្នាំហិរញ្ញវត្ថុ ២០២១៖ ១២ ៧៨៣ លានរៀល ឬ ៤,៧% )។

ក្នុងកំឡុងឆ្នាំនេះ **ផថខ** បានទទួលប្រាក់ចំណូលហិរញ្ញវត្ថុពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា (CIFRS) ១៥ ចំនួន ១១ ៤៤៩ លានរៀល (ឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៤ ២៤៨ លានរៀល) សម្រាប់ទ្រព្យសកម្មដែលទទួលបានពីកុងត្រាលើគម្រោងមួយចំនួន។

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ឆ្នាំហិរញ្ញវត្ថុ ២០២២ | | ឆ្នាំហិរញ្ញវត្ថុ ២០២១ | | ឆ្នាំហិរញ្ញវត្ថុ ២០២០ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់ឱ្យដំណើរការ("EPCC) កិច្ចសន្យាសម្រាប់បណ្តាញអគ្គីសនី និងអនុស្ថានីយ៍ | ២០២ ៥០៨ | ៩៣,៦ | ២៦០ ៨៤៥ | ៩៥,៣ | ១៩៣ ៨៤៥ | ៩៥,៥ |
| ២ | ប្រតិបត្តិការ និងសេវាថែទាំ | ១៣ ៨៤៧ | ៦,៤ | ១២ ៧៨៣ | ៤,៧ | ៩ ១១៥ | ៤,៥ |
| | ចំណូលសរុប | ២១៦ ៣៥៥ | ១០០,០ | ២៧៣ ៦២៨ | ១០០,០ | ២០៣ ០១៤ | ១០០,០ |
| ចំណូលហិរញ្ញប្បទានពីទ្រព្យសកម្មកិច្ចសន្យា | | ១១ ៤៤៩ | គ្មាន | ៤ ២៦៨ | គ្មាន | គ្មាន | គ្មាន |

# ព័ត៌មានអំពី
# អភិបាលកិច្ចសាជីវកម្ម

### ក. រចនាសម្ព័ន្ធគ្រប់គ្រង




### ខ. សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទចាប់ផ្តើមអាណត្តិជាអភិបាល | កាលបរិច្ឆេទផុតកំណត់អាណត្តិជាអភិបាល |
|---|---|---|---|---|
| ១ | Paul Lim Pay Chuan | ប្រធានក្រុមប្រឹក្សាភិបាល | ៥ កុម្ភៈ ២០១០ | ៩ ធ្នូ ២០២៣ |
| ២ | Lim Ah Hock | អភិបាលប្រតិបត្តិ | ៥ កុម្ភៈ ២០១០ | ៩ ធ្នូ ២០២៣ |
| ៣ | Han Fatt Juan | អភិបាលប្រតិបត្តិ /នាយកប្រតិបត្តិ | ២៧ មិថុនា ២០១៨ | ៩ ធ្នូ ២០២៣ |
| ៤ | Charles Tan Pu Hooi | អភិបាលប្រតិបត្តិ | ២៧ មិថុនា ២០១៨ | ៩ ធ្នូ ២០២៣ |
| ៥ | ឯកឧត្តម ដាវ អានសាន | អភិបាលឯករាជ្យ | ២៩ សីហា ២០១៨ | ២៨ សីហា ២០២៣ |

### គ. លេខាធិការក្រុមហ៊ុន

| ល.រ | ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទចាប់ផ្តើមអាណត្តិជាអភិបាល |
|---|---|---|---|
| ១ | Lynda Pan Seng Wee | លេខាធិកាក្រុមហ៊ុន | ៤ សីហា ២០២១ |

# ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់បុគ្គលដែលបានចុះបញ្ជីលក់

ក. ព័ត៌មានអំពីមូលបត្រ

១. ព័ត៌មានអំពីមូលបត្រមូលធន (សម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ)

| | |
|---|---|
| ឈ្មោះអង្គភាព | : ផេសថិក (ខេមបូឌា) ម.ក |
| សញ្ញាណអង្គភាព | : PEPC |
| ប្រភេទមូលបត្រមូលធន | : ភាគហ៊ុនធម្មតា |
| តម្លៃចារិកក្នុងមូលបត្រមូលធនចំនួនមួយ | : ០.១០ ដុល្លារអាមេរិក ឬ ៤០០ រៀល |
| តម្លៃ IPO | : ០.៧៦ ដុល្លារអាមេរិក ឬ ៣,១២០ រៀល |
| ចំនួនភាគហ៊ុនដែលស្ថិតក្រោមការកាន់កាប់របស់ភាគហ៊ុនិកសរុប | : ៧៤,៩៤៥,០០០ |
| ការធ្វើមូលធនកម្មទីផ្សារ | : ៧៤,៩៤៥,០០០<br>(៣,១៤០ រៀល ក្នុងមួយភាគហ៊ុនគិតត្រឹមថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២) |
| អនុញ្ញាតដោយផ្សារមូលបត្ | : ផ្សារមុលបត្រកម្ពុជា |
| កាលបរិច្ឆេទចុះបញ្ជី | : ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ |

ខ. តម្លៃមូលបត្រ និងទំហំជួញដូរ

| មូលបត្រ | | កក្កដា ២១ | សីហា ២១ | កញ្ញា ២១ | តុលា ២១ | វិច្ឆិកា ២១ | ធ្នូ ២១ | មករា ២២ | កុម្ភៈ ២២ | មីនា ២២ | មេសា ២២ | ឧសភា ២២ | មិថុនា ២២ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| តម្លៃជួញដូរ | អតិបរមា | ៣ ១៥០ | ៣ ២២០ | ៣ ១៧០ | ៣ ១៨០ | ៣ ១៤០ | ៣ ១៦០ | ៣ ០៦០ | ៣ ២០០ | ៣ ២៤០ | ៣ ១៧០ | ៣ ២៦០ | ៣ ២៣០ |
| | *ជាមធ្យម | ៣ ១៣៥ | ៣ ១៨០ | ៣ ១៥០ | ៣ ១៥៥ | ៣ ១៣៥ | ៣ ១៥៥ | ៣ ០៥៥ | ៣ ១៩០ | ៣ ១៧០ | ៣ ១៥៥ | ៣ ២៤៥ | ៣ ២១៥ |
| | អប្បបរមា | ៣ ១២០ | ៣ ១៤០ | ៣ ១៣០ | ៣ ១៣០ | ៣ ១៣០ | ៣ ១៣០ | ៣ ០៥០ | ៣ ១៨០ | ៣ ២០០ | ៣ ១៤០ | ៣ ២៣០ | ៣ ២០០ |
| ទំហំជួញដូរ | អតិបរមា | ៥ ០២៣ | ២៥ ៥១៧ | ២ ៥៩៥ | ២ ៦៧៤ | ១ ៦៦១ | ៣ ៤២៦ | ១៣ ៥៥២ | ១៥ ៤៤០ | ៩ ៣២៨ | ៤ ៤៤២ | ២០ ៣៦២ | ១០៥ ៥៥៦ |
| | *ជាមធ្យម | ២ ៥៤០,៥ | ១២ ៨៣៧ | ១ ៣០១,៥ | ១ ៣៨៨ | ៨៣២,៥ | ១ ៧១៩ | ៦ ៧៨៩ | ៧ ៨៨០ | ៤ ៨២៦,៥ | ២ ២២៣,៥ | ១០ ២១៥ | ៥២ ៧៧៨,៥ |
| | អប្បបរមា | ៥៨ | ១៥៧ | ៨ | ១០២ | ៤ | ១២ | ២៦ | ៣២០ | ៣២៥ | ៥ | ៦៨ | ១ |

ព័ត៌មានខាងលើត្រូវបានដកស្រង់ចេញពីគេហទំព័ររបស់ CSX ដោយផ្អែកតាមព័ត៌មាន គិតត្រឹមថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ដែលមានបង្ហាញជូន។w

*ជាកម្រិតមធ្យមរវាង តម្លៃ និងទំហំជួញដូរជាអតិបរមា និងអប្បបរមា។

## គ. ភាគហ៊ុនិកគ្រប់គ្រង (៣០% ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនភាគហ៊ុន | ភាគរយ |
|---|---|---|---|---|
| ១ | PESTECH International Berhad | ម៉ាឡេស៊ី | ៧១ ០០០ ០០០ | ៩៤,៧៤% |
| សរុប | | | ៧១ ០០០ ០០០ | ៩៤,៧៤% |

ព័ត៌មានខាងលើត្រូវបានដកស្រង់ចេញពីគេហទំព័ររបស់ CSX ដោយផ្អែកតាមព័ត៌មាន គិតត្រឹមថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ដែលមានបង្ហាញជូន។

## ឃ. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំ

ក្រុមប្រឹក្សាភិបាលបានក្រុមប្រឹក្សាភិបាលបានប្រកាសភាគលាភចំនួន ០,០០៦៥ ដុល្លារអាមេរិចនៅក្នុងឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២១។ ភាគលាភត្រូវបានទូទាត់ទៅឲ្យភាគហ៊ុនិក ទាំងអស់នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ស្របតាមកំណត់ត្រាចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។

HT&P Partners
Certified Public Accountants

Unit No. G33A02B, Floor 33A
GIA Tower, Koh Pich 120101
Phnom Penh, Cambodia

Tel: +855 23 231 236
info@htppartners.com
www.htppartners.com

**ក្រុមប្រឹក្សាភិបាល**
**ផេសថិក (ខេមបូឌា) ម.ក**
អគារ AAA ជាន់ទី១០ មហាវិថីម៉ៅសេទុង
សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

យោង៖ HTP/HP/LUN

ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២

**ផេសថិក (ខេមបូឌា) ម.ក**
**សវនកម្មផ្ទៃក្នុង**

---

យោងទៅតាមប្រធានបទខាងលើ យើងខ្ញុំសូមភ្ជាប់មកជាមួយនូវរបាយការណ៍សវនកម្មផ្ទៃក្នុងរបស់យើងខ្ញុំសម្រាប់លោកអ្នកពិនិត្យ និង វិនិច្ឆ័យ។ របាយការណ៍សវនកម្មផ្ទៃក្នុង ត្រូវបានពិភាក្សារួចហើយជាមួយអ្នកគ្រប់គ្រងក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ហៅកាត់ថា (“ក្រុមហ៊ុន”)។

យើងខ្ញុំបានធ្វើសវនកម្មផ្ទៃក្នុងលើដំណើរការចេញវិកយប័ត្រនិង ការប្រមូលប្រាក់ គណនីត្រូវបង់ និងដំណើរការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ដែលបានបញ្ចប់នៅក្នុងដំណាច់ឆ្នាំហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០២២ ។ នៅក្នុងរបាយការណ៍ដែលបានភ្ជាប់មកជាមួយ យើងខ្ញុំបានបង្ហាញនូវបញ្ហាជាក់លាក់មួយចំនួន ដែលទាញចំណាប់អារម្មណ៍របស់យើងខ្ញុំក្នុងអំឡុងពេលនៃការធ្វើសវនកម្មផ្ទៃក្នុងហើយយើងខ្ញុំយល់ថាគួរតែត្រូវបានបង្ហាញជូនលោកអ្នក។

យើងខ្ញុំបានរៀបចំរបាយការណ៍នេះសម្រាប់ការប្រើប្រាស់របស់គណៈកម្មាធិការសវនកម្ម អ្នកគ្រប់គ្រង និងបំណងតបតាមកម្មវត្ថុនៃកិច្ចការសវនកម្មផ្ទៃក្នុងនេះ។ ដូច្នេះយើងខ្ញុំជឿជាក់ថាវាមិនសមរម្យទេនៅពេលដែលរបាយការណ៍នេះត្រូវបានផ្តល់ជូនដល់ភាគីទីបី ប្រសិនបើភាគីទីបីនោះទទួលបានច្បាប់ចម្លងដោយគ្មានការដឹងឮជាលាយលក្ខណ៍អក្សរជាមុនអំពីយើងខ្ញុំ ហើយយើងខ្ញុំនឹងមិនទទួលខុសត្រូវលើការពឹងផ្អែកណាមួយដែលមានលើរបាយការណ៍នេះទេ។

យើងខ្ញុំបានដាក់បញ្ចូលនូវការឆ្លើយតបរបស់អ្នកគ្រប់គ្រង ទៅនឹងបញ្ហាផ្សេងៗនៅក្នុងរបាយការណ៍ដែលបានភ្ជាប់មកជាមួយសម្រាប់ចំណាប់អារម្មណ៍របស់លោកអ្នក ។

ជាចុងក្រោយយើងខ្ញុំសូមអរគុណសម្រាប់កិច្ចសហការអំពីបុគ្គលិករបស់លោកអ្នក ក្នុងអំឡុងពេលនៃសវនកម្មផ្ទៃក្នុងនេះ។

អេចធី & ភី ផាតនើរ ឯ.ក
HT & P Partners Co., Ltd.
KINGDOM OF CAMBODIA

**អេចធី & ភី ផាតនើរ ឯ.ក**
**គណនេយ្យករជំនាញ**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# របាយការណ៍ហិរញ្ញវត្ថុ


២៦ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច
២៩ របាយការណ៍របស់សវនករឯករាជ្យ
៣៤ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន
៣៦ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន
៣៨ របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗរបស់សម្ព័ន្ធក្រុមហ៊ុន
៣៩ របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗរបស់ក្រុមហ៊ុន
៤០ របាយការណ៍បម្រែបម្រួលមូលធនរបស់សម្ព័ន្ធក្រុមហ៊ុន
៤១ របាយការណ៍បម្រែបម្រួលមូលធនរបស់ក្រុមហ៊ុន
៤២ របាយការណ៍លំហូរសាច់ប្រាក់របស់សម្ព័ន្ធក្រុមហ៊ុន
៤៤ របាយការណ៍លំហូរសាច់ប្រាក់របស់ក្រុមហ៊ុន
៤៦ កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា




# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មហើយរបស់ក្រុមហ៊ុន និងក្រុមហ៊ុនបុត្រសម្ព័ន្ធ (តទៅនេះហៅកាត់ថា "សម្ព័ន្ធក្រុមហ៊ុន") គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និងសម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ។

**ព័ត៌មានអំពីក្រុមហ៊ុន**

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក បានប្រតិបត្តិការអាជីវកម្មនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ហើយវាជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ១០០% របស់ក្រុមហ៊ុន PESTECH International Berhad ដែលជាក្រុមហ៊ុនចុះបញ្ជី និងមានអាសយដ្ឋាននៅប្រទេសម៉ាឡេស៊ី និងបានចុះបញ្ជីនៅក្នុងទីផ្សារគោលនៃក្រុមហ៊ុន Bursa Malaysia Securities Berhad ជាមួយនឹងដើមទុនដែលបានចុះបញ្ជី និងទូទាត់រួចរាល់ក្នុងសមតុល្យសរុប ៧.១០០.០០០ ដុល្លារអាមេរិក ដែលស្មើនឹង ៧១.០០០.០០០ ភាគហ៊ុនដែលមានតម្លៃចារឹក ០,១០ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន។ ក្រុមហ៊ុនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ("MOC") ក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម ០០០០០៩៥៧។

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ក្រុមហ៊ុនបានចុះជាមួយផ្សារមូលបត្រកម្ពុជា ("CSX") ដោយជោគជ័យ។ ភាគហ៊ុនថ្មីដែលបានចេញផ្សាយមានចំនួន ៣.៩៤៥.០០០ ភាគហ៊ុនជាមួយតម្លៃចារឹក ៤០០ រៀល ឬ០,១០ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុននៅក្នុងតម្លៃបោះផ្សាយ ៣.១២០ រៀល ឬ ០,៧៦ ដុល្លាអាមេរិកក្នុងមួយភាគហ៊ុន។ នៅពេលបញ្ចប់ការចុះបញ្ជី ក្រុមហ៊ុន PESTECH International Berhad បានកាន់កាប់ភាគហ៊ុនចំនួន ៩៤,៧៤% របស់ក្រុមហ៊ុន។

នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ក្រុមហ៊ុនបានទទួលការយល់ព្រមពីក្រសួងពាណិជ្ជកម្មដើម្បីធ្វើវិសោធនកម្មអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុនរបស់ខ្លួន។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺសាងសង់អនុស្ថានីយ៍អគ្គិសនី និងបណ្តាញបញ្ជូន។

ក្រុមហ៊ុន PESTECH (Myanmar) Limited (ហៅកាត់ថា "PML") បានធ្វើប្រតិបត្តិការអាជីវកម្មក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលមានកម្មសិទ្ធិ ១០០% ក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម ១១៧១ FC/២០១៦-២០១៧ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ដែលបានចេញផ្សាយដោយ ក្រសួងផែនការ និងហិរញ្ញវត្ថុនៃរដ្ឋាភិបាលរបស់សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។ ដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុនមានសមតុល្យ ៥០.០០០ ដុល្លារអាមេរិក ដែលស្មើនឹង ៥០.០០០ភាគហ៊ុនធម្មតា។

សកម្មភាពចម្បងរបស់ PML គឺការផ្តល់ជូនគម្រោងគ្រប់គ្រងប្រព័ន្ធបណ្តាញអគ្គិសនី ការសាងសង់ ការរចនា និងការតំឡើងខ្សែបញ្ជូន និងសេវាកម្មពាក់ព័ន្ធនៅក្នុងឧស្សាហកម្មថាមពល។

ក្រុមហ៊ុន PESTECH Hinthar Corporation Limited ("PHC") បានចុះបញ្ជីក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ដែលភាគហ៊ុន ៦០% កាន់កាប់ដោយ PML ក្រោមច្បាប់ក្រុមហ៊ុនមីយ៉ាន់ម៉ា ឆ្នាំ២០១៧។ ដើមទុនចុះបញ្ជីមានចំនួន ៥០.០០០ ដុល្លារអាមេរិកដែលស្មើនឹង ៥០.០០០ ភាគហ៊ុនធម្មតា។

សកម្មភាពអាជីវកម្មចម្បងរបស់ PESTECH Hinthar Corporation Limited ("PHC") គឺបង្កើតហេដ្ឋារចនាសម្ព័ន្ធនៃវិស័យថាមពល និងលើកកម្ពស់ផ្នែកថាមពលដូចជាការផលិត ការបញ្ជូន និងការចែកចាយថាមពល ប្រព័ន្ធ Microgrid និងហេដ្ឋារចនាសម្ព័ន្ធថាមពលផ្សេងៗជូនទៅដល់តំបន់ជនបទ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុន PESTECH Microgrid Limited ("PMG") បានចុះបញ្ជីក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ដែល៩០% កាន់កាប់ដោយ PHC ក្រោមការគ្រប់គ្រងស្របច្បាប់របស់ក្រុមហ៊ុនមីយ៉ាន់ម៉ាឆ្នាំ២០១៧។ ដើមទុនចុះបញ្ជីមានចំនួន ១០.០០០ដុល្លារអាមេរិក ដែលស្មើនឹង១០.០០០ ភាគហ៊ុនធម្មតា។

សកម្មភាពអាជីវកម្មចម្បងរបស់ PMG គឺផ្តល់ប្រព័ន្ធ Microgrid និងហេដ្ឋារចនាសម្ព័ន្ធថាមពលផ្សេងៗជូនតំបន់ជនបទ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុនចាត់ទុកក្រុមហ៊ុន PHC និងក្រុមហ៊ុន PMG ជាក្រុមហ៊ុនបុត្រសម្ព័ន្ធដោយប្រយោល។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន គឺនៅជាន់ទី១០ អគារលេខ៣៥ មហាវិថីម៉ៅសេទុង ភូមិ៩ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ PML PHC និងPMG គឺបានផ្លាស់ប្តូរទីតាំងទៅអគារ ២៤-២៦ ផ្លូវ South Race Course បន្ទប់ PH-C ជាន់ Penthouse ខុនដូ Race Course តំបន់ Tamwe ទីក្រុងយ៉ាន់ហ្គូន នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុនពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពចម្បងរបស់ក្រុមហ៊ុន និងក្រុមហ៊ុនបុត្រសម្ព័ន្ធ និងស្ថានភាពប្រតិបត្តិការ នៅក្នុងអំឡុងកាលបរិច្ឆេទនៃរបាយការណ៍នេះទេ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

លទ្ធផលនៃប្រតិបត្តិការ
លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនសម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និងស្ថានភាពនៅក្នុងការិយបរិច្ឆេទនេះ ត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

ក្រុមប្រឹក្សាភិបាល បានធ្វើសេចក្តីណែនាំឱ្យមានការបែងចែកភាគលាភចុងក្រោយចំនួន ០.០០៦៥ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន ដែលមានសមតុល្យ ៤៨៧.០០០ ដុល្លារអាមេរិក ដែលមាននៅក្នុងចុងបញ្ចប់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១។

ក្រុមប្រឹក្សាភិបាល
សមាជិកក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនអំឡុងការិយបរិច្ឆេទ និងកាលបរិច្ឆេទនៃរបាយការណ៍មានដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង | ថ្ងៃខែតែងតាំង |
|---|---|---|
| Mr. Lim Pay Chuan | ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ | ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ |
| Mr. Lim Ah Hock | អភិបាលប្រតិបត្តិ | ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ |
| Mr. Tan Pu Hooi | អភិបាលប្រតិបត្តិ | ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ |
| Mr. Han Fatt Juan | អភិបាលប្រតិបត្តិ/នាយកប្រតិបត្តិ | ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ |
| Mr. Dav Ansan | អភិបាលមិនមែនប្រតិបត្តិឯករាជ្យ | ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ |

សវនករ
របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុន ហ្គ្រែន ស៊នថុន (ខេមបូឌា) លីមីធីត។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល
ក្នុងអំឡុង និងការិយបរិច្ឆេទដែលបានបញ្ចប់នេះ មិនមានការរៀបចំណាមួយដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន មានគោលបំណងអនុញ្ញាតឱ្យក្រុមប្រឹក្សាភិបាលបច្ចុប្បន្នរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ទទួលបាននូវអត្ថប្រយោជន៍តាមរយៈការជាវភាគហ៊ុន ឬប័ណ្ណបំណុលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ឬសាជីវកម្មស្ថាប័នផ្សេងទៀតនោះទេ។

ចាប់តាំងពីចុងបញ្ចប់នៃចុងការិយបរិច្ឆេទមុន មិនមានក្រុមប្រឹក្សាភិបាលបច្ចុប្បន្នរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបានអត្ថប្រយោជន៍ណាមួយឡើយក្រោមហេតុផលនៃកិច្ចសន្យាដែលធ្វើឡើងដោយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ឬសាជីវកម្មដែលពាក់ព័ន្ធជាមួយសមាជិកនៃក្រុមប្រឹក្សាភិបាល ឬជាមួយក្រុមហ៊ុន ដែលក្រុមប្រឹក្សាភិបាលមានផលប្រយោជន៍ជាសារវន្តនៃផ្នែកហិរញ្ញវត្ថុ លើកលែងតែអត្ថប្រយោជន៍ដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ ២៩ នៃរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ
ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវក្នុងការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ។ នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្របដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្នហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

(ខ) គោរពតាមតម្រូវការលាតត្រដាងនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណា មួយពីតម្រូវការទាំងនោះ ក្នុងការបង្ហាញនូវភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) រក្សាទុកកំណត់ត្រាគណនេយ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនអាចសន្មតថាក្រុមបុត្រសម្ព័ន្ធ និងក្រុមហ៊ុន នឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នាពេលអនាគតបន្តទៀតបាន និង

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមបុត្រសម្ព័ន្ធ និងក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពចូលរួមលើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗទាំងអស់ដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការរបស់ក្រុមបុត្រសម្ព័ន្ធ និងក្រុមហ៊ុនហើយត្រូវប្រាកដថារាល់ការសម្រេចចិត្ត និង/ឬ សេចក្តីណែនាំនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍របស់សវនករឯករាជ្យ

ក្រុមប្រឹក្សាភិបាល ក៏មានទំនួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ហើយក៏ត្រូវចាត់វិធានការឱ្យសមស្របដើម្បីទប់ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថាសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុ បានអនុវត្តតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ ហិរញ្ញវត្ថុ។

**សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល**
តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាលអមជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបាយការណ៍ចំណេញ ឬខាត និងរបាយការណ៍ចំណូលពេញលេញផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ ព្រមទាំងកំណត់សម្គាល់ផ្សេងទៀត ដែលបានរៀបចំឡើងយ៉ាងសមស្រប និងផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរ សាច់ប្រាក់ សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ជំនួសឱ្យក្រុមប្រឹក្សាភិបាល






Lim Pay Chuan
ប្រធានក្រុមប្រឹក្សាភិបាល

ទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី
ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២

# របាយការណ៍របស់សវនករឯករាជ្យ

**ហ្ក្រេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អាគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

ជូនចំពោះភាគហ៊ុនិករបស់
ផេសចិក (ខេមបូឌា) ម.ក

## មតិយោបល់

យើងបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនផេសចិក (ខេមបូឌា) ម.ក ("ក្រុមហ៊ុន") និងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុមហ៊ុន និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន (ដែលត់ទៅនេះហៅកាត់ថា "សម្ព័ន្ធក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ របាយការណ៍ចំណូលលម្អិត របាយការណ៍
បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ដែលបានរួមបញ្ចូលទាំងសេចក្តីសង្ខេបទៅលើគោលការណ៍គណនេយ្យសំខាន់ៗ និងសេចក្តីពន្យល់ព័ត៌មានផ្សេងៗទៀត។

តាមមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់
សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់ សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ
អន្តរជាតិនៃកម្ពុជា ("CIFRSs")។

## មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន ដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដារវិជ្ជាជីវៈ គណនេយ្យអន្តរជាតិ ក្រមសីលធម៌ របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ) ("IESBA Code") រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និងIESBA Code។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន គឺគ្រប់គ្រាន់ និងសម័ស្របដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

## បញ្ហាសវនកម្មសំខាន់ៗ

បញ្ហាសវនកម្មសំខាន់ៗ គឺជាបញ្ហាទាំងឡាយដែលកើតមាននៅក្នុងការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំដែលមាន
សារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។ បញ្ហាទាំងនេះត្រូវបានដោះស្រាយក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍
ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនជារួមក្នុងការបញ្ចេញមតិយោបល់សវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំមិនធ្វើការបញ្ចេញមតិយោបល់ដាច់ដោយឡែកទាក់ទងនឹងបញ្ហាទាំងនេះឡើយ។

# របាយការណ៍របស់សវនករឯករាជ្យ

ខាងក្រោមនេះជាបញ្ហាសវនកម្មសំខាន់ៗ ដែលបានកំណត់អត្តសញ្ញាណក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន៖

| បញ្ហាសវនកម្មសំខាន់ៗ | វិធីសាស្ត្រដែលសវនករយើងខ្ញុំកំណត់នូវបញ្ហាសវនកម្មសំខាន់ៗ |
|---|---|
| **ការទទួលស្គាល់ចំណូល និងថ្លៃដើមក្នុងកិច្ចសន្យាសាងសង់**<br><br>ការទទួលស្គាល់ចំណូល និងថ្លៃដើមទៅលើកិច្ចសន្យាសាងសង់ គឺត្រូវបានទទួលស្គាល់ដោយអនុលោមជាមួយគោលនយោបាយគណនេយ្យ និងការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ ដូចដែលបានបកស្រាយលម្អិតនៅក្នុងកំណត់សម្គាល់ ៤.៤ និង៥ ទៅលើរបាយការណ៍ហិរញ្ញវត្ថុនានា។<br><br>យើងខ្ញុំផ្តោតសំខាន់ទៅលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសំខាន់ៗរបស់គណៈគ្រប់គ្រងត្រូវបានរួមបញ្ចូលទៅក្នុងការកំណត់ដូចខាងក្រោម៖<br><br>(i) តម្លៃប្រតិបត្តិការលើកិច្ចសន្យាសាងសង់ដោយគិតបញ្ចូលទាំងសមាសធាតុហិរញ្ញវត្ថុសំខាន់ៗ<br><br>(ii) តម្លៃសមស្របក្នុងការផ្តល់សេវាកម្មដែលពាក់ព័ន្ធ និងការបែងចែកលើសាច់ប្រាក់ដែលបានទទួលឬត្រូវទទួលបាននៃសេវាកម្មនីមួយៗ<br><br>(iii) ដំណាក់កាលក្នុងការបំពេញកិច្ចការដោយប្រើប្រាស់វិធីសាស្ត្រធាតុចេញ ដោយផ្អែកលើដំណាក់កាលក្នុងការបញ្ចប់គម្រោងអភិវឌ្ឍន៍ដោយមានការបញ្ជាក់ពីវិស្វករជំនាញ ឬអ្នកប្រឹក្សាជំនាញ<br><br>(iv) វិសាលភាពនៃថ្លៃដើមកិច្ចសន្យាដែលបានកើតឡើងរហូតដល់កាលបរិច្ឆេទបច្ចុប្បន្ន<br><br>(v) ថ្លៃដើមកិច្ចសន្យាសាងសង់សរុប និងថ្លៃដើមក្នុងការបញ្ចប់ការសាងសង់ និង<br><br>(vi) សំវិធានធនទៅលើការខូចខាតដែលបានបញ្ជាក់ | ក្នុងការដោះស្រាយបញ្ហាសំខាន់ៗទាំងនេះ យើងខ្ញុំបានអនុវត្តនូវនីតិវិធីផ្សេងៗដូចខាងក្រោម៖<br><br>- រយៈពេលប្រើប្រាស់ និងលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចសន្យាជាមួយអតិថិជន និងអ្នកម៉ៅការបន្ត/អ្នកផ្គត់ផ្គង់ ដើម្បីកំណត់នូវកិច្ចសន្យាសំខាន់ៗដាច់ដោយឡែក និងបានវាយតម្លៃទំនាក់ទំនងរវាងចំណូល និងថ្លៃដើមដែលបានទទួលស្គាល់<br><br>- បានវាយតម្លៃទៅលើចំណូលពីកិច្ចសន្យាសាងសង់សរុបតាមរយៈការពិនិត្យមើលភស្តុតាងដូចជាកិច្ចសន្យាសាងសង់ដែលបានអនុម័តក្នុងការបញ្ជាទិញ និងទំនាក់ទំនងជាមួយអតិថិជន និងការផ្ទៀងផ្ទាត់ទៅលើដំណើរការទូទាត់សង។ ក្នុងករណីដែលគម្រោងត្រូវបានពន្យារពេលបានធ្វើការវាយតម្លៃទៅលើភាពចាំបាច់ និងភាពគ្រប់គ្រាន់លើសំវិធានធនលើការខូចខាតដែលបានបញ្ជាក់ដោយផ្អែកទៅលើប៉ាន់ស្មានរបស់គណៈគ្រប់គ្រងនិងត្រូវបានត្រួតពិនិត្យទៅលើឯកសារយោង ដែលមានដូចជាឯកសារទាក់ទងជាមួយអតិថិជន ឬអ្នកប្រឹក្សាយោបល់ ការពន្យារពេលទៅលើការអនុម័ត និងដំណើរការបង្កើតរបាយការណ៍ដែលបញ្ជាក់ពីហេតុផលនៃការពន្យារពេល<br><br>- បានវាយតម្លៃពីភាពសមស្រប និងភាពស្ថិតស្ថេរនៃការសន្មតសំខាន់ៗដែលបានប្រើប្រាស់ដោយគណៈគ្រប់គ្រងដើម្បីកំណត់តម្លៃប្រតិបត្តិការនៃកិច្ចសន្យាសាងសង់ដោយរួមបញ្ចូលទាំងសមាសធាតុហិរញ្ញវត្ថុសំខាន់ៗ តម្លៃសមស្របនៃសេវាកម្មដែលត្រូវទទួលបាន និង/ឬត្រូវទទួលនៃសេវាកម្មនីមួយៗ<br><br>- បានវាយតម្លៃលើលទ្ធភាព សមត្ថភាព និងគោលបំណងអ្នកប្រឹក្សាយោបល់វិស្វករឯករាជ្យ ឬវិស្វកររបស់ក្រុមហ៊ុន<br><br>- ពិនិត្យមើលដំណាក់កាលក្នុងការបំពេញកិច្ចសន្យាសាងសង់លើមូលដ្ឋានគំរូទៅលើការបំពេញរបាយការណ៍ដោយវិស្វករជំនាញ ឬអ្នកប្រឹក្សាយោបល់<br><br>- បានវាយតម្លៃលើមូលដ្ឋានដែលបានប្រើប្រាស់ក្នុងការកំណត់ចំណាយកិច្ចសន្យាគម្រោងថវិកា<br><br>- បានវាយតម្លៃលើចំណាយជាក់ស្តែងដែលបានកើតឡើងនិងចំណាយបង្ករដោយពិនិត្យលើភស្តុតាងដែលមានដូចជាដំណើរការក្នុងការទាមទារសំណងរបស់អ្នកម៉ៅការនិងការចេញវិក្កយបត្ររបស់អ្នកផ្គត់ផ្គង់ ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ និង/ឬឆ្នាំហិរញ្ញវត្ថុបន្ទាប់<br><br>- ធ្វើការសម្ភាសអ្នកប្រឹក្សាយោបល់វិស្វករឯករាជ្យ ដើម្បីស្វែងយល់ពីមូលដ្ឋានដែលបានប្រើប្រាស់ក្នុងការផ្ទៀងផ្ទាត់ដំណាក់កាលក្នុងការបញ្ចប់ការសាងសង់ និង<br><br>- ធ្វើការសម្ភាសក្រុមគណៈគ្រប់គ្រងគម្រោងលើការសម្រេចបាននូវគម្រោងចំណាយដែលបានព្យាករណ៍ទុកក្នុងការបញ្ចប់ការសាងសង់លើគម្រោងឯកជនដាច់ដោយឡែក។ |

# របាយការណ៍របស់សវនករឯករាជ្យ

| បញ្ហាសវនកម្មសំខាន់ៗ | វិធីសាស្ត្រដែលសវនករយើងខ្ញុំកំណត់នូវបញ្ហាសវនកម្មសំខាន់ៗ |
|---|---|
| លទ្ធភាពដែលអាចប្រមូលបានមកវិញនៃគណនីពាណិជ្ជត្រូវទទួល និងទ្រព្យសកម្មកិច្ចសន្យា<br><br>CIFRS៩ណែនាំពីគំរូឱនភាពនៃការខាតបង់ឥណទានដែលបានរំពឹងទុក ("ECL") ដែលតម្រូវឱ្យមានការប្រើប្រាស់ការសន្មត់សំខាន់ៗអំពីលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត ហើយហានិភ័យឥណទានរបស់អតិថិជនក្នុងការគណនាសំវិធានធនលើការខាតបង់។ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនត្រូវបានវាយតម្លៃលើរយៈពេលនៃការខាតបង់ឥណទាននៃសមតុល្យរបស់គណនីពាណិជ្ជត្រូវទទួល និងទ្រព្យសកម្មកិច្ចសន្យាដែលរំពឹងទុកដោយប្រើប្រាស់វិធីសាស្ត្រសាមញ្ញ។ ដូចដែលបានបង្ហាញក្នុងកំណត់សម្គាល់ ១០ និង១២ ទៅលើរបាយការណ៍ហិរញ្ញវត្ថុសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានទ្រព្យសកម្មកិច្ចសន្យា និងគណនីពាណិជ្ជត្រូវទទួលគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ហើយទាំងនេះជាកត្តាបង្ករឱ្យមានហានិភ័យឥណទាន។ យើងខ្ញុំផ្ដោតសំខាន់ទៅលើបញ្ហានេះព្រោះការវាយតម្លៃរបស់គណៈគ្រប់គ្រងលើ ECL តម្រូវឱ្យមានការវិនិច្ឆ័យសំខាន់ៗទៅលើអត្រាការខាតបង់ដែលបានរំពឹងទុក ព័ត៌មានយោងទៅមុខ និងការប៉ាន់ស្មានដែលអាចកើតមាន។ ព័ត៌មានលម្អិតនៃគោលនយោបាយគណនេយ្យ ប៉ាន់ស្មាន និងការសន្មតសំខាន់ៗ ព្រមទាំងការគ្រប់គ្រងហានិភ័យឥណទានដែលបានប្រើប្រាស់ដោយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់៤.៨ ៥ (ក) និង ៣៣ (ក) ទៅលើរបាយការណ៍ហិរញ្ញវត្ថុ។ | ក្នុងការដោះស្រាយបញ្ហាសំខាន់ៗទាំងនេះ យើងខ្ញុំបានអនុវត្តនូវនីតិវិធីមួយចំនួនដូចខាងក្រោម៖<br><br>- ស្វែងយល់ពីរបៀបដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនកំណត់អត្តសញ្ញាណ និងវាយតម្លៃលើECL សម្រាប់គណនីពាណិជ្ជដែលត្រូវទទួល និងទ្រព្យសកម្មកិច្ចសន្យា<br><br>- ត្រួតពិនិត្យឡើងវិញនូវប្រភពទិន្នន័យសំខាន់ៗ និងការសន្មតលើទិន្នន័យដែលបានប្រើប្រាស់ក្នុងកំណត់អត្រាលំនាំដើម និងបច្ចុប្បន្ន និងការកែប្រែកត្តាដែលបានយោងទៅមុខ<br><br>- ពិចារណាលើកាលកំណត់នៃបំណុល ក៏ដូចជានិន្នាការនៃប្រមូលផ្ដុំដើម្បីវាយតម្លៃលើការប្រមូលផ្ដុំហានិភ័យ<br><br>- ទទួលបានការបញ្ជាក់ពីកូនបំណុល និងត្រួតពិនិត្យលើ លទ្ធភាពដែលអាចប្រមូលបានមកវិញ តាមរយៈរក្សាទុកនូវ ភស្តុតាងជាវិក្កយបត្រពីកូនបំណុលលើមូលដ្ឋានបន្តបន្ទាប់រហូតដល់ចុងបញ្ចប់ការិយបរិច្ឆេទ។ |

**ព័ត៌មានផ្សេងៗ**

ខាងក្រោមនេះជាបញ្ហាសវនកម្មសំខាន់ៗ ដែលបានកំណត់អត្តសញ្ញាណក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន៖

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្ដប់ទៅលើព័ត៌មានផ្សេងៗទេ។ ហើយយើងខ្ញុំក៏មិនផ្ដល់ការធានាក្នុងទម្រង់បែបណាមួយឡើយ។

ភ្ជាប់ជាមួយការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើពត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ថាតើពត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្ត ឬទេ។

ប្រសិនបើ ផ្អែកតាមការងារដែលយើងធ្វើសវនកម្ម យើងខ្ញុំសន្មតថាមានកំហុសជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្ដែង។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍នៅក្នុងករណីនេះឡើយ។

# របាយការណ៍របស់សវនករឯករាជ្យ

**ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងទៅលើរបាយការណ៍ហិរញ្ញវត្ថុ**
គណៈគ្រប់គ្រងរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs") និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើសមត្ថភាពរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ក្នុងការបន្តប្រតិបត្តិការ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាង ប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់និរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំសាយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ឬបញ្ឈប់ ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

**ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ**
គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមាន លក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង បញ្ចេញមតិលើរបាយការណ៍របស់សវនករ ដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់ ប៉ុន្តែវាមិនបានធានាថា ការធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិរបស់កម្ពុជា នឹងតែងតែរកឃើញកំហុសខុសឆ្គង នៅពេលវាកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នក
ប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃជាការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា រៀបចំ និងអនុវត្តនីតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយ សារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុង ដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុននោះទេ។

- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មានក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រង។

- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់គណៈគ្រប់គ្រងលើមូលដ្ឋាននិរន្តរភាព គណនេយ្យផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជា ជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពក្នុងការបន្តនិរន្តរភាពរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវ នឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។

- វាយតម្លៃការបង្ហាញទូទៅ ទម្រង់ និងអត្ថន័យរបស់ព័ត៌មានហិរញ្ញវត្ថុរួមបញ្ចូលទាំងការលាតត្រដាងនានាថាតើព័ត៌មានហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

- ប្រមូលភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ទាក់ទងទៅនឹងព័ត៌មានហិរញ្ញវត្ថុ ឬសកម្មភាពអាជីវកម្មរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនដើម្បីបញ្ចេញមតិយោបល់ទៅលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំទទួលខុសត្រូវចំពោះការចាត់ចែង ការគ្រប់គ្រង និងការអនុវត្តសវនកម្ម។ យើងខ្ញុំទទួលខុសត្រូវតែមតិយោបល់សវនកម្មរបស់យើងតែប៉ុណ្ណោះ។

# របាយការណ៍របស់សវនករឯករាជ្យ

**ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ(ត)**
យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងគណៈគ្រប់គ្រងទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់ជូនគណៈគ្រប់គ្រង នូវសេចក្តីថ្លែងការណ៍មួយដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលនូវបញ្ហាទាំងអស់ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និងការការពារដែលអាចមាន។

បញ្ហានានាដែលយើងខ្ញុំជម្រាបជូនគណៈគ្រប់គ្រង យើងខ្ញុំកំណត់ទៅលើបញ្ហាណាដែលមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទនាពេលបច្ចុប្បន្ន ហើយបញ្ហាទាំងនោះត្រូវកំណត់ថាជា បញ្ហាសវនកម្មសំខាន់ៗ។ យើងខ្ញុំពណ៌នាពីបញ្ហាទាំងនេះនៅក្នុងរបាយការណ៍របស់សវនករយើងខ្ញុំ លើកលែងតែច្បាប់ ឬបទប្បញ្ញត្តិរាំងស្ទះដល់ការបង្ហាញជាសាធារណៈ ឬនៅក្នុងកាលៈទេសៈចាំបាច់ណាមួយ យើងខ្ញុំអាចកំណត់ថាបញ្ហានោះ មិនគួរត្រូវបានពណ៌នានៅក្នុងរបាយការណ៍របស់យើងខ្ញុំទេ ព្រោះផលប៉ះពាល់ជាអវិជ្ជមាននឹងត្រូវបានរំពឹងទុកដោយសមហេតុផលថាវាលើសពីផលប្រយោជន៍ជាសាធារណៈ ដែលកើតចេញពីបញ្ហានោះ។

GRANT THORNTON (CAMBODIA) LIMITED
ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ng Yee Zent
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២

# របាយការណ៍ស្ថានភាព ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| (សម្គាល់៤.២) | កំណត់សម្គាល់ | ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២២ លានរៀល (សម្គាល់៤.២) | ថ្ងៃទ៣០ ខែមិថុនា ២០២១ លានរៀល |
|---|---|---|---|---|---|
| ទ្រព្យសកម្ម | | | | | |
| ទ្រព្យសកម្មរយៈពេលវែង | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៧ | ១៣,៦០៤ | ១៤,១៥០ | ៥៥,៣៦៨ | ៥៧,៦៦១ |
| ទ្រព្យសកម្មអរូបិយ | | ៩ | ៣ | ៣៧ | ១២ |
| ទ្រព្យសកម្មកិច្ចសន្យា | ១០ | ១០៩,២៦២ | ១២២,១៦៧ | ៤៤៤,៦៩៦ | ៤៩៧,៨៣១ |
| ទ្រព្យសកម្មរយៈពេលវែងសរុប | | ១២២,៨៧៥ | ១៣៦,៣២០ | ៥០០,១០១ | ៥៥៥,៥០៤ |
| ទ្រព្យសកម្មរយៈពេលខ្លី | | | | | |
| សន្និធិ | ១១ | ៣,៣៣៨ | ៣,៥០៨ | ១៣,៥៨៦ | ១៤,២៩៥ |
| ទ្រព្យសកម្មកិច្ចសន្យា | ១០ | ១៥៥,៩៥០ | ១២២,៨៥១ | ៦៣៤,៧១៧ | ៥០០,៦១៨ |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ១២ | ៣,១៤២ | ៦,៥០៣ | ១២,៧៨៨ | ២៦,៥០១ |
| សមតុល្យត្រូវទទួលពីភាគីពាក់ព័ន្ធ | ២៨ | ២២៤ | ២ | ៩១១ | ៨ |
| សាច់ប្រាក់ និងសមតុល្យធនាគារ | ១៣ | ៩,៨៧២ | ១៧,១៦៧ | ៤០,១៧៩ | ៦៩,៩៥៦ |
| ទ្រព្យសកម្មរយៈពេលខ្លីសរុប | | ១៧២,៥២៦ | ១៥០,០៣១ | ៧០២,១៨១ | ៦១១,៣៧៨ |
| ទ្រព្យសកម្មសរុប | | ២៩៥,៤០១ | ២៨៦,៣៥១ | ១,២០២,២៨២ | ១,១៦៦,៨៨២ |
| មូលធន និងបំណុល | | | | | |
| មូលធន | | | | | |
| ដើមទុន | ១៤ | ៧,៤៩៤ | ៧,៤៩៤ | ៣០,៧២៥ | ៣០,៧២៥ |
| ដើមទុនបុព្វលាភ | ១៥ | ២,៥៤១ | ២,៥៤១ | ១០,៤២២ | ១០,៤២២ |
| ប្រាក់បម្រុង | ១៦ | (៤០០) | (៤,២៦៩) | (១,៨៨៣) | (១៧,៤៣៥) |
| ចំណេញរក្សាទុក | | ១៧,៣១០ | ១៧,១៩០ | ៧០,៤៥២ | ៧០,០៤០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | | - | - | (៥១) | (២០៦) |
| មូលធនសរុបបែងចែកទៅ | | | | | |
| ម្ចាស់ក្រុមហ៊ុន | | ២៦,៩៤៥ | ២២,៩៥៦ | ១០៩,៦៦៥ | ៩៣,៥៤៦ |
| ភាគហ៊ុនបន្ទាប់បន្សំ | | ៨៦ | ៨៦ | ៣៥១ | ៣៥១ |
| មូលធនសរុប | | ២៧,០៣១ | ២៣,០៤២ | ១១០,០១៦ | ៩៣,៨៩៧ |
| បំណុល | | | | | |
| បំណុលរយៈពេលវែង | | | | | |
| ប្រាក់កម្ចី | ១៨ | ៨២,០៧១ | ៩១,៥៧៥ | ៣៣៤,០២៩ | ៣៧៣,១៦៨ |
| បំណុលភតិសន្យា | ៨ | ២៣០ | ១៤៨ | ៩៣៤ | ៦០៣ |
| ពន្ធពន្យារជាបំណុល | ២៦ | ៩៨៦ | ៧៧៧ | ៤,០១៣ | ៣,១៦៦ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ | ១៩ | ៤៥២ | ៤,៣២១ | ១,៨៣៨ | ១៧,៦០៨ |
| បំណុលរយៈពេលវែងសរុប | | ៨៣,៧៣៩ | ៩៦,៨២១ | ៣៤០,៨១៤ | ៣៩៤,៥៤៥ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| (សម្គាល់៤.២) | កំណត់សម្គាល់ | ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២២ លានរៀល (សម្គាល់៤.២) | ថ្ងៃទ៣០ ខែមិថុនា ២០២១ លានរៀល |
|---|---|---|---|---|---|
| បំណុល (ត) | | | | | |
| បំណុលរយៈពេលខ្លី | | | | | |
| បំណុលកិច្ចសន្យា | ១០ | ១៦២ | - | ៦៥៩ | - |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ | ១៧ | ៤៦,៩៩៧ | ៣៣,៣៩៦ | ១៩១,២៧៥ | ១៣៦,០៨៩ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៨ | ២៦,៨៣៤ | ២៧,០៥៤ | ១០៩,២១៤ | ១១០,២៤៥ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ២៨ | ៨៩,៥៩៧ | ៩០,៦៦៨ | ៣៦៤,៦៥៩ | ៣៦៩,៤៧២ |
| ប្រាក់កម្ចី | ១៨ | ២០,២៨១ | ១៣,៥៤៤ | ៨២,៥៤៤ | ៥៥,១៩២ |
| បំណុលភតិសន្យា | ៨ | ១១៨ | ១៤ | ៤៨២ | ៥៨ |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | | ៦៤២ | ១,៨១២ | ២,៦១៩ | ៧,៣៨៤ |
| បំណុលរយៈពេលខ្លីសរុប | | ១៨៤,៦៣១ | ១៦៦,៤៨៨ | ៧៥១,៤៥២ | ៦៧៨,៤៤០ |
| បំណុលសរុប | | ២៦៨,៣៧០ | ២៦៣,៣០៩ | ១,០៩២,២៦៦ | ១,០៧២,៩៨៥ |
| មូលធន និងបំណុលសរុប | | ២៩៥,៤០១ | ២៨៦,៣៥១ | ១,២០២,២៨២ | ១,១៦៦,៨៨២ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍ស្ថានភាព ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| (សម្គាល់៤.២) | កំណត់សម្គាល់ | ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២២ លានរៀល (សម្គាល់៤.២) | ថ្ងៃទ៣០ ខែមិថុនា ២០២១ លានរៀល |
|---|---|---|---|---|---|
| ទ្រព្យសកម្ម | | | | | |
| ទ្រព្យសកម្មរយៈពេលវែង | | | | | |
| ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | ៩ | ៥០ | ៥០ | ២០៤ | ២០៤ |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៧ | ១៣,៦០៤ | ១៤,១៥០ | ៥៥,៣៦៨ | ៥៧,៦៦១ |
| ទ្រព្យសកម្មអរូបិយ | | ៩ | ៣ | ៣៧ | ១២ |
| ទ្រព្យសកម្មកិច្ចសន្យា | ១០ | ១០៩,២៦២ | ១២២,១៦៧ | ៤៤៤,៦៩៦ | ៤៩៧,៨៣១ |
| ទ្រព្យសកម្មរយៈពេលវែងសរុប | | ១២២,៩២៥ | ១៣៦,៣៧០ | ៥០០,៣០៥ | ៥៥៥,៧០៨ |
| ទ្រព្យសកម្មរយៈពេលខ្លី | | | | | |
| សន្និធិ | ១១ | ៣,៣៣៨ | ៣,៥០៨ | ១៣,៥៨៦ | ១៤,២៩៥ |
| ទ្រព្យសកម្មកិច្ចសន្យា | ១០ | ១៥៥,៩៥០ | ១២២,៨៥១ | ៦៣៤,៧១៧ | ៥០០,៦១៨ |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ១២ | ៣,១៤២ | ៦,៤៩៧ | ១២,៧៨៨ | ២៦,៤៧៥ |
| សមតុល្យត្រូវទទួលពីភាគីពាក់ព័ន្ធ | ២៨ | ២២៤ | ២ | ៩១១ | ៨ |
| សមតុល្យត្រូវទទួលពីក្រុមហ៊ុនបុត្រសម្ព័ន្ធ | ២៨ | ៩៧ | ៧៩ | ៣៩៥ | ៣២២ |
| សាច់ប្រាក់ និងសមតុល្យធនាគារ | ១៣ | ៩,៨៦៦ | ១៧,១៥៤ | ៤០,១៥៥ | ៦៩,៩០៣ |
| ទ្រព្យសកម្មរយៈពេលខ្លីសរុប | | ១៧២,៦១៧ | ១៥០,០៩១ | ៧០២,៥៥២ | ៦១១,៦២១ |
| ទ្រព្យសកម្មសរុប | | ២៩៥,៥៤២ | ២៨៦,៤៦១ | ១,២០២,៨៥៧ | ១,១៦៧,៣២៩ |
| មូលធន និងបំណុល | | | | | |
| មូលធន | | | | | |
| ដើមទុន | ១៤ | ៧,៤៩៤ | ៧,៤៩៤ | ៣០,៧២៥ | ៣០,៧២៥ |
| ដើមទុនបុព្វលាភ | ១៥ | ២,៥៤១ | ២,៥៤១ | ១០,៤២២ | ១០,៤២២ |
| ប្រាក់បម្រុង | ១៦ | (៤០០) | (៤,២៦៩) | (១,៨៨៣) | (១៧,៤៣៥) |
| ចំណេញរក្សាទុក | | ១៧,៥៤២ | ១៧,៤០០ | ៧១,៣៩៥ | ៧០,៩១២ |
| លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | | - | - | (៥០) | (២២៣) |
| មូលធនសរុប | | ២៧,១៧៧ | ២៣,១៦៦ | ១១០,៦០៩ | ៩៤,៤០១ |
| បំណុល | | | | | |
| បំណុលរយៈពេលវែង | | | | | |
| ប្រាក់កម្ចី | ១៨ | ៨២,០៧១ | ៩១,៥៧៥ | ៣៣៤,០២៩ | ៣៧៣,១៦៨ |
| បំណុលភតិសន្យា | ៨ | ២៣០ | ១៤៨ | ៩៣៤ | ៦០៣ |
| ពន្ធពន្យារជាបំណុល | ២៦ | ៩៨៦ | ៧៧៧ | ៤,០១៣ | ៣,១៦៦ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ | ១៩ | ៤៥២ | ៤,៣២១ | ១,៨៣៨ | ១៧,៦០៨ |
| បំណុលរយៈពេលវែងសរុប | | ៨៣,៧៣៩ | ៩៦,៨២១ | ៣៤០,៨១៤ | ៣៩៤,៥៤៥ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍ស្ថានភាព ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| (សម្គាល់៤.២) | ថ្ងៃទ៣០ ខែមិថុនា កំណត់សម្គាល់ | ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារ លានរៀល (សម្គាល់៤.២) | ២០២១ ពាន់ដុល្លារ លានរៀល |
|---|---|---|---|---|---|
| បំណុល (ត) | | | | | |
| បំណុលរយៈពេលខ្លី | | | | | |
| បំណុលកិច្ចសន្យា | ១០ | ១៦២ | - | ៦៥៩ | - |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ | ១៧ | ៤៦,៩៩២ | ៣៣,៣៨២ | ១៩១,២៥៧ | ១៣៦,០៣២ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៨ | ២៦,៨៣៤ | ២៧,០៥៤ | ១០៩,២១៤ | ១១០,២៤៥ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ២៨ | ៨៩,៥៩៧ | ៩០,៦៦៨ | ៣៦៤,៦៥៩ | ៣៦៩,៤៧២ |
| ប្រាក់កម្ចី | ១៨ | ២០,២៨១ | ១៣,៥៤៤ | ៨២,៥៤៤ | ៥៥,១៩២ |
| បំណុលភតិសន្យា | ៨ | ១១៨ | ១៤ | ៤៨២ | ៥៨ |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | | ៦៤២ | ១,៨១២ | ២,៦១៩ | ៧,៣៨៤ |
| បំណុលរយៈពេលខ្លី | | ១៨៤,៦២៦ | ១៦៦,៤៧៤ | ៧៥១,៤៣៤ | ៦៧៨,៣៨៣ |
| បំណុលសរុប | | ២៦៨,៣៦៥ | ២៦៣,២៩៥ | ១,០៩២,២៤៨ | ១,០៧២,៩២៨ |
| មូលធន និងបំណុលសរុប | | ២៩៥,៥៤២ | ២៨៦,៤៦១ | ១,២០២,៨៥៧ | ១,១៦៧,៣២៩ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗរបស់សម្ព័ន្ធក្រុមហ៊ុន

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| បរិច្ឆេទ | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | | សម្រាប់ចុងបញ្ចប់ការិយ | |
|---|---|---|---|---|---|
| (សម្គាល់៤.២)) | កំណត់សម្គាល់ | ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារ លានរៀល (សម្គាល់៤.២) | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារ លានរៀល |
| ចំណូល | ២០ | ៥៣,២០២ | ៦៧,២១៤ | ២១៦,៣៥៥ | ២៧៣,៦២៨ |
| ចំណាយប្រតិបត្តិការ | ២១ | (៤៧,៦៥៩) | (៥៩,៧៤០) | (១៩៣,៨១២) | (២៤៣,២០១) |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២២ | ៦៥ | ១៤៤ | ២៦៤ | ៥៨៦ |
| ប្រាក់ចំណេញផ្សេងៗ | | ១១ | ៥ | ៤៥ | ២០ |
| ចំណេញប្រតិបត្តិការ | | ៥,៦១៩ | ៧,៦២៣ | ២២,៨៥២ | ៣១,០៣៣ |
| ចំណូលហិរញ្ញវត្ថុ | ២៣ | ២,៨៧៤ | ១,០៩៨ | ១១,៦៨៨ | ៤,៤៧០ |
| ថ្លៃដើមហិរញ្ញវត្ថុ | ២៤ | (៧,១៤៥) | (៦,២៤៣) | (២៩,០៥៧) | (២៥,៤១៥) |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | ១,៣៤៨ | ២,៤៧៨ | ៥,៤៨៣ | ១០,០៨៨ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៥ | (៧៤១) | (១,០០៩) | (៣,០១៣) | (៤,១០៨) |
| ចំណេញក្នុងការិយបរិច្ឆេទ | | ៦០៧ | ១,៤៦៩ | ២,៤៧០ | ៥,៩៨០ |
| ចំណេញក្នុងការិយបរិច្ឆេទដែលបែងចែកទៅ៖ | | | | | |
| ម្ចាស់ក្រុមហ៊ុន | | ៦០៧ | ១,៣៨៨ | ២,៤៧០ | ៥,៦៥០ |
| ភាគហ៊ុនបន្ទាប់បន្សំ | | - | ៨១ | - | ៣៣០ |
| ចំណេញក្នុងការិយបរិច្ឆេទ | | ៦០៧ | ១,៤៦៩ | ២,៤៧០ | ៥,៩៨០ |
| ចំណូលពេញលេញផ្សេងៗ- | | | | | |
| សមាសធាតុដែលត្រូវធ្វើចំណាត់ឡើងវិញក្នុងចំណេញ ឬខាត | | | | | |
| ចំណេញពីតម្លៃសមស្រែបពីការការពារ | | | | | |
| ហានិភ័យលំហូរសាច់ប្រាក់ | ៣,៨៦៩ | ១,៥៤៦ | ១៥,៧៣៤ | ៦,២៩៤ | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | (១០០) | (៦១២) |
| ចំណូលពេញលេញសរុបក្នុងការិយបរិច្ឆេទ | | ៤,៤៧៦ | ៣,០១៥ | ១៨,១០៤ | ១១,៦៦២ |
| ចំណេញក្នុងការិយបរិច្ឆេទទាក់ទងទៅនឹង៖ | | | | | |
| ម្ចាស់ក្រុមហ៊ុន | | ៤,៤៧៦ | ២,៨៥៣ | ១៨,១០៤ | ១១,០០២ |
| ភាគហ៊ុនបន្ទាប់បន្សំ | | - | ១៦២ | - | ៦៦០ |
| | | ៤,៤៧៦ | ៣,០១៥ | ១៨,១០៤ | ១១,៦៦២ |
| ចំណូលក្នុងមួយភាគហ៊ុនដែលជាកម្មសិទ្ធិរបស់ម្ចាស់ភាគហ៊ុនរបស់សម្ព័ន្ធក្រុមហ៊ុនក្នុងអំឡុងឆ្នាំមានដូចខាងក្រោម៖ | | | | | |
| ចំណេញមូលដ្ឋានក្នុងមួយភាគហ៊ុន (សេន/រៀល) | ៣២ | ០.៨១ | ១,៨៦ | ៣២,៩៦ | ៧៥,៨៦ |
| ចំណេញថយចុះក្នុងមួយភាគហ៊ុន (សេន/រៀល) | ៣២ | ០.៨១ | ១,៨៦ | ៣២,៩៦ | ៧៥,៨៦ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗរបស់សម្ព័ន្ធក្រុមហ៊ុន

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| បរិច្ឆេទ (សម្គាល់៤.២)) | កំណត់សម្គាល់ | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារអាមេរិក | សម្រាប់ចុងបញ្ចប់ការិយ ថ្ងៃទ៣០ ខែមិថុនា ២០២២ លានរៀល (សម្គាល់៤.២) | ថ្ងៃទ៣០ ខែមិថុនា ២០២១ លានរៀល |
|---|---|---|---|---|---|
| ចំណូល | ២០ | ៥៣,២០២ | ៦៧,២១៤ | ២១៦,៣៥៥ | ២៧៣,៦២៨ |
| ចំណាយប្រតិបត្តិការ | ២១ | (៤៧,៦៣៨) | (៥៩,៦៦១) | (១៩៣,៧២៧) | (២៤២,៨៨០) |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២២ | ៦៥ | ១៤៤ | ២៦៤ | ៥៨៦ |
| ប្រាក់ចំណេញផ្សេងៗ | | ១២ | ១៦ | ៤៩ | ៦៥ |
| ចំណេញប្រតិបត្តិការ | | ៥,៦៤១ | ៧,៧១៣ | ២២,៩៤១ | ៣១,៣៩៩ |
| ចំណូលហិរញ្ញវត្ថុ | ២៣ | ២,៨៧៤ | ១,០៩៨ | ១១,៦៨៨ | ៤,៤៧០ |
| ថ្លៃដើមហិរញ្ញវត្ថុ | ២៤ | (៧,១៤៥) | (៦,២៤៣) | (២៩,០៥៧) | (២៥,៤១៥) |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | ១,៣៧០ | ២,៥៦៨ | ៥,៥៧២ | ១០,៤៥៤ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៥ | (៧៤១) | (១,០០៩) | (៣,០១៣) | (៤,១០៨) |
| ចំណេញក្នុងការិយបរិច្ឆេទ | | ៦២៩ | ១,៥៥៩ | ២,៥៥៩ | ៦,៣៤៦ |
| ចំណូលពេញលេញផ្សេងៗ-<br>សមាសធាតុដែលត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញក្នុង<br>ចំណេញ ឬខាត៖ | | | | | |
| ចំណេញពីតម្លៃសមស្របពីការការពារ<br>ហានិភ័យលំហូរសាច់ប្រាក់ | ៣,៨៦៩ | ១,៥៤៦ | ១៥,៧៣៤ | ៦,២៩៤ | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | (១០០) | (៦១៤) |
| ចំណូលពេញលេញសរុបក្នុងការិយបរិច្ឆេទ | | ៤,៤៩៨ | ៣,១០៥ | ១៨,១៩៣ | ១២,០២៦ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍បម្រែបម្រួលមូលធនរបស់សម្ព័ន្ធក្រុមហ៊ុន

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| | កំណត់សម្គាល់ | ← កម្មសិទ្ធិរបស់ម្ចាស់ភាគហ៊ុន | | | | → | | មូលធនសរុប | |
|---|---|---|---|---|---|---|---|---|---|
| | | ← មិនអាចបែងចែក → | | | អាចបែងចែក | | | | |
| | | ដើមទុន ពាន់ដុល្លារអាមេរិក | បុព្វលាភដើមទុន ពាន់ដុល្លារអាមេរិក | ដើមទុនបម្រុងទុក ពាន់ដុល្លារអាមេរិក | ចំណេញរក្សាទុក ពាន់ដុល្លារអាមេរិក | សរុប ពាន់ដុល្លារអាមេរិក | ភាគហ៊ុនបន្ទាប់បន្សំ ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | លានរៀល (សម្គាល់ ៤.២) |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ | | ៧,៤៩៤ | ២,៥៤១ | (៤,២៦៩) | ១៧,១៩០ | ២២,៩៥៦ | ៨៦ | ២៣,០៤២ | ៩៣,៨៩៧ |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | - | ៦០៧ | ៦០៧ | - | ៦០៧ | ២,៤៧០ |
| ចំណេញពីតម្លៃសមស្របពីការការពារហានិភ័យលំហូរសាច់ប្រាក់ | | - | - | ៣,៨៦៩ | - | ៣,៨៦៩ | - | ៣,៨៦៩ | ១៥,៧៣៤ |
| ភាគលាភដែលបានទូទាត់ទៅម្ចាស់ក្រុមហ៊ុន | ៣៤ | - | - | - | (៤៨៧) | (៤៨៧) | - | (៤៨៧) | (១,៩៨៥) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | - | (១០០) |
| សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | | ៧,៤៩៤ | ២,៥៤១ | (៤០០) | ១៧,៣១០ | ២៦,៩៤៥ | ៨៦ | ២៧,០៣១ | ១១០,០១៦ |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ | | ៧,១០០ | - | (៥,៨១៥) | ១៥,៨០២ | ១៧,០៨៧ | ៥ | ១៧,០៩២ | ៦៩,៩៤៧ |
| ភាគហ៊ុនដែលបានចេញផ្សាយ | ១៤ | ៣៩៤ | ២,៥៤១ | - | - | ២,៩៣៥ | - | ២,៩៣៥ | ១២,០៧៨ |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | - | ១,៣៨៨ | ១,៣៨៨ | ៨១ | ១,៤៦៩ | ៥,៩៨០ |
| ចំណេញពីតម្លៃសមស្របពីការការពារហានិភ័យលំហូរសាច់ប្រាក់ | | - | - | ១,៥៤៦ | - | ១,៥៤៦ | - | ១,៥៤៦ | ៦,២៩៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | - | (៦១២) |
| សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ | | ៧,៤៩៤ | ២,៥៤១ | (៤,២៦៩) | ១៧,១៩០ | ២២,៩៥៦ | ៨៦ | ២៣,០៤២ | ៩៣,៨៩៧ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍បម្រែបម្រួលមូលធនរបស់សម្ព័ន្ធក្រុមហ៊ុន

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| | កំណត់សម្គាល់ | ← មិនអាចបែងចែកបាន → | | | អាចបែងចែកបាន | មូលធនសរុប | |
|---|---|---|---|---|---|---|---|
| | | ដើមទុន ពាន់ដុល្លារអាមេរិក | បុព្វលាភដើមទុនពាន់ដុល្លារអាមេរិក | ដើមទុនបម្រុងទុក ពាន់ដុល្លារអាមេរិក | ចំណេញរក្សាទុក ពាន់ដុល្លារអាមេរិក | ពាន់ដុល្លារអាមេរិក | លានរៀល (សម្គាល់ ៤.២) |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ | | ៧,៤៩៤ | ២,៥៤១ | (៤,២៦៩) | ១៧,៤០០ | ២៣,១៦៦ | ៩៤,៤០១ |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | - | ៦២៩ | ៦២៩ | ២,៥៥៩ |
| ចំណេញពីតម្លៃសមស្របពីការការពារហានិភ័យលំហូរសាច់ប្រាក់ | | - | - | ៣,៨៦៩ | - | ៣,៨៦៩ | ១៥,៧៣៤ |
| ភាគលាភដែលបានទូទាត់ទៅម្ចាស់ក្រុមហ៊ុន | ៣៤ | - | - | - | (៤៨៧) | (៤៨៧) | (១,៩៨៥) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | (១០០) |
| សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | | ៧,៤៩៤ | ២,៥៤១ | (៤០០) | ១៧,៥៤២ | ២៧,១៧៧ | ១១០,៦០៩ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍លំហូរសាច់ប្រាក់របស់សម្ព័ន្ធក្រុមហ៊ុន

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| បរិច្ឆេទ | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | | សម្រាប់ចុងបញ្ចប់ការិយ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២២ លានរៀល (សម្គាល់៤.២) | ថ្ងៃទ៣០ ខែមិថុនា ២០២១ លានរៀល |
| (សម្គាល់៤.២) | | | | | |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | ១,៣៤៨ | ២,៤៧៨ | ៥,៤៨៣ | ១០,០៨៨ |
| និយ័តកម្មសម្រាប់៖ | | | | | |
| រំលស់លើទ្រព្យសកម្មរូបិយ | ២១ | ១,១១៣ | ១,០៥៩ | ៤,៥២៦ | ៤,៣១១ |
| រំលស់លើទ្រព្យសកម្មអរូបិយ | ២១ | ៤ | ៣ | ១៦ | ១២ |
| ចំណូលពីការប្រាក់ | ២៣ | (២,៨៧៤) | (១,០៩៨) | (១១,៦៨៨) | (៤,៤៧០) |
| ចំណាយពីការប្រាក់ | ២៤ | ៧,១៤៥ | ៦,២៤៣ | ២៩,០៥៧ | ២៥,៤១៥ |
| ចំណេញពីការបញ្ចប់ភតិសន្យា | | (៩) | - | (៣៧) | - |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស មិនទាន់សម្រេចបាន | | (៣) | (១០) | (១២) | (៤១) |
| ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល | | ៦,៧២៤ | ៨,៦៧៥ | ២៧,៣៤៥ | ៣៥,៣១៥ |
| **បម្រែបម្រួលដើមទុនបង្វិល** | | | | | |
| បម្រែបម្រួលក្នុង៖ | | | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | | ៣,៣៦១ | (២,៦២៧) | ១៣,៦៦៨ | (១០,៦៩៥) |
| ទ្រព្យសកម្ម/បំណុលកិច្ចសន្យា | | (១៧,២១៧) | (២៨,០២៩) | (៧០,០១៦) | (១១៤,១០៦) |
| សន្និធិ | | ១៧០ | ៨២៧ | ៦៩១ | ៣,៣៦៧ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | | (១,០៤០) | (៣៥,៨៣៨) | (៤,២២៩) | (១៤៥,៨៩៦) |
| សមតុល្យត្រូវទទួល/ត្រូវសងទៅភាគីពាក់ព័ន្ធ | | (១,២៩៣) | ៥៦,៣៤១ | (៥,២៥៨) | ២២៩,៣៦៤ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ | | ១២,០៥០ | ២២,៥០៣ | ៤៩,០០៣ | ៩១,៦១០ |
| សាច់ប្រាក់ទទួលបានពីប្រតិបត្តិការ | | ២,៧៥៥ | ២១,៨៥២ | ១១,២០៤ | ៨៨,៩៥៩ |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | | (១,៧០២) | (៥១៣) | (៦,៩២១) | (២,០៨៨) |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ | | ១,០៥៣ | ២១,៣៣៩ | ៤,២៨៣ | ៨៦,៨៧១ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍លំហូរសាច់ប្រាក់របស់សម្ព័ន្ធក្រុមហ៊ុន

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| បរិច្ឆេទ | កំណត់សម្គាល់ | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារអាមេរិក | សម្រាប់ចុងបញ្ចប់ការិយ ថ្ងៃទ៣០ ខែមិថុនា ២០២២ លានរៀល (សម្គាល់៤.២) | ថ្ងៃទ៣០ ខែមិថុនា ២០២១ លានរៀល (សម្គាល់៤.២) |
|---|---|---|---|---|---|
| **សកម្មភាពវិនិយោគ** | | | | | |
| ទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | (៣១៩) | (២០២) | (១,២៩៧) | (៨២២) |
| ទិញទ្រព្យសកម្មអរូបិយ | | (១០) | (១) | (៤១) | (៤) |
| ការប្រាក់ដែលបានទទួល | | ៥៩ | ៥០ | ២៤០ | ២០៤ |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | (២៧០) | (១៥៣) | (១,០៩៨) | (៦២២) |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ភាគលាភដែលបានទូទាត់ | ៣៤ | (៤៨៧) | - | (១,៩៨៥) | - |
| សាច់ប្រាក់បានមកពីប្រាក់កម្ចី | ២៧ | ១៤,៥០៦ | ៧,៩៩៧ | ៥៨,៩៩១ | ៣២,៥៥៦ |
| ការទូទាត់សងប្រាក់កម្ចី | ២៧ | (២២,៤៥៣) | (១៥,៦១៣) | (៩១,៣០៩) | (៦៣,៥៦១) |
| ចេញផ្សាយដើមទុនបន្ថែម | ១៤ | - | ២,៩៣៥ | - | ១១,៩៤៨ |
| ការប្រាក់ដែលបានទូទាត់ | | (៥,៥៩០) | (៦,២០៩) | (២២,៧៣៣) | (២៥,២៧៧) |
| ការទូទាត់បំណុលភតិសន្យា | | (៥៤) | (១២៤) | (២១៨) | (៥០៥) |
| បុរេប្រទានពីក្រុមហ៊ុនមេ | | ៨២០ | - | ៣,៣៣៥ | - |
| ការដាក់ប្រាក់បញ្ញើមានកាលកំណត់ | | (៣៦២) | (២០៤) | (១,៤៧២) | (៨៣០) |
| ប្រាក់បញ្ញើក្នុងធនាគារបញ្ចាំសម្រាប់ប្រាក់កម្ចី | | - | (២,៤៦៣) | - | (១០,០២៧) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញវត្ថុសាច់ប្រាក់ | | (១៣,៦២០) | (១៣,៦៨១) | (៥៥,៣៩១) | (៥៥,៦៩៦) |
| បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ | | (១២,៨៣៧) | ៧,៥០៥ | (៥២,២០៦) | ៣០,៥៥៣ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា | | ៦,៥៩៩ | (៩០៦) | ២៦,៨៩២ | (៣,៧០៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | (៧៨) | ៤៧ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា | ១៣ | (៦,២៣៨) | ៦,៥៩៩ | (២៥,៣៩២) | ២៦,៨៩២ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍លំហូរសាច់ប្រាក់របស់សម្ព័ន្ធក្រុមហ៊ុន

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| បរិច្ឆេទ<br>(សម្គាល់ ៤.២) | កំណត់សម្គាល់ | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ<br>ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារអាមេរិក | សម្រាប់ចុងបញ្ចប់ការិយ<br>ថ្ងៃទ៣០ ខែមិថុនា ២០២២ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទ៣០ ខែមិថុនា ២០២១ លានរៀល |
|---|---|---|---|---|---|
| សកម្មភាពប្រតិបត្តិការ | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | ១,៣៧០ | ២,៥៦៨ | ៥,៥៧២ | ១០,៤៥៤ |
| និយ័តកម្មសម្រាប់៖ | | | | | |
| រំលស់លើទ្រព្យសកម្មរូបិយ | ២១ | ១,១១៣ | ១,០៥៩ | ៤,៥២៦ | ៤,៣១១ |
| រំលស់លើទ្រព្យសកម្មអរូបិយ | ២១ | ៤ | ៣ | ១៦ | ១២ |
| ចំណូលការប្រាក់ | ២៣ | (២,៨៧៤) | (១,០៩៨) | (១១,៦៨៨) | (៤,៤៧០) |
| ចំណាយការប្រាក់ | ២៤ | ៧,១៤៥ | ៦,២៤៣ | ២៩,០៥៧ | ២៥,៤១៥ |
| ចំណេញពីការបញ្ចប់ភតិសន្យា | | (៩) | - | (៣៧) | - |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស មិនទាន់សម្រេចបាន | | (២) | (១០) | (៨) | (៤១) |
| ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល | | ៦,៧៤៧ | ៨,៧៦៥ | ២៧,៤៣៨ | ៣៥,៦៨១ |
| បម្រែបម្រួលទុនបង្វិល | | | | | |
| បម្រែបម្រួលក្នុង៖ | | | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | | ៣,៣៥៥ | (២,៦៣៦) | ១៣,៦៤៤ | (១០,៧៣១) |
| ទ្រព្យសកម្ម/បំណុលកិច្ចសន្យា | | (១៧,២១៧) | (២៨,០២៩) | (៧០,០១៦) | (១១៤,១០៦) |
| សន្និធិ | | ១៧០ | ៨២៧ | ៦៩១ | ៣,៣៦៧ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | | (១,០៤០) | (៣៥,៨៣៨) | (៤,២២៩) | (១៤៥,៨៩៦) |
| សមតុល្យត្រូវទទួល/ត្រូវសងទៅភាគីពាក់ព័ន្ធ | | (១,២៩៣) | ៥៦,៣៤១ | (៥,២៥៨) | ២២៩,៣៦៤ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ | | ១២,០៥៨ | ២២,៤៨៩ | ៤៩,០៣៦ | ៩១,៥៥៣ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនប៉ុត្រសម្ព័ន្ធ | | - | (៤១) | - | (១៦៧) |
| សាច់ប្រាក់ទទួលបានមកពីប្រតិបត្តិការ | | ២,៧៨០ | ២១,៨៧៨ | ១១,៣០៦ | ៨៩,០៦៥ |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | | (១,៧០២) | (៥១៣) | (៦,៩២១) | (២,០៨៨) |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ | | ១,០៧៨ | ២១,៣៦៥ | ៤,៣៨៥ | ៨៦,៩៧៧ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍លំហូរសាច់ប្រាក់របស់សម្ព័ន្ធក្រុមហ៊ុន

របាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

| បរិច្ឆេទ | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | | សម្រាប់ចុងបញ្ចប់ការិយ | |
|---|---|---|---|---|---|
| (សម្គាល់ ៤.២) | កំណត់សម្គាល់ | ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទ៣០ ខែមិថុនា ២០២២ ពាន់ដុល្លារ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទ៣០ ខែមិថុនា ២០២១ ពាន់ដុល្លារ លានរៀល |
| **សកម្មភាពវិនិយោគ** | | | | | |
| ទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | (៣១៩) | (២០២) | (១,២៩៧) | (៨២២) |
| ទិញទ្រព្យសកម្មអរូបិយ | | (១០) | (១) | (៤១) | (៤) |
| ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | | - | (១៥) | - | (៦១) |
| ការប្រាក់ដែលបានទទួល | | ៥៩ | ៥០ | ២៤០ | ២០៤ |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | (២៧០) | (១៦៨) | (១,០៩៨) | (៦៨៣) |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ភាគលាភដែលបានទូទាត់ | ៣៤ | (៤៨៧) | - | (១,៩៨៥) | - |
| សាច់ប្រាក់បានមកពីប្រាក់កម្ចី | ២៧ | ១៤,៥០៦ | ៧,៩៩៧ | ៥៨,៩៩១ | ៣២,៥៥៦ |
| ការទូទាត់សងប្រាក់កម្ចី | ២៧ | (២២,៤៥៣) | (១៥,៦១៣) | (៩១,៣០៩) | (៦៣,៥៦១) |
| ចេញផ្សាយដើមទុនបន្ថែម | ១៤ | - | ២,៩៣៥ | - | ១១,៩៤៨ |
| ការប្រាក់ដែលបានទូទាត់ | | (៥,៥៩០) | (៦,២០៩) | (២២,៧៣៣) | (២៥,២៧៧) |
| ការទូទាត់បំណុលភតិសន្យា | | (៥៤) | (១២៤) | (២១៨) | (៥០៥) |
| ការដាក់ប្រាក់បញ្ញើមានកាលកំណត់ | | (៣៦២) | (២០៤) | (១,៤៧២) | (៨៣០) |
| ប្រាក់បញ្ញើក្នុងធនាគារបញ្ចាំសម្រាប់ ប្រាក់កម្ចី | | - | (២,៤៦៣) | - | (១០,០២៧) |
| បុរេប្រទានទៅក្រុមហ៊ុនបុត្រសម្ព័ន្ធ | | (១៨) | - | (៧៣) | - |
| បុរេប្រទានពីក្រុមហ៊ុនមេ | | ៨២០ | - | ៣,៣៣៥ | - |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញវត្ថុ | | (១៣,៦៣៨) | (១៣,៦៨១) | (៥៥,៤៦៤) | (៥៥,៦៩៦) |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់** | | | | | |
| សមមូលសុទ្ធ | | (១២,៨៣០) | ៧,៥១៦ | (៥២,១៧៧) | ៣០,៥៩៨ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា | | ៦,៥៨៦ | (៩៣០) | ២៦,៨៣៩ | (៣,៨០៦) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | (៧៨) | ៤៧ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា | ១៣ | (៦,២៤៤) | ៦,៥៨៦ | (២៥,៤១៦) | ២៦,៨៣៩ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

## ១ ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក បានប្រតិបត្តិការអាជីវកម្មនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវបានកម្រិត ហើយជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ១០០% របស់ក្រុមហ៊ុន PESTECH International Berhad ដែលជាក្រុមហ៊ុនចុះបញ្ជី និងមានអាសយដ្ឋាននៅប្រទេសម៉ាឡេស៊ី និងបានចុះបញ្ជីនៅក្នុងទីផ្សារគោលនៃក្រុមហ៊ុន Bursa Malaysia Securities Berhad ជាមួយនឹងដើមទុនដែលបានចុះបញ្ជី និងទូទាត់រួចរាល់ក្នុងសមតុល្យសរុប ៧.១០០.០០០ ដុល្លារអាមេរិក ដែលស្មើនឹង ៧១.០០០.០០០ ភាគហ៊ុនដែលមានតម្លៃចារឹក ០,១០ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន។ ក្រុមហ៊ុនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ("MOC") ក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម ០០០០០៩៥៧។

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ក្រុមហ៊ុនបានចុះបញ្ជីជាមួយផ្សារមូលបត្រកម្ពុជា ("CSX") ដោយជោគជ័យ។ ភាគហ៊ុនថ្មីដែលបានចេញផ្សាយមានចំនួន ៣.៩៤៥.០០០ ភាគហ៊ុនជាមួយតម្លៃចារឹក ៤០០ រៀល ឬ០,១០ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុននៅក្នុងតម្លៃបោះផ្សាយ ៣.១២០ រៀល ឬ ០,៧៦ ដុល្លាអាមេរិកក្នុងមួយភាគហ៊ុន។ នៅពេលបញ្ចប់ការចុះបញ្ជី ក្រុមហ៊ុន PESTECH International Berhad បានកាន់កាប់ភាគហ៊ុនចំនួន ៩៤,៧៤% របស់ក្រុមហ៊ុន។

នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ក្រុមហ៊ុនបានទទួលការយល់ព្រមពីក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើវិសោធនកម្មអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុនរបស់ខ្លួន។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺសាងសង់អនុស្ថានីយ៍អគ្គិសនី និងបណ្តាញបញ្ជូន។

ក្រុមហ៊ុន PESTECH (Myanmar) Limited (ហៅកាត់ថា "PML") បានធ្វើប្រតិបត្តិការអាជីវកម្មក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលមានកម្មសិទ្ធិ ១០០% ក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម ១១៧១ FC/២០១៦-២០១៧ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ដែលបានចេញផ្សាយដោយ ក្រសួងផែនការ និងហិរញ្ញវត្ថុនៃរដ្ឋាភិបាលរបស់សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។ ដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុនមានសមតុល្យ ៥០.០០០ ដុល្លារអាមេរិក ដែលស្មើនឹង ៥០.០០០ភាគហ៊ុនធម្មតា។

សកម្មភាពចម្បងរបស់ PML គឺការផ្តល់ជូនគម្រោងគ្រប់គ្រងប្រព័ន្ធបណ្តាញអគ្គិសនី ការសាងសង់ ការរចនា និងការតំឡើងខ្សែបញ្ជូន និងសេវាកម្មពាក់ព័ន្ធនៅក្នុងឧស្សាហកម្មថាមពល។

ក្រុមហ៊ុន PESTECH Hinthar Corporation Limited ("PHC") បានចុះបញ្ជីក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ដែលភាគហ៊ុន ៦០% កាន់កាប់ដោយ PML ក្រោមច្បាប់ក្រុមហ៊ុនមីយ៉ាន់ម៉ា ឆ្នាំ២០១៧។ ដើមទុនចុះបញ្ជីមានចំនួន ៥០.០០០ ដុល្លារអាមេរិកដែលស្មើនឹង ៥០.០០០ ភាគហ៊ុនធម្មតា។

សកម្មភាពអាជីវកម្មចម្បងរបស់ PESTECH Hinthar Corporation Limited ("PHC") គឺបង្កើតហេដ្ឋារចនាសម្ព័ន្ធនៃវិស័យថាមពល និងលើកកម្ពស់ផ្នែកថាមពលដូចជាការផលិត ការបញ្ជូន និងការចែកចាយថាមពល ប្រព័ន្ធ Microgrid និងហេដ្ឋារចនាសម្ព័ន្ធថាមពលផ្សេងៗជូនទៅដល់តំបន់ជនបទ នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុន PESTECH Microgrid Limited ("PMG") បានចុះបញ្ជីក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ដែល៩០% កាន់កាប់ដោយ PHC ក្រោមការគ្រប់គ្រងស្របច្បាប់របស់ក្រុមហ៊ុនមីយ៉ាន់ម៉ាឆ្នាំ២០១៧។ ដើមទុនចុះបញ្ជីមានចំនួន ១០.០០០ដុល្លារអាមេរិក ដែលស្មើនឹង១០.០០០ ភាគហ៊ុនធម្មតា។

សកម្មភាពអាជីវកម្មចម្បងរបស់ PMG គឺផ្តល់ប្រព័ន្ធ Microgrid និងហេដ្ឋារចនាសម្ព័ន្ធថាមពលផ្សេងៗជូនតំបន់ជនបទ នៃសាធារណរដ្ឋ សហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុនចាត់ទុកក្រុមហ៊ុន PHC និងក្រុមហ៊ុន PMG ជាក្រុមហ៊ុនបុត្រសម្ព័ន្ធដោយប្រយោល។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន ស្ថិតនៅជាន់ទី១០ អគារលេខ៣៥ មហាវិថីម៉ៅសេទុង ភូមិ៩ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ PML PHC និងPMG ស្ថិតនៅអគារលេខ ២៤-២៦ ផ្លូវ South Race Course បន្ទប់ PH-C ជាន់ Penthouse ខុនដូ Race Course តំបន់ Tamwe ទីក្រុងយ៉ានហ្គូន នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

ក្រុមហ៊ុនពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពចម្បងរបស់ក្រុមហ៊ុន និងក្រុមហ៊ុនបុត្រសម្ព័ន្ធ នៅក្នុងអំឡុងកាលបរិច្ឆេទនៃរបាយការណ៍នេះទេ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

## ២. មូលដ្ឋាននៃការរៀបចំនិងការអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា("CIFRSs")។

ក្រុមប្រឹក្សាគណនេយ្យជាតិនៃព្រះរាជាណាចក្រកម្ពុជា យោងតាមសេចក្តីប្រកាសដែលបានធ្វើការកែប្រែ (សារាចរ) លេខ ០៦៨-សហវ-ប្រក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ ដែលបានចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនៃកម្ពុជា ត្រូវបានសម្រេចឱ្យអនុវត្តទាំងស្រុងទៅលើស្តង់ដារទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ("IFRSs") ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ("IASB") ដោយមិនមានការកែប្រែ ឡើយ។ ស្តង់ដារទាំងនេះ ដូចគ្នាទៅនឹងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។

## ៣. ស្តង់ដារថ្មី ឬវិសោធនកម្ម និងការបកស្រាយ

### ៣.១ស្តង់ដារ វិសោធនកម្ម និងការបកស្រាយស្តង់ដារមានស្រាប់ ដែលមានប្រសិទ្ធភាពគិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនបានអនុម័តទៅលើស្តង់ដារ និងការបកស្រាយគណនីទាំងអស់គិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១។ ស្តង់ដារគណនេយ្យថ្មី និងស្តង់ដារគណនេយ្យដែលបានកែប្រែ ព្រមទាំងការបកស្រាយគណនេយ្យត្រូវបានវាយតម្លៃថាអាចអនុវត្តបានទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានដូចខាងក្រោម៖

- និយមន័យអាជីវកម្ម (បានកែប្រែទៅជា CIFRS ៣)
- និយមន័យភាពជាសារវន្ត (បានកែប្រែទៅជា CIAS ១ និង CIAS ៨)
- ក្របខណ្ឌទស្សនទានសម្រាប់របាយការណ៍ហិរញ្ញវត្ថុ
- កំណែទម្រង់លើអត្រាការប្រាក់ (បានកែប្រែទៅជា CIFRS ៩ CIAS ៣៩ និង CIFRS ៧)

គណៈគ្រប់គ្រង បានវាយតម្លៃថាការអនុម័តស្តង់ដារគណនេយ្យទាំងនេះ មិនមានផលប៉ះពាល់ជាសារវន្តដល់របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុននោះទេ។

### ៣.២ ស្តង់ដារ វិសោធនកម្ម និងការបកស្រាយស្តង់ដារមានស្រាប់ដែលមិនទាន់មានប្រសិទ្ធភាព និងមិនទាន់ត្រូវបានអនុវត្តជាមុនដោយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន

នាកាលបរិច្ឆេទនៃការចេញផ្សាយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ស្តង់ដារថ្មី និងស្តង់ដារគណនេយ្យដែលបានកែប្រែត្រូវបានចេញផ្សាយរួចរាល់ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព និងមិនទាន់បានអនុវត្តជាមុនដោយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានដូចខាងក្រោម៖

- កិច្ចសន្យាធានារ៉ាប់រង CIFRS ១៧
- កំណែទម្រង់លើអត្រាការប្រាក់ — ដំណាក់កាលទី ២ (វិសោធនកម្មទៅជា CIFRS ៩ CIAS ៣៩ CIFRS ៧ និង CIFRS ១៦)
- ឯកសារយោងចំពោះក្របខណ្ឌទស្សនទាន (វិសោធនកម្មទៅជា CIFRS ៣)
- ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃបំណុលជាបំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែង — ពន្យារពេលចូលជាធរមាន (វិសោធនកម្មទៅជា CIAS ១)
- ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ — ចំណូលដែលទទួលបានមុនពេលការប្រើប្រាស់ដែលបានគ្រោងទុក (វិសោធនកម្មទៅជា CIAS ១៦)
- កិច្ចសន្យាស្មុគស្មាញ — ចំណាយនៃការបំពេញកិច្ចសន្យា (វិសោធនកម្មទៅជា CIAS ៣៧)
- ការកែតម្រូវប្រចាំឆ្នាំទៅលើស្តង់ដារ CIFRS ២០១៨–២០២០
- ការបង្ហាញពីគោលនយោបាយគណនេយ្យ (វិសោធនកម្មទៅជា CIAS ១ និង របាយការណ៍អនុវត្តលើ CIFRS ២)
- និយមន័យរបស់គណនេយ្យប៉ាន់ស្មាន (វិសោធនកម្មទៅជា CIAS ៨)
- ជម្ងឺកូវីដ-១៩ - ដែលទាក់ទងនឹងសម្បទានជួល (វិសោធនកម្មទៅជា CIFRS១៦)

គណៈគ្រប់គ្រងមិនរំពឹងថា ការអនុវត្តស្តង់ដារគណនេយ្យដែលមានខាងលើនឹងមានផលប៉ះពាល់ជាសារវន្តដល់របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុននាពេលអនាគតទេ។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ

### ៤.១មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ត្រូវបានបង្ហាញជាដុល្លារអាមេរិក("USD") ត្រូវបានរៀបចំក្រោមថ្លៃដើមជាប្រវត្តិសាស្ត្រ និងត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.២រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ប៉ុន្តែដោយសារក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមជាប្រាក់ដុល្លារអាមេរិក ក្រុមប្រឹក្សាភិបាលបានកំណត់យកប្រាក់ដុល្លារអាមេរិក ("USD") ជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់គោលបំណងក្នុងការវាស់វែង និងបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃសេដ្ឋកិច្ចក្រោមព្រឹត្តិការណ៍ និងស្ថានការណ៍របស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ក្រៅពីប្រាក់ដុល្លារអាមេរិក គឺត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ក្នុងអត្រាប្តូរប្រាក់ស្ថិតនៅកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងបំណុលជារូបិយវត្ថុ ដែលកំណត់ដោយរូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក នាកាលបរិច្ឆេទនៃរបាយការណ៍ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ភាពលម្អៀងនៃអត្រា ប្តូរប្រាក់ គឺត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលពេញលេញផ្សេងៗ។

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាខ្មែររៀលដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានដាក់បញ្ចូលទាំងស្រុងដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មនៃកម្ពុជា (ខែមេសា ឆ្នាំ២០១៦) ហើយត្រូវបានធ្វើឡើងដោយប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការ ដែលបានបង្ហាញជាខ្មែររៀល ដោយយោងទៅតាមអត្រាប្តូរប្រាក់ក្នុង ១ដុល្លារអាមេរិក ដែលបានប្រកាសដោយធនាគារជាតិនៃកម្ពុជា ("NBC") ៖

| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ |
|---|---|---|
| អត្រាប្តូរប្រាក់ជាមធ្យម* | ៤.០៦៧ | ៤.០៧១ |
| អត្រាប្តូរប្រាក់ចុងគ្រា | ៤.០៧០ | ៤.០៧៥ |

*អត្រាប្តូរប្រាក់ជាមធ្យម គឺត្រូវបានគណនាដោយប្រើអត្រាប្តូរប្រាក់ប្រចាំខែក្នុងអំឡុងការិយបរិច្ឆេទ

ការប្តូររូបិយប័ណ្ណទាំងនេះ គឺមិនត្រូវបានធ្វើសវនកម្មឡើយ និងមិនត្រូវបានបកស្រាយថាជាតំណាងនៃប្រាក់ដុល្លារអាមេរិក ដែលអាចនឹងត្រូវបាន ឬអាចប្តូរទៅជាប្រាក់រៀលនៅថ្ងៃអនាគតតាមអត្រាដែលបានបង្ហាញនេះឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។ សមតុល្យជាដុល្លារអាមេរិក និងរៀល ត្រូវបានបង្ហាញក្នុងសមតុល្យខ្ទង់ពាន់ដុល្លារអាមេរិក និងលានរៀលដែលនៅជិតបំផុត លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ៤.៣មូលដ្ឋាននៃការដាក់បញ្ចូលគ្នា

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន បានរួមបញ្ចូលទាំងរបាយការណ៍របស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន។ ក្រុមហ៊ុន ទទួលបាន និងធ្វើការត្រួតពិនិត្យតាមរយៈការកាន់កាប់ច្រើនជាងពាក់កណ្តាលនៃសិទ្ធិបោះឆ្នោតក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ។

ការចំណេញ និងខាតមិនទាន់សម្រេចបានលើប្រតិបត្តិការរវាងសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនត្រូវបានលុបចោល។ នៅពេលការខាតបង់ពីការលក់ទ្រព្យសម្បត្តិនៅក្នុងសម្ព័ន្ធក្រុមហ៊ុន ត្រូវបានកត់ត្រាបញ្ច្រាស់ក្នុងការដាក់បញ្ចូលគ្នា ហើយទ្រព្យសម្បត្តិមូលដ្ឋានក៏ត្រូវបានធ្វើតេស្តសម្រាប់ឱនភាព។ សមតុល្យដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានកែតម្រូវនៅពេលចាំបាច់ ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់ជាមួយគោលនយោបាយគណនេយ្យដែលបានអនុវត្តដោយសម្ព័ន្ធក្រុមហ៊ុន។

ប្រាក់ចំណេញ ឬការខាតរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមកពីការទិញ ឬលុបចោលក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានទទួលស្គាល់ចាប់ពីកាលបរិច្ឆេទដែលមានសុពលភាពនៃការទិញ ឬរហូតដល់កាលបរិច្ឆេទដែលមានសុពលភាពពីការលុបចោលតាមដែលអាចអនុវត្តបាន។

### ៤.៤ការទទួលស្គាល់ចំណូល

ប្រាក់ចំណូលត្រូវបានទទួលស្គាល់នៅពេលឬជាកាតព្វកិច្ចអនុវត្តក្នុងកិច្ចសន្យាជាមួយអតិថិជនបានបំពេញ គឺនៅពេលសិទ្ធិក្នុងការ "គ្រប់គ្រង" ទំនិញ ឬសេវាកម្មដែលមានមូលដ្ឋានលើកាតព្វកិច្ចអនុវត្តជាក់លាក់ត្រូវបានផ្ទេរទៅឱ្យអតិថិជន។

ការអនុវត្តកាតព្វកិច្ច គឺជាការសន្យាក្នុងការផ្ទេរទំនិញឬសេវាកម្មចែកដាច់ពីគ្នា (ទំនិញឬ សេវាកម្មដែលមានលក្ខណៈដូចគ្នាច្រើន និងមានលំនាំនៃការផ្ទេរដូចគ្នា) ទៅអតិថិជនដែលត្រូវបញ្ជាក់យ៉ាងច្បាស់នៅក្នុងកិច្ចសន្យា និងបញ្ជាក់នៅក្នុងការអនុវត្តអាជីវកម្មរបស់សម្ព័ន្ធ ក្រុមហ៊ុន និងក្រុមហ៊ុន។

ចំណូលត្រូវបានវាស់វែង តាមតម្លៃតបស្នងដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនជឿជាក់ថាមានសិទ្ធិក្នុងការផ្ទេរទំនិញ ឬសេវាកម្ម ដែលបានសន្យាជូនអតិថិជនដោយមិនរាប់បញ្ចូលសមតុល្យ ដែលប្រមូលបានពីតតិយជនដូចជាពន្ធអាករលើធាតុចេញ ឬពន្ធលើទំនិញនិងសេវាកម្ម។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៤ ការទទួលស្គាល់ចំណូល (ត)

ប្រសិនបើតម្លៃតបស្នងដែលក្រុមហ៊ុនរំពឹងថានឹងទទួលបានប្រែប្រួលដោយសារអប្បហារ ការបង្វិលសង ការជំពាក់ ប្រាក់លើកទឹកចិត្ត ការពិន័យ និងធាតុប្រហាក់ប្រហែលផ្សេងទៀតដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ត្រូវប៉ាន់ស្មានតម្លៃតបស្នងដែលរំពឹងថានឹងទទួលបានដោយផ្អែកទៅលើតម្លៃដែលរំពឹងទុក ឬតម្លៃដែលមានលទ្ធផលសមស្របបំផុត។ ប្រសិនបើកិច្ចសន្យារវាងអតិថិជនមានការអនុវត្តកាតព្វកិច្ចច្រើនជាងមួយនោះតម្លៃតបស្នងនឹងត្រូវបានបែងចែកទៅឱ្យការអនុវត្តកាតព្វកិច្ចនីមួយៗ ដោយពឹងផ្អែកទៅលើតម្លៃលក់ទំនិញ ឬសេវាកម្ម ដែលបានសន្យានៅក្នុងកិច្ចសន្យា។

ប្រាក់ចំណូលត្រូវបានទទួលស្គាល់ក្នុងវិសាលភាពដែលមានលទ្ធភាពខ្ពស់ក្នុងការកត់ត្រាបញ្ច្រាសសំខាន់ៗ នៃសមតុល្យប្រាក់ចំណូលបង្គរដែលបានទទួលស្គាល់ហើយនឹងមិនកើតឡើងនៅពេលដែលភាពមិនជាក់លាក់ដែលទាក់ទងនឹងការបម្រែបម្រួលនៃការពិចារណាដែលបានដោះស្រាយជាបន្តបន្ទាប់។

ការគ្រប់គ្រងទំនិញឬសេវាកម្មដែលបានសន្យាអាចត្រូវបានផ្ទេរតាមពេលវេលា ឬនៅក្នុងពេលវេលាណាមួយ។ ចំណូលសម្រាប់ការអនុវត្តកាតព្វកិច្ចដែលមិនបានបំពេញតាមពេលវេលាត្រូវបានទទួលស្គាល់ពេលវេលាណាមួយដែលអតិថិជនទទួលបានការគ្រប់គ្រងទំនិញ ឬ សេវាកម្មដែលបានសន្យា។

ការគ្រប់គ្រងលើទំនិញ ឬសេវាកម្មត្រូវបានផ្ទេរតាមពេលវេលាហើយចំណូលត្រូវបានទទួលស្គាល់តាមពេលវេលាប្រសិនបើ៖

- អតិថិជនទទួលបាន និងប្រើប្រាស់អត្ថប្រយោជន៍ក្នុងពេលដំណាលគ្នាដែលក្រុមបុត្រសម្ព័ន្ធ និងក្រុមហ៊ុនអនុវត្ត ក្នុងនាមជាសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន
- សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន បំពេញកាតព្វកិច្ចក្នុងកិច្ចសន្យាទៅលើទ្រព្យសកម្មដែលបានបង្កើតឡើង ឬបានកែលម្អ ឬ
- ការអនុវត្តកាតព្វកិច្ចរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន មិនបង្កើតទ្រព្យក្នុងគោលបំណងការប្រើប្រាស់ជំនួសទេ ហើយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន មានសិទ្ធិទទួលបានការទូទាត់សម្រាប់ប្រតិបត្តិការរហូតដល់កាលបរិច្ឆេទបញ្ចប់។

ចំណូលសម្រាប់ការអនុវត្តកាតព្វកិច្ចដែលមិនបានបំពេញតាមពេលវេលាត្រូវបានទទួលស្គាល់នៅចំណុចណាមួយ។

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ទទួលស្គាល់ប្រាក់ចំណូលពីការអភិវឌ្ឍគម្រោងតាមពេលវេលា ប្រសិនបើវាបង្កើតជាទ្រព្យសកម្មដោយគ្មានការប្រើប្រាស់ជំនួសហើយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន មានសិទ្ធិអនុវត្តការទូទាត់សម្រាប់ការអនុវត្តរហូតដល់កាលបរិច្ឆេទដែលបានបញ្ចប់ការងារទាំងនោះ។ ចំណូលត្រូវបានទទួលស្គាល់ក្នុងអំឡុងពេលនៃកិច្ចសន្យាដោយយោងទៅលើវឌ្ឍនភាពឆ្ពោះទៅរកការពេញចិត្តនៃកាតព្វកិច្ចដែលបានអនុវត្តនោះ។

វឌ្ឍនភាពក្នុងការបំពេញកាតព្វកិច្ចត្រូវបានវាស់វែងការបំពេញកាតព្វកិច្ចរបស់សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនពីការខិតខំប្រឹងប្រែងឬលទ្ធផលពីការបំពេញកាតព្វកិច្ច(ឧទាហរណ៍ដោយយោងទៅលើការវាស់វែងនៃកាតព្វកិច្ចការងារពេលគឺដំណាក់កាលនៃការបញ្ចប់)។

ចំណូលពីកិច្ចសន្យាសាងសង់ និងកិច្ចសន្យាប្រតិបត្តិការត្រូវបានទទួលស្គាល់ដោយផ្អែកលើវិធីសាស្ត្រតាមភាគរយដែលបានសាងសង់ដែលត្រូវបានវាយតម្លៃតាមរយៈការរួមបញ្ចូលគ្នារវាងការវាយតម្លៃរបស់អ្នកជំនាញ និងតាមរយៈការគិតគូរលើថ្លៃដើមកិច្ច សន្យាដែលបានកើតឡើងហើយប្រៀបធៀបទៅនឹងការប៉ាន់ស្មានថ្លៃដើមសរុបដែលបានផ្តល់ឱ្យមិនមានភាពមិនជាក់លាក់សំខាន់ៗណាមួយដែលទាក់ទងនឹងការទទួលសាច់ប្រាក់ចុងក្រោយនិងការចំណាយពាក់ព័ន្ធអាចត្រូវបានកំណត់ដោយហេតុផលសមស្រប។

នៅពេលដែលលទ្ធផលនៃការអភិវឌ្ឍមិនអាចប៉ាន់ស្មានបានដោយសមហេតុផលប្រាក់ចំណូល ត្រូវបានទទួលស្គាល់តាមវិសាលភាពថ្លៃដើមនៃការសាងសង់ដែលកើតមានឡើងនោះ អាចនឹងប្រមូលយកមកវិញបាន ហើយថ្លៃដើមការសាងសង់ ត្រូវទទួលស្គាល់ថាជាការចំណាយមួយក្នុងរយៈពេលដែលពួកវាបានកើតឡើង។

នៅពេលដែលអាចធ្វើទៅបានលើចំណាយសរុប ដែលនឹងលើសពីចំណូលសរុប ការខាតបង់ដែលអាចស្មានទុកជាមុន ត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងប្រាក់ចំណេញ ឬខាត ដោយមិនគិតថាតើការសាងសង់បានចាប់ផ្តើមឬអត់ ឬដំណាក់កាលបញ្ចប់នៃសកម្មភាពសាងសង់ ឬសមតុល្យប្រាក់ចំណេញដែលរំពឹងថានឹងកើតឡើងលើកិច្ចសន្យាដែលមិនទាក់ទងផ្សេងៗទៀត។

ប្រាក់ចំណូលលើសពីការទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាត ដែលមានលើវិក្កយបត្រ ដែលផ្ញើជូនអតិថិជនកិច្ចសន្យាត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មកិច្ចសន្យា។

វិក្កយបត្រលើសពីកិច្ចសន្យាអតិថិជនលើប្រាក់ចំណូល ដែលបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាត ត្រូវបានទទួលស្គាល់ថាជាបំណុលកិច្ចសន្យា។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៤ ការទទួលស្គាល់ចំណូល (ត)

ប្រាក់ចំណូលផ្សេងទៀតដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ទទួលបានតំណាងឱ្យចំណូលការប្រាក់ដែលត្រូវបានទទួលស្គាល់តាមមូលដ្ឋានសមាមាត្រសម្បទាន។

*កិច្ចសន្យាសាងសង់ និងការផ្តល់សេវាកម្ម*

ចំណូលដែលបានមកពីការផ្តល់សេវាវិស្វកម្ម និងការលក់សម្ភារ ត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ ឬខាតនៅពេលដែលសេវាកម្មត្រូវបានបំពេញ និងនៅពេលដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន បានធ្វើការផ្ទេរការទទួលខុសត្រូវទៅលើសម្ភារទាំងនោះទៅឱ្យអ្នកទិញរៀងៗគ្នា។

ដើម្បីកំណត់ថាតើ ប្រាក់ចំណូលដែលត្រូវទទួលស្គាល់ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន អនុវត្តតាមនីតិវិធី ៥ ជំហានដូចខាងក្រោម៖

១. កំណត់អត្តសញ្ញាណកិច្ចសន្យាជាមួយអតិថិជន
២. កំណត់ការអនុវត្តកាតព្វកិច្ច
៣. កំណត់តម្លៃប្រតិបត្តិការ
៤. ការបែងចែកតម្លៃប្រតិបត្តិការទៅនឹងការអនុវត្តកាតព្វកិច្ច
៥. ទទួលស្គាល់ចំណូលនៅពេល /កាតព្វកិច្ចបំពេញការងារត្រូវបានបំពេញ

*ប្រាក់ចំណូលគួរឱ្យកត់សម្គាល់លើការមិនធ្វើអប្បហារ*

ប្រាក់ចំណូលគួរឱ្យកត់សម្គាល់លើការមិនធ្វើអប្បហារពីសំណង់ដែលទទួលបាន ត្រូវបានបង្គរតាមមូលដ្ឋានសមាមាត្រពេលវេលាដោយគិតទៅលើតម្លៃតបស្នង និងសមតុល្យដែលនៅសល់ត្រូវទទួល និងអត្រាអប្បហារដែលអាចអនុវត្តបានដែលមានប្រសិទ្ធភាព។

សមតុល្យទាំងនេះបានមកពីភាពខុសគ្នានៃតម្លៃបច្ចុប្បន្ននៃប្រាក់ចំណូលនាពេលអនាគត និងប្រាក់ចំណូលដែលបានទទួលស្គាល់ក្នុងអំឡុងពេលសាងសង់។

### ៤.៥ ចំណាយប្រតិបត្តិការ

ចំណាយប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត ក្នុងអំឡុងការិយបរិច្ឆេទដែលចំណាយទាំងនោះបានកើតឡើង។

### ៤.៦ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

គ្រប់សមាសធាតុគណនីទាំងអស់នៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារត្រូវបានកំណត់ដំបូងតាមថ្លៃដើមនៃការទិញចូល ឬថ្លៃដើមក្នុងការផលិត រួមបញ្ចូលទាំងថ្លៃដើមទាំងឡាយដែលទាក់ទងដោយផ្ទាល់ក្នុងការនាំយកទ្រព្យសកម្មទៅកាន់ទីតាំង និងលក្ខខណ្ឌដែលសមស្របក្នុងប្រតិបត្តិការដែលបានគ្រោងទុកដោយគណៈគ្រប់គ្រង។ ការចំណាយបន្តបន្ទាប់រួមបញ្ចូលទាំងសមតុល្យយោងនៃទ្រព្យសកម្មដែលត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែក ឬនៅពេលដែលវាទំនងបានផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតលើសពីស្តង់ដារដែលបានវាយតម្លៃដំបូងនៃការអនុវត្តនៃទ្រព្យសកម្មដែលមានស្រាប់ទៅនឹងលំហូរទៅសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ហើយតម្លៃរបស់ទ្រព្យនោះត្រូវបានអាចវាស់វែងបានដោយភាពជឿជាក់ដែលអាចទុកចិត្តបាន។ រាល់ចំណាយលើការជួសជុល និងថែទាំ ត្រូវបានគិតនៅក្នុងគណនីចំណេញ ឬខាត ក្នុងអំឡុងឆ្នាំនៅពេលដែលចំណាយនោះបានកើតឡើង។

បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងរាល់ការខាតបង់លើឱនភាពតម្លៃ។

*រំលស់*

រំលស់ត្រូវបានគណនា ដោយការប្រើប្រាស់វិធីសាស្ត្ររំលស់ថេរទៅតាមអត្រារំលស់ប្រចាំឆ្នាំដូចខាងក្រោម៖

| | អត្រារំលស់ |
|---|---|
| បរិក្ខារ | ៤% - ១០% |
| ម៉ូតូ យានយន្ត | ២០% |
| កុំព្យូទ័រ | ៣០% |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | ២០% |
| ផ្លាកសញ្ញា | ១០% |
| ការកែលម្អឡើងវិញ | ១០% |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៦ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

តម្លៃកាកសំណល់ អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់ត្រូវបានត្រួតពិនិត្យឡើងវិញនៅការិយបរិច្ឆេទហិរញ្ញវត្ថុនីមួយៗ ដើម្បីធានាថា សមតុល្យ វិធីសាស្ត្រ និងរយៈពេលនៃការរំលស់ គឺមានភាពស្របគ្នាជាមួយការប៉ាន់ស្មានពីមុន និងទម្រង់នៃការប្រើប្រាស់ដែលរំពឹងទុកនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលរួមបញ្ចូលរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារទាំងនោះ។

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ នឹងត្រូវឈប់ទទួលស្គាល់នៅពេលមានការលក់ ឬនៅពេលដែលគ្មានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលត្រូវបានគេរំពឹងទុកថានឹងទទួលបានពីការប្រើប្រាស់របស់វា ឬការលក់សមាសធាតុទាំងនោះ។ រាល់ការចំណេញ ឬខាតដែលកើតមានឡើងពីការឈប់ទទួលស្គាល់ទ្រព្យសកម្មត្រូវបានរួមបញ្ចូលទៅក្នុងរបាយការណ៍ចំណូលពេញលេញ ក្នុងការិយបរិច្ឆេទដែលទ្រព្យសកម្ម នោះត្រូវបានឈប់ទទួលស្គាល់។ ចំណេញ និងខាត បានរួមបញ្ចូលទាំងប្រាក់ចំណេញ ឬខាត។

### ៤.៧ ការធ្វើតេស្តឱនភាពតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ដើម្បីធ្វើការវាយតម្លៃឱនភាព ទ្រព្យសកម្មត្រូវបានចាត់ជាក្រុមក្នុងកម្រិតទាបបំផុត ដែលមានលំហូរសាច់ប្រាក់ឯករាជ្យមួយផ្នែកធំ (ឯកតាបង្កើតសាច់ប្រាក់)។ ជាលទ្ធផលទ្រព្យសកម្មមួយចំនួនត្រូវបានវាយតម្លៃឱនភាពដាច់ដោយឡែក និងមួយចំនួនទៀតវាយតម្លៃជាកម្រិត ឯកតាបង្កើតសាច់ប្រាក់។ ទ្រព្យសកម្មទាំងអស់ ដែលត្រូវធ្វើរំលស់ ឬឯកតាបង្កើតសាច់ប្រាក់ត្រូវបានធ្វើតេស្តលើឱនភាពនៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរក្នុងកាលៈទេសៈណាមួយ ដែលបានបង្ហាញថាសមតុល្យយោងទាំងនោះមិនអាចប្រមូលយកមកវិញបានទេ។

ការខាតបង់លើឱនភាពតម្លៃ នឹងត្រូវបានទទួលស្គាល់នូវចំនួនដែលលើសរវាងទ្រព្យសកម្ម ឬតម្លៃយោងនៃឯកតាបង្កើតសាច់ប្រាក់ និងចំនួនដែលអាចស្រង់មកវិញបានហើយតម្លៃដែលអាចស្រង់មកវិញគឺជាតម្លៃមួយណាដែលខ្ពស់ជាងរវាងតម្លៃទីផ្សារសមស្របដកការចំណាយដែលពាក់ព័ន្ធក្នុងការលក់ និងតម្លៃនាអំឡុងពេលប្រើប្រាស់។ ដើម្បីកំណត់តម្លៃប្រើប្រាស់ គណៈគ្រប់គ្រង ត្រូវធ្វើការប៉ាន់ស្មានតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតនៃក្រុមនីមួយៗដោយកំណត់អត្រាការប្រាក់ដ៏សមរម្យដើម្បីគណនាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ទាំងនោះ។ ទិន្នន័យប្រើប្រាស់ដើម្បី ធ្វើការវាយតម្លៃឱនភាព មានការទាក់ទងដោយផ្ទាល់ទៅនឹងគម្រោងផែនការថវិការបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ដែលបានអនុម័ត និងធ្វើនិយ័តកម្មប្រសិនបើចាំបាច់ ដើម្បីដកផលប៉ះពាល់ពីការរៀបចំ និងធ្វើឱ្យប្រសើរឡើងវិញនៃទ្រព្យសកម្មនោះនាពេលអនាគត។ អត្រាអប្បហារត្រូវបានកំណត់ឡើងសម្រាប់ក្រុមទ្រព្យសកម្មនីមួយៗដើម្បីឆ្លុះបញ្ចាំងពីប្រវត្តិសង្ខេបនៃហានិភ័យរបស់ទ្រព្យសកម្មនីមួយៗ ដូចដែលបានវាយតម្លៃដោយគណៈគ្រប់គ្រង។

ឱនភាពខាតបង់ទៅលើឯកតាបង្កើតសាច់ប្រាក់ ដែលបានកាត់បន្ថយសមតុល្យយោងដំបូងនៃទ្រព្យសកម្មអរូបិយដែលបានបែងចែកទៅឯកតាបង្កើតសាច់ប្រាក់ទាំងនោះ។ ការខាតបង់ឱនភាពដែលនៅសេសសល់ណាមួយត្រូវបានគិតបន្ទុកតាមអនុបាតទៅនឹងទ្រព្យសកម្មផ្សេងទៀតនៅក្នុងឯកតាបង្កើតសាច់ប្រាក់។ រាល់ទ្រព្យសកម្មទាំងអស់ត្រូវបានវាយតម្លៃឡើងវិញជាបន្តបន្ទាប់សម្រាប់សូចនាករដែលថា ឱនភាពខាតដែលបានទទួលស្គាល់ពីមុនអាចលែងមានទៀតហើយ។ ការគិតថ្លៃលើឱនភាពនឹងត្រូវបានកត់ត្រាបញ្ច្រាស ប្រសិនបើសមតុល្យនៃ ឯកតាបង្កើតសាច់ប្រាក់ដែលអាចប្រមូលមកវិញបានរបស់ឯកតាបង្កើតសាច់ប្រាក់លើសពីសមតុល្យយោងរបស់វា។

### ៤.៨ ឧបករណ៍ហិរញ្ញវត្ថុ

ការទទួលស្គាល់ដំបូង និងការវាស់វែង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់នៅពេលដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនបានក្លាយទៅជាភាគីសំវិធានធនកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវឈប់ទទួលស្គាល់នៅពេលដែលសិទ្ធិទៅលើលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានផុតកាលកំណត់ ឬនៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុ និងរាល់ហានិភ័យបន្ទាប់បន្សំទាំងអស់ និងអត្ថប្រយោជន៍ទាំងអស់ត្រូវបានផ្ទេរចេញ។ បំណុលហិរញ្ញវត្ថុត្រូវឈប់ទទួលស្គាល់ នៅពេលដែលកាតព្វកិច្ចនៃកិច្ចសន្យាបានបញ្ចប់ បានលុបចោល ឬផុតកាលកំណត់។

ការធ្វើចំណាត់ថ្នាក់ និងការវាស់វែងដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ

លើកលែងសម្រាប់គណនីពាណិជ្ជត្រូវទទួល ដែលមិនមានសមាសធាតុហិរញ្ញវត្ថុសំខាន់ៗ និងត្រូវបានវាស់វែងតាមតម្លៃប្រតិបត្តិការដោយអនុលោមតាម CIFRS ១៥ រាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ គឺត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្របដែលបានធ្វើការកែប្រែលើថ្លៃដើមប្រតិបត្តិការ (ប្រសិនបើមាន)។

ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមែនជាឧបករណ៍ជម្លៀសហានិភ័យ ត្រូវបានចាត់ថ្នាក់ជាប្រភេទដូចខាងក្រោម៖

- ថ្លៃដើមបានរំលស់
- តម្លៃទីផ្សារសមស្របតាមរយៈប្រាក់ចំណេញ ឬខាត (FVTPL) ឬ
- តម្លៃទីផ្សារសមស្របតាមរយៈប្រាក់ចំណូលលម្អិតផ្សេងៗ (FVOCI)

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៨ ឧបករណ៍ហិរញ្ញវត្ថុ (ត)

ក្នុងការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុនេះ បានកំណត់ដូចខាងក្រោម៖
- គំរូអាជីវកម្មរបស់អង្គភាពសម្រាប់គ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខណៈនៃលំហូរសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ។

រាល់ចំណូលនិងចំណាយ ដែលទាក់ទងទៅជាមួយទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលលម្អិតដែលបង្ហាញនៅក្នុងរបាយការណ៍ចំណូលពេញលេញផ្សេងៗ។

នៅកាលបរិច្ឆេទនៃរបាយការណ៍សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន បានវាស់វែងសមតុល្យយោងរបស់ទ្រព្យសកម្មហិរញ្ញវត្ថុតាមថ្លៃដើមបានរំលស់ដែលមាននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

**ទ្រព្យសកម្មហិរញ្ញវត្ថុ - ការវាស់វែងជាបន្តបន្ទាប់**

**ទ្រព្យសកម្មហិរញ្ញវត្ថុតាមថ្លៃដើមបានរំលស់**
ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ ប្រសិនបើទ្រព្យសកម្មនោះមានលក្ខណៈដូចខាងក្រោម (និងមិនត្រូវបានកំណត់ជា FVTPL)៖
- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានរក្សាក្រោមគំរូអាជីវកម្មក្នុងគោលបំណងគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុនិងប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុធ្វើឲ្យមានការកើនឡើងនូវលំហូរសាច់ប្រាក់ដែលទាក់ទងនឹងការទូទាត់សងលើប្រាក់ដើម និងការប្រាក់នៃសមតុល្យដែលនៅសេសសល់។

បន្ទាប់ពីមានការកត់ត្រាដំបូង ឧបករណ៍ទាំងនោះត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ ការធ្វើអប្បហារតម្លៃត្រូវបានលុបចោលនៅពេលដែលប្រសិទ្ធភាពនៃការធ្វើអប្បហារនេះ រាអសារវន្ត។ គណនីអតិថិជននិងគណនីត្រូវទទួលជាក់លាក់ សមតុល្យដែលត្រូវទទួលពីភាគីពាក់ព័ន្ធ សមតុល្យដែលត្រូវទទួលពីសម្ព័ន្ធញាតិ និងសាច់ប្រាក់ និងសាច់ប្រាក់សមមូលរបស់ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ត្រូវស្ថិតក្នុងចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុទាំងនេះ។

**ការឈប់ទទួលស្គាល់**
ទ្រព្យសកម្មហិរញ្ញវត្ថុ ឬផ្នែកណាមួយរបស់វាត្រូវបានឈប់ទទួលស្គាល់នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុ ផុតកំណត់ ឬភាពជាកម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅភាគីដទៃទៀត ហើយមិនរក្សាការគ្រប់គ្រង ឬហានិភ័យ និងអត្ថប្រយោជន៍នៃទ្រព្យសកម្ម។

ក្នុងការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងសមតុល្យយោង និងផលបូកនៃការទទួលបានរួមជាមួយនឹងចំណេញ ឬខាតបង្គរណាមួយ ដែលបានទទួលស្គាល់នៅក្នុងមូលធននៃប្រាក់ចំណេញ ឬខាត។

**ទ្រព្យសកម្មហិរញ្ញវត្ថុ-ឱនភាព**
សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ពិចារណាលើព័ត៌មានទូលំទូលាយ នៅពេលវាយតម្លៃហានិភ័យឥណទាន និងការខាតបង់ឥណទានដែលរំពឹងទុករួមទាំងព្រឹត្តិការណ៍ពីមុន បច្ចុប្បន្ន និងការព្យាករណ៍ដ៏សមហេតុផល និងអាចជឿជាក់បាន ដែលប៉ះពាល់ដល់លទ្ធភាពនៃការប្រមូលនៃលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុទាំងនោះ។

ដើម្បីអនុវត្តវិធីសាស្ត្ររំពឹងទុកនេះ បង្កឱ្យមានភាពខុសគ្នារវាង៖

- សម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានធ្លាក់ចុះតម្លៃយ៉ាងខ្លាំង ចាប់តាំងពីថ្ងៃកត់ត្រាដំបូង ឬដែលមានហានិភ័យឥណទានទាប (ដំណាក់កាលទី១) និង

- សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលបានធ្លាក់ចុះតម្លៃយ៉ាងខ្លាំង ចាប់តាំងពីថ្ងៃកត់ត្រាដំបូង ហើយមានហានិភ័យឥណទានខ្ពស់ (ដំណាក់កាលទី២)។.

ដំណាក់កាលទី៣គ្របដណ្តប់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលមានភស្តុតាងជាក់ស្តែងទាក់ទងនឹងឱនភាពនាកាលបរិច្ឆេទនៃរបាយការណ៍។

"ECL សម្រាប់រយៈពេល ១២ខែ" ត្រូវបានទទួលស្គាល់សម្រាប់ដំណាក់កាលទី១ ហើយ "ECL សម្រាប់ពេញមួយអាយុកាល" ត្រូវបានទទួលស្គាល់សម្រាប់ដំណាក់កាលទី២។

ការវាស់វែងលើការខាតបង់ឥណទានដែលរំពឹងទុក ត្រូវបានកំណត់ដោយការប៉ាន់ប្រមាណផលចំណេញសមស្រប នៃការខាតបង់ឥណទានលើវដ្តជីវិតនៃឧបករណ៍ហិរញ្ញវត្ថុដែលរំពឹងទុក។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

៣០ មិថុនា ២០២២

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៨ ឧបករណ៍ហិរញ្ញវត្ថុ (ត)

**ទ្រព្យសកម្មហិរញ្ញវត្ថុ-ឱនភាព (ត)**

<u>គណនីអតិថិជនដែលត្រូវទទួល និងទ្រព្យសកម្មកិច្ចសន្យា</u>

សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនបានអនុវត្តតាមវិធីសាស្ត្រសាមញ្ញមួយក្នុងគណនីអតិថិជនដែលត្រូវទទួលហើយបានកត់ត្រាសំវិធានធន ខាតបង់នូវអាយុកាលដែលបានរំពឹងទុកនៃឥណទានខាតបង់។ ការរំពឹងទុកទាំងនេះ ត្រូវបានចាត់ចូលទៅក្នុងលំហូរសាច់ប្រាក់តាមកិច្ចសន្យាហើយពិចារណាពីសក្តានុពលនៃការខកខាននៅចំណុចណាមួយនាអំឡុងពេលនៃអាយុកាលរបស់ឧបករណ៍ហិរញ្ញវត្ថុទាំងនោះ។ ក្នុងការគណនា សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ប្រើប្រាស់បទពិសោធន៍ប្រវត្តិសាស្ត្រកន្លងមក ហើយសូចនាករខាងក្រៅ និងព័ត៌មាននាពេលខាងមុខ ដែលគណនាពីការខាតបង់ឥណទានដែលបានរំពឹងទុក ដោយប្រើប្រាស់តាមវិធីសាស្ត្រស្តង់ដារខាងក្រៅនោះ។

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន បានវាយតម្លៃពីឱនភាពនៃគណនីពាណិជ្ជដែលត្រូវទទួលលើមូលដ្ឋានសមូហភាព ដោយសារអតិថិជនបានប្រើប្រាស់លក្ខណៈឥណទានស្រដៀងគ្នា។ ការវិភាគលម្អិតអំពីរបៀបនៃឱនភាពតាមការតម្រូវ CIFRS 9 ត្រូវបានអនុវត្តនោះ គឺស្ថិតនៅក្នុងកំណត់សម្គាល់៣៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

**បំណុលហិរញ្ញវត្ថុ-ការធ្វើចំណាត់ថ្នាក់ និងការវាស់វែង**

បំណុលហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនរួមមានគណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ជាក់លាក់ផ្សេងទៀត សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ និងសមតុល្យត្រូវសងទៅភាគីភាគីពាក់ព័ន្ធ ប្រាក់កម្ចី និងឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ។

បំណុលហិរញ្ញវត្ថុ ត្រូវបានវាស់ដំបូងតាមរយៈតម្លៃសមស្រប ហើយនៅពេលដែលអាចអនុវត្តបានត្រូវបានកែតម្រូវនៃថ្លៃដើមប្រតិបត្តិការ លើកលែងតែសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន បានកំណត់នូវបំណុលហិរញ្ញវត្ថុក្នុងតម្លៃសមស្របតាមរយៈប្រាក់ចំណេញ ឬខាត។

បន្ទាប់មកទៀត បំណុលហិរញ្ញវត្ថុធ្វើការការពារហានិភ័យទៅលើការវិនិយោគសុទ្ធនៅក្នុងប្រតិបត្តិការបរទេស (ការការពារហានិភ័យមូលនិធិវិនិយោគសុទ្ធ)។ ត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាពលើកលែងតែឧបករណ៍និស្សន្ទ និងបំណុលហិរញ្ញវត្ថុដែលត្រូវបានកំណត់ FVTPL ដែលត្រូវបានអនុវត្តជាបន្តរបន្ទាប់ដោយតម្លៃសមស្របជាមួយនឹងប្រាក់ចំណេញ ឬខាត ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត (ក្រៅពីឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទដែលត្រូវបានកំណត់ និងមានប្រសិទ្ធភាពដូចជាឧបករណ៍ការពារហានិភ័យ)។

រាល់ចំណាយការប្រាក់ហើយប្រសិនបើអាចទៅរួច ការផ្លាស់ប្តូរតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ចំណូលលម្អិត ត្រូវបានរាប់បញ្ចូលទាំងប្រាក់ចំណូលហិរញ្ញវត្ថុ និងចំណាយហិរញ្ញវត្ថុ។

**ឧបករណ៍និស្សន្ទ និងសកម្មភាពការពារហានិភ័យ**

ឧបករណ៍និស្សន្ទ ត្រូវបានទទួលស្គាល់ដំបូងដោយតម្លៃសមស្របនៅកាលបរិច្ឆេទដែលកិច្ចសន្យានិស្សន្ទ ត្រូវបានចូលនិងត្រូវបានវាយតម្លៃឡើងវិញជាបន្តបន្ទាប់នៅតម្លៃសមស្របរបស់ពួកគេនៅចុងបញ្ចប់នៃការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ។

គណនេយ្យសម្រាប់ការផ្លាស់ប្តូរជាបន្តបន្ទាប់នៃតម្លៃសមស្របអាស្រ័យលើថាតើនិស្សន្ទត្រូវបានគេកំណត់ជាឧបករណ៍ការពារហានិភ័យរួមបញ្ចូលលក្ខណៈនៃវត្ថុដែលត្រូវបានគេការពារ។ សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនកំណត់ចំណាំឧបករណ៍ហិរញ្ញវត្ថុជាក់លាក់មួយចំនួនដូចជា៖

(i) ធ្វើការការពារហានិភ័យទៅលើទ្រព្យឬបំណុលដែលបានទទួលស្គាល់ឬមានកិច្ចសន្យាយ៉ាងច្បាស់លាស់ (ការការពារហានិភ័យតាមតម្លៃសមស្រប)
(ii) ធ្វើការការពារហានិភ័យទៅលើហានិភ័យជាក់លាក់មួយដែលពាក់ព័ន្ធជាមួយនឹងទ្រព្យសកម្ម ឬបំណុល ដែលត្រូវបានគេទទួលស្គាល់ ឬប្រតិបត្តិការព្យាករណ៍ដែលមានសក្តានុពលខ្ពស់ (ការការពារហានិភ័យលំហូរសាច់ប្រាក់) ឬ
(iii) ធ្វើការការពារហានិភ័យទៅលើការវិនិយោគសុទ្ធនៅក្នុងប្រតិបត្តិការបរទេស (ការការពារហានិភ័យមូលនិធិវិនិយោគសុទ្ធ)។

នៅពេលចាប់ផ្តើមធ្វើការការពារហានិភ័យសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនបានកត់ត្រាទំនាក់ទំនងសេដ្ឋកិច្ចរវាងឧបករណ៍ការពារហានិភ័យ និងខ្ទង់គណនីដែលមានហានិភ័យរួមទាំងការផ្លាស់ប្តូរលំហូរសាច់ប្រាក់នៃឧបករណ៍ការពារហានិភ័យ ត្រូវបានគេរំពឹងថានឹងទូទាត់ការផ្លាស់ប្តូរលំហូរសាច់ប្រាក់នៃខ្ទង់គណនីដែលត្រូវបានការពារ។ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន បានកត់ត្រាគោលបំណង និងយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់ខ្លួនក្នុងការអនុវត្តប្រតិបត្តិការការពារហានិភ័យរបស់ខ្លួន។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.៨ ឧបករណ៍ហិរញ្ញវត្ថុ (ត)

**ឧបករណ៍និស្សន្ទ និងសកម្មភាពការពារហានិភ័យ (ត)**

តម្លៃសមស្របនៃឧបករណ៍និស្សន្ទផ្សេងៗដែលត្រូវបានប្រើសម្រាប់គោលបំណងការពារហានិភ័យត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់៣០ នៃរបាយការណ៍ហិរញ្ញវត្ថុ។ បម្រែបម្រួលលើទុនបម្រុងដែលបានធ្វើការការពារក្នុងចំណូលដែលមានលក្ខណៈទូលំទូលាយផ្សេងទៀតត្រូវបានបង្ហាញនៅក្នុងរបាយការណ៍បម្រែបម្រួលមូលធន។ សមតុល្យនិស្សន្ទពេញលេញត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្ម ឬបំណុលរយៈពេលវែងនៅពេលដែលអាយុកាលច្រើនជាង ១២ខែ និងបានចាត់ថ្នាក់ជាទ្រព្យសកម្ម ឬបំណុលរយៈពេលខ្លី នៅពេលដែលអាយុកាលទាបជាង ១២ខែ។ ការជួញដូរឧបករណ៍និស្សន្ទ ត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្ម ឬបំណុលរយៈពេលខ្លី។

(i) ការការពារហានិភ័យតម្លៃសមស្រប
ការផ្លាស់ប្តូរតម្លៃសមស្របនៃឧបករណ៍និស្សន្ទដែលត្រូវបានកំណត់និងមានលក្ខណៈគ្រប់គ្រាន់ដូចជាការការពារហានិភ័យតម្លៃសមស្របត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញឬខាតរួមជាមួយនឹងការផ្លាស់ប្តូរណាមួយនៃតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុលដែលត្រូវបានកំណត់ដោយហានិភ័យ។ ចំណេញឬខាតទាក់ទងនឹងការដកចេញមានប្រសិទ្ធភាពនៃអត្រាការប្រាក់ដែលប្តូរនឹងអត្រាប្រាក់កម្ចីមានអត្រាថេរ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតក្នុង "ចំណាយហិរញ្ញវត្ថុ"។ ចំណេញ ឬខាតទាក់ទងនឹងការដកចេញដែលមិនមានប្រសិទ្ធភាព ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាតក្នុង "ចំណេញ/(ខាតផ្សេងៗ)-សុទ្ធ"។ ការផ្លាស់ប្តូរតម្លៃសមស្របនៃអត្រាការប្រាក់របស់ប្រាក់កម្ចីមានអត្រាថេរ ដែលនឹងត្រូវបានបង្កឡើងដោយហានិភ័យអត្រាការប្រាក់ ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាតក្នុង "ចំណាយហិរញ្ញវត្ថុ"។
.

ប្រសិនបើការការពារហានិភ័យលែងមានលក្ខណៈវិនិច្ឆ័យសម្រាប់គណនេយ្យការពារហានិភ័យ ការកែតម្រូវទៅលើសមតុល្យយោងរបស់សមាសធាតុដែលត្រូវបានវាស់វែងតាមវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាពហើយត្រូវបានគេយកទៅរំលស់ហើយកត់ត្រាក្នុងរបាយការណ៍ចំណេញឬខាតក្នុងរយៈពេលដល់កាលកំណត់សងដោយប្រើប្រាស់គណនាឡើងវិញនៃអត្រាការប្រាក់មានប្រសិទ្ធភាព។

(ii) ការការពារហានិភ័យលំហូរសាច់ប្រាក់
ការដកចេញដ៏មានប្រសិទ្ធភាពនៃការផ្លាស់ប្តូរតម្លៃសមស្របនៃឧបករណ៍និស្សន្ទដែលត្រូវបានចាត់តាំងនិងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចជាមូលនិធិលំហូរសាច់ប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណូលពេញលេញផ្សេងៗនិងបង្គរដែលបម្រុងទុកនៅក្នុងមូលធន។ ចំណេញឬខាត ដែលទាក់ទងនឹងការដកចេញដែលមិនមានប្រសិទ្ធភាព ត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងប្រាក់ចំណេញ ឬខាតក្នុង"ចំណេញ/(ខាត)-សុទ្ធ"។ សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន មិនរួមបញ្ចូលមូលដ្ឋានរូបិយប័ណ្ណបរទេសដែលរៀបចំតាមឧបករណ៍និស្សន្ទ ដែលប្រើជាឧបករណ៍ការពារហានិភ័យ ការផ្លាស់ប្តូរមូលដ្ឋានរូបិយប័ណ្ណបរទេសនៃឧបករណ៍ការពារហានិភ័យត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណូលពេញលេញផ្សេងៗនិងបង្គរថ្លៃដើមនៃការការពារហានិភ័យនៅក្នុងមូលធន។ សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន កំណត់ថ្លៃដើមនៃការពារហានិភ័យ ដែលពាក់ព័ន្ធនឹងមូលដ្ឋានរូបិយប័ណ្ណបរទេស ក្នុងការការពារហានិភ័យតាមគោលការណ៍នៃការការពារហានិភ័យ។

សមតុល្យដែលបង្គរនៅក្នុងមូលធន (រាប់បញ្ចូលទាំងថ្លៃដើមនៃការការពារហានិភ័យបម្រុងទុក) ត្រូវបានចាត់ថ្នាក់ឡើងវិញក្នុងចំណេញឬខាតក្នុងរយៈពេលដែលលំហូរសាច់ប្រាក់ ដែលមានផលប៉ះពាល់ដល់ប្រាក់ចំណេញឬខាត។ ចំណេញឬខាតដែលទាក់ទងនឹងការដកចេញមានប្រសិទ្ធភាពនៃអត្រាការប្រាក់បានផ្លាស់ប្តូរអត្រាប្រាក់កម្ចី ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញឬខាតនៅក្នុង "ចំណាយហិរញ្ញវត្ថុ"។ ចំណេញឬខាត ដែលទាក់ទងនឹងការដកចេញដែលមិនមានប្រសិទ្ធភាព ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាតក្នុង "ចំណេញ/(ខាត)-សុទ្ធ"។

នៅពេលឧបករណ៍ការពារហានិភ័យហួសកំណត់ ឬបានលក់ ឬឧបករណ៍ការពារហានិភ័យលែងស្ថិតនៅក្នុងលក្ខខណ្ឌការពារហានិភ័យគណនេយ្យ ចំណេញ ឬខាតបង្គរណាមួយដែលមាននៅក្នុងមូលធន ហើយនឹងរក្សានៅក្នុងមូលធនដដែល និងទទួលស្គាល់នៅពេលការការពារហានិភ័យលំហូរសាច់ប្រាក់ប៉ះពាល់ដល់ចំណេញ ឬខាត។

(iii) ការការពារហានិភ័យមូលនិធិវិនិយោគសុទ្ធ
ការការពារហានិភ័យលើការវិនិយោគសុទ្ធនៅក្នុងប្រតិបត្តិការបរទេសត្រូវបានគេរាប់បញ្ចូលក្នុងការការពារហានិភ័យលំហូរសាច់ប្រាក់។

ចំណេញឬខាតណាមួយនៅលើឧបករណ៍ការពារហានិភ័យដែលទាក់ទងនឹងចំណែកដ៏មានប្រសិទ្ធភាពនៃការការពារហានិភ័យត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណូលពេញលេញផ្សេងទៀតនិងបង្គរដែលបម្រុងទុកនៅក្នុងមូលធន។ ចំណេញឬខាតទាក់ទងនឹងការដកចេញមិនមានប្រសិទ្ធភាពត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងរបាយការណ៍ចំណេញ ឬខាតក្នុង "ចំណេញ/(ខាត)សុទ្ធ"។

ចំណេញ និងការខាតបង់បង្គរនៅក្នុងមូលធន ត្រូវបានរាប់បញ្ចូលទាំងប្រាក់ចំណេញ ឬខាតនៅពេលប្រតិបត្តិការបរទេសត្រូវបានលុបចោលឬទុកចោលមួយចំណែក។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

ឧបករណ៍និស្សន្ទជាក់លាក់នេះ មិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការការពារហានិភ័យគណនេយ្យនោះទេ។ ការផ្លាស់ប្តូរតម្លៃសមស្របនៃឧបករណ៍និស្សន្ទដែលមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការការពារហានិភ័យគណនេយ្យត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងប្រាក់ចំណេញ ឬខាត និងត្រូវបានរាប់បញ្ចូលក្នុង "ចំណេញ/(ខាត)-សុទ្ធ"។

## ៤.៩ សន្និធិ

សន្និធិត្រូវបានបង្ហាញតាមថ្លៃដើមទាបនិងតម្លៃសុទ្ធជាក់ស្តែង។ ថ្លៃដើមនៃការទិញសម្ភារសំណង់រួមទាំងថ្លៃដើម ដែលកើតឡើងក្នុងការនាំរបស់សម្ភារនីមួយៗទៅទីតាំងនិងស្ថានភាពបច្ចុប្បន្នរបស់ពួកគេ ហើយត្រូវបានរាប់បញ្ចូលដោយប្រើវិធីសាស្រ្តថ្លៃដើមមធ្យមភាគ។ តម្លៃសុទ្ធជាក់ស្តែងគឺជាតម្លៃលក់ ដែលបានប៉ាន់ស្មាននៅក្នុងដំណើរការអាជីវកម្មធម្មតាដកចំណាយដែលបានប៉ាន់ស្មាននៅក្នុងការលក់ ឬថ្លៃដើមជំនួសទ្រព្យសកម្មបច្ចុប្បន្ន។

## ៤.១០ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ក្នុងដៃ និងសាច់ប្រាក់នៅក្នុងធនាគារផ្សេងៗ ដែលមានរយៈពេលខ្លីសម្រាប់ការវិនិយោគងាយស្រួលបង្វិល ដែលរួចរាល់ក្នុងការបំប្លែងទៅជាសាច់ប្រាក់ ហើយប្រឈមនឹងហានិភ័យក្នុងការផ្លាស់ប្តូរតម្លៃតិចដកចេញគណនីឥណទានវិបារូបន៍។

## ៤.១១ មូលធន ទុនបម្រុងទុក និងការទូទាត់ភាគលាភ

ដើមទុនតំណាងឲ្យតម្លៃចារឹកនៃតម្លៃដើមភាគហ៊ុនដែលបានបោះផ្សាយ។ ប្រាក់ចំណេញរក្សាទុករួមមានប្រាក់ចំណេញនាការិយបរិច្ឆេទបច្ចុប្បន្ន និងការិយបរិច្ឆេទចាស់ទាំងអស់។

ដើមទុនបម្រុងទុកតំណាងដោយតម្លៃសមស្របនៃភាគហ៊ុនដែលបានផ្តល់ក្រោមគម្រោងជំនួយភាគហ៊ុន។ វាជាភាគហ៊ុនអាស្រ័យលើគម្រោងទូទាត់ដែលបានផ្តល់ដោយក្រុមហ៊ុនមេ Pestech International Berhad ទៅនិយោជិតរបស់ក្រុមហ៊ុន។ តម្លៃសមស្របនៃភាគហ៊ុនដែលត្រូវបានផ្តល់ត្រូវបានវាស់វែងតាមតម្លៃសមស្របតាមកាលបរិច្ឆេទនៃការផ្តល់និងត្រូវបានទទួលស្គាល់ជាការចំណាយលើអត្ថប្រយោជន៍និយោជិតដែលមានការកើនឡើងនៅក្នុងមូលធន។

ដើមទុនបម្រុងតំណាងឱ្យការប្រែប្រួលតម្លៃសមស្របនៃអត្រាការប្រាក់នៃកិច្ចសន្យាប្តូរប្រាក់ដែលកំណត់ថាជាការពារហានិភ័យដែលត្រូវបានរួមបញ្ចូលក្នុងការពារហានិភ័យលើមូលធនបម្រុង និងបន្តដោះស្រាយលើចំណូល/ខាតពេញលេញផ្សេងៗ រហូតដល់ការទូទាត់ប្រាក់កម្ចី ឬកាលកំណត់នៃកិច្ចសន្យាទៅតាមភាពជាក់ស្តែង ឬធ្វើការទូទាត់ដែលលឿនជាងនេះ។ សម្រាប់កិច្ចសន្យាដែលមិនបានកំណត់ថាជាការការពារហានិភ័យ ការផ្លាស់ប្តូរតម្លៃសមស្រប ត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ ឬខាត។

## ៤.១២ សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនមានកាតព្វកិច្ចស្របច្បាប់ឬប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ដែលវាទំនងជាមានលំហូរចេញនៃប្រភពសេដ្ឋកិច្ចរបស់សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន និងសមតុល្យដែលអាចប៉ាន់ស្មានបានជាក់ស្តែង។ ការកំណត់លំហូរចេញនៃពេលវេលាឬសមតុល្យនៅតែអាចមានភាពមិនច្បាស់លាស់។ កាតព្វកិច្ចបច្ចុប្បន្នកើតឡើងតាំងពីវត្តមាននៃការសន្យា ផ្លូវច្បាប់ ឬការទាមទារផ្សេងទៀតដែលកើតចេញពីព្រឹត្តិការណ៍កន្លងមក ឧទាហរណ៍ការធានារ៉ាប់រងផលិតផល ច្បាប់ដោះស្រាយជម្លោះ ឬកិច្ចសន្យាស្មុគស្មាញ។

សំវិធានធន ត្រូវបានវាស់វែងដោយការប៉ាន់ស្មានលើការចំណាយដែលចាំបាច់ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ដោយយោងតាមភស្តុតាងដែលអាចជឿទុកចិត្តបាន នៅចុងការិយបរិច្ឆេទនៃរបាយការណ៍រួមទាំងហានិភ័យ និងភាពមិនជាក់លាក់ ដែលទាក់ទងទៅនឹងកាតព្វកិច្ចបច្ចុប្បន្ន។ នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នា ដែលអាចនឹងតម្រូវឱ្យមានលំហូរចេញនៃសាច់ប្រាក់ដើម្បីបំពេញនូវកាតព្វកិច្ច ត្រូវបានកំណត់ដោយ ការពិចារណាទៅលើចំណាត់ថ្នាក់នីមួយៗនៃកាតព្វកិច្ចនោះជារួម។ សំវិធានធន ត្រូវធ្វើអប្បហារទៅជាតម្លៃបច្ចុប្បន្ន ប្រសិនបើតម្លៃនោះមានភាពជាសារវន្ត។

សំណងណាមួយដែលសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនជឿជាក់ថានឹងអាចមានសិទ្ធិប្រមូលបានពីតតិយជននឹងត្រូវបានគេទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែកមួយ។ ទ្រព្យសម្បត្តិនេះមិនអាចលើសពីសមតុល្យដែលពាក់ព័ន្ធទៅនឹងសំវិធានធននោះទេ។ រាល់សំវិធានធនត្រូវបានពិនិត្យឡើងវិញនៅរាល់ចុងការិយបរិច្ឆេទរបាយការណ៍និងបានកែសម្រួលដើម្បីសមស្របនឹងការប៉ាន់ស្មានថ្មីដែលល្អបំផុត។

ក្នុងករណីទាំងនោះ ពេលដែលមានភាពអាចទៅរួចនៃលំហូរចេញធនធានសេដ្ឋកិច្ច ដែលជាលទ្ធផលនៃកាតព្វកិច្ចបច្ចុប្បន្នគឺត្រូវបានចាត់ទុកថាមិនទំនង ឬនៅឆ្ងាយ ដូច្នេះពុំមានបំណុលត្រូវបានទទួលស្គាល់នោះទេ។

លំហូរចូលដែលអាចកើតមាននៃអត្ថប្រយោជន៍សេដ្ឋកិច្ចទៅកាន់ក្រុមហ៊ុន ដែលមិនគ្រប់លក្ខខណ្ឌក្នុងការទទួលស្គាល់ទ្រព្យសកម្មត្រូវចាត់ទុកជាទ្រព្យសកម្មយថាហេតុ។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១៣ ប្រតិបត្តិការតាមផ្នែក

ប្រតិបត្តិការតាមផ្នែក ជាសមាសធាតុរបស់សម្ព័ន្ធក្រុមហ៊ុនដែលពាក់ព័ន្ធក្នុងសកម្មភាពអាជីវកម្ម ហើយអាចទទួលបានប្រាក់ចំណូល និងបង្កើតចំណាយរួមទាំងចំណូលនិងចំណាយដែលទាក់ទងជាមួយប្រតិបត្តិការនូវរាល់សមាសធាតុណាមួយរបស់សម្ព័ន្ធក្រុមហ៊ុន។ លទ្ធផលប្រតិបត្តិការតាមផ្នែកទាំងអស់ត្រូវបានត្រួតពិនិត្យយ៉ាងទៀតទាត់ ដោយប្រធានប្រតិបត្តិការជាអ្នកធ្វើសេចក្តីសម្រេចចិត្តដើម្បីធ្វើការសម្រេចអំពីធនធានដែលត្រូវបែងចែកទៅតាមផ្នែកនិងវាយតម្លៃទៅលើលទ្ធផលរបស់វាព្រមទាំងសម្រាប់ព័ត៌មានហិរញ្ញវត្ថុដាច់ដោយឡែកដែលកើតមាន។

សម្ព័ន្ធក្រុមហ៊ុនមានរបាយការណ៍តាមផ្នែកដូចជាផ្នែកវិស្វករ ផ្នែកលទ្ធកម្ម ផ្នែកសាងសង់ និងផ្នែកវាយតម្លៃ។ ប្រធានប្រតិបត្តិការជាអ្នកធ្វើសេចក្តីសម្រេច និងធ្វើការត្រួតពិនិត្យលើរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលរាយការណ៍ពីលទ្ធផលតាមផ្នែកទាំងមូលរបស់ក្រុមហ៊ុនដើម្បីធ្វើការវាយតម្លៃលើលទ្ធផលតាមផ្នែកដែលបានរាយការណ៍។

### ៤.១៤ ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ពេញលេញ រួមមានការបូកសរុបនៃពន្ធពន្យារ និងពន្ធបច្ចុប្បន្នដែលមិនបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលពេញលេញ ឬរបាយការណ៍មូលធន។

ពន្ធលើប្រាក់ចំណូលជាទ្រព្យសកម្មនិង/ឬបំណុលរួមមានកាតព្វកិច្ចឬការទាមទារពីអាជ្ញាធរសារពើពន្ធដែលទាក់ទងនឹងចុងការិយបរិច្ឆេទ នៃរបាយការណ៍បច្ចុប្បន្ន ឬពីពេលកន្លងមក ដែលមិនបានទូទាត់នាការិយបរិច្ឆេទនៃរបាយការណ៍នោះ។ ពន្ធបច្ចុប្បន្ន គឺជាបំណុលលើប្រាក់ចំណេញជាប់ពន្ធដែលខុសពីប្រាក់ចំណេញឬខាតក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការគណនាពន្ធបច្ចុប្បន្ន គឺផ្អែកលើអត្រាពន្ធនិងច្បាប់សារពើពន្ធដែលត្រូវបានអនុម័តឬត្រូវបានអនុម័តនៅពេលបន្ទាប់ នាចុងការិយបរិច្ឆេទនៃរបាយការណ៍។

ពន្ធពន្យារលើប្រាក់ចំណូលត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្ត្របំណុលលើភាពខុសគ្នាបណ្តោះអាសន្នរវាងសមតុល្យយោងនៃទ្រព្យសកម្ម និងបំណុល និងមូលដ្ឋានពន្ធរបស់ពួកគេ។ ទោះជាយ៉ាងណា ពន្ធពន្យារមិនត្រូវបានទទួលស្គាល់ដំបូងលើមូលធនពាណិជ្ជកម្ម ឬលើការទទួលស្គាល់ដំបូងរបស់ទ្រព្យសកម្ម ឬបំណុលលើកលែងតែប្រតិបត្តិការដែលពាក់ព័ន្ធប៉ះពាល់លើពន្ធឬគណនីចំណេញ។

ពន្ធពន្យារជាទ្រព្យសកម្មនិងជាបំណុលត្រូវបានគណនាដោយមិនគិតអប្បហារនៅអត្រាពន្ធដែលរំពឹងថានឹងអនុវត្តទៅតាមរយៈពេលនៃការទទួលស្គាល់របស់ពួកគេដោយសារអត្រាពន្ធទាំងនោះត្រូវបានអនុម័តឬអនុម័តនៅពេលបន្ទាប់នៅចុងការិយបរិច្ឆេទនៃរបាយការណ៍។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានទទួលស្គាល់ដើម្បីពង្រីកវិសាលភាពដែលប្រហែលជាមានការខាតបង់ឬភាពខុសគ្នាបណ្តោះអាសន្ន ដែលកាត់កងបាននឹងអាចប្រើប្រាស់បានដើម្បីកាត់កងនឹងប្រាក់ចំណូលជាប់ពន្ធនាពេលអនាគត។ ការវាយតម្លៃនេះ គឺផ្អែកលើការព្យាករណ៍របស់ក្រុមហ៊ុនទៅលើលទ្ធផលប្រតិបត្តិការនាពេលអនាគត ដែលត្រូវបានកែតម្រូវសម្រាប់ប្រាក់ចំណូលនិងការចំណាយដែលមិនជាប់ពន្ធ និងការកំណត់ជាក់លាក់លើការប្រើប្រាស់ការខាតបង់ពន្ធដែលមិនបានប្រើណាមួយ និងពន្ធត្រូវបង់។ ពន្ធពន្យារជាបំណុលតែងតែត្រូវបានទទួលស្គាល់ទាំងអស់។

ពន្ធពន្យារជាទ្រព្យសកម្ម និងជាបំណុលអាចកាត់កងបានតែនៅពេលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានសិទ្ធិនិងគោលបំណងក្នុងការទូទាត់ពន្ធបច្ចុប្បន្នជាទ្រព្យសកម្ម និងបំណុលពីអាជ្ញាធរពន្ធដារតែមួយ។

ការផ្លាស់ប្តូរពន្ធពន្យារជាទ្រព្យសកម្មនិងជាបំណុលត្រូវបានទទួលស្គាល់ជាផ្នែកនៃពន្ធលើប្រាក់ចំណេញឬចំណាយនៅក្នុងរបាយការណ៍ចំណូលលម្អិត លើកលែងតែនៅពេលដែលពន្ធទាំងនោះ មានការទាក់ទងនឹងផ្នែកទាំងអស់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតផ្សេងទៀត (ដូចជាការវាយតម្លៃដីឡើងវិញ) ឬមូលធនក្នុងករណីណាមួយ ពេលពន្ធពន្យារដែលទាក់ទង ក៏ត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតផ្សេងទៀត ឬរបាយការណ៍មូលធន។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១៥ ភតិសន្យា

**សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនក្នុងនាមជាអ្នកជួល**

សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនប្រើប្រាស់ការរៀបចំភតិសន្យាចម្បងសម្រាប់ការជួលការិយាល័យ កន្លែងស្នាក់នៅរបស់បុគ្គលិក និងឃ្លាំង។ កិច្ចសន្យាជួលសម្រាប់ការិយាល័យ ការស្នាក់នៅរបស់បុគ្គលិក និងឃ្លាំងត្រូវបានចរចាជាធម្មតាក្នុងលក្ខខណ្ឌពី ៣ ទៅ ៥ឆ្នាំ។ សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនមិនមានការរៀបចំក្នុងការលក់បន្តនិងការជួលបន្តទ្រព្យជួលទាំងនោះទេ។ កិច្ចសន្យាជួលទាំងអស់ត្រូវបានចរចាជាលក្ខណៈដាច់ដោយឡែកនិងមានរយៈពេលនិងលក្ខខណ្ឌផ្សេងៗគ្នាជាច្រើនដូចជាការដាក់កំហិតពីការចាត់តាំងនិងការជួលបន្តនៃទ្រព្យដែលជួល ហើយត្រូវធ្វើការទូទាត់យ៉ាងទៀងទាត់ដោយអនុលោមតាមកិច្ចសន្យានិងផ្តល់ការយកចិត្តទុកដាក់យ៉ាងល្អចំពោះទ្រព្យសម្បត្តិរោងចក្រនិងបរិក្ខារដែលមានស្រាប់។

សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនវាយតម្លៃថាតើកិច្ចសន្យាមាន ឬមានកិច្ចសន្យាជួលនៅពេលចាប់ផ្តើមកិច្ចសន្យា។ ភតិសន្យាបានបង្ហាញពីសិទ្ធិក្នុងការប្រើប្រាស់ដោយផ្ទាល់និងទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើននៃទ្រព្យសកម្មដែលបានកំណត់ក្នុងរយៈពេលមួយជាថ្នូរនឹងការដោះដូរតាមតម្លៃតបស្នង។

**ការវាស់វែង និងការទទួលស្គាល់ភតិសន្យាក្នុងនាមជាអ្នកជួល**

នាកាលបរិច្ឆេទចុះកិច្ចសន្យាជួល សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនទទួលស្គាល់សិទ្ធិប្រើប្រាស់លើទ្រព្យសកម្មនិងបំណុលភតិសន្យានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ សិទ្ធិប្រើប្រាស់លើទ្រព្យសកម្មត្រូវបានវាស់វែងតាមថ្លៃដើម ដែលត្រូវបានបង្កើតឡើងដោយការវាស់វែងដំបូងនៃបំណុលភតិសន្យា ថ្លៃដើមដំបូងណាមួយដែលកើតឡើងដោយក្រុមហ៊ុន ការប៉ាន់ស្មានលើការចំណាយនៃការរុះរើ និងដកហូតទ្រព្យសកម្មនៅចុងបញ្ចប់នៃភតិសន្យា ហើយរាល់ការទូទាត់ទៅលើភតិសន្យាណាមួយដែលបានធ្វើឡើងមុនថ្ងៃចាប់ផ្តើមនៃការជួល (ប្រាក់លើកទឹកចិត្តដែលទទួលបានសុទ្ធ)។

សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនធ្វើរំលស់ទៅសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មសតាមមូលដ្ឋានរំលស់ថេរគិតចាប់ពីថ្ងៃចាប់ផ្តើមនៃភតិសន្យារហូតដល់ពេលបញ្ចប់នៃអាយុកាលសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មឬចុងបញ្ចប់នៃកិច្ចសន្យា។ ក្រុមហ៊ុនក៏ធ្វើការវាយតម្លៃទៅលើឱនភាពតម្លៃនៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មនៅពេលដែលវាបានកើតមានឡើង។

នាកាលបរិច្ឆេទចាប់ផ្តើមនៃភតិសន្យា សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនបានវាស់វែងលើបំណុលភតិសន្យាទៅតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ថ្លៃជួលដែលមិនទាន់បានទូទាត់នាកាលបរិច្ឆេទត្រូវបានធ្វើអប្បហារដោយប្រើប្រាស់អត្រាការប្រាក់ដែលបានព្រមព្រៀងនៅក្នុងភតិសន្យា ប្រសិនបើអត្រាទាំងនេះកើតមានរួចហើយ ឬការកើតឡើងនៃអត្រាប្រាក់កម្ចីរបស់ក្រុមហ៊ុន។

បន្ទាប់ពីការវាស់វែងដំបូង បំណុលនឹងត្រូវបានកាត់បន្ថយតាមរយៈការទូទាត់បំណុលភតិសន្យាដែលត្រូវបានបែងចែករវាងការទូទាត់ប្រាក់ដើមនិងចំណាយហិរញ្ញវត្ថុ។ ចំណាយហិរញ្ញវត្ថុ គឺជាសមតុល្យដែលបង្កើតអត្រាការប្រាក់ថេរតាមកាលកំណត់លើសមតុល្យដែលនៅសេសសល់នៃបំណុលភតិសន្យា។

ការវាស់វែងឡើងវិញទៅលើបំណុលភតិសន្យាត្រូវបានធ្វើឡើងតាមរយៈការកាត់បន្ថយសមតុល្យយោងរបស់សិទ្ធិប្រើប្រាស់លើទ្រព្យសកម្មដើម្បីឆ្លុះបញ្ចាំងអំពីការបញ្ចប់កិច្ចសន្យាភតិសន្យាមួយផ្នែកឬទាំងស្រុងសម្រាប់ការកែប្រែលើភតិសន្យាដែលកាត់បន្ថយវិសាលភាពនៃភតិសន្យា។ ចំណេញឬខាត ដែលទាក់ទងទៅនឹងការបញ្ចប់កិច្ចសន្យាភតិសន្យាមួយផ្នែកឬទាំងស្រុងត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញឬខាត។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម គឺត្រូវបានកែប្រែនៅពេលដែលមានការកែប្រែលើភតិសន្យាទាំងអស់។

សិទ្ធិប្រើប្រាស់លើទ្រព្យសកម្មនិងបំណុលភតិសន្យាត្រូវបានបង្ហាញដាច់ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនបានជ្រើសរើសគណនីភតិសន្យារយៈពេលខ្លីនិងភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាបដោយប្រើប្រាស់ឯកសារយោងជាក់ស្តែង។ ជំនួសឱ្យការទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្មនិងបំណុលភតិសន្យា ការទូទាត់ដែលទាក់ទងទៅលើគណនីទាំងនេះ គឺត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍ចំណូលលម្អិតតាមមូលដ្ឋានរំលស់ថេរលើរយៈពេលជួល។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ៤.១៦ ភាគីពាក់ព័ន្ធ

ភាគីពាក់ព័ន្ធ គឺជាបុគ្គលឬអង្គភាពដែលមានទំនាក់ទំនងជាមួយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។ ប្រតិបត្តិការភាគីពាក់ព័ន្ធ គឺជាការផ្ទេរធនធាន សេវាកម្ម ឬកាតព្វកិច្ចរវាងសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន និងភាគីពាក់ព័ន្ធរបស់ខ្លួនទោះបីជាបានគិតថ្លៃ ឬមិនបានគិតថ្លៃ។ សម្រាប់គោលបំណងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ភាគីពាក់ព័ន្ធត្រូវបានកំណត់ ប្រសិនបើបុគ្គលឬអង្គភាពទាំងនោះបានបំពេញតាមលក្ខខណ្ឌណាមួយខាងក្រោម៖

ក. បុគ្គលឬមនុស្សដែលជិតស្និទ្ធជាមួយបុគ្គលនៃគ្រួសារនោះ គឺមានការពាក់ព័ន្ធជាមួយសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន ប្រសិនបើបុគ្គលនោះ៖

i. មានសិទ្ធិគ្រប់គ្រងឬចូលរួមក្នុងការគ្រប់គ្រងលើសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន
ii. មានឥទ្ធិពលខ្លាំងលើសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន ឬ
iii. គឺជាសមាជិកនៃក្រុមប្រឹក្សាភិបាលជាន់ខ្ពស់របស់ក្រុមហ៊ុនមេចុងក្រោយដែលកាន់កាប់នៃសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន ឬក្រុមបុត្រសម្ព័ន្ធនិងក្រុមហ៊ុន។

ខ. អង្គភាពដែលចាត់ចូលជាភាគីពាក់ព័ន្ធនៃសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន ប្រសិនបើស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

i. សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន គឺជាសមាជិកនៃសម្ព័ន្ធក្រុមហ៊ុនតែមួយ
ii. អង្គភាពមួយដែលជាការចូលរួមឬការបណ្តាក់ទុនរួមគ្នានៃអង្គភាពផ្សេងទៀត
iii. អង្គភាពទាំងពីរធ្វើរការបណ្តាក់ទុនរួមលើភាគីទីបីដូចគ្នា
iv. អង្គភាពមួយគឺ ជាភាគហ៊ុនរួមនៃអង្គភាពភាគីទីបីនឹងអង្គភាពផ្សេងទៀតគឺជាអង្គភាពរួមបញ្ចូលគ្នានៃភាគីទីបី
v. អង្គភាព គឺជាគម្រោងអត្ថប្រយោជន៍ក្រោយការងារសម្រាប់អត្ថប្រយោជន៍របស់និយោជិតរបស់សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន
vi. អង្គភាពត្រូវបានគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយបុគ្គលដែលបានបញ្ជាក់នៅក្នុង (ក) ខាងលើ
vii. បុគ្គលដែលបានកំណត់អត្តសញ្ញាណនៅក្នុង (ក.១) ខាងលើមានឥទ្ធិពលគួរឱ្យកត់សម្គាល់លើអង្គភាពឬជាសមាជិកនៃក្រុមប្រឹក្សាភិបាលសំខាន់ៗ ដែលកំពុងកាន់កាប់ក្រុមហ៊ុនចុងក្រោយឬអង្គភាព
viii. អង្គភាពឬសមាជិកនៃសម្ព័ន្ធ ដែលជាផ្នែកមួយផ្តល់នូវសេវាកម្មគ្រប់គ្រងសំខាន់ៗ ដល់សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន។

## ៥. ការវិនិច្ឆ័យ ការសន្មត និងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ

សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនបានធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យទាក់ទងនឹងប្រតិបត្តិការនាពេលអនាគតដែលមានភាពមិនស្មើនឹងលទ្ធផលជាក់ស្តែង។ គណនេយ្យប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដែលអាចបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការទទួលស្គាល់និងវាស់វែងលើទ្រព្យសកម្ម បំណុល ចំណូល និងចំណាយត្រូវបានសង្ខេបដូចខាងក្រោម៖

### ក. ការប៉ាន់ស្មាន និងការសន្មតគណនេយ្យសំខាន់ៗ

**ឱនភាព**
ក្នុងការវាយតម្លៃឱនភាព គណៈគ្រប់គ្រងប៉ាន់ស្មាននូវសមតុល្យដែលអាចស្រង់មកវិញបានរបស់ទ្រព្យសកម្មនីមួយៗ ឬឯកតាបង្កើតសាច់ប្រាក់ ដោយផ្អែកលើការរំពឹងទុកនៃលំហូរសាច់ប្រាក់នាពេលអនាគត និងការប្រើប្រាស់អត្រាការប្រាក់ដើម្បីធ្វើអប្បហារ។ ការប៉ាន់ស្មានដែលមិនជាក់លាក់ទាក់ទងនឹងការប៉ាន់ស្មានអំពីលទ្ធផលប្រតិបត្តិការនាពេលអនាគតនិងការកំណត់យកអប្បហារដែលសមស្រប។

**អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មដែលអាចធ្វើរំលស់បាន**
សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនធ្វើការត្រួតពិនិត្យលើការប៉ាន់ស្មាននៃអាយុកាលប្រើប្រាស់នៃទ្រព្យសកម្ម ដែលអាចធ្វើរំលស់បាននៅរាល់ការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដោយផ្អែកទៅលើការប្រើប្រាស់ទ្រព្យសកម្មដែលបានរំពឹងទុកទាំងនោះ។

**កិច្ចសន្យាសាងសង់-ចំណូលកិច្ចសន្យា**
សមតុល្យនៃចំណូលកិច្ចសន្យាសាងសង់និងគណនីត្រូវទទួលដែលពាក់ព័ន្ធដែលត្រូវបានទទួលស្គាល់ឆ្លុះបញ្ចាំងពីការប៉ាន់ស្មានដែលត្រឹមត្រូវបំផុតរបស់គណៈគ្រប់គ្រងនៃលទ្ធផលនៃកិច្ចសន្យានីមួយៗនិងដំណាក់កាលនៃការបញ្ចប់ការសាងសង់។នេះរួមបញ្ចូលទាំងការវាយតម្លៃនៃលទ្ធភាពទទួលបានផលចំណេញពីកិច្ចសន្យាសាងសង់ដែលកំពុងដំណើរការនិងកិច្ចការដែលរាំងស្ទះពីមុនៗ។ កិច្ចសន្យាស្មុគស្មាញជាក់លាក់មួយចំនួន ថ្លៃដើមក្នុងការបញ្ចប់ការសាងសង់ និងលទ្ធភាពដែលអាចទទួលបាននៃផលចំណេញពីកិច្ចសន្យា គឺជាកម្មវត្ថុនៃការប៉ាន់ស្មានមិនជាក់លាក់សំខាន់ៗមួយចំនួន។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ៥. ការវិនិច្ឆ័យ ការសន្មត និងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ (ត)

### ក. ការប៉ាន់ស្មាន និងការសន្មតគណនេយ្យសំខាន់ៗ

**សន្និធិ**
សន្និធិត្រូវបានវាស់ដោយតាមថ្លៃដើមទាបនិងតម្លៃសុទ្ធជាក់ស្តែង។ ការប៉ាន់ស្មាននៃតម្លៃសុទ្ធជាក់ស្តែង គណៈគ្រប់គ្រងត្រូវយកភស្តុតាងដែលអាចទុកចិត្តបំផុតដែលមាននៅពេលដែលការប៉ាន់ស្មានត្រូវបានធ្វើឡើង។ អាជីវកម្មស្នូលរបស់សម្ព័ន្ធក្រុមហ៊ុន ស្ថិតនៅក្រោមការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ចនិងបច្ចេកវិទ្យាដែលអាចបណ្តាលឱ្យមានការផ្លាស់ប្តូរតម្លៃលក់យ៉ាងឆាប់រហ័សហើយប្រាក់ចំណេញរបស់សម្ព័ន្ធក្រុមហ៊ុននឹងមានការផ្លាស់ប្តូរ។

**ភតិសន្យា - ការប៉ាន់ស្មានអត្រាកម្ចីបន្ថែម**
សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន មិនអាចកំណត់បានដោយងាយស្រួលនូវអត្រាការប្រាក់ដែលជាប់ពាក់ព័ន្ធក្នុងភតិសន្យានោះទេ ដូច្នេះក្រុមហ៊ុនត្រូវប្រើអត្រាប្រាក់កម្ចីបន្ថែមរបស់ខ្លួន ("IBR") ដើម្បីវាស់វែងបំណុលភតិសន្យា។ IBR ជាអត្រាការប្រាក់ដែលក្រុមបុត្រសម្ព័ន្ធនិងក្រុមហ៊ុននឹងត្រូវបង់លើប្រាក់កម្ចីក្នុងរយៈពេលស្រដៀងគ្នា ហើយមានការដាក់ប្រាក់តម្កល់ស្រដៀងគ្នាមូលនិធិ ' ដែលចាំបាច់ដើម្បីទទួលបានទ្រព្យសកម្មនៃតម្លៃស្រដៀងគ្នាទៅនឹងសិទ្ធិប្រើប្រាស់នៃទ្រព្យសកម្មក្នុងស្ថានភាពសេដ្ឋកិច្ចស្រដៀងគ្នា។ ក្រុមបុត្រសម្ព័ន្ធនិងក្រុមហ៊ុនបានប៉ាន់ស្មាន IBR ដោយប្រើអត្រាប្រាក់កម្ចីជាមធ្យមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ចំណាយពន្ធលើប្រាក់ចំណូល**
សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុននឹងទទួលស្គាល់បំណុលសម្រាប់ការចំណាយពន្ធដែលបានរំពឹងទុកដោយផ្អែកលើការបកស្រាយបច្ចុប្បន្នរបស់គណៈគ្រប់គ្រងតាមច្បាប់ពន្ធដារ។ ទោះយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងនេះអាចប្រែប្រួលតាមកាលកំណត់ ហើយការកំណត់ចុងក្រោយនៃការចំណាយពន្ធនឹងត្រូវធ្វើឡើងបន្ទាប់ពីការត្រួតពិនិត្យនិងស៊ើបអង្កេតដោយអគ្គនាយកដ្ឋានពន្ធដារ។

នៅពេលដែលលទ្ធផលពន្ធចុងក្រោយទាំងនេះមានភាពខុសគ្នាពីសមតុល្យដែលត្រូវបានទទួលស្គាល់ដំបូង ភាពខុសគ្នាបែបនេះនឹងអាចប៉ះពាល់ដល់ការធ្វើសំវិធានធនពន្ធក្នុងការិយបរិច្ឆេទដែលការកំណត់បែបនេះត្រូវបានធ្វើឡើង។

### ខ. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

**ការទទួលស្គាល់ចំណូលកិច្ចសន្យាសាងសង់**
ការទទួលស្គាល់កិច្ចសន្យាសាងសងតម្រូវឱ្យមានការវិនិច្ឆ័យសំខាន់ៗ ដើម្បីកំណត់នូវព្រឹត្តិការណ៍សំខាន់ៗ ការងារជាក់ស្តែងដែលបានអនុវត្ត និងថ្លៃដើមក្នុងការបញ្ចប់ការសាងសង់ដែលបានប៉ាន់ស្មានទុក។

## ៦. ការបន្តនិរន្តរភាព

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនត្រូវបានរៀបចំឡើងលើមូលដ្ឋានបន្តនិរន្តរភាពគឺអាស្រ័យទៅលើការបន្តការគាំទ្រពីក្រុមហ៊ុនមេ PESTECH International Berhad ជាក្រុមហ៊ុនដែលមានមូលដ្ឋានអាជីវកម្មនិងស្ថិតនៅក្នុងប្រទេសម៉ាឡេស៊ី។ ក្រុមហ៊ុនមេបានធានាបន្តការគាំទ្រផ្នែកហិរញ្ញវត្ថុដែលចាំបាច់ទៅដល់សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនក្នុងការទូទាត់បំណុលនៅពេលដែលដល់កាលកំណត់សង។

គណៈគ្រប់គ្រងជឿជាក់យ៉ាងមុតមាំថា សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន មានភាពសមស្របក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនទៅលើមូលដ្ឋានបន្តនិរន្តរភាពដែលបានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុពីក្រុមហ៊ុនមេ។ របាយការណ៍ហិរញ្ញវត្ថុ មិនរួមបញ្ចូលនូវរាល់ការកែតម្រូវដែលពាក់ព័ន្ធទៅនឹងលទ្ធភាពដែលអាចប្រមូលមកវិញបាននិងការធ្វើចំណាត់ថ្នាក់តម្លៃនៃទ្រព្យសកម្មដែលបានកត់ត្រា ឬទៅលើសមតុល្យ និងការធ្វើចំណាត់ថ្នាក់លើបំណុលដែលចាំបាច់ ប្រសិនបើមូលដ្ឋាននៃការបន្តនិរន្តរភាពក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន មានភាពមិនសមស្របនោះទេ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

៣០ មិថុនា ២០២២

## ៧. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន | បរិក្ខារ ពាន់ដុល្លារអាមេរិក | ម៉ូតូ យានយន្ត ពាន់ដុល្លារអាមេរិក | កុំព្យូទ័រ ពាន់ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ ពាន់ដុល្លារអាមេរិក | សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម ពាន់ដុល្លារអាមេរិក | ផ្លាកសញ្ញា ពាន់ដុល្លារអាមេរិក | ការកែលម្អឡើងវិញ ពាន់ដុល្លារអាមេរិក | សរុប ពាន់ដុល្លារអាមេរិក | សរុប លានរៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | | | |
| គិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ | ១៦ ៧៧៥ | ៥៥៩ | ៣២ | ៧៨ | ៣០៦ | ១៩ | ៥៩ | ១៧ ៨២៨ | ៧២ ៦៤៩ |
| ទិញបន្ថែម | ២១ | ២៥៣ | ៧ | ២១ | ៣៩០ | - | ១៧ | ៧០៩ | ២ ៨៨៦ |
| ការលុបចោលដោយសារការបញ្ចប់កិច្ចសន្យាភតិសន្យា | - | - | - | - | (២០៤) | - | - | (២០៤) | (៨៣០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | (៩០) |
| សមតុល្យថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | ១៦ ៧៩៦ | ៨១២ | ៣៩ | ៩៩ | ៤៩២ | ១៩ | ៧៦ | ១៨ ៣៣៣ | ៧៤ ៦១៥ |
| **រំលស់បង្គរ** | | | | | | | | | |
| គិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ | (៣ ០៦៤) | (៤៣៦) | (២៥) | (៣១) | (១២១) | (១) | - | (៣ ៦៧៨) | (១៤ ៩៨៨) |
| រំលស់ | (៨៨៥) | (៨៨) | (៥) | (១៤) | (១១២) | (២) | (៧) | (១ ១១៣) | (៤ ៥២៦) |
| ការលុបចោលដោយសារការបញ្ចប់កិច្ចសន្យាភតិសន្យា | - | - | - | - | ៦២ | - | - | ៦២ | ២៥២ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ១៥ |
| សមតុល្យថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | (៣ ៩៤៩) | (៥២៤) | (៣០) | (៤៥) | (១៧១) | (៣) | (៧) | (៤ ៧២៩) | (១៩ ២៤៧) |
| សមតុល្យយោងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | ១២ ៨៤៧ | ២៨៨ | ៩ | ៥៤ | ៣២១ | ១៦ | ៦៩ | ១៣ ៦០៤ | ៥៥ ៣៦៨ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

៣០ មិថុនា ២០២២

## ៧. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | បរិក្ខារ ពាន់ដុល្លារ អាមេរិក | ម៉ូតូ យានយន្ត ពាន់ដុល្លារ អាមេរិក | កុំព្យូទ័រពាន់ ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ ពាន់ដុល្លារ អាមេរិក | សិទ្ធិប្រើប្រាស់ លើទ្រព្យសកម្ម ពាន់ដុល្លារ អាមេរិក | ផ្លាកសញ្ញា ពាន់ដុល្លារ អាមេរិក | ការកែលម្អឡើងវិញ ពាន់ដុល្លារ អាមេរិក | សរុប ពាន់ដុល្លារ អាមេរិក | សរុប លានរៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|---|---|---|---|
| ថ្ងៃដើម | | | | | | | | | |
| គិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ | ១៧ ២៩២ | ៥៥៩ | ២៦ | ៣១ | ១៦២ | - | - | ១៨ ០៧០ | ៧៣ ៩៦១ |
| ទិញបន្ថែម | ៧១ | - | ៦ | ៤៧ | ២០៥ | ១៩ | ៥៩ | ៤០៧ | ១ ៦៥៧ |
| ផ្ទេរចេញ | (៥៨៨) | - | - | - | - | - | - | (៥៨៨) | (២ ៣៩៤) |
| កត់ត្រាបញ្ញោស | - | - | - | - | (៦១) | - | - | (៦១) | (២៤៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | (៣២៧) |
| សមតុល្យថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ | ១៦ ៧៥៥ | ៥៥៩ | ៣២ | ៧៨ | ៣០៦ | ១៩ | ៥៩ | ១៧ ៨២៨ | ៧២ ៦៤៩ |
| រំលស់បង្គរ | | | | | | | | | |
| គិតត្រឹមថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ | (២ ១៩៩) | (៣៤៨) | (២១) | (២៨) | (៧០) | - | - | (២ ៦៦៦) | (១០ ៩១២) |
| រំលស់កត់ត្រាបញ្ញោស | (៨៦៥) | (៨៨) | (៤) | (៣) | (៩៨) | (១) | - | (១ ០៥៩) | (៤ ៣១១) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | ៤៧ | - | - | ៤៧ | ១៩១ |
| | - | - | - | - | - | - | - | - | ៤៤ |
| សមតុល្យថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ | (៣ ០៦៤) | (៤៣៦) | (២៥) | (៣១) | (១៧១) | (១) | - | (៣ ៦៧៨) | (១៤ ៩៨៨) |
| សមតុល្យយោងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ | ១៣ ៧១១ | ១២៣ | ៧ | ៤៧ | ១៨៥ | ១៨ | ៥៩ | ១៤ ១៥០ | ៥៧ ៦៦១ |

## ៨. បំណុលភតិសន្យា

**សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនក្នុងនាមជាអ្នកជួល**
សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនមានកិច្ចសន្យាភតិសន្យាទៅលើទ្រព្យសម្បត្តិដែលបានប្រើប្រាស់ជាទីតាំងការិយាល័យនិងកន្លែងស្នាក់នៅសម្រាប់បុគ្គលិក និងឃ្លាំង។

បំណុលភតិសន្យាត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានដូចខាងក្រោម៖

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) |
| បំណុលរយៈពេលខ្លី | **១១៨** | ១៤ | **៤៨២** | ៥៨ |
| បំណុលរយៈពេលវែង | **២៣០** | ១៤៨ | **៩៣៤** | ៦០៣ |
| | **៣៤៨** | ១៦២ | **១,៤១៦** | ៦៦១ |

ការបង្ហាញខាងក្រោម គឺជាសមតុល្យយោងនៃបំណុលភតិសន្យា និងបម្រែបម្រួលក្នុងការិយបរិច្ឆេទ៖

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារអាមេរិក** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២)** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) |
| សមតុល្យនៅដើមការិយបរិច្ឆេទ | **១៦២** | ៩៥ | **៦៦១** | ៣៨៩ |
| ទិញបន្ថែម | **៣៩០** | ២០៥ | **១,៥៩១** | ៨៣៥ |
| ការកើនឡើងនៃការប្រាក់ | **២២** | ១៥ | **៩១** | ៦១ |
| ការបញ្ចប់ភតិសន្យា | **(១៥០)** | (១៤) | **(៦១៥)** | (៥៧) |
| ការទូទាត់សង | **(៧៦)** | (១៣៩) | **(៣០៩)** | (៥៦៦) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | **(៣)** | (១) |
| សមតុល្យនៅចុងការិយបរិច្ឆេទ | **៣៤៨** | ១៦២ | **១,៤១៦** | ៦៦១ |

អត្រាកម្ចីបន្ថែមជាមធ្យមត្រូវបានអនុវត្តចំពោះបំណុលភតិសន្យាដែលត្រូវបានទទួលស្គាល់តាមស្តង់ដារ CIFRS ១៦ មានអត្រា ៧,២% ក្នុងមួយឆ្នាំ។

តារាងខាងក្រោមនេះ ជាការពិពណ៌នាអំពីលក្ខណៈនៃភតិសន្យារបស់ក្រុមហ៊ុន និងសម្ព័ន្ធក្រុមហ៊ុនតាមប្រភេទនៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ៖

| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ចំនួនសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ចំណាត់ថ្នាក់នៃរយៈពេលជួលដែលនៅសល់ | រយៈពេលភតិសន្យាដែលនៅសល់ជាមធ្យម | ចំនួននៃការជួលជាមួយជម្រើសបន្ថែម | ចំនួននៃភតិសន្យាដែលមានជម្រើសបញ្ចប់ |
|---|---|---|---|---|---|
| ផ្ទះ | ៥ | ០.៥ ទៅ ២.១ ឆ្នាំ | ២.១ ឆ្នាំ | ១ | ៥ |
| អគារការិយាល័យ | ១ | ៣.២ ឆ្នាំ | ៣.២ ឆ្នាំ | ១ | ១ |
| ឃ្លាំង | ១ | ៣.៥ ឆ្នាំ | ៣.៥ ឆ្នាំ | - | ១ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ៨. បំណុលភតិសន្យា (ត)

ព័ត៌មានលម្អិតពីការទូទាត់បំណុលភតិសន្យាអប្បបរមានាពេលអនាគត ត្រូវបានសង្ខេបដូចខាងក្រោម៖

| | ការទូទាត់បំណុលភតិសន្យាអប្បបរមានៅជំពាក់ | | | | |
|---|---|---|---|---|---|
| | **ក្នុងអំឡុងពេល ១ឆ្នាំ ពាន់ដុល្លារអាមេរិក** | **ចាប់ពី១ឆ្នាំទៅ៣ឆ្នាំ ពាន់ដុល្លារអាមេរិក** | **ចាប់ពី៣ឆ្នាំទៅ៥ឆ្នាំ ពាន់ដុល្លារអាមេរិក** | **សរុប ពាន់ដុល្លារអាមេរិក** | **សរុប លានរៀល (សម្គាល់ ៤.២)** |
| **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២** | | | | | |
| **ការទូទាត់ភតិសន្យា** | ១៤០ | ២២៨ | ១៨ | ៣៨៦ | ១ ៥៧១ |
| **បន្ទុកហិរញ្ញវត្ថុ** | (២២) | (១៦) | - | (៣៨) | (១៥៥) |
| **តម្លៃបច្ចុប្បន្នសុទ្ធ** | ១១៨ | ២១២ | ១៨ | ៣៤៨ | ១,៤១៦ |
| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ | | | | | |
| ការទូទាត់ភតិសន្យា | ១៥ | ២៥ | ១៥៧ | ១៩៧ | ៨០៤ |
| បន្ទុកហិរញ្ញវត្ថុ | (១) | (២២) | (១២) | (៣៥) | (១៤៣) |
| តម្លៃបច្ចុប្បន្នសុទ្ធ | ១៤ | ៣ | ១៤៥ | ១៦២ | ៦៦១ |

## ៩. ការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

| | ក្រុមហ៊ុន | | | |
|---|---|---|---|---|
| | ៣០ មិថុនា ២០២២ **ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ **ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២២ លានរៀល **(សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល **(សម្គាល់ ៤.២)** |
| ថ្លៃដើម-សន្លឹកហ៊ុនដែលមិនបានដាក់តម្លៃ | | | | |
| សមតុល្យយោងពីការិយបរិច្ឆេទចាស់ | ៥០ | ៣៥ | ២០៤ | ១៤៣ |
| ភាគហ៊ុនបន្ថែម | - | ១៥ | - | ៦១ |
| | ៥០ | ៥០ | ២០៤ | ២០៤ |

ព័ត៌មានលម្អិតនៃក្រុមហ៊ុនបុត្រសម្ព័ន្ធមានដូចខាងក្រោម៖

| ឈ្មោះ | ប្រទេសនៃសហប្រតិបត្តិការ និងប្រតិបត្តិការ | ការប្រាក់មានប្រសិទ្ធភាព% **៣០ មិថុនា ២០២២** | ៣០ មិថុនា ២០២១ | សកម្មភាពសំខាន់ៗ |
|---|---|---|---|---|
| PESTECH (Myanmar) Limited ("PML") | មីយ៉ាន់ម៉ា | **១០០.០០%** | ១០០.០០% | ការផ្តល់ការគ្រប់គ្រងគម្រោង ការសាងសង់អនុស្ថានីយអគ្គិសនី បណ្តាញបញ្ជូន និងដំឡើង ការត្រួតពិនិត្យលើការធ្វើតេស្តនិងការងារស៊ីវិល។ |
| **បុត្រសម្ព័ន្ធនៃ PML** PESTECH Hinthar Corporation Limited ("PHC") | មីយ៉ាន់ម៉ា | ៦០.០០% | ៦០.០០% | បង្កើតហេដ្ឋារចនាសម្ព័ន្ធក្នុងឧស្សាហកម្មថាមពល និងលើកកម្ពស់ការផលិតថាមពល ដូចជា ការបង្កើតថាមពល ការបញ្ជូនថាមពល ការចែកចាយថាមពល ប្រព័ន្ធ microgrid និងហេដ្ឋារចនាសម្ព័ន្ធថាពលផ្សេងទៀតទៅកាន់តំបន់ដាច់ស្រយាលនៃប្រទេសមីយ៉ាន់ម៉ា។ |
| **បុត្រសម្ព័ន្ធនៃ PHC** PESTECH Microgrid Company Limited | មីយ៉ាន់ម៉ា | ៥៤.០០% | ៥៤.០០% | ផ្តល់ប្រព័ន្ធ microgrid និងឥទ្ធិពលនៃហេដ្ឋារចនាសម្ព័ន្ធទៅដល់តំបន់ដាច់ស្រយាលនៃប្រទេសមីយ៉ាន់ម៉ា។. |

## ១០. ទ្រព្យសកម្មកិច្ចសន្យា/បំណុល

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | ៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | ៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២) | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| សមតុល្យនៅដើមការិយបរិច្ឆេទ | ២៤៥ ០១៨ | ២១៦ ៩៨៩ | ៩៩៨ ៤៤៩ | ៨៨៨ ១៣៦ |
| ចំណូលបានទទួលស្គាល់ | ៥៣ ២០២ | ៦៧ ២១៤ | ២១៦ ៣៥៥ | ២៧៣ ៦២៨ |
| វិក្កយបត្របានចេញ | (៣៥ ៩៨៥) | (៤០ ២៣៣) | (១៤៦ ៣៣៩) | (១៦៣ ៧៨៩) |
| ចំណូលហិរញ្ញវត្ថុដែលបានទទួលស្គាល់ | ២ ៨១៥ | ១ ០៤៨ | ១១ ៤៤៨ | ៤ ២៦៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (១ ១៥៩) | (៣ ៧៩២) |
| សមតុល្យនៅចុងការិយបរិច្ឆេទ | ២៦៥ ០៥០ | ២៤៥ ០១៨ | ១ ០៧៨ ៧៥៤ | ៩៩៨ ៤៤៩ |
| បានបង្ហាញជា៖ | | | | |
| រយៈពេលខ្លី | ១៥៥ ៩៥០ | ១២២ ៨៥១ | ៦៣៤ ៧១៧ | ៥០០ ៦១៨ |
| រយៈពេលវែង | ១០៩ ២៦២ | ១២២ ១៦៧ | ៤៤៤ ៦៩៦ | ៤៩៧ ៨៣១ |
| | ២៦៥ ២១២ | ២៤៥ ០១៨ | ១ ០៧៩ ៤១៣ | ៩៩៨ ៤៤៩ |
| បំណុលកិច្ចសន្យារយៈពេលខ្លី | (១៦២) | - | (៦៥៩) | - |
| | ២៦៥ ០៥០ | ២៤៥ ០១៨ | ១ ០៧៨ ៧៥៤ | ៩៩៨ ៤៤៩ |

ទ្រព្យសកម្មកិច្ចសន្យា តំណាងឱ្យសិទ្ធិរបស់សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុន ដើម្បីពិចារណាលើការងារដែលបានបញ្ចប់តាមកិច្ចសន្យាសាងសង់ ប៉ុន្តែមិនទាន់បានចេញវិក្កយបត្រនៅកាលបរិច្ឆេទនៃរបាយការណ៍នោះទេ។ សមតុល្យនឹងត្រូវចេញវិក្កយបត្រតាមកាលវិភាគនៃការចេញវិក្កយបត្រដូចដែលបានចែងនៅក្នុងកិច្ចសន្យាសាងសង់។

បំណុលកិច្ចសន្យាត្រូវបានទទួលស្គាល់ ប្រសិនបើវិក្កយបត្របានដាក់ជូនទៅអតិថិជនមុនពេលដែលសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនទទួលបានសិទ្ធិក្នុងការទទួលបានតម្លៃតបស្នងនៅពេលការងារបានបញ្ចប់។

## ១១. សន្និធិ

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | ៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | ៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២) | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| វត្ថុធាតុដើមនៃការសាងសង់ | ៣ ៣៣៨ | ៣ ៥០៨ | ១៣ ៥៨៦ | ១៤ ២៩៥ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ១២. គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ

| | សម្ព័ន្ធក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| គណនីអតិថិជនត្រូវទទួល | **១ ៣៧៥** | ២ ៩៥០ | **៥ ៥៩៦** | ១២ ០២១ |
| ប្រាក់បញ្ញើ | **៣៧** | ២៤១ | **១៥១** | ៩៨៤ |
| បុរេប្រទានបុគ្គលិក | **៣៧** | ៣០ | **១៥១** | ១២២ |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | **១ ៤៤៩** | ៣ ២២១ | **៥ ៨៩៨** | ១៣ ១២៧ |
| ចំណាយបង់មុន | **១ ៤៣៤** | ២ ១៤៦ | **៥ ៨៣៦** | ៨ ៧៤៥ |
| អាករលើតម្លៃបន្ថែម | **២៥៩** | ១ ១៣៦ | **១ ០៥៤** | ៤ ៦២៩ |
| ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ | **១ ៦៩៣** | ៣ ២៨២ | **៦ ៨៩០** | ១៣ ៣៧៤ |
| | **៣ ១៤២** | ៦ ៥០៣ | **១២ ៧៨៨** | ២៦ ៥០១ |

| | សម្ព័ន្ធក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| គណនីអតិថិជនត្រូវទទួល | **១ ៣៧៥** | ២ ៩៥០ | **៥ ៥៩៦** | ១២ ០២១ |
| ប្រាក់បញ្ញើ | **៣៧** | ២៣៥ | **១៥១** | ៩៥៨ |
| បុរេប្រទានបុគ្គលិក | **៣៧** | ៣០ | **១៥១** | ១២២ |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | **១ ៤៤៩** | ៣ ២១៥ | **៥ ៨៩៨** | ១៣ ១០១ |
| ចំណាយបង់មុន | **១ ៤៣៤** | ២ ១៤៦ | **៥ ៨៣៦** | ៨ ៧៤៥ |
| អាករលើតម្លៃបន្ថែម | **២៥៩** | ១ ១៣៦ | **១ ០៥៤** | ៤ ៦២៩ |
| ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ | **១ ៦៩៣** | ៣ ២៨២ | **៦ ៨៩០** | ១៣ ៣៧៤ |
| | **៣ ១៤២** | ៦ ៤៩៧ | **១២ ៧៨៨** | ២៦ ៤៧៥ |

## ១៣. សាច់ប្រាក់ និងសមតុល្យធនាគារ

| | សម្ព័ន្ធក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| សាច់ប្រាក់ក្នុងធនាគារ (ក) | **៨ ០៩១** | ១៥ ៧៥៣ | **៣២ ៩៣០** | ៦៤ ១៩៤ |
| ប្រាក់បញ្ញើជាមួយធនាគារមានអាជ្ញាប័ណ្ណ (ខ)) | **១ ៧៦៦** | ១ ៤០៤ | **៧ ១៨៨** | ៥ ៧២១ |
| សាច់ប្រាក់ក្នុងដៃ | **១៥** | ១០ | **៦១** | ៤១ |
| | **៩ ៨៧២** | ១៧ ១៦៧ | **៤០ ១៧៩** | ៦៩ ៩៥៦ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ១៣. សាច់ប្រាក់ និងសមតុល្យធនាគារ (ត)

| | **ក្រុមហ៊ុន** | | | |
|---|---|---|---|---|
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| សាច់ប្រាក់ក្នុងធនាគារ (ក) | **៨ ០៨៥** | ១៥ ៧៤១ | **៣២ ៩០៦** | ៦៤ ១៤៥ |
| ប្រាក់បញ្ញើជាមួយធនាគារមានអាជ្ញាប័ណ្ណ (ខ) | **១ ៧៦៦** | ១ ៤០៤ | **៧ ១៨៨** | ៥ ៧២១ |
| សាច់ប្រាក់ក្នុងដៃ | **១៥** | ៩ | **៦១** | ៣៧ |
| | **៩ ៨៦៦** | ១៧ ១៥៤ | **៤០ ១៥៥** | ៦៩ ៩០៣ |

(ក) គណនីធនាគារចំនួនពីរ ត្រូវបានដាក់ជាទ្រព្យធានាក្នុងការទទួលឥណទានហិរញ្ញវត្ថុ ហើយគណនីធនាគារមួយក្នុងចំណោមគណនីធនាគារទាំងនេះ ត្រូវបានដាក់ទ្រព្យធានាចំពោះគណនីឥណទានវិបារូបន៍ ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ ១៨ (គ.៥) និងកំណត់សម្គាល់ ១៨ (ក.៣)។

(ខ) ប្រាក់បញ្ញើរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ជាមួយធនាគារដែលមានអាជ្ញាប័ណ្ណ ត្រូវបានដាក់ធានាជាទ្រព្យបញ្ចាំសម្រាប់ឥណទានវិបារូបន៍ ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ ១៨ (ក.២) និង ១៨ (គ.៦)។ ប្រាក់បញ្ញើនេះ បានទទួលការប្រាក់តាមអត្រា ៤,២៥% ក្នុងមួយឆ្នាំ។

សម្រាប់គោលបំណងក្នុងការបង្ហាញរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលមានដូចខាងក្រោម៖

| | **សម្ព័ន្ធក្រុមហ៊ុន** | | | |
|---|---|---|---|---|
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល (ដូចខាងលើ) | **៩ ៨៧២** | ១៧ ១៦៧ | **៤០ ១៧៩** | ៦៩ ៩៥៦ |
| ឥណទានវិបារូបន៍ (កំណត់សម្គាល់ ១៨) | **(៧ ៧០១)** | (២ ៥២១) | **(៣១ ៣៤៥)** | (១០ ២៧៣) |
| ប្រាក់បញ្ញើមានកាលកំណត់សម្រាប់ធានាប្រាក់កម្ចី | **(១ ៧៦៦)** | (១ ៤០៤) | **(៧ ១៨៨)** | (៥ ៧២១) |
| សាច់ប្រាក់ក្នុងធនាគារបញ្ចាំសម្រាប់ប្រាក់កម្ចី | **(៦ ៦៤៣)** | (៦ ៦៤៣) | **(២៧ ០៣៨)** | (២៧ ០៧០) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលក្នុងរបាយការណ៍លំហូរសាច់ប្រាក់ | **(៦ ២៣៨)** | ៦ ៥៩៩ | **(២៥ ៣៩២)** | ២៦ ៨៩២ |

| | **ក្រុមហ៊ុន** | | | |
|---|---|---|---|---|
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| សាច់ប្រាក់និងសាច់ប្រាក់សមមូល (ដូចខាងលើ) | **៩ ៨៦៦** | ១៧ ១៥៤ | **៤០ ១៥៥** | ៦៩ ៩០៣ |
| ឥណទានវិបារូបន៍ (កំណត់សម្គាល់ ១៨) | **(៧ ៧០១)** | (២ ៥២១) | **(៣១ ៣៤៥)** | (១០ ២៧៣) |
| ប្រាក់បញ្ញើមានកាលកំណត់សម្រាប់ធានាប្រាក់កម្ចី | **(១ ៧៦៦)** | (១ ៤០៤) | **(៧ ១៨៨)** | (៥ ៧២១) |
| សាច់ប្រាក់ក្នុងធនាគារបញ្ចាំសម្រាប់ប្រាក់កម្ចី | **(៦ ៦៤៣)** | (៦ ៦៤៣) | **(២៧ ០៣៨)** | (២៧ ០៧០) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលក្នុងរបាយការណ៍លំហូរសាច់ប្រាក់ | **(៦ ២៤៤)** | ៦ ៥៨៦ | **(២៥ ៤១៦)** | ២៦ ៨៣៩ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ១៤. ដើមទុន

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | | | |
|---|---|---|---|---|---|---|
| | ចំនួនភាគហ៊ុន | | សមតុល្យ | | | |
| | ៣០ មិថុនា ២០២២ | ៣០ មិថុនា ២០២១ | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| ភាគហ៊ុនដែលបានចេញផ្សាយ និងទូទាត់រួចរាល់៖ | | | | | | |
| -ដើមការិយបរិច្ឆេទ | **៧៤ ៩៤៥ ០០០** | ៧១ ០០០ ០០០ | **៧ ៤៩៤** | ៧ ១០០ | **៣០ ៧២៥** | ២៨ ៨៦៩ |
| -ភាគហ៊ុនបានចេញផ្សាយ | - | ៣ ៩៤៥ ០០០ | - | ៣៩៤ | - | ១ ៨៥៦ |
| ចុងដើមការិយបរិច្ឆេទ | **៧៤ ៩៤៥ ៥០០** | ៧៤ ៩៤៥ ៥០០ | **៧ ៤៩៤** | ៧ ៤៩៤ | **៣០ ៧២៥** | ៣០ ៧២៥ |

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ក្រុមហ៊ុនជោគជ័យក្នុងការចុះបញ្ជីនៅលើទីផ្សារមូលបត្រកម្ពុជា ("ផ.ម.ក")។ ភាគហ៊ុនថ្មីត្រូវបានបោះផ្សាយចំនួន ៣.៩៤៥.០០០ ភាគហ៊ុនក្នុងតម្លៃចារឹក ៤០០ រៀល ឬ០,១០ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន នៅក្នុងតម្លៃបោះផ្សាយ ៣.១២០ រៀល ឬ ០,៧៦ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន។

## ១៥. ដើមទុនបុព្វលាភ

ដើមទុនបុព្វលាភ តំណាងឱ្យសមតុល្យលើសដែលទទួលបានពីក្រុមហ៊ុន លើតម្លៃចារឹកនៃភាគហ៊ុនរបស់ខ្លួន ដោយអនុលោមតាមការចេញផ្សាយភាគហ៊ុនដកចេញនូវថ្លៃដើមផ្ទាល់នៃប្រតិបត្តិការដែលអាចបែងចែកបាននៅក្នុងការបោះផ្សាយភាគហ៊ុន។

## ១៦. ទុនបម្រុង

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| ទុនបម្រុងដើមទុន | **៥២** | ៥២ | **២១២** | ២១២ |
| ទុនបម្រុងលើលំហូរសាច់ប្រាក់ | **(៤៥២)** | (៤ ២៣១) | **(១ ៨៣៨)** | (១៧ ៦០៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | **(២៥៧)** | (៣៩) |
| | **(៤០០)** | (៤ ២៦៩) | **(១ ៨៨៣)** | (១៧ ៤៣៥) |

ដើមទុនបម្រុងទុក តំណាងឱ្យតម្លៃទីផ្សារសមស្របដែលបានផ្តល់ជម្រើសដើមទុន ក្នុងការទូទាត់ មូលធនទៅឱ្យនិយោជិតនៅក្នុងក្រុមហ៊ុនដែលផ្តល់ដោយក្រុមហ៊ុនមេនៅក្នុងខែតុលា ឆ្នាំ២០១៧។ ដើមទុនបម្រុងទុក គឺត្រូវបានបង្កើតឡើងដោយតម្លៃបង្គរទុកនៃការទទួលសេវាកម្មពីនិយោជិតដែលបានកត់ត្រាតាមរយៈពេលដែលមានសិទ្ធិ គិតចាប់ពីថ្ងៃដែលទទួលបានជម្រើសដើមទុន ក្នុងការទូទាត់ មូលធន និងត្រូវបានកាត់បន្ថយដោយផ្អែកទៅលើជម្រើសដើមទុន ឬការទូទាត់ទៅឱ្យក្រុមហ៊ុនមេ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ១៧. គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ

**សម្ព័ន្ធក្រុមហ៊ុន**

| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|
| សំវិធានធនសម្រាប់ថ្លៃដើមគម្រោង | **៤៤ ១៤១** | ៣១ ៦១៥ | **១៧៩ ៦៥៤** | ១២៨ ៨៣១ |
| គណនីអ្នកផ្គត់ផ្គង់ត្រូវបង់ | **១ ៧៨០** | ៨៩២ | **៧ ២៤៥** | ៣ ៦៣៥ |
| គណនីបង្គរ | **៨០២** | ៧៣០ | **៣ ២៦២** | ២ ៩៧៥ |
| គណនីត្រូវបង់ផ្សេងៗ | **១៦០** | ៣៤ | **៦៥០** | ១៣៩ |
| **បំណុលហិរញ្ញវត្ថុ** | **៤៦ ៨៨៣** | ៣៣ ២៧១ | **១៩០ ៨១១** | ១៣៥ ៥៨០ |
| ពន្ធត្រូវបង់ | **១១៤** | ១២៥ | **៤៦៤** | ៥០៩ |
| **បំណុលមិនមែនហិរញ្ញវត្ថុ** | **១១៤** | ១២៥ | **៤៦៤** | ៥០៩ |
| | **៤៦ ៩៩៧** | ៣៣ ៣៩៦ | **១៩១ ២៧៥** | ១៣៦ ០៨៩ |

**ក្រុមហ៊ុន**

| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|
| សំវិធានធនសម្រាប់ថ្លៃដើមគម្រោង | **៤៤ ១៤១** | ៣១ ៦១៥ | **១៧៩ ៦៥៤** | ១២៨ ៨៣១ |
| គណនីអ្នកផ្គត់ផ្គង់ត្រូវបង់ | **១ ៧៨០** | ៨៩២ | **៧ ២៤៥** | ៣ ៦៣៥ |
| គណនីបង្គរ | **៨០២** | ៧២១ | **៣ ២៦៤** | ២ ៩៣៨ |
| គណនីត្រូវបង់ផ្សេងៗ | **១៥៥** | ២៩ | **៦៣០** | ១១៩ |
| **បំណុលហិរញ្ញវត្ថុ** | **៤៦ ៨៧៨** | ៣៣ ២៥៧ | **១៩០ ៧៩៣** | ១៣៥ ៥២៣ |
| ពន្ធត្រូវបង់ | **១១៤** | ១២៥ | **៤៦៤** | ៥០៩ |
| **បំណុលមិនមែនហិរញ្ញវត្ថុ** | **១១៤** | ១២៥ | **៤៦៤** | ៥០៩ |
| | **៤៦ ៩៩២** | ៣៣ ៣៨២ | **១៩១ ២៥៧** | ១៣៦ ០៣២ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

៣០ មិថុនា ២០២២

## ១៨. ប្រាក់កម្ចី

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| **ប្រាក់កម្ចីរយៈពេលខ្លី** | | | | |
| មានទ្រព្យធានា៖ | | | | |
| ឥណទានវិបារូបន៍ | **៧ ៧០១** | ២ ៥២១ | **៣១ ៣៤៥** | ១០ ២៧៣ |
| ឥណទានបង្វិល | **៣ ០៨០** | ២ ៥២៣ | **១២ ៥៣៦** | ១០ ២៨១ |
| ឥណទានមានកាលកំណត់ | **៩ ៥០០** | ៨ ៥០០ | **៣៨ ៦៦៣** | ៣៤ ៦៣៨ |
| **ប្រាក់កម្ចីរយៈពេលខ្លីសរុប** | **២០ ២៨១** | ១៣ ៥៤៤ | **៨២ ៥៤៤** | ៥៥ ១៩២ |
| **ប្រាក់កម្ចីរយៈពេលវែង** | | | | |
| មានទ្រព្យធានា៖ | | | | |
| ឥណទានមានកាលកំណត់ | **៨២ ០៧១** | ៩១ ៥៧៥ | **៣៣៤ ០២៩** | ៣៧៣ ១៦៨ |
| **ប្រាក់កម្ចីរយៈពេលវែងសរុប** | **៨២ ០៧១** | ៩១ ៥៧៥ | **៣៣៤ ០២៩** | ៣៧៣ ១៦៨ |
| | **១០២ ៣៥២** | ១០៥ ១១៩ | **៤១៦ ៥៧៣** | ៤២៨ ៣៦០ |

សមាសធាតុកម្ចីខាងលើ គឺមានទ្រព្យធានាដូចបង្ហាញខាងក្រោម៖

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | |
|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ % | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ % |
| ឥណទានវិបារូបន៍ (ក) | ៧.០ ទៅ ៨.៥ | ៧.៥ ទៅ ៨.៥ |
| ឥណទានបង្វិល (ខ) | ៧.២ | ៧.២ |
| ឥណទានមានកាលកំណត់ (គ) | ៤.៩ ទៅ ៧.៥ | ៤.១ ទៅ ៧.៥ |

The above facilities are secured by the following:

ឥណទានវិបារូបន៍

ក.១ សមាសធាតុកម្ចីដែលផ្តល់ឱ្យក្រុមហ៊ុនក្រោមលិខិតផ្តល់ជូន។

ក.២ ប្រាក់បញ្ញើរបស់ក្រុមហ៊ុន ជាមួយធនាគារដែលមានអាជ្ញាប័ណ្ណដូចដែលបានបង្ហាញនៅក្នុងសម្គាល់១៣។

ក.៣ ការដាក់បញ្ចាំគណនីធនាគារ។

ក.៤ ការធានាអាជីវកម្មពីសំណាក់ក្រុមហ៊ុនមេ PESTECH International Berhad។

ឥណទានបង្វិល

ខ.១ ការធានាអាជីវកម្មរបស់ក្រុមហ៊ុនពីសំណាក់ក្រុមហ៊ុនមេ គឺក្រុមហ៊ុន PESTECH International Berhad ។

ឥណទានមានកាលកំណត់

គ.១ សិទ្ធិចាត់តាំង និងអត្ថប្រយោជន៍នានានៃឯកសារគម្រោងដែលមានរវាងក្រុមហ៊ុន និងអតិថិជន

គ.២ ការធានាអាជីវកម្មក្រុមហ៊ុនពីសំណាក់ក្រុមហ៊ុនមេ PESTECH International Berhad

គ.៣ ធានារ៉ាប់រងទៅលើគម្រោង

គ.៤ ផ្តល់សិទ្ធិជាក់លាក់មួយចំនួនទៅឱ្យក្រុមហ៊ុនតាមរយៈកិច្ចព្រមព្រៀងផ្ទាល់ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលបានចុះកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន និងអតិថិជន

គ.៥ ការដាក់បញ្ចាំគណនីធនាគារ

គ.៦ ការដាក់ប្រាក់បញ្ញើរបស់ក្រុមហ៊ុនជាមួយធនាគារដែលមានអាជ្ញាប័ណ្ណ ដូចបានបង្ហាញក្នុងកំណត់សម្គាល់ ១៣។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ១៩. ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | | | |
|---|---|---|---|---|---|---|
| | ៣០ មិថុនា ២០២២ | ៣០ មិថុនា ២០២១ | ៣០ មិថុនា ២០២២ | ៣០ មិថុនា ២០២១ | ៣០ មិថុនា ២០២២ | ៣០ មិថុនា ២០២១ |
| | **តម្លៃជាតិ** | | **បំណុលតម្លៃសមស្រប** | | | |
| | **ពាន់ដុល្លារអាមេរិក** | ពាន់ដុល្លារអាមេរិក | **ពាន់ដុល្លារអាមេរិក** | **ពាន់ដុល្លារអាមេរិក** | លានរៀល (សម្គាល់ ៤.២) | លានរៀល (សម្គាល់ ៤.២) |
| ការដោះដូរអត្រាការប្រាក់ | ៤២ ១០០ | ៤៧ ២៥០ | ៤៥២ | ៤ ៣២១ | ១ ៨៣៨ | ១៧ ៦០៨ |

នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ និងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ សម្ព័ន្ធក្រុមហ៊ុនបានចុះកិច្ចសន្យាដោះដូរអត្រាការប្រាក់ ("IRS") ដើម្បីការពារហានិភ័យរបស់សម្ព័ន្ធក្រុមហ៊ុនពីហានិភ័យអត្រាការប្រាក់ទៅលើប្រាក់កម្ចីរបស់ខ្លួន។ IRS ផ្តល់សិទ្ធិឱ្យសម្ព័ន្ធក្រុមហ៊ុនទទួលបានការប្រាក់តាមអត្រាទីផ្សារលើសមតុល្យដែលបានកំណត់និងកាតព្វកិច្ចរបស់សម្ព័ន្ធក្រុមហ៊ុនបង់ការប្រាក់តាមអត្រាការប្រាក់ថេរតាមសមតុល្យដែលបានកំណត់ដែលអនុញ្ញាតឱ្យសម្ព័ន្ធក្រុមហ៊ុនបង្កើនប្រាក់កម្ចីតាមអត្រាអណ្តែតហើយប្តូរទៅជាអត្រាការប្រាក់ថេរ។

ការដោះដូរតម្លៃទីផ្សារនៃ IRS ដែលត្រូវបានគេកំណត់ថាជាការការពារហានិភ័យរួមបញ្ចូលទាំងការការពារហានិភ័យក្នុងដើមទុនបម្រុង និងត្រូវបានចេញផ្សាយជាបន្តបន្ទាប់ទៅជាចំណូលពេញលេញរហូតដល់ការសងប្រាក់កម្ចីឬថ្ងៃកំណត់សងនៃ IRS ណាមួយដែលលឿនជាង។ សម្រាប់ IRS ដែលមិនត្រូវបានគេកំណត់ថាជាការការពារហានិភ័យការផ្លាស់ប្តូរតម្លៃសមរម្យត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាត។

## ២០. ចំណូល

| | **សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន** | | | |
|---|---|---|---|---|
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| កិច្ចសន្យាសាងសង់ និងការផ្តល់សេវាកម្ម | **៥៣ ២០២** | ៦៧ ២១៤ | **២១៦ ៣៥៥** | ២៧៣ ៦២៨ |

### ២០.១ ព័ត៌មានទៅលើចំណូលដែលបានបែងចែក

| | **សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន** | | | |
|---|---|---|---|---|
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| រយៈពេលនៃការទទួលស្គាល់ចំណូល៖ តាមអំឡុងពេល | ៥៣ ២០២ | ៦៧ ២១៤ | ២១៦ ៣៥៥ | ២៧៣ ៦២៨ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ២១. ចំណាយប្រតិបត្តិការ

| | សម្ព័ន្ធក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ** | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | |
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| ថ្លៃដើមផ្ទាល់ | | | | |
| វត្ថុធាតុដើម និងសម្ភារប្រើប្រាស់ | **៤០ ១៧០** | ៥២ ៦១១ | **១៦៣ ៣៥៨** | ២១៤ ១៧៩ |
| ចំណាយបន្ទាប់បន្សំ | **២ ៤៧៦** | ២ ៥៣៨ | **១០ ០៦៩** | ១០ ៣៣២ |
| | **៤២ ៦៤៦** | ៥៥ ១៤៩ | **១៧៣ ៤២៧** | ២២៤ ៥១១ |
| អត្ថប្រយោជន៍បុគ្គលិក | | | | |
| ប្រាក់បៀវត្ស ប្រាក់ម៉ោង បុព្វលាភ និង ប្រាក់ឧបត្ថម្ភផ្សេងៗ | **១ ៥២៧** | ១ ២៩៥ | **៦ ២១០** | ៥ ២៧២ |
| លាភការរបស់អភិបាល | **៤៦៨** | ៣៩៤ | **១ ៩០៣** | ១ ៦០៤ |
| រំលស់ទ្រព្យសកម្មអរូបិយ | | | | |
| ទ្រព្យសកម្មអរូបិយ | **៤** | ៣ | **១៦** | ១២ |
| រំលស់ទ្រព្យសកម្មរូបិយ | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | **១ ០០១** | ៩៦១ | **៤ ០៧១** | ៣ ៩១២ |
| សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម | **១១២** | ៩៨ | **៤៥៥** | ៣៩៩ |
| | **១ ១១៣** | ១ ០៥៩ | **៤ ៥២៦** | ៤ ៣១១ |
| ចំណាយទូទៅ | | | | |
| ពន្ធកាត់ទុក | **៨៦១** | ៧៣២ | **៣ ៥០១** | ២ ៩៨០ |
| សេវាគ្រប់គ្រង | **៤** | ៥៦៥ | **១៦** | ២ ៣០០ |
| សេវាវិជ្ជាជីវៈ | **២១២** | ១៥១ | **៨៦២** | ៦១៥ |
| សេវាធនាគារ | **២០១** | ៦៩ | **៨១៧** | ២៨១ |
| ចំណាយផ្សេងៗ | **៦២៣** | ៣២៣ | **២ ៥៣៤** | ១ ៣១៥ |
| | **១ ៩០១** | ១ ៨៤០ | **៧ ៧៣០** | ៧ ៤៩១ |
| | **៤៧ ៦៥៩** | ៥៩ ៧៤០ | **១៩៣ ៨១២** | ២៤៣ ២០១ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ២១. ចំណាយប្រតិបត្តិការ (ត)

| | **ក្រុមហ៊ុន** | | | |
|---|---|---|---|---|
| | **សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ** | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | |
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| ថ្លៃដើមផ្ទាល់ | | | | |
| វត្ថុធាតុដើម និងសម្ភារប្រើប្រាស់ | **៤០ ១៧០** | ៥២ ៦១១ | **១៦៣ ៣៥៨** | ២១៤ ១៧៩ |
| ចំណាយបន្ទាប់បន្សំ | **២ ៤៧៦** | ២ ៥៣៨ | **១០ ០៦៩** | ១០ ៣៣២ |
| | **៤២ ៦៤៦** | ៥៥ ១៤៩ | **១៧៣ ៤២៧** | ២២៤ ៥១១ |
| អត្ថប្រយោជន៍បុគ្គលិក | | | | |
| ប្រាក់បៀវត្ស ប្រាក់ម៉ោង បុព្វលាភ និងប្រាក់ឧបត្ថម្ភផ្សេងៗ | **១ ៥២៤** | ១ ២៧៣ | **៦ ១៩៨** | ៥ ១៨៣ |
| លាភការរបស់អភិបាល | **៤៦៨** | ៣៩៤ | **១ ៩០៣** | ១ ៦០៤ |
| រំលស់ទ្រព្យសកម្មអរូបិយ | | | | |
| ទ្រព្យសកម្មអរូបិយ | **៤** | ៣ | **១៦** | ១២ |
| រំលស់ទ្រព្យសកម្មរូបិយ | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | **១ ០០១** | ៩៦១ | **៤ ០៧១** | ៣ ៩១២ |
| សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម | **១១២** | ៩៨ | **៤៥៥** | ៣៩៩ |
| | **១ ១១៣** | ១ ០៥៩ | **៤ ៥២៦** | ៤ ៣១១ |
| ចំណាយទូទៅ | | | | |
| ពន្ធកាត់ទុក | **៨៦១** | ៧៣២ | **៣ ៥០១** | ២ ៩៨១ |
| សេវាគ្រប់គ្រង | **៤** | ៥៦៥ | **១៦** | ២ ៣០០ |
| សេវាវិជ្ជាជីវៈ | **២០៦** | ១៤៧ | **៨៣៨** | ៥៩៨ |
| សេវាធនាគារ | **២០១** | ៦៨ | **៨១៧** | ២៧៧ |
| ចំណាយផ្សេងៗ | **៦១១** | ២៧១ | **២ ៤៨៥** | ១ ១០៣ |
| | **១ ៨៨៣** | ១ ៧៨៣ | **៧ ៦៥៧** | ៧ ២៥៩ |
| | **៤៧ ៦៣៨** | ៥៩ ៦៦១ | **១៩៣ ៧២៧** | ២៤២ ៨៨០ |

## ២២. ចំណូលប្រតិបត្តិការផ្សេងៗ

| | **សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន** | | | |
|---|---|---|---|---|
| | **សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ** | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | |
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| សេវាគ្រប់គ្រងទៅលើភាគីពាក់ព័ន្ធ | **៤៨** | - | **១៩៥** | - |
| សេវាគ្រប់គ្រងគម្រោងទៅភាគីពាក់ព័ន្ធផ្សេងៗ | **១៧** | ១៤២ | **៦៩** | ៥៧៨ |
| ផ្សេងៗ | **-** | ២ | **-** | ៨ |
| | **៦៥** | ១៤៤ | **២៦៤** | ៥៨៦ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ២៣. ចំណូលហិរញ្ញវត្ថុ

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ** | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | |
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| ចំណូលការប្រាក់សម្រាប់៖ | | | | |
| ទ្រព្យសកម្មកិច្ចសន្យា | **២ ៨១៥** | ១ ០៤៨ | **១១ ៤៤៨** | ៤ ២៦៦ |
| ប្រាក់បញ្ញើមានកាលកំណត់ | **៥៩** | ៥០ | **២៤០** | ២០៤ |
| | **២ ៨៧៤** | ១ ០៩៨ | **១១ ៦៨៨** | ៤ ៤៧០ |

## ២៤. ចំណាយហិរញ្ញវត្ថុ

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ** | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | |
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| ចំណូលការប្រាក់សម្រាប់៖ | | | | |
| ឥណទានមានកាលកំណត់ | **៥ ០៦៨** | ៥ ៤៩៣ | **២០ ៦០៨** | ២២ ៣៦២ |
| ចំណាយកាត់កងដោយក្រុមហ៊ុនពាក់ព័ន្ធ | **១ ៦៣១** | ៤១៣ | **៦ ៦៣៣** | ១ ៦៨១ |
| ឥណទានវិបារូបន៍ | **២០៥** | ១៨៧ | **៨៣៤** | ៧៦១ |
| ឥណទានបង្វិល | **២១៩** | ១៣៥ | **៨៩១** | ៥៥០ |
| បំណុលភតិសន្យា | **២២** | ១៥ | **៩១** | ៦១ |
| | **៧ ១៤៥** | ៦ ២៤៣ | **២៩ ០៥៧** | ២៥ ៤១៥ |

## ២៥. ចំណាយពន្ធលើប្រាក់ចំណូល

ព្រះរាជាណាចក្រកម្ពុជា
ដោយអនុលោមទៅតាមច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូល ("ToI") នៅអត្រាការប្រាក់ ២០% នៃប្រាក់ចំណូលជាប់ពន្ធ។

ក្រៅពីពន្ធលើប្រាក់ចំណូល អ្នកជាប់ពន្ធនៅក្នុងប្រទេសកម្ពុជាមានកាតព្វកិច្ចដាច់ដោយឡែកមួយទៀតក្នុងការបង់ពន្ធអប្បបរមា។ ពន្ធអប្បបរមា គឺជាពន្ធប្រចាំឆ្នាំ ដែលមានអត្រាស្មើនឹង ១% នៃផលរបរប្រចាំសរុប ដែលរួមបញ្ចូលពន្ធទាំងអស់ លើកលែងពន្ធអាករលើតម្លៃបន្ថែម ហើយមិនគិតពីស្ថានភាពចំណេញ ឬខាតរបស់អ្នកជាប់ពន្ធឡើយ។ ក្រុមហ៊ុន មានកាតព្វកិច្ចក្នុងការបង់ពន្ធលើតម្លៃមួយណាដែលខ្ពស់ជាងពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា។

លិខិតប្រកាសពន្ធរបស់ក្រុមហ៊ុន ត្រូវឆ្លងកាត់ការត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ។ ដោយសារការអនុវត្តច្បាប់ពន្ធ និងបទប្បញ្ញត្តិសម្រាប់ប្រតិបត្តិការមានច្រើនប្រភេទគឺងាយនឹងមានការបកស្រាយខុសគ្នាពីចំនួនដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ អាចផ្លាស់ប្តូរនៅពេលក្រោយតាមការកំណត់ចុងក្រោយរបស់អាជ្ញាធរពន្ធដារ។

ប្រទេសមីយ៉ាន់ម៉ា
ដោយអនុលោមតាមច្បាប់ពន្ធលើប្រាក់ចំណូលរបស់សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ក្រុមហ៊ុនបុត្រសម្ព័ន្ធផ្ទាល់/និងប្រយោលមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលសាជីវកម្មតាមអត្រា ២៥% នៃប្រាក់ចំណូលជាប់ពន្ធ។ ក្រុមហ៊ុនបុត្រសម្ព័ន្ធមិនត្រូវបានជាប់ពន្ធលើប្រាក់ចំណូល នោះទេ សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និងឆ្នាំ២០២១ ទេព្រោះពួកគេមិនទាន់បានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មនៅឡើយទេ។

## ២៥. ចំណាយពន្ធលើប្រាក់ចំណូល (ត)

ការចំណាយពន្ធលើប្រាក់ចំណូលសម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និងឆ្នាំ២០២១ រួមមាន៖

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ** | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | |
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| ពន្ធបច្ចុប្បន្ន | **៥៣២** | ៦៨៥ | **២ ១៦៣** | ២ ៧៨៩ |
| ពន្ធពន្យារ | **២០៩** | ៣២៤ | **៨៥០** | ១ ៣១៩ |
| ចំណាយពន្ធលើប្រាក់ចំណូល | **៧៤១** | ១ ០០៩ | **៣ ០១៣** | ៤ ១០៨ |

### ២៥.១ ការផ្ទៀងផ្ទាត់រវាងប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល និងប្រាក់ចំណូលជាប់ពន្ធ

ការផ្ទៀងផ្ទាត់រវាងចំណេញតាមគណនេយ្យមុនបង់ពន្ធលើប្រាក់ចំណូលនិងប្រាក់ចំណូលជាប់ពន្ធសម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ មានដូចខាងក្រោម៖

| | សម្ព័ន្ធក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ** | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | |
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| ចំណេញតាមគណនេយ្យមុនគិតពន្ធ | **១ ៣៤៨** | ២ ៤៧៨ | **៥ ៤៨៣** | ១០ ០៨៨ |
| បូក៖ | | | | |
| ចំណាយមិនអាចកាត់កងបាន | **១ ៣៧៦** | ៩៤៧ | **៥ ៥៩៦** | ៣ ៨៥៥ |
| **ប្រាក់ចំណេញជាប់ពន្ធ** | **២ ៧២៤** | ៣ ៤២៥ | **១១ ០៧៩** | ១៣ ៩៤៣ |
| ចំណាយពន្ធលើប្រាក់ចំណូលនៅអត្រា២០% | **៥៤៥** | ៦៨៥ | **២ ២១៦** | ២ ៧៨៩ |
| ការកាត់បន្ថយអត្រាពន្ធ ២,៧៦%** | **(៧៥)** | - | **(៣០៦)** | - |
| ចំណាយពន្ធលើប្រាក់ចំណូលតាមអត្រាពន្ធមានប្រសិទ្ធភាព១៧,២៤%/២០% (ក) | **៤៧០** | ៦៨៥ | **១ ៩១០** | ២ ៧៨៩ |
| ពន្ធអប្បបរមា (ខ) | **៥៣២** | ៦៧២ | **២ ១៦៣** | ២ ៧៣៦ |
| **ចំណាយពន្ធដែលបានប៉ាន់ស្មាន (តម្លៃណាដែលខ្ពស់ជាងរវាង ក ឬ ខ)** | **៥៣២** | ៦៨៥ | **២ ១៦៣** | ២ ៧៨៩ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ២៥. ចំណាយពន្ធលើប្រាក់ចំណូល (ត)

២៥.១ ការផ្ទៀងផ្ទាត់រវាងប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល និងប្រាក់ចំណូលជាប់ពន្ធ (ត)

| | ក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ** | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | |
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារ អាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| ចំណេញតាមគណនេយ្យមុនគិតពន្ធ | ១ ៣៧០ | ២ ៥៦៨ | ៥ ៥៧២ | ១០ ៤៥៤ |
| បូក៖ | | | | |
| ចំណាយមិនអាចកាត់កងបាន | ១ ៣៥៤ | ៨៥៧ | ៥ ៥០៦ | ៣ ៤៨៩ |
| **ប្រាក់ចំណេញជាប់ពន្ធ** | ២ ៧២៤ | ៣ ៤២៥ | ១១ ០៧៨ | ១៣ ៩៤៣ |
| ចំណាយពន្ធលើប្រាក់ចំណូលនៅអត្រា២០% | ៥៤៥ | ៦៨៥ | ២ ២១៦ | ២ ៧៨៩ |
| ការកាត់បន្ថយអត្រាពន្ធ ២,៧៦%** | (៧៥) | - | (៣០៦) | - |
| ចំណាយពន្ធលើប្រាក់ចំណូលតាមអត្រាពន្ធមានប្រសិទ្ធភាព១៧,២៤%/២០% (ក) | ៤៧០ | ៦៨៥ | ១ ៩១០ | ២ ៧៨៩ |
| ពន្ធអប្បបរមា (ខ) | ៥៣២ | ៦៧២ | ២ ១៦៣ | ២ ៧៣៦ |
| **ចំណាយពន្ធដែលបានប៉ាន់ស្មាន (តម្លៃណាដែលខ្ពស់ជាងរវាង ក ឬ ខ)** | ៥៣២ | ៦៨៥ | ២ ១៦៣ | ២ ៧៨៩ |

* ដោយអនុលោមតាមប្រកាសលេខ១៨៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ដែលត្រូវបានផ្តល់នៅអនុក្រឹត្យលេខ០១ទាក់ទងនឹងការកាត់បន្ថយពន្ធលើប្រាក់ចំណូល ៥០% នៃពន្ធលើប្រាក់ចំណូលដែលត្រូវបង់រយៈពេល ៣ឆ្នាំរបស់ក្រុមហ៊ុន។ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ត្រូវបានគណនាដោយផ្អែកលើភាគរយនៃភាគហ៊ុនដែលបានចេញ។ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ក្រុមហ៊ុនបានទទួលលិខិតលេខ ១៤៣៣១ ដែលចេញដោយ អគ្គនាយកដ្ឋានពន្ធដារដើម្បីអនុម័តលើការស្នើសុំការលើកលែងពន្ធរបស់ខ្លួនលើពន្ធប្រាក់ចំណូល។

២៥.២ ពន្ធយថាហេតុ

ប្រព័ន្ធពន្ធដារនៅកម្ពុជាមានលក្ខណៈថ្មីហើយត្រូវបានកំណត់ដោយពន្ធជាច្រើន ហើយច្បាប់ពន្ធមានការផ្លាស់ប្តូរជាញឹកញាប់ធ្វើឱ្យមានភាពមិនច្បាស់លាស់និងត្រូវបានយកមកបកស្រាយ។ ការបកស្រាយខុសគ្នាជាញឹកញាប់កើតមានឡើងក្នុងចំណោមអាជ្ញាធរពន្ធដារ និងយុត្តាធិការជាច្រើន។ ពន្ធ ជាកម្មវត្ថុនៃការត្រួតពិនិត្យនិងការស៊ើបអង្កេតដោយអាជ្ញាធរមួយចំនួន ដែលត្រូវបានអនុញ្ញាតដោយច្បាប់ក្នុងការដាក់ពិន័យធ្ងន់ធ្ងរ ការផាកពិន័យ និងពិន័យជាការប្រាក់។

កត្តាទាំងនេះអាចបង្កឱ្យមានហានិភ័យពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានចំនួនច្រើនជាងប្រទេសដទៃទៀត។ គណៈគ្រប់គ្រងជឿជាក់ថាបំណុលពន្ធត្រូវបានបង់គ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយច្បាប់ពន្ធរបស់ខ្លួន។ ទោះបីយ៉ាងនេះក្តី សមត្ថកិច្ចពន្ធពាក់ព័ន្ធអាចការបកស្រាយខុសៗគ្នាហើយអាចធ្វើឱ្យមានផលប៉ះពាល់សំខាន់ៗចាប់តាំងពីក្រុមហ៊ុនចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

៣០ មិថុនា ២០២២

## ២៦. បំណុលពន្ធពន្យារ

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | **សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ** | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | |
| | **៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក** | ៣០ មិថុនា ២០២១ ពាន់ដុល្លារ អាមេរិក | **៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២)** | ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
| **ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ** | | | | |
| សមតុល្យដើមគ្រា | **៧៧៧** | ៤៥៣ | **៣ ១៦៦** | ១ ៨៥៤ |
| ចំណេញ ឬខាតដែលបានទទួលស្គាល់ | **២០៩** | ៣២៤ | **៨៥០** | ១ ៣១៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | - | **(៣)** | (៧) |
| **សមតុល្យចុងគ្រា** | **៩៨៦** | ៧៧៧ | **៤ ០១៣** | ៣ ១៦៦ |

## ២៧. ការផ្ទៀងផ្ទាត់ទៅលើបំណុលដែលកើតឡើងពីសកម្មភាពហិរញ្ញវត្ថុ

បម្រែបម្រួលបំណុលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនដែលកើតឡើងពីសកម្មភាពហិរញ្ញវត្ថុ អាចធ្វើចំណាត់ថ្នាក់ដូចខាងក្រោមៈ

| | **១ កក្កដា ២០២១** | **មិនមែនលំហូរសាច់ប្រាក់** | | **លំហូរសាច់ប្រាក់** | | | **៣០ មិថុនា ២០២២** |
|---|---|---|---|---|---|---|---|
| | **ពាន់ដុល្លារ អាមេរិក** | **ទិញបន្ថែម ពាន់ដុល្លារ អាមេរិក** | **កត់ត្រាបញ្ច្រាស ពាន់ដុល្លារ អាមេរិក** | **សាច់ប្រាក់បានទទួល ពាន់ដុល្លារ អាមេរិក** | **ការទូទាត់ ពាន់ដុល្លារ អាមេរិក** | **ពាន់ដុល្លារ អាមេរិក** | **លានរៀល (សម្គាល់ ៤.២)** |
| ឥណទានមានកាលកំណត់ | **១០០ ០៧៥** | **-** | **-** | **-** | **(៨ ៥០៤)** | **៩១ ៥៧១** | **៣៧២ ៦៩២** |
| ឥណទានបង្វិល | **២ ៥២៣** | **-** | **-** | **១៤ ៥០៦** | **(១៣ ៩៤៩)** | **៣ ០៨០** | **១២ ៥៣៦** |
| បំណុលភតិសន្យា | **១៦២** | **៤១២** | **(១៥០)** | **-** | **(៧៦)** | **៣៤៨** | **១ ៤១៦** |
| | **១០២ ៧៦០** | **៤១២** | **(១៥០)** | **១៤ ៥០៦** | **(២២ ៥២៩)** | **៩៤ ៩៩៩** | **៣៨៦ ៦៤៤** |

| | ១ កក្កដា ២០២១ | មិនមែនលំហូរសាច់ប្រាក់ | | លំហូរសាច់ប្រាក់ | | | ៣០ មិថុនា ២០២២ |
|---|---|---|---|---|---|---|---|
| | ពាន់ដុល្លារ អាមេរិក | ទិញបន្ថែម ពាន់ដុល្លារ អាមេរិក | កត់ត្រាបញ្ច្រាស ពាន់ដុល្លារ អាមេរិក | សាច់ប្រាក់បានទទួល ពាន់ដុល្លារ អាមេរិក | ការទូទាត់ ពាន់ដុល្លារ អាមេរិក | ពាន់ដុល្លារ អាមេរិក | លានរៀល (សម្គាល់ ៤.២) |
| ឥណទានមានកាលកំណត់ | ១០៨ ៥៨២ | - | - | - | (៨ ៥០៧) | ១០០ ០៧៥ | ៤០៧ ៨០៦ |
| ឥណទានបង្វិល | ១ ៦៣២ | - | - | ៧ ៩៩៧ | (៧ ១០៦) | ២ ៥២៣ | ១០ ២៨១ |
| បំណុលភតិសន្យា | ៩៥ | ២២០ | (១៤) | - | (១៣៩) | ១៦២ | ៦៦១ |
| | ១១០ ៣០៩ | ២២០ | (១៤) | ៧ ៩៩៧ | (១៥ ៧៥២) | ១០២ ៧៦០ | ៤១៨ ៧៤៨ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

៣០ មិថុនា ២០២២

## ២៨. សមតុល្យ និងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

ខាងក្រោម គឺជាសមតុល្យដែលនៅសល់ជាមួយភាគីពាក់ព័ន្ធ៖

| ភាគីពាក់ព័ន្ធ | ទំនាក់ទំនង | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២) | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន** | | | | | |
| **សមតុល្យត្រូវទទួលពីភាគីពាក់ព័ន្ធ** | | | | | |
| Diamond Power Limited | ភាគីសម្ព័ន្ធញាតិ | **៤** | ២ | **១៦** | ៨ |
| Green Sustainable Ventures (Cambodia) Co., Ltd. | ភាគីសម្ព័ន្ធញាតិ | **២២០** | - | **៨៩៥** | - |
| | | **២២៤** | ២ | **៩១១** | ៨ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | | | | | |
| PESTECH Sdn Bhd | ភាគីសម្ព័ន្ធញាតិ | **១១ ៤៦៤** | ១៦ ៣០៨ | **៤៦ ៦៥៨** | ៦៦ ៤៥៥ |
| Enersol Co., Ltd | ភាគីសម្ព័ន្ធញាតិ | **៣៦ ៥៦៦** | ៣៤ ៨២៨ | **១៤៨ ៨២៤** | ១៤១ ៩២៤ |
| PESTECH Energy Sdn Bhd | ភាគីសម្ព័ន្ធញាតិ | **១៥** | - | **៦១** | - |
| ODM Power Line Co Ltd | ភាគីសម្ព័ន្ធញាតិ | **៣៨ ០៣២** | ២៧ ០០៦ | **១៥៤ ៧៩០** | ១១០ ០៤៩ |
| PESTECH Transmission Sdn Bhd | ភាគីសម្ព័ន្ធញាតិ | **៣ ៥២០** | ៣ ៥០០ | **១៤ ៣២៦** | ១៤ ២៦៣ |
| Green Sustainable Ventures (Cambodia) Co., Ltd. | ភាគីសម្ព័ន្ធញាតិ | - | ៩ ០២៦ | - | ៣៦ ៧៨១ |
| | | **៨៩ ៥៩៧** | ៩០ ៦៦៨ | **៣៦៤ ៦៥៩** | ៣៦៩ ៤៧២ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនហូលឌីង | | | | | |
| PESTECH International Berhad | ក្រុមហ៊ុន ហូលឌីង | **២៦ ៨៣៤** | ២៧ ០៥៤ | **១០៩ ២១៤** | ១១០ ២៤៥ |
| ក្រុមហ៊ុន | | | | | |
| សមតុល្យត្រូវទទួលពីក្រុមហ៊ុនបុត្រសម្ព័ន្ធ | | | | | |
| PESTECH (Myanmar) Limited | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | **៩៧** | ៧៩ | **៣៩៥** | ៣២២ |

សមតុល្យដែលត្រូវទទួលពី/ត្រូវសងទៅភាគីពាក់ព័ន្ធ មិនមានទ្រព្យធានា គ្មានការប្រាក់ ហើយការទូទាត់សងតាមតម្រូវការ លើកលែងតែសមតុល្យជាក់លាក់ដែលត្រូវសងទៅក្រុមហ៊ុន PESTECH International Berhad Enersol Co., Ltd និង PESTECH Sdn Bhd ដែលមានការប្រាក់ ២,៣២% ទៅ៤,៥% (ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១៖ មានចំនួន ៤,៥% ទៅ៥%) ក្នុងមួយឆ្នាំ។

## ២៨. សមតុល្យ និងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ (ត)

ក្នុងអំឡុងការិយបរិច្ឆេទ ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ត្រូវបានបង្ហាញដូចខាងក្រោម៖

### សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន

| ភាគីពាក់ព័ន្ធ | ទំនាក់ទំនង | ប្រតិបត្តិការ | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ៣០ មិថុនា ២០២២ ពាន់ដុល្លារអាមេរិក | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ៣០ មិថុនា ២០២១ ពាន់ដុល្លារអាមេរិក | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ៣០ មិថុនា ២០២២ លានរៀល (សម្គាល់ ៤.២) | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ ៣០ មិថុនា ២០២១ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|---|
| Diamond Power Limited | ភាគីសម្ព័ន្ធញាតិ | ចំណូលពីសេវាគ្រប់គ្រងគម្រោង | ១០ | - | ៣៩ | - |
| | | ប្រតិបត្តិការ និងសេវាថែទាំ | ១ ៥៣៣ | ១ ២៨៩ | ៦ ២៣៥ | ៥ ២៤៨ |
| PESTECH Sdn Bhd | ភាគីសម្ព័ន្ធញាតិ | វិក្កយបត្រដែលកំពុងដំណើរការ | ៣ ៥២៣ | - | ១៤ ៣២៧ | - |
| | | ថ្លៃដើមកិច្ចសន្យាបានកើតឡើង | ១១ ៣២៥ | ២០ ១៩៣ | ៤៦ ០៦០ | ៨២ ២០៦ |
| | | ចំណាយការប្រាក់ | ១៤៦ | ៤២ | ៥៩៦ | ១៧១ |
| Enersol Co., Ltd | ភាគីសម្ព័ន្ធញាតិ | ថ្លៃដើមកិច្ចសន្យាបានកើតឡើង/(កត់ត្រាបញ្ច្រាស) | ១ ១៦៦ | (៨៣) | ៤ ៧៤០ | (៣៣៨) |
| | | ចំណាយការប្រាក់ | ៦៣៩ | - | ២ ៥៩៩ | - |
| PESTECH Transmission Sdn Bhd | ភាគីសម្ព័ន្ធញាតិ | ថ្លៃដើមកិច្ចសន្យាបានកើតឡើង | ៣៩ | ៧២៦ | ១៥៩ | ២ ៩៥៦ |
| | | ចំណូលពីសេវាគ្រប់គ្រងគម្រោង | ១៧ | ១៤២ | ៦៩ | ៥៧៨ |
| ODM Power Line Co Ltd | ភាគីសម្ព័ន្ធញាតិ | ថ្លៃដើមកិច្ចសន្យាបានកើតឡើង | - | ១០ ០០០ | - | ៤០៧១០ |
| | | ចំណូលពីសេវាគ្រប់គ្រងគម្រោង | ២០ | - | ៨១ | - |
| | | ចំណូលពីការជួល | - | ២ | - | ៨ |
| PESTECH International Berhad | ក្រុមហ៊ុន ហូលឌីង | ចំណាយនៃសេវាគ្រប់គ្រង | - | ៥៦៥ | - | ២ ៣០០ |
| | | ចំណាយការប្រាក់ | ៨៤៦ | ៣៧១ | ៣ ៤៤០ | ១ ៥១០ |
| Green Sustainable Ventures (Cambodia) Co., Ltd. | ភាគីសម្ព័ន្ធញាតិ | ចំណូលពីសេវាគ្រប់គ្រងគម្រោង | ១៨ | - | ៧៥ | - |
| | | ប្រតិបត្តិការ និងសេវាថែទាំ | ៦០ | - | ២៤៤ | - |
| | | វិក្កយបត្រដែលកំពុងដំណើរការ | ១៩ ០០៨ | ២ ៥៩២ | ៧៧ ៣០៦ | ១០ ៥៥២ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ២៩. ប្រតិបត្តិការជាមួយគណៈគ្រប់គ្រងសំខាន់ៗ

គណៈគ្រប់គ្រងសំខាន់ៗ ត្រូវបានកំណត់ថាជាបុគ្គលដែលមានសិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការធ្វើផែនការ ដឹកនាំ និងត្រួតពិនិត្យសកម្មភាពរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនដោយផ្ទាល់ ឬដោយប្រយោល។ គណៈគ្រប់គ្រងសំខាន់ រួមបញ្ចូលទាំងអភិបាលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | |
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) |
| ប្រាក់បៀវត្ស និងបុព្វលាភ | ៤៦៨ | ៣៩៤ | ១.៩០៣ | ១.៦០៤ |

## ៣០. តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ

តារាងខាងក្រោមបង្ហាញអំពីសមតុល្យយោង និងតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ រួមទាំងកម្រិតរបស់វានៅក្នុងតម្លៃសមស្រប។ វាមិនរាប់បញ្ចូលព័ត៌មាននៃតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលត្រូវបានប៉ាន់ស្មាន ប្រសិនបើសមតុល្យយោង គឺជាការប៉ាន់ស្មានដ៏សមរម្យតាមតម្លៃសមស្រប។ សមតុល្យយោង និងសមតុល្យក្នុងធនាគារ សមតុល្យដែលត្រូវសង/ទទួលពីភាគីពាក់ព័ន្ធ សមតុល្យត្រូវទទួលពីក្រុមហ៊ុនសម្ព័ន្ធ សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងទៀត និងគណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ និងប្រាក់កម្ចី គឺជាការប៉ាន់ស្មានដ៏សមរម្យនៃតម្លៃសមស្របទៅតាម លក្ខណៈរយៈពេលខ្លី ឬឧបករណ៍វាស់វែងអត្រាបណ្តែត ដែលត្រូវបានកំណត់តម្លៃឡើងវិញតាមអត្រាការប្រាក់នៃទីផ្សារ ឬនៅជិតចុងបញ្ចប់នៃកាលបរិច្ឆេទនៃរបាយការណ៍។

កម្រិតខុសគ្នារបស់វាត្រូវបានបង្ហាញដូចខាងក្រោម៖

- តម្លៃដែលបានដកស្រង់ (មិនទាន់កែតម្រូវ) ក្នុងសកម្មភាពទីផ្សារសម្រាប់កត់សម្គាល់ទៅលើទ្រព្យសកម្ម ឬបំណុល (កម្រិត១)។
- ធាតុចូលផ្សេងក្រៅពីតារាងតម្លៃ រួមបញ្ចូលទាំងកម្រិតទី១ ដែលអាចសង្កេតបានទៅលើការទទួលខុសត្រូវនៃទ្រព្យសកម្ម ឬបំណុល មិនថាដោយផ្ទាល់ ឬដោយប្រយោល (កម្រិតទី២)។
- ធាតុចូលនៃទ្រព្យសកម្ម ឬបំណុលដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលមិនអាចសង្កេតបាន (កម្រិតទី៣)។

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ | |
| បំណុលហិរញ្ញវត្ថុ | សមតុល្យយោង ពាន់ដុល្លារអាមេរិក | កម្រិត ២ ពាន់ដុល្លារអាមេរិក | សមតុល្យយោង ពាន់ដុល្លារអាមេរិក | កម្រិត ២ ពាន់ដុល្លារអាមេរិក |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ | ៤៥២ | ៤៥២ | ៤.៣២១ | ៤.៣២១ |

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុដែលមានប្រតិបត្តិការនៅក្នុងទីផ្សារ គឺផ្អែកទៅលើតម្លៃទីផ្សារដែលបានដកស្រង់នៅការិយបរិច្ឆេទនៃរបាយការណ៍។ ទីផ្សារត្រូវបានចាត់ទុកជាប្រតិបត្តិការ ប្រសិនបើតារាងនៃតម្លៃដកស្រង់គឺត្រូវបានត្រៀមរួចរាល់ និងទៀតទាត់ដែលមានសម្រាប់ការផ្លាស់ប្តូរ អ្នកចែកចាយ ឈ្មួញកណ្តាល សហគ្រាសក្រុមហ៊ុន សេវាកម្មកំណត់តម្លៃ ឬភ្នាក់ងារច្បាប់ និងការបង្ហាញតម្លៃជាក់ស្តែង រួមទាំងប្រតិបត្តិការទីផ្សារទៀតទាត់តាមមូលដ្ឋានរយៈពេលវែង។ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានរួមបញ្ចូលទៅក្នុងកម្រិតទី១។.

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ ដែលមិនមានប្រតិបត្តិការក្នុងទីផ្សារសកម្ម (ឧទាហរណ៍៖ និស្សន្ទដែលហួសកម្រិត) ត្រូវបានកំណត់ដោយប្រើវិធីសាស្ត្របច្ចេកទេសក្នុងការវាយតម្លៃ។ វិធីសាស្ត្រទាំងនេះ បង្កើនការប្រើប្រាស់ទិន្នន័យទីផ្សារដែលអាចសង្កេតបាន នៅពេលដែលមានហើយពឹងផ្អែកតិចតួចតាមដែលអាចធ្វើទៅបានតាមការប៉ាន់ស្មានជាក់លាក់របស់អង្គភាព។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

៣០ មិថុនា ២០២២

## ៣០.តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ (ត)

ប្រសិនបើធាតុចូលសំខាន់ៗទាំងអស់ ត្រូវទាមទារឱ្យតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុគឺធ្វើការសង្កេតបាន ឧបករណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានរួមបញ្ចូលទៅក្នុងកម្រិតទី២។ ប្រសិនបើធាតុចូលសំខាន់ៗទាំងនេះមានចំនួនមួយ ឬច្រើន គឺមិនត្រូវបានពឹងផ្អែកទៅលើទិន្នន័យ ទីផ្សារដែលអាចសង្កេតបាន ឧបករណ៍ហិរញ្ញវត្ថុទាំងនោះត្រូវបានរួមបញ្ចូលទៅក្នុងកម្រិតទី៣។

ការដោះដូរអត្រាការប្រាក់នៃតម្លៃសមស្របដែលត្រូវបានគណនាជាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតដែលបានប៉ាន់ស្មានផ្អែកលើខ្សែកោងទិន្នផលដែលអាចសង្កេតបាន។

## ៣១.ចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ

តារាងខាងក្រោមបង្ហាញអំពីការវិភាគរបស់ឧបករណ៍ហិរញ្ញវត្ថុទៅតាមចំណាត់ថ្នាក់នីមួយៗ៖

| | សម្ព័ន្ធក្រុមហ៊ុន | | | |
|---|---|---|---|---|
| ទ្រព្យសកម្មហិរញ្ញវត្ថុ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) |
| តាមថ្លៃដើមរំលស់ | | | | |
| សាច់ប្រាក់ និងសមតុល្យធនាគារ | ៩.៨៧២ | ១៧.១៦៧ | ៤០.១៧៩ | ៦៩.៩៥៦ |
| គណនីអតិថិជននិងគណនីត្រូវទទួលផ្សេងៗ | ១.៤៤៩ | ៣.២២១ | ៥.៨៩៨ | ១៣.១២៧ |
| សមតុល្យត្រូវទទួលពីភាគីពាក់ព័ន្ធ | ២២៤ | ២ | ៩១១ | ៨ |
| | ១១.៥៤៥ | ២០.៣៩០ | ៤៦.៩៨៨ | ៨៣.០៩១ |

| | ក្រុមហ៊ុន | | | |
|---|---|---|---|---|
| ទ្រព្យសកម្មហិរញ្ញវត្ថុ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) |
| តាមថ្លៃដើមរំលស់ | | | | |
| សាច់ប្រាក់ និងសមតុល្យធនាគារ | ៩.៨៦៦ | ១៧.១៥៤ | ៤០.១៥៥ | ៦៩.៩០៣ |
| គណនីអតិថិជននិងគណនីត្រូវទទួលផ្សេងៗ | ១.៤៤៩ | ៣.២១៥ | ៥.៨៩៨ | ១៣.១០១ |
| សមតុល្យត្រូវទទួលពីក្រុមហ៊ុនបុត្រសម្ព័ន្ធ | ៩៧ | ៧៩ | ៣៩៥ | ៣២២ |
| សមតុល្យត្រូវទទួលពីភាគីពាក់ព័ន្ធ | ២២៤ | ២ | ៩១១ | ៨ |
| | ១១.៦៣៦ | ២០.៤៥០ | ៤៧.៣៥៩ | ៨៣.៣៣៤ |

| | សម្ព័ន្ធក្រុមហ៊ុន | | | |
|---|---|---|---|---|
| បំណុលហិរញ្ញវត្ថុ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) |
| តាមថ្លៃដើមរំលស់ | | | | |
| គណនីអ្នកផ្គត់ផ្គង់និងគណនីត្រូវបង់ផ្សេងៗ | ៤៦.៨៨៣ | ៣៣.២៧១ | ២៦០.៥៩៥ | ១៣៥.៥៨០ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៦.៨៣៤ | ២៧.០៥៤ | ១០៩.២១៤ | ១១០.២៤៥ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ៨៩.៥៩៧ | ៩០.៦៦៨ | ៣៦៤.៦៥៩ | ៣៦៩.៤៧២ |
| ប្រាក់កម្ចី | ១០២.៣៥២ | ១០៥.១១៩ | ៤១៦.៥៧៣ | ៤២៨.៣៦០ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទសម្រាប់ការការពារហានិភ័យ | | | | |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទមិនស្ថិតក្នុងវិសាលភាពនៃ CIFRS ៩ | ៥២ | ៤.៣២១ | ១.៨៣៨ | ១៧.៦០៨ |
| បំណុលភតិសន្យា | ៣៤៨ | ១៦២ | ១.៤១៦ | ៦៦១ |
| | ២៦៦.៤៦៦ | ២៦០.៥៩៥ | ១.០៨៤.៥១១ | ១.០៦១.៩២៦ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ៣១.ចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ (ត)

តារាងខាងក្រោមបង្ហាញអំពីការវិភាគរបស់ឧបករណ៍ហិរញ្ញវត្ថុទៅតាមចំណាត់ថ្នាក់នីមួយៗ៖ (ត0

| | ក្រុមហ៊ុន | | | |
|---|---|---|---|---|
| បំណុលហិរញ្ញវត្ថុ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) |
| តាមថ្លៃដើមរំលស់ | | | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ | ៤៦.៨៧៨ | ៣៣.២៥៧ | ១៩០.៧៩៣ | ១៣៥.៥២៣ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៦.៨៣៤ | ២៧.០៥៤ | ១០៩.២១៤ | ១១០.២៤៥ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ៨៩.៥៩៧ | ៩០.៦៦៨ | ៣៦៤.៦៥៩ | ៣៦៩.៤៧២ |
| ប្រាក់កម្ចី | ១០២.៣៥២ | ១០៥.១១៩ | ៤១៦.៥៧៣ | ៤២៨.៣៦០ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទសម្រាប់ការការ ពារហានិភ័យ | ៤៥២ | ៤.៣២១ | ១.៨៣៨ | ១៧.៦០៨ |
| ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទមិនស្ថិតក្នុងវិសាលភាពនៃ CIFRS ៩ | | | | |
| បំណុលភតិសន្យា | ៣៤៨ | ១៦២ | ១.៤១៦ | ៦៦១ |
| | ២៦៦.៤៦១ | ២៦០.៥៨១ | ១.០៨៤.៤៩៣ | ១.០៦១.៨៦៩ |

## ៣២.ប្រាក់ចំណេញ ក្នុងមួយសន្លឹកហ៊ុន

ប្រាក់ចំណេញក្នុងមួយសន្លឹកហ៊ុន គឺត្រូវបានគណនាដោយការបែងចែកប្រាក់ចំណេញឱ្យទៅអ្នកកាន់កាប់ភាគហ៊ុនរបស់សម្ព័ន្ធក្រុមហ៊ុនតាមចំនួនមធ្យមនៃសន្លឹកហ៊ុនធម្មតាដែលបានបោះផ្សាយក្នុងការិយបរិច្ឆេទជាបន្តបន្ទាប់ ដូចដែលបានបង្ហាញដូចខាងក្រោម៖

| | សម្ព័ន្ធក្រុមហ៊ុន | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) |
| ចំណេញដែលអាចបែងចែកទៅឱ្យម្ចាស់ក្រុមហ៊ុន | ៦០៧ | ១.៣៨៨ | ២.៤៧០ | ៥.៦៥០ |
| ចំនួនភាគហ៊ុនមធ្យម | ៧៤.៩៤៥.000 | ៧៤.៤៨០.២៤៧ | ៧៤.៩៤៥.000 | ៧៤.៤៨០.២៤៧ |
| ចំណេញមូលដ្ឋានក្នុងមួយសន្លឹកហ៊ុន (សេន/រៀល) | 0,៨១ | ១,៨៦ | ៣២,៩៦ | ៧៥,៨៦ |
| ចំណេញថយចុះក្នុងមួយសន្លឹកហ៊ុន (សេន/រៀល | 0,៨១ | ១,៨៦ | ៣២,៩៦ | ៧៥,៨៦ |

ចំណេញដែលថយចុះក្នុងមួយសន្លឹកហ៊ុន គឺត្រូវបានគណនាដោយការកែប្រែនៃចំនួនសន្លឹកហ៊ុនធម្មតាជាមធ្យមដែលនៅសល់ ដើម្បីសន្មតការបំលែងភាគហ៊ុនធម្មតាដែលមានសក្តានុពល។

សម្ព័ន្ធក្រុមហ៊ុន មិនមានការថយចុះទៅលើសន្លឹកហ៊ុនធម្មតាដែលមានសក្តានុពល នាអំឡុងចុងការិយបរិច្ឆេទនោះឡើយ។ ដូច្នេះហើយប្រាក់ចំណូលដែលធ្លាក់ចុះក្នុងមួយសន្លឹកហ៊ុន គឺស្មើនឹងចំណេញក្នុងមួយសន្លឹកហ៊ុន។

## ៣៣.គោលបំណង និងគោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យ

*ហានិភ័យហិរញ្ញវត្ថុ*

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនត្រូវប្រឈមនឹងហានិភ័យហិរញ្ញវត្ថុដែលកើតឡើងពីប្រតិបត្តិការអាជីវកម្ម និងការប្រើប្រាស់ឧបករណ៍ ហិរញ្ញវត្ថុ។ គោលនយោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដើម្បីធានាថាមានធនធានគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍអាជីវកម្មរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ខណៈពេលដែលមានការគ្រប់គ្រងលើហានិភ័យឥណទាន ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យអត្រាការប្រាក់ និងហានិភ័យរូបិយប័ណ្ណបរទេស។ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនដំណើរស្របតាមគោលនយោបាយ និងនីតិវិធីដែលបានកំណត់យ៉ាងច្បាស់ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលដើម្បីធានាប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងហានិភ័យ។

## ៣៣.គោលបំណង និងគោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យ(ត)

*ហានិភ័យហិរញ្ញវត្ថុ(ត)*

ផ្នែកសំខាន់ៗនៃហានិភ័យហិរញ្ញវត្ថុដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនបានប្រឈមមុខ និងគោលនយោបាយនៃសកម្មភាពរតនាគារសំខាន់ៗត្រូវបានកំណត់ដូចខាងក្រោម៖

(ក) ហានិភ័យឥណទាន
ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ប្រសិនបើអតិថិជន ឬសមភាគីនៃឧបករណ៍ហិរញ្ញវត្ថុមិនអាចបំពេញតាមកាតព្វកិច្ចតាមកិច្ចសន្យារបស់ខ្លួនបាន។

គោលនយោបាយរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន បានឈានចូលក្នុងការប្រើប្រាស់នូវឧបករណ៍ហិរញ្ញវត្ថុ ជាមួយសមភាគីដែលមានប្រវត្តិឥណទានល្អ (creditworthy counterparties)។ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមិនរំពឹងទុកថា នឹងទទួលរងនូវការខាតបង់ឥណទានជាសារវន្តលើទ្រព្យសកម្ម ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត។

ការប្រមូលផ្តុំនៃហានិភ័យឥណទាន នៅពេលមានការផ្លាស់ប្តូរកត្តាសេដ្ឋកិច្ច ឧស្សាហកម្ម និងភូមិសាស្ត្រដែលមានឥទ្ធិពលដល់ក្រុមសមភាគី ហើយការប៉ះពាល់សំខាន់ៗដល់ឥណទានសរុប នឹងមានការប៉ះពាល់ឥណទានសរុបរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។ ប្រតិបត្តិការរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ត្រូវបានបញ្ចូលទៅក្នុងសមភាគីដែលជាឥណទានមានប្រវត្តិឥណទានល្អ ដូច្នេះហើយជាហេតុនៃការកាត់បន្ថយការប្រមូលផ្តុំហានិភ័យសំខាន់ៗរបស់ឥណទាន។

ចំណុចដែលបង្ករឱ្យសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ទទួលរងការប៉ះពាល់នូវហានិភ័យឥណទានមានដូចជា ៖

គណនីត្រូវទទួល និងទ្រព្យសកម្មកិច្ចសន្យា
សមតុល្យយោងសុទ្ធនៃគណនីពាណិជ្ជ ត្រូវបានចាត់ទុកថាជាតម្លៃប្រហាក់ប្រហែលដ៏សមស្រប។

ក្នុងការវាស់វែងឥណទានខាតបង់ដែលបានរំពឹងទុក គណនីពាណិជ្ជត្រូវបានវាយតម្លៃជាលក្ខណៈដាច់ដោយឡែក ដោយការវាយតម្លៃពី លក្ខណៈហានិភ័យរបស់អតិថិជនទៅនឹងការវាយតម្លៃខាងក្រៅដូចដែលបានចេញផ្សាយដោយទីភ្នាក់ងារវាយតម្លៃឥណទានអន្តរជាតិ និង អត្រាលំនាំដើមដែលមានភាពស៊ីចង្វាក់គ្នា ត្រូវបានប្រើដើម្បីគណនា ECL។

អតិថិជនត្រូវបានកំណត់អត្រាជា "AAA" ដោយសារក្រុមហ៊ុនមិនទទួលរងការខាតបង់ណាមួយពីអតិថិជនកន្លងមកនោះទេ ដូច្នេះអត្រាលំនាំដើម 0% ត្រូវបានប្រើប្រាស់។ ដូច្នេះហើយ មិនមាន ECL នោះទេគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។

សាច់ប្រាក់ និងសាច់ប្រាក់សមមូល
ហានិភ័យឥណទានសម្រាប់សាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបានចាត់ទុកថាតិចតួច ពីព្រោះសមភាគីជាធនាគារនៅក្នុងស្រុកដ៏ល្បី។

ឧបករណ៍ហិរញ្ញវត្ថុប្រើក្នុងសកម្មភាពការពារហានិភ័យ
សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ប្រឈមនឹងការខាតបង់ឥណទាន នៅក្នុងព្រឹត្តិការណ៍នៃមិនបានធ្វើប្រតិបត្តិការដោយសមភាគីនៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនមានការរំពឹងទុកថាមានសមភាគីណាមួយ មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបាន។

(ខ) ហានិភ័យសាច់ប្រាក់ងាយស្រួល
ហានិភ័យសាច់ប្រាក់ងាយស្រួល " ជាហានិភ័យមូលនិធិដែលសហគ្រាសជួបការលំបាកក្នុងការរៃអង្គាសថវិកាដើម្បីបំពេញការសន្យារបស់ក្រុមហ៊ុនជាមួយនឹងឧបករណ៍ហិរញ្ញវត្ថុ។

ហានិភ័យសាច់ប្រាក់ងាយស្រួល អាចជាលទ្ធផលនៃភាពអសមត្ថភាពក្នុងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ បានលឿននៅក្នុងតម្លៃសមស្រប។

គោលនយោបាយរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ត្រូវធ្វើការត្រួតពិនិត្យជាទៀងទាត់នូវតម្រូវការសាច់ប្រាក់ងាយស្រួលបច្ចុប្បន្ន ដែលបានរំពឹងទុកដើម្បីធានាថា វារក្សាបាននូវទុនបម្រុងសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីបំពេញតាមតម្រូវការសាច់ប្រាក់ងាយស្រួលក្នុងរយៈពេលខ្លី និងរយៈពេលវែង។

ហានិភ័យសាច់ប្រាក់ងាយស្រួល ជាទូទៅកើតឡើងពីប្រាក់កម្ចី គណនីពាណិជ្ជ និងគណនីត្រូវបង់ផ្សេងទៀត និងគណនីត្រូវបង់ទៅភាគីពាក់ព័ន្ធ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ៣៣.គោលបំណង និងគោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យ(ត)

*ហានិភ័យហិរញ្ញវត្ថុ(ត)*

(ខ) ហានិភ័យសាច់ប្រាក់ងាយស្រួល(ត)

*ការវិភាគទៅលើឧបករណ៍ហិរញ្ញវត្ថុតាមរយៈកាលកំណត់នៃកិច្ចសន្យា*
តារាងខាងក្រោម គឺជាការវិភាគអំពីទម្រង់នៃកាលកំណត់បំណុលភតិសន្យារបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ដោយផ្អែកលើលំហូរសាច់ប្រាក់កិច្ចសន្យាដែលមិនបានធ្វើអប្បហា ដែលអាចនឹងខុសគ្នាពីតម្លៃយោងនៃបំណុលនាកាលបរិច្ឆេទនៃរបាយការណ៍៖

សម្ព័ន្ធក្រុមហ៊ុន

| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | តាមតម្រូវការ ឬក្នុងពេល ១ឆ្នាំ ពាន់ដុល្លារអាមេរិក | ១ឆ្នាំ ទៅ ៥ឆ្នាំ ពាន់ដុល្លារអាមេរិក | លើសពី៥ឆ្នាំ ពាន់ដុល្លារអាមេរិក | លំហូរសាច់ប្រាក់កិច្ចសន្យាសរុប ពាន់ដុល្លារអាមេរិក | លំហូរសាច់ប្រាក់កិច្ចសន្យាសរុប លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ | ៤៦.៨៨៣ | - | - | ៤៦.៨៨៣ | ១៩០.៨១១ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៦.៨៣៤ | - | - | ២៦.៨៣៤ | ១០៩.២១៤ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ៨៩.៥៩៧ | - | - | ៨៩.៥៩៧ | ៣៦៤.៦៥៩ |
| បំណុលភតិសន្យា | ១៤០ | ២៤៦ | - | ៣៨៦ | ១.៥៧១ |
| ប្រាក់កម្ចី | ២៤.១៣៦ | ៥៩.៣១៩ | ៣៣.៣៧៩ | ១១៦.៨៣៤ | ៤៧៥.៥១៥ |
| | ១៨៧.៥៩០ | ៥៩.៥៦៥ | ៣៣.៣៧៩ | ២៨០.៥៣៤ | ១.១៤១.៧៧០ |

| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ | តាមតម្រូវការ ឬក្នុងពេល ១ឆ្នាំ ពាន់ដុល្លារអាមេរិក | ១ឆ្នាំ ទៅ ៥ឆ្នាំ ពាន់ដុល្លារអាមេរិក | លំហូរសាច់ប្រាក់កិច្ចសន្យាសរុប ពាន់ដុល្លារអាមេរិក | លំហូរសាច់ប្រាក់កិច្ចសន្យាសរុប លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ | ៣៣.២៧១ | - | ៣៣.២៧១ | ១៣៥.៥៨០ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៧.០៥៤ | - | ២៧.០៥៤ | ១១០.២៤៥ |
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ៩០.៦៦៨ | - | ៩០.៦៦៨ | ៣៦៩.៤៧២ |
| បំណុលភតិសន្យា | ១៥ | ១៨២ | ១៩៧ | ៨០៤ |
| ប្រាក់កម្ចី | ១៨.៥០៧ | ១០១.៥៩៥ | ១២០.១០២ | ៤៨៩.៤១៦ |
| | ១៦៩.៥១៥ | ១០១.៧៧៧ | ២៧១.២៩២ | ១.១០៥.៥១៧ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ៣៣.គោលបំណង និងគោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យ(ត)

*ហានិភ័យហិរញ្ញវត្ថុ(ត)*

(ខ) ហានិភ័យសាច់ប្រាក់ងាយស្រួល(ត)

ក្រុមហ៊ុន

| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | តាមតម្រូវការ ឬក្នុងពេល ១ឆ្នាំ ពាន់ដុល្លារអាមេរិក | ១ឆ្នាំ ទៅ ៥ឆ្នាំ ពាន់ដុល្លារអាមេរិក | លើសពី៥ឆ្នាំ ពាន់ដុល្លារអាមេរិក | លំហូរសាច់ប្រាក់កិច្ចសន្យាសរុប ពាន់ដុល្លារអាមេរិក | លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|---|
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ | ៤៦.៨៧៨ | - | - | ៤៦.៨៧៨ | ១៩០.៧៩៣ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៦.៨៣៤ | - | - | ២៦.៨៣៤ | ១០៩.២១៤ |
| សមតុល្យត្រូវសងទៅភាគពាក់ព័ន្ធ | ៨៩.៥៩៧ | - | - | ៨៩.៥៩៧ | ៣៦៤.៦៥៩ |
| បំណុលភតិសន្យា | ១៤០ | ២៤៦ | - | ៣៨៦ | ១.៥៧១ |
| ប្រាក់កម្ចី | ២៤.១៣៦ | ៥៩.៣១៩ | ៣៣.៣៧៩ | ១១៦.៨៣៤ | ៤៧៥.៥១៥ |
| | ១៨៧.៥៨០ | ៥៩.៥៦៥ | ៣៣.៣៧៩ | ២៨០.៥៣៤ | ១.១៤១.៧៧០ |

| ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | តាមតម្រូវការ ឬក្នុងពេល ១ឆ្នាំ ពាន់ដុល្លារអាមេរិក | ១ឆ្នាំ ទៅ ៥ឆ្នាំ ពាន់ដុល្លារអាមេរិក | លំហូរសាច់ប្រាក់កិច្ចសន្យាសរុប ពាន់ដុល្លារអាមេរិក | លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ | ៣៣.២៥៧ | - | ៣៣.២៥៧ | ១៣៥.៥២៣ |
| សមតុល្យត្រូវសងទៅក្រុមហ៊ុនមេ | ២៧.០៥៤ | - | ២៧.០៥៤ | ១១០.២៤៥ |
| សមតុល្យត្រូវសងទៅភាគពាក់ព័ន្ធ | ៩០.៦៦៨ | - | ៩០.៦៦៨ | ៣៦៩.៤៧២ |
| បំណុលភតិសន្យា | ១៥ | ១៨២ | ១៩៧ | ៨០៤ |
| ប្រាក់កម្ចី | ១៨.៥០៧ | ១០១.៥៩៥ | ១២០.១០២ | ៤៨៩.៤១៦ |
| | ១៦៩.៥០១ | ១០១.៧៧៧ | ២៧១.២៧៨ | ១.១០៥.៤៦០ |

(គ). ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលតម្លៃសមស្របរបស់លំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធ ក្រុមហ៊ុន និងក្រុមហ៊ុន នឹងប្រែប្រួលព្រោះតែការផ្លាស់ប្តូរក្នុងអត្រាការប្រាក់របស់ទីផ្សារ។

*ការវិភាគលើហានិភ័យអត្រាការប្រាក់*

សម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនប្រឈមនឹងការប្រែប្រួលនៅក្នុងទីផ្សារអត្រាការប្រាក់តាមរយៈឥណទានធនាគារដែលមានអត្រាការប្រាក់អថេរ។ ខាងក្រោមនេះ គឺជាការបង្ហាញពីអត្រាការប្រាក់របស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុននៃឧបករណ៍ហិរញ្ញវត្ថុដែលមានការប្រាក់សំខាន់ៗ ដោយផ្អែកលើសមតុល្យយោងគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍៖

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន

| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២០) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២០) |
|---|---|---|---|---|
| ឧបករណ៍ហិរញ្ញវត្ថុតាមអត្រាបណ្តែត | | | | |
| បំណុលហិរញ្ញវត្ថុ | | | | |
| ប្រាក់កម្ចី | ៥៤.៦៨៧ | ៥៧.៨៦៩ | ២២២.៥៧៦ | ២៣៥.៨១៦ |
| បំណុលហិរញ្ញវត្ថុសុទ្ធ | ៥៤.៦៨៧ | ៥៧.៨៦៩ | ២២២.៥៧៦ | ២៣៥.៨១៦ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

៣៣.គោលបំណង និងគោលនយោបាយក្នុងការគ្រប់គ្រងហានិភ័យ (ត)
*ហានិភ័យហិរញ្ញវត្ថុ(ត)*

(គ). ហានិភ័យអត្រាការប្រាក់
តារាងខាងក្រោមបង្ហាញពីភាពប្រែប្រួលនៃប្រាក់ចំណេញចំពោះការផ្លាស់ប្តូរអត្រាការប្រាក់សមរម្យ +/- ០,២៥% ។ ការផ្លាស់ប្តូរទាំងនេះត្រូវបានគេចាត់ទុកថាអាចធ្វើទៅបានដោយផ្អែកលើការសង្កេតលើលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន។ ការគណនា គឺផ្អែកលើការផ្លាស់ប្តូរអត្រាការប្រាក់ទីផ្សារជាមធ្យមសម្រាប់រយៈពេលនីមួយៗ និងឧបករណ៍ហិរញ្ញវត្ថុដែលបានធ្វើឡើងនៅកាលបរិច្ឆេទរបាយការណ៍នីមួយៗដែលងាយនឹងផ្លាស់ប្តូរអត្រាការប្រាក់។ អថេរផ្សេងទៀតទាំងអស់ត្រូវបានរក្សាថេរ។

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ | | | |
| | ពាន់ដុល្លារអាមេរិក | +០,២៥% លានរៀល (សម្គាល់ ៤.២) | ពាន់ដុល្លារ អាមេរិក | +០,២៥% លានរៀល (សម្គាល់ ៤.២) |
| សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | (១៣៧) | (៥៥៨) | ១៣៧ | ៥៥៨ |
| សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ | (១៤៥) | (៥៩១) | ១៤៥ | ៥៩១ |

(ឃ).ហានិភ័យរូបិយប័ណ្ណបរទេស
ហានិភ័យរូបិយប័ណ្ណបរទេស គឺជាហានិភ័យដែលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់នាពេលអនាគតរបស់ឧបករណ៍ហិរញ្ញវត្ថុនឹងមានការ ប្រែប្រួល ពីព្រោះតែមានការផ្លាស់ប្តូរក្នុងអត្រាប្តូរប្រាក់បរទេស។

ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេសរបស់សម្ព័ន្ធក្រុមហ៊ុន កើតឡើងពីប្រតិបត្តិការជារូបិយប័ណ្ណបរទេស រីងហ្គិត ម៉ាឡេស៊ី ("RM")។ ក្នុងអំឡុងនៃការិយបរិច្ឆេទ ការប៉ះពាល់របស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនចំពោះហានិភ័យនេះ គឺមានតិចតួចបំផុត ព្រោះប្រតិបត្តិការភាគច្រើនរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។

ការប្រឈមនឹងហានិភ័យរូបិយប័ណ្ណបរទេសរបស់សម្ព័ន្ធក្រុមហ៊ុនគឺអាស្រ័យលើសមតុល្យយោងគិតត្រឹមចុងបញ្ចប់ការិយបរិច្ឆេទមាន៖

| បានធ្វើប្រតិបត្តិការក្នុងរូបិយប័ណ្ណ RM | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) |
|---|---|---|---|---|
| សមតុល្យត្រូវសងទៅភាគីពាក់ព័ន្ធ | ៤២ | ៤២ | ១៧១ | ១៧១ |

*ការវិភាគលើហានិភ័យរូបិយប័ណ្ណបរទេស៖*
តារាងខាងក្រោម បង្ហាញពីហានិភ័យប្រាក់ចំណេញរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនក្នុងកាលបរិច្ឆេទក្នុង +/-៥% ការប្រែប្រួលនៅក្នុង រូបិយប័ណ្ណ RM គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ដើម្បីទូទាត់ជាមួយរូបិយប័ណ្ណគោលរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន អថេរផ្សេងទៀតទាំងអស់ត្រូវបានរក្សាថេរ៖

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | | សម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទ | |
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) |
| RM/ដុល្លារអាមេរិក | | | | |
| ខ្លាំង | (២) | (២) | (៨) | (៨) |
| ខ្សោយ | ២ | ២ | ៨ | ៨- |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា
៣០ មិថុនា ២០២២

## ៣៤.ភាគលាភ
ក្នុងអំឡុងពេលនេះ ភាគលាភដែលត្រូវទូទាត់ដោយក្រុមហ៊ុនទៅឱ្យម្ចាស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| | សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន | | | |
|---|---|---|---|---|
| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ពាន់ដុល្លារ អាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ពាន់ដុល្លារ អាមេរិក | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ លានរៀល (សម្គាល់ ៤.២) | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លានរៀល (សម្គាល់ ៤.២) |
| នៅក្នុងកាលបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១៖ | | | | |
| ០,០០៦៥ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុនដែលបានប្រកាសនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ និងបានទូទាត់ពេញលេញនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ | ៤៨៧ | - | ១.៩៨៥ | - |

## ៣៥.ការប្តេជ្ញាចិត្ត
ក្រុមហ៊ុន បានប្តេជ្ញាចិត្តក្នុងការទិញធានារ៉ាប់រងហានិភ័យនយោបាយរយៈពេល ១០ ឆ្នាំ សម្រាប់គម្រោងសាងសង់ប្រព័ន្ធបញ្ជូនថាមពលអគ្គិសនីតាមដងទន្លេ ២៣០ គីឡូវ៉ុល ស្ទឹងតាតៃ -ភ្នំពេញ ក្នុងតម្លៃសរុប ៤.៩៦៨.៦០០ ដុល្លារអាមេរិកដើម្បីធានាដល់ទីតាំងខ្ចីប្រាក់ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ ១៨ គ.៣។ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ សមតុល្យដែលមិនបានបង់មាន ២.០៨១.៤២៧ ដុល្លារអាមេរិក (ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១៖ មានសមតុល្យ ២.៧៦១.៧៣៣ ដុល្លារអាមេរិក)។

បន្ថែមពីនេះទៀត ក្រុមហ៊ុនបានប្តេជ្ញាចិត្តក្នុងទិញការធានារ៉ាប់រងហានិភ័យនយោបាយរយៈពេល៧ ឆ្នាំសម្រាប់ការសាងសង់បណ្តាញបញ្ជូនពីរខ្សែ ២៣០ គីឡូវ៉ុល និង៥០០ គីឡូវ៉ុល ពីភ្នំពេញទៅក្រុងព្រះសីហនុដែលមានសមតុល្យសរុប ៣.២២២.១២៥ ដុល្លារ អាមេរិក ដើម្បីធានាដល់ទីតាំងខ្ចីប្រាក់ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ទី ១៨ គ.៣ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ សមតុល្យដែលមិនបានបង់មានចំនួន ១.៨២៦.៦៤៦ ដុល្លារអាមេរិក (ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១៖ មានសមតុល្យ ២.៣២០.០០៥ ដុល្លារអាមេរិក)។

## ៣៦.ការគ្រប់គ្រងដើមទុន
គោលបំណងចម្បងនៃការគ្រប់គ្រងដើមទុនរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ដើម្បីធានាថារក្សាបាននូវអនុបាតដើមទុនគ្រប់គ្រាន់ដើម្បីគាំទ្រដល់អាជីវកម្មរបស់ក្រុមហ៊ុន និងបង្កើនតម្លៃជូនភាគហ៊ុនិកជាអតិបរមា។

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនគ្រប់គ្រងរចនាសម្ព័ន្ធដើមទុនរបស់ខ្លួន និងធ្វើការកែសម្រួលនៃការផ្លាស់ប្តូរនៅក្នុងលក្ខខណ្ឌសេដ្ឋកិច្ច។ ដើម្បីរក្សា ឬកែសម្រួលរចនាសម្ព័ន្ធដើមទុន ហើយសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន អាចកែសម្រួលភាគលាភដែលត្រូវបង់ជូនម្ចាស់ភាគហ៊ុន ការបង្វិលដើមទុនជូនទៅម្ចាស់ភាគហ៊ុន ឬអនុម័តដើមទុនថ្មី។ មិនមានការផ្លាស់ប្តូរណាមួយត្រូវបានធ្វើឡើងក្នុងគោលបំណង គោលនយោបាយ ឬដំណើរការនានាក្នុងការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និង២០២១នេះទេ។

## ៣៧.ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនៃរបាយការណ៍
ពុំមានព្រឹត្តិការណ៍សំខាន់ៗបានកើតឡើងបន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍ និងរហូតដល់កាលបរិច្ឆេទនៃសេចក្តីអនុម័តឱ្យចេញផ្សាយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ដែលតម្រូវឱ្យមានការកែតម្រូវ ឬធ្វើការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ។

## ៣៨.ការអនុម័តនៅលើរបាយការណ៍ហិរញ្ញវត្ថុ
របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និងសម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទត្រូវបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុនានា

៣០ មិថុនា ២០២២

This page is intentionally left blank.

# ព័ត៌មានអំពី
# ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ
# និងទំនាស់ផលប្រយោជន៍

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញពីព័ត៌មានប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធនៅក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយបញ្ជាក់ពីឈ្មោះ ទំនាក់ទំនងរវាងបុគ្គលចុះបញ្ជីលក់មូលបត្រ និងភាគីជាប់ពាក់ព័ន្ធ ទំហំនៃប្រតិបត្តិការ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងនោះដូចខាងក្រោម៖

ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកមានភាគហ៊ុនចាប់ពី ៥% ឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ។

| ក្រុមហ៊ុន | ទំនាក់ទំនង | ប្រតិបត្តិការ | ឆ្នាំបញ្ចប់ | | ឆ្នាំបញ្ចប់ | |
|---|---|---|---|---|---|---|
| | | | ៣០ មិថុនា ២០២២ | ៣០ មិថុនា ២០២១ | ៣០ មិថុនា ២០២២ | ៣០ មិថុនា ២០២១ |
| | | | 000 ដុល្លារអាមេរិក | 000 ដុល្លារអាមេរិក | លានរៀល | លានរៀល |
| PESTECH International Berhad | ក្រុមហ៊ុនហ៊ូលឌីង | ថ្លៃសេវាគ្រប់គ្រង | - | ៥៦៥ | - | ២ ៣០០ |
| PESTECH International Berhad | ក្រុមហ៊ុនហ៊ូលឌីង | ការប្រាក់ | ៨៤៦ | ៣៧១ | ៣ ៤៤០ | ១ ៥១០ |

ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់
ពុំមានប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ឡើយ។

គ. ប្រតិបត្តិការពាក់ព័ន្ធនឹងអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ/លក់ទ្រព្យសកម្ម និងសេវាកម្ម
ពុំមានប្រតិបត្តិការពាក់ព័ន្ធនឹងអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ/លក់ទ្រព្យសកម្ម និងសេវាកម្មក្នុងរយៈពេល២ (ពីរ) ឆ្នាំចុងក្រោយឡើយ។

ឃ. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥% ឡើងទៅ
ពុំមានប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥% ឡើងទៅ ក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយឡើយ។

ង. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះ កើតមាននៅក្នុងប្រតិបត្តិការណាមួយ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ
ពុំមានប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះ កើតមាននៅក្នុងប្រតិបត្តិការណាមួយ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រឡើយ។

ច. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធនឹងបុគ្គលធ្លាប់ជាអភិបាល
ពុំមានប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធនឹងបុគ្គលធ្លាប់ជាអភិបាលឡើយ។

ឆ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ
ពុំមានប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគមឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រឡើយ។

# ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ចំណូលសម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២២ បានកត់ត្រាត្រឹម ២១៦ ៣៥៥ លានរៀល ដែលបានថយចុះចំនួន៥៧ ២៧៣ លានរៀល ឬ ២០,៩៣% បើធៀបទៅនឹងឆ្នាំហិរញ្ញវត្ថុ ២០២១ ដែលបានកត់ត្រាត្រឹម ២៧៣ ៦២៨ លានរៀល។ ការផ្លាស់ប្តូរនៃចំណូលបង្ហាញពីការដំណើរការអនុវត្តគម្រោងនានានៅប្រទេសកម្ពុជា។ ការថយចុះនេះភាគច្រើនបណ្តាលមកពីចំណូលដែលទទួលបានមកពីដំណាក់កាលបញ្ចប់គម្រោងនៅបាវិតមានចំនួនតិចតួចនិងដំណើរការគម្រោងនៅភាគខាងកើតនៃខេត្តសៀមរាបដែលជិតបញ្ចប់បានផ្តល់ចំណែកកាន់តែតិចជាងមុន។

### ២. ការវិភាគចំណូលតាមផ្នែក

កិច្ចសន្យាវិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់ឲ្យដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គិសនី និងអនុស្ថានីយ៍គឺជាកត្តាចូលរួមដ៏សំខាន់សម្រាប់ចំណូលប្រចាំឆ្នាំមានទឹកប្រាក់ចំនួន ២០២ ៥០៨ លានរៀល (ឆ្នាំហិរញ្ញវត្ថុ ២០២១៖ ២៦០ ៨៥៤ លានរៀល) ដែលស្មើនឹងប្រមាណ ៩៣,៦ % (ឆ្នាំហិរញ្ញ វត្ថុ ២០២១៖ ៩៥,៣%) នៃចំណូលសរុប។
ការបំពេញបន្ថែមលើសេវាកម្ម EPCC ដែលជាប្រតិបត្តិការ និងសេវាថែទាំ ("O&M") ដែលស្មើនឹងប្រមាណ ១៣ ៨៤៧ លានរៀល ឬ ៦,៤% នៃចំណូលសរុប (ឆ្នាំ ២០២១៖ ១២ ៧៨៣ លានរៀល ឬ ៤.៧%)។

### ៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងឆ្នាំហិរញ្ញវត្ថុ ២០២២ ត្រូវបានកត់ត្រាត្រឹម ១៧,៥៦% បើធៀបទៅនឹង ១៦,៣៤% នៅក្នុងឆ្នាំហិរញ្ញវត្ថុ ២០២១ ដែលកើនឡើងចំនួន ១,២២%។ ការផ្លាស់ប្តូរនៃកម្រិតគម្លាតនៃចំណេញដុលពឹងលើការគម្លាតចំណេញរបស់គម្រោងនីមួយៗដែលបានបញ្ចប់ប្រចាំឆ្នាំ។ គម្លាតចំណេញដុលគឺស្ថិតក្នុងការរំពឹងទុករបស់ក្រុមហ៊ុន។

### ៤. ការវិភាគចំណេញ/(ខាត)មុនបង់ពន្ធ

ចំណេញមុនបង់ពន្ធ ("PBT") សម្រាប់ឆ្នាំហិរញ្ញវត្ថុនេះត្រូវបានកត់ត្រាត្រឹម ៥ ៤៨៣ លានរៀល ដែលថយចុះចំនួន ៤ ៦០៥ លានរៀល ឬ ៤៥,៦៥% បើធៀបទៅនឹង PBT សម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២១ ដែលមានចំនួន ១០ ០៨៨ លានរៀល ។ PBT ទាបបណ្តាលមកពីការចំណាយផ្នែកហិរញ្ញវត្ថុច្រើន បើធៀបនឹងឆ្នាំហិរញ្ញវត្ថុមុន។

### ៥. ការវិភាគចំណេញក្នុងការិយបរិច្ឆេទ

ចំណេញក្រោយពេលបង់ពន្ធ ("PAT") ត្រូវបានកត់ត្រាត្រឹម ២ ៤៧០ លានរៀល ដែលថយចុះចំនួន ៣ ៥១០លានរៀល បើធៀបទៅនឹង PAT សម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២១ ដែលមានចំនួន ៥ ៩៨០ លានរៀល។

## ខ. កត្តាសំខាន់ដែលប៉ះពាល់លើផលចំណេញ

ក្នុងឆ្នាំហិរញ្ញវត្ថុនេះមិនមានកត្តាសំខាន់ដែលប៉ះពាល់លើផលចំណេញរបស់ក្រុមហ៊ុននោះទេ។

## គ. បម្រែបម្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២២ ត្រូវបានកត់ត្រាត្រឹម ២១៦ ៣៥៥ លានរៀល ដែលថយចុះចំនួន ៥៧ ២៧៣ លានរៀល ឬ ២០,៩៣% បើធៀបទៅនឹងឆ្នាំហិរញ្ញវត្ថុ ២០២១ ត្រូវបានកត់ត្រារហូត ២៧៣ ៦២៨ លានរៀល។ ការផ្លាស់ប្តូរនៃចំណូលបង្ហាញពីការដំណើរការអនុវត្តគម្រោងនានានៅប្រទេសកម្ពុជា។ ការថយចុះនេះភាគច្រើនបណ្តាលមកពីការបញ្ចប់គម្រោងនៅបាវិត និងដំណើរការគម្រោងនៅភាគខាងកើតនៃខេត្តសៀមរាបដែលខិតជិតមកដល់ការបញ្ចប់។

# ការពិភាក្សា និងការវិភាគ របស់គណៈគ្រប់គ្រង

ឃ.　ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ

ចំណូលពីការលក់ និងការទិញរបស់យើង ភាគច្រើនត្រូវបានធ្វើឡើងជាដុល្លារអាមេរិក។ ដូច្នេះ យើងមិនទទួលរងផលប៉ះពាល់យ៉ាងខ្លាំងក្លាពីការឡើងចុះនៃអត្រាប្តូររូបិយប័ណ្ណបរទេសនៅក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ នេះទេ។ ការប្រឈមមុខនឹងអត្រាប្តូររូបិយប័ណ្ណបរទេសភាគច្រើនបណ្តាលមកពីការរាយការណ៍។

សម្រាប់ហានិភ័យនៃអត្រាការប្រាក់ ផថខ ប្រឈមមុខនឹងបម្រែបម្រួលតាមរយៈលិខិតូបករណ៍នៃអត្រាការប្រាក់អណ្តែតពោលគឺការខ្ចីប្រាក់នៅក្នុងអត្រាអថេរ។

ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីការឡើងចុះនៃតម្លៃទំនិញឡើយ។

ង.　ផលប៉ះពាល់នៃអតិផរណា

ការចំណាយសម្រាប់អាជីវកម្មគឺដោយសារផលប៉ះពាល់នៃអតិផរណាដែលមានចំនួនប្រហែល ១៤% នៃចំណូលរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ អតិផរណានៅក្នុងប្រទេសកម្ពុជាមានចំនួន ៦,៥% (គិតត្រឹម ថ្ងៃទី៣ ខែសីហា ឆ្នាំ ២០២២ ប្រភព៖ខ្មែរថាមស៍៖អតិផរណានៅក្នុងប្រទេសកម្ពុជារំពឹងថានឹងធ្លាក់ចុះដល់ ៣,២ភាគរយ) ដែលបានបង្កផលប៉ះពាល់ប្រហែល ១% តែប៉ុណ្ណោះចំពោះប្រាក់ចំណេញរបស់យើង។ រាល់ចំណាយប្រតិបត្តិការទាំងអស់មានតម្លៃថេរនៅក្នុងអំឡុងពេលនៃកិច្ចសន្យាទាំងមូល។ ក្រៅពីការលើកឡើងខាងលើពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀតដែលបណ្តាលមកពីអតិផរណាឡើយ។

ច.　គោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬ កត្តានានាដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុ នៅក្នុងអំឡុងឆ្នាំនេះនោះទេ។

# ព័ត៌មានចាំបាច់ផ្សេងទៀត សម្រាប់ការការពារវិនិយោគិន

លោក Charles Tan នាយកប្រតិបត្តិមានភារកិច្ចត្រួតពិនិត្យសកម្មភាពអភិវឌ្ឍន៍សាជីវកម្មដល់ **ផថខ** ដែលពាក់ព័ន្ធនឹងទំនាក់ទំនងវិនិយោគិន។ គាត់បានចូលរួមជានិច្ចជាមួយនឹងអ្នកវិភាគ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីលើកកម្ពស់សក្តានុពលកំណើនសាជីវកម្មរបស់ **ផថខ** ព្រមទាំងធ្វើបច្ចុប្បន្នភាពជាប្រចាំជាមួយការអភិវឌ្ឍន៍ថ្មីៗរបស់ក្រុមហ៊ុន។

គេហទំព័រសាជីវកម្មរបស់ **ផថខ** www.pestech.com.kh ជាគន្លឹះសំខាន់សម្រាប់ភាគហ៊ុនិក វិនិយោគិន សមាជិកសាធារណជន និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីទទួលបាននូវព័ត៌មានថ្មីៗអំពីសកម្មភាពក្រុមហ៊ុន លទ្ធផលហិរញ្ញវត្ថុការអភិវឌ្ឍន៍យុទ្ធសាស្រ្តសំខាន់ៗ និងបញ្ហាផ្សេងៗទៀតដែលប៉ះពាល់ដល់ផលប្រយោជន៍នៃភាគីពាក់ព័ន្ធ។

# ហត្ថលេខារបស់អភិបាលនៃ ផេសថិក (ខេមបូឌា) ម.ក

កាលបរិច្ឆេទ៖ ២១ កញ្ញា ២០២២

បានអាន និងឯកភាពដោយ៖






ហត្ថលេខា

ឈ្មោះ៖ Paul Lim Pay Chuan

មុខតំណែង៖ ប្រធានក្រុមប្រឹក្សាភិបាល

កាលបរិច្ឆេទ៖ ២១ កញ្ញា ២០២២

បានអាន និងឯកភាពដោយ៖



ហត្ថលេខា

ឈ្មោះ៖ Lim Ah Hock

មុខតំណែង៖ អភិបាលប្រតិបត្តិ

កាលបរិច្ឆេទ៖ ២១ កញ្ញា ២០២២

បានអាន និងឯកភាពដោយ៖



ហត្ថលេខា

ឈ្មោះ៖ Han Fatt Juan

មុខតំណែង៖ អភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ

កាលបរិច្ឆេទ៖ ២១ កញ្ញា ២០២២

បានអាន និងឯកភាពដោយ៖



ហត្ថលេខា

ឈ្មោះ៖ Charles Tan Pu Hooi

មុខតំណែង៖ អភិបាលប្រតិបត្តិ

កាលបរិច្ឆេទ៖ ២១ កញ្ញា ២០២២

បានអាន និងឯកភាពដោយ៖



ហត្ថលេខា

ឈ្មោះ៖ ដាវ អានសាន

មុខតំណែង៖ អភិបាលឯករាជ្យ

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី១ - ភាគហ៊ុនិក

### ក. រចនាសម្ព័ន្ធភាគហ៊ុនិក

**ព័ត៌មានភាគហ៊ុនិក** (គិតត្រឹម ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២)

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៩៧៩ | ៧៣២,០៤២ | 0.៩៨% |
| | | នីតិបុគ្គល | ២ | ១៦៥,០៦៨ | 0.២២% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១១១ | ៤១៦,៣១១ | 0.៥៦% |
| | | នីតិបុគ្គល | ១ | ២,៦៣១,៥៧៩ | ៣.៥១% |
| ចាប់ពី ៥% ដល់ ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | 0 | 0 | 0.00% |
| | | នីតិបុគ្គល | 0 | 0 | 0.00% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | 0 | 0 | 0.00% |
| | | នីតិបុគ្គល | 0 | 0 | 0.00% |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | 0 | 0 | 0.00% |
| | | នីតិបុគ្គល | 0 | 0 | 0.00% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | 0 | 0 | 0.00% |
| | | នីតិបុគ្គល | ១ | ៧១,000,000 | ៩៤.៧៤% |
| | | | | ៧៤,៩៤៥,000 | ១00.00% |

ភាគហ៊ុនិកដែលជាអភិបាលនិងជានិយោជិតរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ (គិតត្រឹមថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២)

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ (%) |
|---|---|---|---|
| អភិបាល | ៤ | ១៦៥,៣០៥ | 0.២២ |
| និយោជិត | ៤៧ | ១១៤,៤៤២ | 0.១៥ |
| សរុប | ៥១ | ២៧៩,៧៤៧ | 0.៣៧ |

### ខ. សិទ្ធិរបស់ភាគហ៊ុនិកនិងការការពារសិទ្ធិរបស់ភាគហ៊ុនិក

ការការពារសិទ្ធិរបស់ភាគហ៊ុនិកនិងសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិចនិងការអនុវត្តរបស់ក្រុមហ៊ុនក្នុងការការពារសិទ្ធិរបស់ភាគហ៊ុនិកដូចខាងក្រោម៖

ក) ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនធម្មតា មានសិទ្ធិបោះឆ្នោតពេញលេញដោយ ១ ភាគហ៊ុន ស្មើនឹង ១ សម្លេង។

ខ) ករណីមានការរំលាយក្រុមហ៊ុន ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនធម្មតាមានសិទ្ធិទទួលបានទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបន្ទាប់ពីមានការរំលាយក្រុមហ៊ុនទៅតាមចំណែកភាគហ៊ុនដែលខ្លួនកាន់កាប់។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

គ) ភាគហ៊ុនិកម្នាក់ៗមានសិទ្ធិ:

- បោះឆ្នោត និងបញ្ចេញមតិក្នុងរាល់កិច្ចប្រជុំភាគហ៊ុនិករបស់ក្រុមហ៊ុន
- ទទួលបានភាគលាភដែលបានប្រកាសដោយក្រុមហ៊ុន
- ទទួលបានទ្រព្យសម្បត្តិដែលនៅសល់របស់ក្រុមហ៊ុនបន្ទាប់ពីការរំលាយក្រុមហ៊ុន
- ពិនិត្យបញ្ជីឈ្មោះរបស់ភាគហ៊ុនិកទាំងឡាយបាននៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬ នៅកន្លែងរក្សាទុកបញ្ជីលក់មូលបត្រនោះនៅក្នុងម៉ោងធ្វើការ ឬពេលប្រជុំមហាសន្និបាតភាគហ៊ុ និកដែលបញ្ជីឈ្មោះត្រូវបានរៀបចំ និង
- អាចពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនក្នុងម៉ោងធ្វើការ និងទទួលបានរបាយការណ៍នេះដោយឥតគិតថ្លៃយោងតាមមាត្រា ២២៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

## គ. មហាសន្និបាតភាគហ៊ុនិក

១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

ក) ភាគហ៊ុនិកអាចចូលរួមបោះឆ្នោតដោយផ្ទាល់ឬដោយអាណត្តិគាហកៈតាមរយៈលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខា កាលបរិច្ឆេទ និងភ្ជាប់មកជាមួយនូវព័ត៌មានដូចខាងក្រោម៖

(i) ចំនួនភាគហ៊ុនដែលកាន់កាប់ដោយភាគហ៊ុនិក
(ii) ឈ្មោះ និងអាសយដ្ឋានរបស់អាណត្តិគាហកៈ និង
(iii) រយៈពេលនៃការតែងតាំងអាណត្តិគាហកៈ

ខ) ប្រសិនបើអាណត្តិគាហកៈស្នើសុំធ្វើការបោះឆ្នោតនៅក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក នោះលិខិតផ្ទេរសិទ្ធិជាអាណត្តិគាហកៈត្រូវរក្សាទុកនៅប្រធានក្រុមប្រឹក្សាភិបាលនៅមុនពេល ឬនៅអំឡុងពេលចាប់ផ្តើមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។

គ) រាល់កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកគឺតម្រូវឲ្យភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីចូលរួមដោយផ្ទាល់ឬអាណត្តិគាហកៈភាគហ៊ុនទាំងអស់មានសិទ្ធិបោះឆ្នោតលើរបៀបវារៈណាមួយនឹងបង្កើតជាកូរ៉ុមសម្រាប់ក្រុមនោះហើយធ្វើការបោះឆ្នោតសម្រាប់ចំណាត់ការលើរបៀបវរៈនោះ។ នៅពេលភាគហ៊ុនរួមតែមួយត្រូវបានជាតំណាងនៅក្នុងកិច្ចប្រជុំក្រៅពីគោលបំណងរៀបចំកិច្ចប្រជុំឬធ្វើប្រតិបត្តិការអាជីវកម្មភាគហ៊ុននោះត្រូវបានចាត់ទុកថាមានវត្តមានសម្រាប់គោលបំណងកូរ៉ុមសម្រាប់ផ្នែកផ្សេងទៀតនៃកិច្ចប្រជុំនិងសម្រាប់ការលើកកិច្ចប្រជុំទៅកាលបរិច្ឆេទ ពេលវេលា ឬទីកន្លែងថ្មី លើកលែងតែកាលបរិច្ឆេទកំណត់ទុកថ្មីត្រូវបានឬដាច់ខាតត្រូវបានកំណត់សម្រាប់ការលើកពេលការប្រជុំ ។

ឃ) ករណីគ្រប់កូរ៉ុម របៀបវារៈមួយត្រូវបានអនុម័តដោយផ្អែកលើសម្លេងភាគច្រើននៃអ្នកចូលរួមបោះឆ្នោត ដែលមានន័យថាសម្លេងអ្នកបោះឆ្នោតស្រប ត្រូវច្រើនជាងសម្លេងអ្នកបោះឆ្នោតប្រឆាំង លើកលែងតែច្បាប់និងបទប្បញ្ញត្តិឬលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្ទុយពីនេះ។

ង) ពេលអនុវត្តសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក ការបោះឆ្នោតត្រូវឈរលើគោលការណ៍មួយភាគហ៊ុន មួយសម្លេង។ មានតែភាគហ៊ុនិកដែលបានចុះឈ្មោះត្រឹមត្រូវនិងបានទូទាត់ប្រាក់គ្រប់ចំនួនទៅឲ្យក្រុមហ៊ុនទើបមានសិទ្ធិបោះឆ្នោតដោយផ្ទាល់ឬដោយអាណត្តិគាហកៈនៅក្នុងមហាសន្និបាតភាគហ៊ុនិក។

ច) ការសម្រេចរបស់ភាគហ៊ុនិកដែលចងភ្ជាប់កាតព្វកិច្ចក្រុមហ៊ុនលុះត្រាតែធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់ភាគហ៊ុនិក។ សេចក្តីសម្រេចរបស់ភាគហ៊ុនិកតម្រូវឲ្យមានការបោះឆ្នោតគាំទ្រយ៉ាងហោចណាស់ដោយសម្លេងភាគច្រើននៃភាគហ៊ុនមានសិទ្ធិបោះឆ្នោត ដែលកាន់កាប់ដោយភាគហ៊ុនិកនិងអាណត្តិគាហកៈនៅក្នុងកិច្ចប្រជុំ ក្នុងករណីសេចក្តីសម្រេចធម្មតានិងក្នុងករណីសេចក្តីសម្រេច ត្រូវធ្វើឡើងដោយសម្លេងភាគច្រើនដាច់ខាត គឺមិនតិចជាង ២/៣ (ពីរភាគបី )។ សេចក្តីសម្រេចរបស់ភាគហ៊ុនិកមិនអាចយកជាការបានឡើយ ប្រសិនបើមិនគោរពតាមលក្ខខណ្ឌដែលការអនុម័តនេះ។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

២. ព័ត៌មានអំពីមហាសន្និបាតភាគហ៊ុនិក

មហាសន្និបាទភាគហ៊ុនិកបានធ្វើឡើងកាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ដោយមានភាគហ៊ុននិកភាគច្រើន បានចូលរួមនិងបានអនុម័តនូវសេចក្តីសម្រេចដូចខាងក្រោម៖

ក) ការទទួលបានលទ្ធផលអាជីវកម្មប្រចាំឆ្នាំសម្រាប់ឆ្នាំហិរញ្ញវត្ថុបានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១

ខ) អនុម័តលើលាភការ របស់ក្រុមប្រឹក្សាភិបាល

គ) អនុម័តលើការតែងតាំងអភិបាលប្រតិបត្តិបន្តទៀត
(i) លោក Paul Lim Pay Chuan
(ii) លោក Lim Ah Hock
(iii) លោក Han Fatt Juan
(iv) លោក Charles Tan Pu Hooi

ឃ) អនុម័តលើការបែងចែងភាគលាភចំនួន ០,០០៦៥ ក្នុងមួយភាគហ៊ុនសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១

ង) អនុម័តលើអំណាចក្នុងការកំណត់ និងបែងចែកភាគលាភសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២

ច) អនុម័តលើអំណាចក្នុងការចេញនិងបែងចែកហ៊ុនស្របតាមលក្ខន្តិកៈក្រុមហ៊ុន

ឆ) អនុម័តលើការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន

ជ) អនុម័តលើវិសោធនកម្មរបស់លក្ខន្តិកៈក្រុមហ៊ុន ដោយលុបចោលមាត្រាចាស់ចោលនិងជំនួសវិញដោយមាត្រាថ្មីសេចក្តីលម្អិតបានដាក់ជូននៅក្នុងសេចក្តីជូនដំណឹងរបស់មហាសន្និបាតរបស់ភាគហ៊ុនិក។

## ឃ. ការបែងចែកភាគលាភ

### គោលការណ៍បែងចែកភាគលាភ

**ថផក** មានបំណងបែងចែកភាគលាភអប្បបរមាចំនួនសាមសិបភាគរយ (៣០%) នៃប្រាក់ចំណេញរបស់ខ្លួនបន្ទាប់ពីកាត់ពន្ធរួចដោយយោងទៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍សាច់ប្រាក់ ប្រាក់ចំណេញរក្សាទុកចំណាយមូលធន និងកត្តាផ្សេងទៀតដែលក្រុមប្រឹក្សាភិបាលគិតថាជាប់ពាក់ព័ន្ធ។

ក្រុមហ៊ុនអាចពិចារណាបែងចែកភាគលាភជាសាច់ប្រាក់ ជាភាគហ៊ុនសម្រាប់វិនិយោគនៅក្នុងក្រុមហ៊ុន ឬជម្រើសទាំងពីរបញ្ចូលគ្នា។ នៅពេលមានជម្រើស ភាគហ៊ុនិកអាចមានសិទ្ធិជ្រើសរើសយកកាបែងចែកភាគហ៊ុនជាសាច់ប្រាក់ ជាភាគហ៊ុន ឬជម្រើសទាំងពីរដោយគោរពទៅតាមច្បាប់និងបទប្បញ្ញត្តិតម្រូវនៃព្រះរាជាណាចក្រកម្ពុជា។

### ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល៣ឆ្នាំចុងក្រោយ

ក្រុមប្រឹក្សាភិបាលបានប្រកាសបែងចែកភាគលាភចំនួន ០.០០៦៥ ដុល្លារអាមេរិក ក្នុងមួយហ៊ុនសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។ ភាគលាភត្រូវបានបង់ជូនភាហ៊ុនិកទាំងអស់នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ស្របតាមកំណត់ត្រានៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ផ្នែកទី ២- ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទចាប់ផ្ដើមអាណត្តិជាអភិបាល | កាលបរិច្ឆេទផុតកំណត់អាណត្តិជាអភិបាល |
|---|---|---|---|---|
| ១ | Paul Lim Pay Chuan | ប្រធានក្រុមប្រឹក្សាភិបាល | ៥ កុម្ភៈ ២០១០ | ៩ ធ្នូ ២០២៣ |
| ២ | Lim Ah Hock | អភិបាលប្រតិបត្តិ | ៥ កុម្ភៈ ២០១០ | ៩ ធ្នូ ២០២៣ |
| ៣ | Han Fatt Juan | អភិបាលប្រតិបត្តិ /នាយកប្រតិបត្តិ | ២៧ មិថុនា ២០១៨ | ៩ ធ្នូ ២០២៣ |
| ៤ | Charles Tan Pu Hooi | អភិបាលប្រតិបត្តិ | ២៧ មិថុនា ២០១៨ | ៩ ធ្នូ ២០២៣ |
| ៥ | ឯកឧត្តម ដាវ អានសាន | អភិបាលឯករាជ្យ | ២៩ សីហា ២០១៨ | ២៨ សីហា ២០២៣ |

## ប្រវត្តិរូបសង្ខេបរបស់អភិបាល

### PAUL LIM PAY CHUAN,
### ប្រធានក្រុមប្រឹក្សាភិបាល

លោក PAUL LIM PAY CHUAN មានសញ្ជាតិម៉ាឡេស៊ី អាយុ ៥២ ឆ្នាំ ជាប្រធានក្រុមប្រឹក្សាភិបាលដែលបានតែងតាំងនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០។

គាត់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រវិស្វកម្មអគ្គិសនី នៅសាកលវិទ្យាល័យ Mississippi សហរដ្ឋអាមេរិក (Summa Cum Laude) នៅឆ្នាំ១៩៩៣។ ក្រោយមកគាត់បានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតវិស្វកម្ម (អគ្គិសនី) ពីសាកលវិទ្យាល័យ Cornell University សហរដ្ឋអាមេរិកក្នុងឆ្នាំ ១៩៩៤។ បច្ចុប្បន្នគាត់បានចុះឈ្មោះជាសមាជិកនៃវិទ្យាស្ថានវិស្វករម៉ាឡេស៊ីនិងវិស្វករវិជ្ជាជីវៈជាមួយក្រុមប្រឹក្សាភិបាលវិស្វករ ម៉ាឡេស៊ីនៅ ឆ្នាំ២០០៧ ក្នុងវិស័យវិស្វកម្មអគ្គិសនី។ ចាប់តាំងពីឆ្នាំ២០១១ គាត់ក៏ជាអ្នកគ្រប់គ្រងគម្រោងវិជ្ជាជីវៈ ដែលមានបញ្ជាក់ពីវិទ្យាស្ថានគ្រប់គ្រងគម្រោងសមាគមវិជ្ជាជីវៈសកលដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកនិងមានការិយាល័យប្រចាំតំបន់ទូទាំងពិភពលោក។ គាត់បានចុះបញ្ជីជាវិស្វករជំនាញនៃធម្មនុញ្ញអាស៊ានចាប់តាំងពីឆ្នាំ២០១៦។ នៅឆ្នាំ២០១៧ គាត់បានចុះបញ្ជីនៅក្រោមបញ្ជីឈ្មោះសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិកនិងបញ្ជីអន្តរជាតិនៃវិស្វករអាជីពនិងវិស្វករអាស៊ាន។

នៅឆ្នាំ១៩៩៤ លោកបានចាប់ផ្តើមវិជ្ជាជីវៈជាមួយនឹងក្រុមហ៊ុន Motorola Malaysia Sdn Bhd ក្នុងនាមជាវិស្វករផលិតផលម្នាក់។ បន្ទាប់មកនៅឆ្នាំ១៩៩៥ លោកបានចូលរួមជាមួយនឹងក្រុមហ៊ុន Toprank Corporation Sdn Bhd (បច្ចុប្បន្នដែលគេស្គាល់ថាជា ក្រុមហ៊ុន Toshiba Transmission & Distribution System Asia Sdn Bhd) ក្នុងនាមជាវិស្វករគម្រោង ដែលនៅទីនោះលោកត្រូវបានឡើងតំណែងជាប្រធានគម្រោងនៅឆ្នាំ១៩៩៧ និងបន្ទាប់មក ក្លាយជាជំនួយការនាយកគ្រប់គ្រងទូទៅនៅឆ្នាំ១៩៩៨។ នៅឆ្នាំ២០០០ លោកបានចូលរួមជាមួយក្រុមហ៊ុនសម្ព័ន្ធផសចិក ក្នុងតួនាទីជាប្រធានគ្រប់គ្រងទូទៅនិងបានឡើងដំណែងជានាយកប្រតិបត្តិក្នុងឆ្នាំ២០០៨។

លោកបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរីកចម្រើននិងអភិវឌ្ឍន៍របស់សម្ព័ន្ធក្រុមហ៊ុនផសចិកដោយចាប់ផ្តើមពីក្រុមហ៊ុនខ្នាតតូចរហូតក្លាយជាក្រុមហ៊ុនបច្ចេកវិទ្យាថាមពលអគ្គិសនីនៅក្នុងវិស័យអាជីវកម្មចែកចាយនិងបញ្ជូនថាមពលជាមួយនឹងប្រតិបត្តិការនៅក្នុងស្រុកនិងបណ្ដាប្រទេសជាច្រើនទៀត។

នៅឆ្នាំ២០១០ គាត់ទទួលបានពានរង្វាន់សហគ្រិនឆ្នើមប្រចាំ ឆ្នាំ២០១០ ដោយសហគ្រាសអាស៊ីដោយសារការយកចិត្តទុកដាក់និងភាពជាអ្នកដឹកនាំរបស់គាត់ក្នុងការដឹកនាំក្រុមដើម្បីក្លាយជាតួអង្គសំខាន់ក្នុងអាជីវកម្មបញ្ជូននិងចែកចាយថាមពលក្នុងនិងក្រៅប្រទេស។

មកដល់បច្ចុប្បន្នបញ្ជីឈ្មោះដឹកនាំដោយ PAUL LIM មានដូចខាងក្រោម៖

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

| បញ្ជីឈ្មោះក្រុមហ៊ុនលោកដឹកនាំ | | |
|---|---|---|
| PESTECH International Berhad | PESTECH Power One Sdn Bhd | BETSOL (Sarawak) Sdn Bhd |
| Astoria Solar Farm Sdn Bhd | PESTECH REI Sdn Bhd | BETSOL International Sdn Bhd |
| CRSE Sdn Bhd | PESTECH Sdn Bhd | BETSOL Sdn Bhd |
| Diamond Power Ltd | PESTECH Solutions Sdn Bhd | Enlightyx Sdn Bhd |
| Enersol Co., Ltd | PESTECH System Siam Ltd | Fornix Biotech Sdn Bhd |
| Fornix Sdn Bhd | PESTECH Technology Sdn Bhd | Fornix Capital Sdn Bhd |
| Forward Metal Works Sdn Bhd | PESTECH Transmission Sdn Bhd | Fornix Foodstuffs Sdn Bhd |
| PESTECH (Brunei) Sdn Bhd | PESTECH Transmission Ltd | Imbiss Sdn Bhd |
| PESTECH (Myanmar) Limited | PESTECH Vietnam Company Limited | JAP Wylis Sdn Bhd |
| PESTECH (PNG) Ltd | PESTECH Hinthar Corporation Limited | Mercula Sdn Bhd |
| PESTECH (Sarawak) Sdn Bhd | PESTECH Microgrid Co. Ltd | PC Wylis Sdn Bhd |
| PESTECH Aerotrain Sdn Bhd | PESTECH Power Sdn Bhd | Riviera Wylis Sdn Bhd |
| PESTECH Energy Sdn Bhd | PESTECH Transmission CDI SARL | Wylis Corporation Sdn Bhd |
| PESTECH GTI Sdn Bhd | PESTECH Corporation | Wylis Sdn Bhd |
| ODM Power Line Company Limited | Asiapac Builders Sdn Bhd | Transmission Energy Inc |
| Green Sustainable Ventures (Cambodia) Co. Ltd. | Asiapac Machineries Sdn Bhd | PESTECH Pluginfinite Sdn Bhd |

**LIM AH HOCK**

លោក Lim Ah Hock មានសញ្ជាតិម៉ាឡេស៊ី អាយុ ៧០ ឆ្នាំ ជាអភិបាល ថផខ។ លោកត្រូវបានតែងតាំងនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០។

នៅឆ្នាំ១៩៧៨ លោកបានទទួលបរិញ្ញបត្រផ្នែកវិទ្យាសាស្ត្រជំនាញវិស្វកម្មមេកានិក (ជ័យលាភីក្រុមលំដាប់លេខមួយ) ពីសាកលវិទ្យាល័យ Strathclyde ក្រុង Glasgow ប្រទេសអង់គ្លេស។ លោកជាសមាជិកនៃវិទ្យាស្ថានវិស្វករប្រទេសម៉ាឡេស៊ីចាប់តាំងពីឆ្នាំ១៩៨១។

នៅឆ្នាំ១៩៧៩ លោកបានចាប់ផ្តើមវិជ្ជាជីវៈជាសាស្ត្រាចារ្យនៅសាលាបច្ចេកទេស Ngee Ann នៅប្រទេសសិង្ហបុរី (នៅឆ្នាំ១៩៨២ ត្រូវបានប្តូរឈ្មោះជាសាលាពហុបច្ចេកទេស Ngee Ann) ដោយលោកបានទទួលបន្ទុកបង្រៀនមុខវិជ្ជាទែម៉ូឌីណាមិច និងមេកានិចរាវ (thermo dynamics and fluid mechanics)។ នៅឆ្នាំ១៩៨០ លោកបានចូលរួមជាមួយក្រុមហ៊ុន Mechmar Kejuruteraan Sdn Bhd ("Mechmar") ក្នុងនាមជាវិស្វករសេវាកម្ម ដែលនៅទីនោះលោកគ្រប់គ្រងលើផ្នែកសេវាកម្មនិងការផ្តល់សេវាកម្មក្រោយលក់និងការជួសជុលម៉ាស៊ីនកម្តៅធំៗ។ បន្ទាប់មកទៀត លោកបានចាកចេញពីក្រុមហ៊ុន Mechmar នៅឆ្នាំ១៩៨៤ និងបានចូលរួមជាមួយនឹងក្រុមហ៊ុន Sing Mah Pressure Vessels Co. ក្នុងនាមជាប្រធានសាខាអំឡុងឆ្នាំ១៩៨៤ និង១៩៨៩ ដែលនៅទីនោះលោកទទួលបន្ទុកក្នុងការលក់ទាំងស្រុងនៅភាគខាងត្បូងរហូតដល់វិស័យឧស្សាហកម្មចម្រាញ់ដូងប្រេង ចំណីអាហារ និងឧស្សាហកម្មឈើ ក៏ដូចជាឧស្សាហកម្មទាំងឡាយដែលមាននៅភាគខាងត្បូងឧបទ្វីប Sabah និង Sarawak។ នៅឆ្នាំ១៩៨៩ លោកបានក្លាយជាអភិបាលនៃក្រុមហ៊ុន VESTECH Engineering Sdn Bhd ដល់បច្ចុប្បន្ន។

នៅឆ្នាំ១៩៩១ លោកបានបង្កើតក្រុមហ៊ុន PSB នៅ Johor Bahru ប្រទេសម៉ាឡេស៊ី។ មកទល់បច្ចុប្បន្ន តួនាទីរបស់លោកនៅក្នុងសម្ព័ន្ធក្រុមហ៊ុនផេសថិកគឺទទួលបន្ទុកផ្នែកផែនការអភិវឌ្ឍអាជីវកម្មធំៗតម្រង់ទិសដៅអភិវឌ្ឍម៉ាក្រូអាជីវកម្មជាមួយនាយកប្រតិបត្តិត្រួតពិនិត្យមើលស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពរបស់សម្ព័ន្ធ ក្រុមហ៊ុនផេសថិក ដែលរួមមានផ្តល់ការណែនាំក្នុងការគ្រប់គ្រង និងដឹកនាំបុគ្គលិក។

មកដល់បច្ចុប្បន្ននេះបញ្ជីឈ្មោះដឹកនាំដោយលោក Lim Ah Hock មានដូចខាងក្រោម៖

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

**បញ្ជីឈ្មោះក្រុមហ៊ុនលោកដឹកនាំ**

| | | |
|---|---|---|
| PESTECH International Berhad | PESTECH Energy Sdn Bhd | PESTECH Solutions Sdn Bhd |
| Astoria Solar Farm Sdn Bhd | PESTECH Engineering Technology China Co., Ltd | PESTECH System Siam Ltd |
| CRSE Sdn Bhd | PESTECH GTI Sdn Bhd | PESTECH Technology Sdn Bhd |
| Diamond Power Ltd | PESTECH Hinthar Corporation Limited | PESTECH Transmission Sdn Bhd |
| Enersol Co., Ltd | PESTECH Power Sdn Bhd | Asiapac Machineries Sdn Bhd |
| Fornix Sdn Bhd | PESTECH Power One Sdn Bhd | Fornix Biotech Sdn Bhd |
| Forward Metal Works Sdn Bhd | PESTECH REI Sdn Bhd | Fornix Capital Sdn Bhd |
| PESTECH (Sarawak) Sdn Bhd | PESTECH Sdn Bhd | Fornix Foodstuffs Sdn Bhd |
| PESTECH Aerotrain Sdn Bhd | ODM Power Line Company Limited | Vestech Engineering Sdn Bhd |
| | | PESTECH Pluginfinite Sdn Bhd |

## HAN FATT JUAN

លោក Han Fatt Juan មានសញ្ជាតិម៉ាឡេស៊ី អាយុ ៥៧ ឆ្នាំ ជាអភិបាលប្រតិបត្តិនិងជានាយកប្រតិបត្តិរបស់ **ផថខ**។ លោកត្រូវបានតែងតាំងជាក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។

លោកទទួលបន្ទុកក្នុងការសម្រេចឲ្យបាននូវគោលដៅចំណូលនិងចំណេញរបស់ក្រុមហ៊ុនឲ្យស្របតាមគម្រោងអាជីវកម្មរបស់ក្រុមហ៊ុន និងធានាឲ្យបាន់ថាក្រុមហ៊ុនមានគោលដៅផែនការនិងថវិកាដែលតម្រូវដើម្បីសម្រេចគោលដៅហិរញ្ញវត្ថុនិងប្រតិបត្តិការរយៈពេលខ្លីនិងរយៈពេលវែងដូចដែលបានកំណត់ទុកក្នុងផែនការអាជីវកម្មក្រុមហ៊ុន។

នៅឆ្នាំ១៩៨៤ លោកបានចាប់ផ្តើមវិជ្ជាជីវៈជាអ្នកត្រួតពិនិត្យការដ្ឋាននៅក្រុមហ៊ុន Metral Villar Sdn Bhd ដោយទទួលបន្ទុកក្នុងការត្រួតពិនិត្យមើលនិងសម្របសម្រួលសកម្មភាពរបស់កម្មករទាក់ទងនឹងការដឹកនិងការលាយស៊ីម៉ង់។ នៅឆ្នាំ១៩៨៨ លោកបានចាកចេញពីក្រុមហ៊ុនដើម្បីបន្តការសិក្សានៅសាកលវិទ្យាល័យ South Dakota State សហរដ្ឋអាមេរិក។ អំឡុងពេលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅទីនោះ លោកបាន បំពេញការងារជាជំនួយការបង្រៀននៅសាកលវិទ្យាល័យ South Dakota State សហរដ្ឋអាមេរិក។ នៅឆ្នាំ ១៩៩២ លោកបានចូលរួមជាមួយក្រុមហ៊ុន Zafas Sdn Bhd ក្នុងនាមជាវិស្វករការដ្ឋាននិងបានចំណាយពេលនៅទីនោះអស់រយៈពេល១៧ឆ្នាំ រហូតដល់ឆ្នាំ២០០៩ លោកត្រូវបានតម្លើងជានាយកគម្រោង។ អំឡុងពេលបំពេញការងារ លោកបានចូលរួមគម្រោងជាច្រើនរួមមានការងារតម្លើងខ្សែកាបក្រោមដីនិងខ្សែ បណ្តាញបញ្ជូនថាមពលឆ្លងកាត់ប្រទេសម៉ាឡេស៊ីនិងប្រទេសប្រ៊ុយណេ។

ក្នុងឆ្នាំ២០០៩ លោកបានចូលរួមជាមួយក្រុមហ៊ុនសម្ព័ន្ធផេសថិក ក្នុងតួនាទីជាប្រធានគម្រោងនិងត្រូវបានតែងតាំងជាប្រធានគ្រប់គ្រងទូទៅ(GM) ក្នុងគម្រោងយុទ្ធសាស្ត (ការអភិវឌ្ឍន៍អាជីវកម្ម) នៅឆ្នាំ ២០១១ ក្រោយមកក្លាយជាប្រធានគ្រប់គ្រងទូទៅផ្នែកបណ្តាញថាមពល និងខ្សែកាបរបស់សម្ព័ន្ធក្រុមហ៊ុនផេសថិក។ ក្នុងនាមជាប្រធានគ្រប់គ្រងទូទៅផ្នែកបណ្តាញថាមពលនិងខ្សែកាប ក្រុមរបស់លោកទទួលបន្ទុកការងារកិច្ចសន្យា EPCC ដែលគ្របដណ្តប់លើដំណើរការគ្រប់គ្រងគម្រោងការផ្គត់ផ្គង់គ្រឿងបរិក្ខារ ដំណើរការ ការដ្ឋាន សំណង់ និងការដំឡើងបណ្តាញបញ្ជូនថាមពលនិងខ្សែកាបក្រោមដី។

មកដល់បច្ចុប្បន្ន លោក Han Fatt Juan ដឹកនាំក្រុមហ៊ុន PESTECH (Myanmar) Ltd ក្រុមហ៊ុន PESTECH Hinthar Corporation Limited ក្រុមហ៊ុន PESTECH Transmission Ltd ក្រុមហ៊ុន PESTECH Transmission CDI SARL និងក្រុមហ៊ុន Imbiss Sdn Bhd.

## CHARLES TAN PU HOOI

Charles Tan សញ្ជាតិម៉ាឡេស៊ី អាយុ៥០ឆ្នាំ មានតួនាទីជាអភិបាលប្រតិបត្តិរបស់ **ផថខ** លោកបានតែងតាំងក្នុងក្រុមប្រឹក្សាភិបាលនៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៨។ លោកទទួលបន្ទុកផ្នែករៀបចំនិងអនុវត្តកិច្ចការអាជីវកម្មផ្សេងៗមានដូចជា ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងការបោះផ្សាយលក់មូលបត្របំណុល ការបំបែកមូលបត្រ(share split) ផែនការបែងចែកភាគហ៊ុន (share grant plant) ព្រមទាំងការបង្កើតនិងការអនុវត្តនូវសកម្មភាពកៀរគរមូលធន។

ចាប់តាំងពីឆ្នាំ១៩៩៧ លោកមានបទពិសោធន៍លើផ្នែកហិរញ្ញវត្ថុសាជីវកម្មយ៉ាងទូលំទូលាយ ដោយលោកបានធ្វើការជាមួយនឹងធនាគារវិនិយោគនៅប្រទេសម៉ាឡេស៊ីនិងជាសហស្ថាបនិកនៃក្រុមហ៊ុនប្រឹក្សាហិរញ្ញវត្ថុសាជីវកម្មមួយដែលទទួលស្គាល់ដោយគណៈកម្មការមូលបត្រនៃប្រទេសម៉ាឡេស៊ី។

លោកទទួលបានគុណវុឌ្ឍិផ្នែកហិរញ្ញវត្ថុសាជីវកម្មដែលទទួលស្គាល់ដោយវិទ្យាស្ថានគណនេយ្យករជំនាញ (Institute of Chartered Accountants) នៅប្រទេសអង់គ្លេស និងប្រទេសវ៉ែល (ICAEW) និងជាសមាជិក សមាគមផែនការហិរញ្ញវត្ថុ (Financial Planning Association) នៃប្រទេសម៉ាឡេស៊ី (FPAN”)។
មកដល់បច្ចុប្បន្ន លោកបានដឹកនាំក្រុមហ៊ុនមួយចំនួនដូចជា ក្រុមហ៊ុន ដាយអឹមិន ផៅវ័រ លីមីធីត ក្រុមហ៊ុន PESTECH (PNG) Ltd. ក្រុមហ៊ុន PESTECH System Siam Ltd ក្រុមហ៊ុន Fornix Biotech Sdn Bhd ក្រុមហ៊ុន Fornix Foodstuffs Sdn Bhd និងក្រុមហ៊ុន PESTECH Corporation និងក្រុមហ៊ុន ហ្វ្រីន សីស្តែនណេប៊ល វេនឈ័រ (ខេមបូឌា) ឯ.ក។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

### ឯកឧត្តម ដាវ អានសាន

ឯកឧត្តម ដាវ អានសាន មានសញ្ជាតិខ្មែរ អាយុ ៤៣ ឆ្នាំ ជាអភិបាលឯករាជ្យដែលបានតែងតាំងនៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៨។

ឯកឧត្តមជាសារការីនិងជាអនុប្រធានប្រចាំមន្ទីរសារការី សេដ្ឋាវិទូចាប់តាំងពីឆ្នាំ២០១៤។ ឯកឧត្តមមានបទពិសោធន៍ការងារជាង១០ឆ្នាំក្នុងវិស័យច្បាប់ នយោបាយសង្គម និងសេដ្ឋកិច្ច។ ឯកឧត្តមមានឯកទេសខាងគម្រោងនិងហិរញ្ញវត្ថុសាជីវកម្ម។ មុនពេលចូលរួមជាមួយមន្ទីរសារការី សេដ្ឋាវិទូ ឯកឧត្តមជាអ្នកអនុវត្តច្បាប់នៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៣។ មុនពេលចូលរួមជាមួយ អ.វ.ត.ក ជាអ្នកផ្តល់ប្រឹក្សានិងអ្នកស្រាវជ្រាវនៅស្ថានទូតសាធារណរដ្ឋកូរ៉េប្រចាំប្រទេសកម្ពុជានិងនៅស្ថាប័នស្រាវជ្រាវសាធារណៈនៃរដ្ឋាភិបាលកម្ពុជាក្នុងវិស័យផ្នែកច្បាប់តស៊ូមតិ សេដ្ឋកិច្ចពាណិជ្ជកម្មឆ្លងដែន និងផ្នែកអាជីវកម្ម (Business Enabling Environment)។ ឯកឧត្តមក៏ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យរដ្ឋនិងឯកជនមួយចំនួនក្នុងរាជធានីភ្នំពេញផងដែរចាប់ពីឆ្នាំ២០០៣ដល់ឆ្នាំ២០១៣។

ឯកឧត្តម ដាវ អានសាន ជាទីប្រឹក្សារបស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមក៏ជាសមាជិកនៃគណកម្មការកណ្តាលនៃសហភាពសហព័ន្ធកម្ពុជាដែលជាអង្គការមិនមែនរដ្ឋាភិបាល ដែលដឹកនាំដោយ ឯកឧត្តម ហ៊ុន ម៉ានី សមាជិកនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

ឯកឧត្តម ដាវ អានសាន ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ចនយោបាយពីសាកលវិទ្យាល័យ Williams College ក្នុង Massachusetts សហរដ្ឋអាមេរិកក្នុង ឆ្នាំ២០០៩ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ចពី រាជបណ្ឌិត្យសភាកម្ពុជា ក្នុងឆ្នាំ២០០៣។

ឯកឧត្តមនិយាយភាសាខ្មែរដែលជាភាសាកំណើត ភាសាអង់គ្លេសកម្រិតខ្ពស់ ហើយគាត់អាចទំនាក់ទំនងជាភាសាបារាំងផងដែរ។

មកដល់បច្ចុប្បន្ន ឯកឧត្តម ដាវ អានសាន ក៏បានដឹកនាំមន្ទីរសារការី សេដ្ឋាវិទូ និង Propey Microfinance Plc ផងដែរ។

### តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត

ទំនួលខុសត្រូវចម្បងរបស់ក្រុមប្រឹក្សាភិបាលផ្អែកលើការវាយតម្លៃដែលបានកំណត់ជាមុនលើភាពពាក់ព័ន្ធនានាដូចជាការផ្តល់ទិសដៅយុទ្ធសាស្ត្រ ការកំណត់កត្តាហានិភ័យចម្បងៗ និងសូចនាករសំខាន់ៗ ប្រតិបត្តិការ ធុរៈកិច្ចរបស់ក្រុមហ៊ុន ការតាមដានការសម្រេចចិត្តលើការវិនិយោគ ការពិចារណាលើកិច្ចការហិរញ្ញវត្ថុសំខាន់ៗ និងការពិនិត្យឡើងវិញនូវលទ្ធផលការងាររបស់គណៈគ្រប់គ្រងទាក់ទងនឹងផែនការអាជីវកម្ម ថវិកា និងស្តង់ដាឧស្សាហកម្ម។

ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវឲ្យបានច្បាស់លាស់លើការងារគ្រប់គ្រងក្រុមហ៊ុននិងបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវលើកិច្ចការដូចខាងក្រោម៖

(ក) រក្សាគ្រប់គ្រងក្រុមហ៊ុនទាំងស្រុងប្រកបដោយប្រសិទ្ធភាពនិងតាមដានគណៈគ្រប់គ្រងក្នុងការអនុវត្តផែនការនិងយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាភិបាល
(ខ) ធានាថាប្រព័ន្ធគោលការណ៍និងនីតិវិធីគ្រប់ជ្រុងជ្រោយត្រូវបានដំណើរការ
(គ) កំណត់និងតាមដានការងារមិនមែនហិរញ្ញវត្ថុដែលទាក់ទងនឹងអាជីវកម្ម
(ឃ) ត្រូវធានាថាមានក្រមសីលធម៌អនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ការធ្វើសវនកម្ម គោលការណ៍និងគណនេយ្យការគ្រប់គ្រងឯកសារ និងក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុន
(ង) ខិតខំអនុវត្តសកម្មភាពខាងលើ និងឲ្យលើសពីតម្រូវការអប្បបរមានិងដើម្បីប្រកួតប្រជែងនឹងការអនុវត្តស្តង់ដាអន្តរជាតិ មិនត្រឹមតែការអនុវត្តទេ ប៉ុន្តែត្រូវធ្វើឲ្យបាន។
(ច) កំណត់នូវកម្រិតនៃភាពជាសារវ័ន្តដោយរក្សាអំណាចរបស់ក្រុមប្រឹក្សាភិបាលនិងធ្វើប្រតិភូកិច្ចការផ្សេងទៀតចាំបាច់ត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅឲ្យគណៈគ្រប់គ្រងនិងបង្កើតយន្តការប្រកបដោយប្រសិទ្ធភាពដែលធានានូវទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើការអនុវត្តមុខងាររបស់ខ្លួន
(ឆ) ធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវចំពោះភាគីពាក់ព័ន្ធនានារបស់ក្រុមហ៊ុន និង
(ជ) យល់ដឹងនិងប្តេជ្ញាចិត្តអនុវត្តឱ្យបាននូវគោលការណ៍សំខាន់ៗស្តីពីអភិបាលកិច្ចសាជីវកម្មល្អដែលអនុលោមតាមគោលការណ៍អភិបាលកិច្ចសាជីវកម្មក្រុមហ៊ុនដោយត្រូវត្រួតពិនិត្យឡើងវិញឲ្យបានទៀតទាត់។

ក្រុមប្រឹក្សាភិបាលយល់ពីសារៈសំខាន់នៃការវាយតម្លៃលើប្រសិទ្ធភាពរបស់រាល់អភិបាលនីមួយៗទាំងក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការរបស់ខ្លួន។ ក្រុមប្រឹក្សាភិបាលដោយមានជំនួយពីគណៈកម្មាធិការ តែងតាំងនិងលាភការត្រូវពិនិត្យនិងវាយតម្លៃលើការប្រតិបត្តិរបស់ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការក្រុមប្រឹក្សាភិបាល និងអភិបាលនីមួយៗ រួមទាំងការវាយតម្លៃលើអភិបាលឯករាជ្យជារៀងរាល់ឆ្នាំ។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

### កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ចាប់ពីកាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ រហូតដល់ឆ្នាំហិរញ្ញវត្ថុបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ មានកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួនប្រាំ (៥) លើកដែលអភិបាលគ្រប់រូបបានចូលរួមជាគណៈ កម្មាធិការ និងកិច្ចប្រជុំក្រុមប្រឹក្សាដូចខាងក្រោម៖

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ |
|---|---|---|
| ១ | ១២ សីហា ២០២១ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>កិច្ចប្រជុំគណៈកម្មាធិការសវនកម្ម<br>កិច្ចប្រជុំគណៈកម្មាធិការតែងតាំង និងលាភការ |
| ២ | ២៣ កញ្ញា ២០២១ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>កិច្ចប្រជុំគណៈកម្មាធិការសវនកម្ម |
| ៣ | ១១ November ២០២១ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>កិច្ចប្រជុំគណៈកម្មាធិការសវនកម្ម |
| ៤ | ១០ វិច្ឆិកា ២០២២ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>កិច្ចប្រជុំគណៈកម្មាធិការសវនកម្ម |
| ៥ | ៦ កុម្ភៈ ២០២២ | កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>កិច្ចប្រជុំគណៈកម្មាធិការសវនកម្ម<br>កិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងហានិភ័យ |

### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ឯកឧត្តម ដាវ់ អានសាន | អភិបាលឯករាជ្យ | ២៩ សីហា ២០១៨ | ៥ | ៥ |
| ២ | Paul Lim Pay Chuan | ប្រធានក្រុមប្រឹក្សាភិបាល | ២៩ សីហា ២០១៨ | ៥ | |
| ៣ | Charles Tan Pu Hooi | អភិបាល | ២៩ សីហា ២០១៨ | ៥ | |

តួនាទី និងភារកិច្ចរបស់ គណៈកម្មាធិការសវនកម្ម៖

(i) ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ
(ii) ត្រួតពិនិត្យការគ្រប់គ្រងផ្ទៃក្នុង
(iii) ត្រួតពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង
(iv) ត្រួតពិនិត្យការធ្វើសវនកម្មផ្ទៃក្រៅ និង
(v) រាយការណ៍ពីសកម្មភាពនៃគណៈកម្មាធិការជូនប្រធានក្រុមប្រឹក្សាភិបាល.

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

**គណៈកម្មាធិការតែងតាំងនិងលាភការ**

| ល.រ. | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ឯកឧត្តម ដាវ អានសាន | អភិបាលឯករាជ្យ | ២៩ សីហា ២០១៨ | ១ | ១ |
| ២ | Lim Ah Hock | អភិបាល | ២៩ សីហា ២០១៨ | ១ | |
| ៣ | Charles Tan Pu Hooi | អភិបាល | ២៩ សីហា ២០១៨ | ១ | |

តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការតែងតាំង និងលាភការ

(i) ត្រួតពិនិត្យនិងវាយតម្លៃលើគុណវុឌ្ឍិរបស់បេក្ខជនសម្រាប់តួនាទីជាអភិបាលឬបុគ្គលិកជាន់ខ្ពស់ដែលត្រូវបានចាត់តាំងដោយប្រធានក្រុមប្រឹក្សាភិបាល
(ii) ពិនិត្យផ្តល់អនុសាសន៍លើប្រាក់បំណាច់លាភការរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និង
(iii) ពិនិត្យធ្វើបច្ចុប្បន្នភាពយន្តការវាយតម្លៃប្រសិទ្ធភាពនៃប្រធានក្រុមប្រឹក្សាភិបាល អភិបាល និងគណៈកម្មាធិការនានាយ៉ាងតិច ១ ដងក្នុងមួយឆ្នាំ

**គណៈកម្មាធិការគ្រប់គ្រងហានិភ័យ**

| ល.រ. | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ឯកឧត្តម ដាវ អានសាន | អភិបាលឯករាជ្យ | ២៩ សីហា ២០១៨ | ១ | ១ |
| ២ | Paul Lim Pay Chuan | ប្រធានក្រុមប្រឹក្សាភិបាល | ២៩ សីហា ២០១៨ | ១ | |
| ៣ | Han Fatt Juan | អភិបាលប្រតិបត្តិ/ នាយកប្រតិបត្តិ | ២៩ សីហា ២០១៨ | ១ | |

តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

(i) វិភាគហានិភ័យ រួមទាំងបរិយាយហានិភ័យ កំណត់ហានិភ័យ និងព្យាករណ៍ហានិភ័យ
(ii) វាយតម្លៃហានិភ័យ
(iii) រាយការណ៍ពីហានិភ័យ
(iv) ដោះស្រាយហានិភ័យនិង
(v) តាមដានត្រួតពិនិត្យហានិភ័យ

លាភការ ឬ ប្រាក់បំណាច់

គោលនយោបាយសង្ខេបស្តីពីលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់
(ក) ប្រធានក្រុមប្រឹក្សាភិបាលជាអ្នកស្នើនិងផ្តល់អនុសាសន៍អំពីទំហំនៃលាភការដែលត្រូវផ្តល់ឲ្យអភិបាលនិងស្នើសុំការសម្រេចពីភាគហ៊ុនិកនៅក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។
(ខ) ទំហំនិងការប៉ះប៉ូវលាភការត្រូវតែមានចំនួនសមល្មមដើម្បីទាក់ទាញ និងរក្សាសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលដែលត្រូវការជាចាំបាច់ក្នុងការដំណើរការក្រុមហ៊ុនឱ្យបានជោគជ័យ
(គ) អភិបាលមិនប្រតិបត្តិពុំទទួលបានភាគហ៊ុនឬផលប្រយោជន៍ផ្សេងៗក្រៅពីប្រាក់កម្រៃជាអភិបាលមិនប្រតិបត្តិនិងប្រាក់ឧបត្ថម្ភសម្រាប់កិច្ចប្រជុំដែលពួកគាត់បានចូលរួម។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

(ឃ) សមាជិកប្រតិបត្តិពុំទទួលបានប្រាក់កម្រៃឡើយប៉ុន្តែទទួលបានប្រាក់បៀវត្សរ៍ ក្នុងនាមជានិយោជិតរបស់ក្រុមហ៊ុន ដោយយោងទៅតាមកិច្ចសន្យាការងាររបស់ពួកគេជាមួយនឹងក្រុមហ៊ុន។

(ង) គោលនយោបាយលាភការនិងកញ្ចប់លាភការសម្រាប់សមាជិកក្រុមប្រឹក្សាភិបាលនីមួយៗត្រូវមាននីតិវិធីច្បាស់លាស់និងប្រកបដោយតម្លាភាព។

(ច) អភិបាលមិនត្រូវជជែកវែកញែកនិងបោះឆ្នោតទាក់ទងនឹងកញ្ចប់លាភការរបស់ខ្លួនក្នុងកិច្ចប្រជុំក្រុម ប្រឹក្សាភិបាល ឬកិច្ចប្រជុំគណៈកម្មាធិការឡើយ។

**បុគ្គលទទួលលាភការ ឬប្រាក់បំណាច់**

| ល.រ. | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនលាភការ ឬប្រាក់បំណាច់ (គិតជាដុល្លារ) | ផ្សេងៗ |
|---|---|---|---|
| ១ | អភិបាល | ៤៣៨ ៣៥៣,១៩ | - |
| ២ | បុគ្គលិកដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥ រូប | ២៦៧ ៩៤៦,១២ | - |

**ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាលអភិបាល គណៈកម្មាធិការនិងនាយកប្រតិបត្តិ**

| ល.រ | បរិយាយ | លក្ខណៈវិនិច្ឆ័យ | ដំណើរការនៃការវាយតម្លៃ |
|---|---|---|---|
| ១ | ក្រុមប្រឹក្សាភិបាល | ការវាយតម្លៃលើខ្លួនឯងបានធ្វើឡើងដោយយោងលើការវិនិច្ឆ័យ ឬ គូសធីក បាទ/ចាស ឬទេ ដូចខាងក្រោម៖<br>១. ខ្សោយ<br>២. តម្រូវឲ្យមានការ ពង្រឹងបន្ថែម<br>៣. គ្រប់គ្រាន់<br>៤. ល្អសមរម្យ<br>៥. ខ្លាំង | គណៈកម្មាធិការលាភការនិងប្រាក់បំណាច់វាយតម្លៃលើបំពេញការងាររបស់ក្រុមប្រឹក្សាភិបាល ដែលការអនុវត្តតួនាទីនិងទំនួលខុសត្រូវរបស់ពួកគាត់នឹងត្រូវយកមកពិនិត្យនិងពិចារណា។ |
| ២ | អភិបាល | | ការអនុវត្តរបស់ក្រុមប្រឹក្សាភិបាលនិងការវាយតម្លៃពីខ្លួនលើកម្រិតនៃការរួមចំណែកអន្តរកម្ម គុណភាពនៃការចូលរួម យល់ដឹងអំពីតួនាទីរបស់អភិបាលនិងប្រធានក្រុមប្រឹក្សាភិបាល។ |
| ៣ | គណៈកម្មាធិការ | | គណៈកម្មាធិការលាភការនិងប្រាក់បំណាច់វាយតម្លៃលើការបំពេញការងាររបស់គណៈកម្មាធិការសវនកម្ម ក្នុងការក្នុងលក្ខខណ្ឌ គុណភាពនិងសមាសភាព ជំនាញ និងសមត្ថភាពការប្រជុំ ការគ្រប់គ្រង និងការប្រតិបត្តិ ភារកិច្ច និងទំនួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុងនិងផ្ទៃក្រៅ។ |
| ៤ | នាយកប្រតិបត្តិ | | ការវាយតម្លៃសម្រាប់នាយកប្រតិបត្តិបានរួមបញ្ចូលនៅក្នុងការបំពេញតួនាទីរបស់ក្រុមប្រឹក្សាភិបាល និងការវាយតម្លៃពីខ្លួនឯងដែលការវាយតម្លៃបានធ្វើឡើងពាក់ព័ន្ធនឹងកម្រិតនៃការរួមចំណែកក្នុងអន្តរកម្ម គុណភាពនៃការចូលរួម យល់ដឹងអំពីតួនាទីរបស់ អភិបាល និងប្រធានក្រុមប្រឹក្សាភិបាល។ |

គណៈកម្មាធិការតែងតាំងនិងលាភការបានសម្តែងការពេញចិត្តដល់ការបំពេញតួនាទីរបស់ក្រុមប្រឹក្សាភិបាល អភិបាល គណៈកម្មាធិការ និងនាយកប្រតិបត្តិ។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

ការបណ្តុះបណ្តាលសម្រាប់អភិបាល

ក្រុមប្រឹក្សាភិបាលដោយមានជំនួយពីគណៈកម្មាធិការតែងតាំងនិងលាភការត្រូវកំណត់ពីវគ្គបណ្តុះបណ្តាលដែលចាំបាច់ដល់អភិបាល យោងតាមការវាយតម្លៃប្រចាំឆ្នាំនៃក្រុមប្រឹក្សាភិបាលគណៈកម្មាធិការ ក្រុមប្រឹក្សាភិបាល និងអភិបាលម្នាក់ៗដើម្បីកំណត់ប្រភេទនៃការបណ្តុះបណ្តាលដែលតម្រូវសម្រាប់អភិបាលម្នាក់ៗ។ កម្មវិធីអប់រំបន្តនេះនឹងត្រូវទទួលរងបន្ទុកចំណាយដោយក្រុមហ៊ុន។

អំឡុងឆ្នាំហិរញ្ញវត្ថុ អភិបាល និងបុគ្គលិកជាន់ខ្ពស់បានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលដូចខាងក្រោម៖

| ល.រ. | ឈ្មោះ | តំណែង | វគ្គបណ្តុះបណ្តាល |
|---|---|---|---|
| ១ | Paul Lim Pay Chuan | ប្រធានក្រុមប្រឹក្សាភិបាល | • Maybank Invest Asean 2021 Country Week: Market Strategy & Economic Outlook Malaysia: Cautiously Constructive<br>• Maybank Invest Asean 2021 Country Week: Market Strategy & Economic Outlook Indonesia: Entering A New Chapter<br>• Maybank Invest Asean 2021 Country Week: Market Strategy & Economic Outlook Philippines: Marching On<br>• Maybank Invest Asean 2021 Country Week: Market Strategy & Economic Outlook Thailand: Against All Odds<br>• AI4S Enhanced Programme<br>• Double Tax Agreement Benefits for Malaysian Businesses in Cambodia<br>• Post COVID-19 Strategies and the Way Forward<br>• Malaysia Budget 2022: Reinforcing the Nascent Recovery<br>• Navigating the Regional Comprehensive Economic Partnership (RCEP) Series 2: How to Leverage on RCEP for Market Access of Manufactured Goods<br>• Coverage on Foreign Source Income Exemption and Prosperities Tax<br>• HSBC Investment Outlook 2022: Remaking Asia's Future<br>• HSBC Investment Outlook 2022: Great Transition to a Digital and Net Zero World<br>• Maybank: Tax Measures and Impact on Businesses and Households – Malaysia Budget 2022<br>• HSBC Investment Outlook 2022: Capturing Opportunities from Technological Innovation in the Greater Bay Area<br>• HSBC Investment Outlook 2022: Southeast Asia Investment Outlook<br>• BNP Paribas: Global Insights 2022<br>• HSBC Investment Outlook 2022: 2022 Asia's Credit Market Outlook<br>• Affin Hwang Macro Outlook and Environmental Sustainability<br>• Asia Pacific Rail 2022 Exhibition |
| ២ | Han Fatt Juan | នាយកប្រតិបត្តិ | • Briefing Session on the Technical and Commercial Aspects of Rooftop Solar |
| ៣ | Lim Ah Hock | អភិបាល | • CIMB Webinar: A Bumpy, Transitional Year – Recovery to continue despite headwinds |

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

| ល.រ. | ឈ្មោះ | តំណែង | វគ្គបណ្តុះបណ្តាល |
|---|---|---|---|
| ៤ | Charles Tan Pu Hooi | អភិបាល | • 1st Asia Europe Economic and Business Forum |
| ៥ | ឯកឧត្តម ដាវ់ អានសាន | អភិបាលឯករាជ្យ | • Roles of a Technical University in High-Tech Startup Ecosystem<br>• STI Survey on Manufacturing in Cambodia<br>• The Role of Plant Biotechnology in Response to Climate Change<br>• Model of Technology Transfer<br>• Resource Efficiency and Cleaner Production Strategy and Action Plan for Industry and SME Sectors<br>• Building Soil Organic Carbon for Sustainable Agricultural Soil Health Management<br>• Roadmap for Automobiles and Electronic Industry in Cambodia<br>• Innovation, Technology and Firm Productivity<br>• Protected Horticulture<br>• Technology Consumption and Transfer in Cambodia<br>• Innovation of Agricultural Product Development<br>• Understanding Ground Water Flow System<br>• Introduction to Photovoltaic Thermal (PVT) Modules and its Application |

## ផ្នែកទី ៣- ការអនុវត្តក្រមសីលធម៌សម្រាប់ការអនុវត្តធុរកិច្ច

### ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

#### ទំនាស់ផលប្រយោជន៍

មាត្រា ២២.២ នៃលក្ខន្តិកៈរបស់ក្រុមហ៊ុនលើកឡើងថាប្រសិនបើកិច្ចប្រជុំរបស់អភិបាលណាមួយឬផ្នែកមួយនៃកិច្ចប្រជុំរបស់អភិបាលពាក់ព័ន្ធនឹងប្រតិបត្តិការឬកិច្ចព្រមព្រៀងណាមួយជាមួយក្រុមហ៊ុន ដែលនៅក្នុងនោះអភិបាលម្នាក់មានផលប្រយោជន៍ក្នុងនោះ អភិបាលរូបនោះនឹងមិនត្រូវបានរាប់ថាបានចូលរួមក្នុងកិច្ចប្រជុំនោះឡើយ ឬផ្នែកមួយនេះនៃកិច្ចប្រជុំឡើយ សម្រាប់គោលបំណងចំនួនកូរ៉ុម ឬការបោះឆ្នោត ប្រសិនបើកិច្ចសន្យានេះមិនមែនជា៖

(i) កិច្ចព្រមព្រៀងជាប្រាតិភោគសម្រាប់ប្រាក់ដែលបានឲ្យគេខ្ចីឬសម្រាប់កាតព្វកិច្ច ដែលអនុវត្តដោយគាត់ដើម្បីជាផលប្រយោជន៍របស់ក្រុមហ៊ុនឬរបស់សាខាក្រុមហ៊ុន
(ii) កិច្ចសន្យាដែលពាក់ព័ន្ធជាពិសេសចំពោះបៀវត្សរ៍គោលរបស់គាត់ ក្នុងនាមជាអភិបាល មន្ត្រី និយោជិត ឬភ្នាក់ងាររបស់ក្រុមហ៊ុនឬរបស់សាខាក្រុមហ៊ុន
(iii) កិច្ចសន្យាសម្រាប់សំណងការខូចខាត ឬធានារ៉ាប់រង ឬ
(iv) កិច្ចសន្យាជាមួយនឹងបុគ្រសម្ព័ន្ធក្រុមហ៊ុន

#### ប្រតិបត្តិការធុរកិច្ច និងការប្រកួតប្រជែងដោយស្មោះត្រង់

ជាផ្នែកនៃតម្លៃរួមនៅក្នុងក្រមសីលធម៌របស់ PESTECH Group យើងជឿថាវាជាការសម្រេចបាននូវការកែតម្រូវក្រុមសីលធម៌សនិទានភាព ច្បាប់ សមធម៌និងយុត្តិធម៌ និងការយល់ឃើញពីភាពសមស្របនៃការអនុវត្តការព្យាបាលអន្តរបុគ្គល វិធាន និងនីតិវិធីនៅក្នុងប្រតិបត្តិការធុរកិច្ចនិងប្រតិបត្តិការពាណិជ្ជកម្មដោយស្មោះត្រង់។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ការរក្សាការសម្ងាត់វិជ្ជាជីវៈពាណិជ្ជកម្ម

នៅក្នុងសៀវភៅណែនាំរបស់ PESTECH Group រាល់និយោជិតទាំងអស់ត្រូវរក្សាការសម្ងាត់ដោយផ្ទាល់ឬដោយប្រយោល។ នៅរយៈពេលបំពេញការងារ និយោជិតទាំងអស់ត្រូវចុះហត្ថលេខាលើការព្រមព្រៀងមិនបញ្ចេញការសម្ងាត់។

## ប្រើប្រាស់ធនធាន ទ្រព្យសកម្ម និងព័ត៌មានក្រុមហ៊ុន

**ថផខ** ដាក់ដំណើរការនិងនីតិវិធីត្រឹមត្រូវក្នុងការគ្រប់គ្រងធនធាន ទ្រព្យសកម្ម និងព័ត៌មានរបស់ក្រុមហ៊ុន។ រាល់ប្រាក់បម្រុងឬប្រាក់បុរេប្រទានដល់និយោជិតដើម្បីជួយសម្រួលដល់ការងាររបស់គាត់សម្រាប់ប្រតិបត្តិការរបស់ក្រុមហ៊ុន នឹងត្រូវបានកត់ត្រា និងទទួលស្គាល់យ៉ាងត្រឹមត្រូវ ហើយរាល់ការទូទាត់ទាំងអស់ត្រូវតែមានវិក្កយបត្រ ឬបង្កាន់ដៃយ៉ាងត្រឹមត្រូវ។ ទន្ទឹមនឹងនេះ ទ្រព្យសកម្មទាំងអស់ត្រូវដាក់សញ្ញាសម្គាល់ឲ្យបានត្រឹមត្រូវដោយដាក់ សម្គាល់ទីតាំង និងម្ចាស់ ខណៈដែលពត៌មានត្រូវបានរក្សាទុក និងកត់ចូលក្នុងប្រព័ន្ធដោយភាពសម្ងាត់។ អ្នកប្រើប្រាស់ទាំងអស់តម្រូវឲ្យចុះហត្ថលេខាបិទ និងទទួលស្គាល់ការប្រើប្រាស់ទ្រព្យសកម្ម និងពត៌មានរបស់ក្រុមហ៊ុនណាមួយហើយត្រូវបានចងភ្ជាប់ដោយមាត្រារក្សាការសម្ងាត់។

## ច្បាប់ការងារនិងគោលការណ៍ពាក់ព័ន្ធផ្សេងៗ

**ថផខ** អនុវត្តស្របតាមច្បាប់និងគោលការណ៍ពាក់ព័ន្ធនឹងការងារនៅប្រទេសកម្ពុជា។

## វិន័យការងារ និងបទបញ្ជាផ្ទៃក្នុង

**ថផខ** អនុម័តគោលការណ៍ការងារនិងបទបញ្ជាផ្ទៃក្នុងជាច្រើនទាក់ទងនឹងធនធានមនុស្ស ការផ្គត់ផ្គង់ រដ្ឋបាល ដំណើរការគម្រោង ប្រតិបត្តិការ និងថែទាំ ដើម្បីធានាថានិយោជិតទាំងអស់យល់ពីការងារដែលរំពឹងទុកដោយការគោរពស្តង់ដារនៃចរិយាមាយាទ ការបំពេញការងារឯកសណ្ឋានភាព និងស្ថិរភាពក្នុងការសម្រេចចិត្ត និងដំណើរការប្រតិបត្តិការ។

## អ្នកផ្តល់ពត៌មាន

**ថផខ** ផ្តល់យន្តការឲ្យអភិបាលទាំងអស់ គណៈគ្រប់គ្រង និយោជិត អ្នកលក់នៃក្រុមហ៊ុន PESTECH និង ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនក៏ដូចជាសមាជិកសាធារណៈ ("បុគ្គល") អាចរាយការណ៍ដោយសម្ងាត់និងអនាមិកទៅកាន់ក្រុមប្រឹក្សាភិបាលទាក់ទងរាល់បញ្ហាដូចដែលមានចែងក្នុងក្រមសីលធម៌ក្នុងការប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុន បញ្ហាផ្លូវច្បាប់ និងគណនេយ្យឬសវនកម្ម។

សេចក្តីណែនាំទាក់ទងនឹងអ្នកផ្តល់ពត៌មានអនុញ្ញាតឲ្យគណៈគ្រប់គ្រងអាចចាត់ចែងចាត់វិធានការបង្ការនិងកែតម្រូវសមស្របនៅក្នុងក្រុមហ៊ុនដោយគ្មានផលប៉ះពាល់អវិជ្ជមានដែលមកជាមួយការផ្តល់ពត៌មានជាសាធារណៈដូចជាការបាត់បង់មុខមាត់ក្រុមហ៊ុនឬកេរ្តិ៍ឈ្មោះ បញ្ហាហិរញ្ញវត្ថុ ការបាត់បង់ទំនុកចិត្តរបស់វិនិយោគិន ឬការធ្លាក់ចុះនៃតម្លៃភាគហ៊ុន។

បុគ្គលអាចរាយការណ៍ពីបញ្ហាដែលខ្លួនមានទៅកាន់អ៊ីម៉ែល whistleblower@pestech.com.my

## ដំណោះស្រាយវិវាទ

**ថផខ** អាចស្វែងរកដំណោះស្រាយវិវាទលើជម្លោះដោយការសម្របសម្រួលតាមដំណាក់កាលដើម្បីស្វែងរកប្រភពនៃវិវាទ ហើយអនុញ្ញាតឲ្យភាគីជម្លោះទាំងពីរអាចជជែកគ្នាបាន។ ការស៊ើបអង្កេតលើស្ថានការនោះមានបំណងស្វែងរកដំណោះស្រាយមួយដែលស្របគ្នាហើយភាគីទាំងពីរអាចព្រមព្រៀងគ្នាបាន។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

ការបម្រើអតិថិជននិងទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ អ្នកលក់ និងអ្នកម៉ៅការ ផេសថិក ព្យាយាមផ្តោតការយកចិត្តទុកដាក់លើផលប្រយោជន៍របស់អតិថិជនជាចម្បងជាជាងផលប្រយោជន៍ផ្ទាល់ដើម្បីលើកតម្កើងកេរ្តិ៍ឈ្មោះនិងទំនុកចិត្តលើក្រុមហ៊ុន។ ផេសថិក ប្តេជ្ញាផ្តល់ជូននូវផលិតផល និងសេវាកម្មប្រកបដោយប្រសិទ្ធភាព និង ភាពឥតខ្ចោះតាមលក្ខណៈសមធម៌។

**ផថខ** ជឿជាក់ថាក្រមសីលធម៌គឺជាមូលដ្ឋានក្នុងចំណោមគុណតម្លៃរួមដូចខាងក្រោមដែលមានសារៈសំខាន់ សម្រាប់ភាពជាអ្នកដឹកនាំផ្ទាល់ និងជាបុគ្គលមួយដែលដឹកនាំផ្តល់ជូន និងបម្រើអ្នកដទៃ៖

| | | |
|---|---|---|
| **ស្មោះត្រង់/សុច្ចរិត** | : | យើងជឿជាក់ថាចរិតលក្ខណៈ និងបញ្ជាក់ពីភាពវិជ្ជមាន និងគុណធម៌ ផ្សេងទៀតដូចជាភាពស្មោះត្រង់ ការជឿជាក់ និងសុចរិតភាពដែលជា ផ្នែកសំខាន់នៃចរិតរបស់យើង។ |
| **ទំនុកចិត្ត** | : | យើងជឿជាក់ថាការកំណត់ចំពោះទំនាក់ទំនងជារង្វង់ និងអន្តរកម្មឥទ្ធិ ពលសង្គម (ជំនឿចិត្ត និងភាពជឿជាក់) ហេតុដូច្នេះភាពជាអ្នកដឹកនាំ-ការប្តេជ្ញាចិត្តក្នុងកិច្ចសន្យា។ |
| **សុច្ចរិតភាព** | : | យើងជឿជាក់ថាការប្តេជ្ញាចិត្តមិនរុញរានិងអាចទាយបានដើម្បីគោរព សីលធម៌ និងគោលការណ៍ គឺជាផ្នែកមួយដ៏ធំ-នៃចរិយាសម្បត្តិល្អ ធ្វើអំពើល្អ និងត្រឹមត្រូវទោះបីមិនមាននរណាមើលឃើញក៏ ដោយ។ |
| **សមធម៌** | : | យើងជឿជាក់ថាស្ថានភាព ឋានៈនិងល័ក្ខខ័ណ្ឌសម្រាប់ការអនុវត្តច្បាប់ បទបញ្ញត្តិនិងយុត្តិធម៌។ |
| **យុត្តិធម៌** | : | យើងជឿជាក់ថាការទទួលបាននូវសីលធម៌/ការកែតម្រូវសីលធម៌ សនិទានភាព ច្បាប់ សមធម៌ និង យុត្តិធម៌។ |
| **ភាពត្រឹមត្រូវ** | : | យើងជឿជាក់ថាការយល់ឃើញអំពីភាពសមស្របនៃការអនុវត្តទំនាក់ទំនងបុគ្គល ច្បាប់ និងនីតិវិធី។ |
| **យកចិត្តទុកដាក់ចំពោះអ្នកដទៃ** | : | យើងជឿជាក់ថាលទ្ធភាពពិចារណាចំពោះអ្នកដទៃមុនខ្លួនយើងនិងផ្តល់ជូនអ្នកដទៃតាមរបៀបដែលយើងចង់ទទួលបាននូវការគោរព ដែលមិនមែនដើម្បីយកឈ្នះ ការបោកបញ្ឆោត និងការសងសឹកឡើយ។ |

## គ. យន្តការនិងនីតិវិធីតាមដានអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

ក្រមសីលធម៌របស់ក្រុមហ៊ុនអាចស្វែករកនិងចូលមើលបានតាមរយៈគេហទំព័ររបស់ក្រុមហ៊ុនហូលឌីងរបស់យើងដែលមានដូចជា https://pestech-international.com/code-of-conduct-0.

## ឃ. ប្រតិបត្តិការភាគីជាប់ពាក់ព័ន្ធ

### ១. គោលនយោបាយប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

ក្នុងនាមជាក្រុមហ៊ុនហូលឌីងនៃ **ផថខ** ក្រុមហ៊ុន PESTECH International Berhad បានចុះបញ្ជីលក់មូលបត្រនៅលើផ្សារមូលបត្រនៃប្រទេសម៉ាឡេស៊ី Bursa Malaysia Securities Berhad **ផថខ** គឺជាកម្មវត្ថុដែលតម្រូវឲ្យអនុលោមតាមបទបញ្ញត្តិពាក់ព័ន្ធនៃទីផ្សារគោលរបស់គណៈកម្មការមូលបត្រ Bursa Malaysia Securities Berhad ដែលរួមមានប្រតិបត្តិការភាគីពាក់ព័ន្ធជាមួយក្រុមហ៊ុនហូលឌីង ក្រុមហ៊ុនចម្រុះរួមក្រុមហ៊ុនបុត្រសម្ព័ន្ធ ភាគហ៊ុនិកធំ និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ អភិបាល/បុគ្គលិក និងគ្រួសាររបស់ពួកគេ។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ២. ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | ប្រភេទទំនាក់ទំនង | ប្រភេទប្រតិបត្តិការ | ឆ្នាំហិរញ្ញវត្ថុ ៣០ មិថុនា ២០២២ (០០០ ដុល្លារអាមេរិក) |
|---|---|---|---|---|
| ១ | ក្រុមហ៊ុន ដាយអឹមិន ផៅវ័រ លីមីធីត | បុត្រសម្ព័ន្ធ | ក) ចំណូលសេវាគ្រប់គ្រង<br>ខ) សេវាកម្មប្រតិបត្តិការ និងថែទាំ | ១០<br>១ ៥៣៣ |
| ២ | PESTECH Sdn Bhd | បុត្រសម្ព័ន្ធ | ក) ដំណើរការបង់ប្រាក់<br>ខ) តម្លៃកិច្ចសន្យាជាប់ការប្រាក់<br>គ) បង់ការប្រាក់ | ៣ ៥២៣<br>១១ ៣២៥<br>១៤៦ |
| ៣ | ENERSOL Co., Ltd | បុត្រសម្ព័ន្ធ | ក) តម្លៃកិច្ចសន្យា (បង្វិល) ជាប់<br>ខ) បង់ការប្រាក់ | ១ ១៦៦<br>៦៣៩ |
| ៤ | PESTECH Transmission Sdn Bhd | បុត្រសម្ព័ន្ធ | ក) តម្លៃកិច្ចសន្យាជាប់<br>ខ) ចំណូលកិច្ចសន្យាជាប់ថ្លៃគម្រោងគ្រប់គ្រង | ៣៩<br>១៧ |
| ៥ | ក្រុមហ៊ុន អូឌីអិម ផៅវ័រ ឡាញ ឯ.ក | បុត្រសម្ព័ន្ធ | ក) តម្លៃកិច្ចសន្យាជាប់<br>ខ) ចំណូលសេវាគ្រប់គ្រង<br>គ) ចំណូលពីការជួលទីតាំង | -<br>២០<br>- |
| ៦ | PESTECH International Berhad | ក្រុមហ៊ុន ហូលឌីង | ក) ការប្រាក់ថ្លៃគ្រប់គ្រង<br>ខ) បង់ការប្រាក់ | -<br>៨៤៦ |
| ៧ | ក្រុមហ៊ុន ហ្គ្រីន សីស្តែនណេបិល វេនឈឺរ (ខេមបូឌា) ឯ.ក | បុត្រសម្ព័ន្ធ | ក) ចំណូលសេវាគ្រប់គ្រង<br>ខ) សេវាកម្មប្រតិបត្តិការ និងថែទាំ<br>គ) ដំណើរការបង់ប្រាក់ | ១៨<br>៦០<br>១៩ ០០៨ |

## ផ្នែកទី ៤ - ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

### ក. សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ

ក្របខណ្ឌគោលនយោបាយគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុនគឺគ្រប់គ្រងដោយគោលនយោបាយគ្រប់គ្រងហានិភ័យនៃសម្ព័ន្ធ PESTECH International Berhad Group (The Group) និងគោលការណ៍ណែនាំ ដែលធានាថាការគ្រប់គ្រងហានិភ័យគឺស្របតាមបទប្បញ្ញត្តិមានទំនួលខុសត្រូវ និងគណនេយ្យភាពហើយត្រូវបានបញ្ជាក់យ៉ាងច្បាស់គ្រប់លំដាប់ថ្នាក់។

ក្របខណ្ឌគោលនយោបាយគ្រប់គ្រងហានិភ័យរបស់សម្ព័ន្ធ មានធាតុសំខាន់ៗចំនួន ៦ (ប្រាំមួយ) ដូចខាងក្រោម ហើយរាល់ហានិភ័យចម្បង ឬចំណុចខ្សោយលើការគ្រប់គ្រងហានិភ័យត្រូវបានកំណត់ វាយតម្លៃ រាយការណ៍ តាមដាន និងកែតម្រូវយ៉ាងត្រឹមត្រូវទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព៖

- យុទ្ធសាស្ត្រហានិភ័យ និងកម្រិតទទួលយកហានិភ័យ
- អភិបាលកិច្ចហានិភ័យ
- វប្បធម៌ហានិភ័យ
- ការវាយតម្លៃហានិភ័យ និងវាស់វែង
- ការគ្រប់គ្រង និងតាមដានហានិភ័យ
- ការរាយការណ៍ពីហានិភ័យ

អំឡុងឆ្នាំហិរញ្ញវត្ថុគណៈកម្មាធិការគ្រប់គ្រងហានិភ័យបានកែប្រែគោលការណ៍គ្រប់គ្រងហានិភ័យនិងឯកសារគោលការណ៍ណែនាំបន្ទាប់ពីគិតគូរលើបរិបទជុំកិច្ចដែល**ផផខ**កំពុងប្រតិបត្តិការលើរចនាសម្ព័ន្ធនិងតម្រូវការប្រតិបត្តិការក្នុងគោលបំណងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

## ខ. សង្ខេបពីប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង

ធាតុសំខាន់ៗនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ **ផថខ** ត្រូវបានសង្ខេបដូចខាងក្រោម៖

- ស្ថានភាពគ្រប់គ្រង

  សារៈសំខាន់នៃស្ថានភាពគ្រប់គ្រងដែលមានលក្ខណៈត្រឹមត្រូវ បានបញ្ជាក់ឲ្យដឹងទូទាំងក្រុមហ៊ុន។ ការផ្តោតលើស្ថានភាពគ្រប់គ្រងដែលមានលក្ខណៈត្រឹមត្រូវនេះត្រូវបានសង្កត់ធ្ងន់ទៅលើការបង្កើនគុណភាព និងសមត្ថភាពរបស់បុគ្គលិកតាមរយៈការផ្តល់ការអប់រំ និងការបណ្តុះបណ្តាលបន្តបន្ទាប់ស្តីពីជំនាញបច្ចេកទេសទាំងរឹងនិងទន់ដូចជាការគ្រប់គ្រងហានិភ័យវិជ្ជាជីវៈ និងសុចរិតភាពដែលអាចត្រូវបានរៀបចំឡើងយូរៗម្តងទៅតាមតម្រូវការ។

- រចនាសម្ព័ន្ធនៃការគ្រប់គ្រង

  ក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងបានបង្កើតរចនាសម្ព័ន្ធក្រុមហ៊ុនដោយបានកំណត់យ៉ាងច្បាស់នូវគណនេយ្យភាពនិងអំណាចនៃសិទ្ធិដែលផ្ទេរជូន។ រចនាសម្ព័ន្ធនេះរួមបញ្ចូលទាំងទំនួលខុសត្រូវរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងផ្សេងៗ រួមទាំងវិសាលភាពនៃសិទ្ធិសម្រេចនូវរាល់កិច្ចការធុរកិច្ចទាំងអស់។

  ធាតុសំខាន់ៗនៃរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនគ្របដណ្តប់លើគោលការណ៍និងនីតិវិធីផ្សេងៗដែលបានចងក្រងជាឯកសារក្នុងគោលបំណងគ្រប់គ្រងលើដំណើរការធុរកិច្ចសំខាន់ៗ។ គោលការណ៍និងនីតិវិធីទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ការធ្វើលទ្ធកម្មបច្ចេកវិទ្យាព័ត៌មាន សុខភាពនិងសុវត្ថិភាព មូលធនមនុស្ស ការថែទាំទ្រព្យសកម្ម និងទំនាក់ទំនងជាមួយភាគីជាប់ពាក់ព័ន្ធ។ ការធ្វើលទ្ធកម្ម ការគ្រប់គ្រងឥណទាន ការរៀបចំទំនិញ បញ្ចូលឃ្លាំងការគ្រប់គ្រងសាច់ប្រាក់ និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធកំពុងត្រូវបាន កែប្រែ/ពិនិត្យឡើងវិញដើម្បីពង្រឹងដំណើរការគ្រប់គ្រងផ្ទៃក្នុង និង នីតិវិធីបន្ថែមទៀត។

- សវនកម្មផ្ទៃក្នុង

  **ផថខ** បានប្រើប្រាស់សេវាខាងក្រៅពីក្រុមហ៊ុន HT & P Partners Co. Ltd. ("HTP") ដើម្បីធ្វើសវនកម្មត្រួតពិនិត្យផ្ទៃក្នុងរបស់ **ផថខ**។ ការត្រួតពិនិត្យផ្ទៃក្នុងនេះនឹងរាយការណ៍ផ្ទាល់ទៅគណៈ កម្មាធិការ សវនកម្ម ("AC") អំពីភាពពេញលេញនៃការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៃអង្គភាពប្រតិបត្តិការនិងវិសាលភាពអនុលោមតាមដំណើរការ គោលនយោបាយនិងនីតិវិធី ច្បាប់ និងបទបញ្ញត្តិជាធរមាន។

  HTP បានធ្វើសវនកម្មលើដំណើរការនៃការចេញវិក្កយបត្រនិងការប្រមូល ការទូទាត់ និងដំណើរការគ្រប់គ្រងនាយកដ្ឋានហិរញ្ញវត្ថុ និងបានធ្វើបទបង្ហាញអំពីលទ្ធផលនៃការធ្វើសវនកម្មលើចំណុចមួយចំនួនដូចខាងក្រោមនេះទៅ AC៖

  ១. ការផ្សះផ្សារបាយការណ៍របស់អ្នកផ្គត់ផ្គង់
  ២. គោលការណ៍គណនេយ្យ

  សរុបមក ចំណុចដែលបានរកឃើញចេញពីការធ្វើសវនកម្មលើកិច្ចលទ្ធកម្មនិងការគ្រប់គ្រងគម្រោង ភាគច្រើនគឺដំណើរការប្រតិបត្តិការ ហើយហានិភ័យដែលកើតចេញពីនោះគឺមានតិចតួច។

  កំហុសនិង/ឬភាពខ្វះចន្លោះធ្ងន់ធ្ងរលើការគ្រប់គ្រងដែលបាន សម្គាល់ឃើញពីការត្រួតពិនិត្យឡើងវិញនឹង ត្រូវ ចងក្រងទុកជាឯកសារនិងត្រូវរាយការណ៍ដល់គណៈគ្រប់គ្រងដើម្បីធ្វើការត្រួតពិនិត្យឡើងវិញ និងផ្តល់ ចំណាត់ការកែតម្រូវ។ សវនករផ្ទៃក្នុងត្រូវរាយការណ៍ជូន AC អំពីការពុំអនុលោមតាមបទប្បញ្ញត្តិ ចំណុច ខ្សោយនៃការគ្រប់គ្រងផ្ទៃក្នុង និងចំណាត់ការដែលធ្វើឡើងដោយគណៈគ្រប់គ្រងដើម្បីដោះស្រាយបញ្ហាសវនកម្មដែលបានរកឃើញ។

  សវនករផ្ទៃក្នុងត្រូវទទួលខុសត្រូវលើការធ្វើផែនការ អនុវត្ត និងរាយការណ៍អំពីគ្រោងការណ៍ សវនកម្មផ្ទៃក្នុង និងសកម្មភាពផ្សេងៗរបស់ក្រុមហ៊ុន។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

**គ. ការធ្វើសវនកម្ម**

សវនកម្មផ្ទៃក្នុង

កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង

- អភិវឌ្ឍផែនការសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំជាប់ពន្ធនីមួយៗដើម្បីស្នើសុំការអនុម័តពីគណៈកម្មាធិការសវនកម្ម/ប្រធានក្រុមប្រឹក្សាភិបាល
- រៀបចំផែនការ សម្របសម្រួល និងអនុវត្តការងារសវនកម្ម
- បែងចែកធនធានសវនកម្មផ្ទៃក្នុងឲ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីបំពេញការងារសវនកម្មបានទាន់ពេលវេលាដែលបានគ្រោងទុក
- បង្ហាញភ្លាមៗជូនបុគ្គលតំណាងរបស់ **ផថខ** អំពីបញ្ហាប្រឈមនិងបញ្ហាដែលត្រូវបានជួបប្រទះក្នុងពេលធ្វើសវនកម្មដែលអាចរារាំង/ប៉ះពាល់លើលទ្ធផលសវនកម្ម
- បង្ហាញពីបញ្ហាដែលបានរកឃើញអំពីការត្រួតពិនិត្យលើការគ្រប់គ្រងផ្ទៃក្នុងជូនគណៈគ្រប់គ្រងនៅក្នុងកិច្ចប្រជុំតាមឬតាមការតម្រូវរបស់គណៈកម្មាធិការសវនកម្ម
- សម្របសម្រួល/អនុវត្តការងារពិនិត្យតាមដានស្ថានភាពផែនការចំណាត់ការគ្រប់គ្រងបន្ទាប់ពីធ្វើការត្រួតពិនិត្យលើការគ្រប់គ្រងផ្ទៃក្នុង (ប្រសិនបើចាំបាច់)

សវនករផ្ទៃក្រៅ

| ល.រ | ឈ្មោះក្រុមហ៊ុន | សេវាកម្ម | កាលបរិច្ឆេទចុះកិច្ចព្រមព្រៀង | កម្រៃសវនកម្ម (គិតជាដុល្លារ) | កម្រៃពុំមែនសវនកម្ម |
|---|---|---|---|---|---|
| ១ | ក្រុមហ៊ុន ហ្គ្រែន សនថុន (ខេមបូឌា) លីមីធីត | ពិនិត្យឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំ ឆ្នាំហិរញ្ញវត្ថុ ២០២២ | ១១ តុលា ២០២១ | ៣២ ៥០០ | - |

**ផ្នែកទី ៥- ភាគីពាក់ព័ន្ធ**

ការគ្រប់គ្រងបុគ្គលិកនិងការការពារ

**ផថខ** ផ្តល់អាទិភាពសំខាន់លើផ្នែកសុខភាពរបស់បុគ្គលិក។ **ផថខ** ប្តេជ្ញាការពារសុវត្ថិភាពនិងសុខភាពរបស់និយោជិតនិងអ្នកពាក់ព័ន្ធនៅគ្រប់ទីកន្លែងដែលពួកគេធ្វើការ។ គោលនយោបាយនីតិវិធីស្តីពីសុខភាពនិងសុវត្ថិភាពការងារស្របតាម ISO 4500: 2018 ការគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារឆ្នាំ ២០១៨ ត្រូវបានបង្កើតឡើងដើម្បីពិនិត្យតាមដានស្ថានភាពសុវត្ថិភាពនិងសុខភាពនៅកន្លែងធ្វើការរបស់យើង។

សម្ព័ន្ធក្រុមហ៊ុន ផេសចិក អនុវត្តប្រតិបត្តិការប្រចាំថ្ងៃស្របតាមស្តង់ដារប្រកបដោយគុណភាពខ្ពស់ដែលផ្តោតលើសារៈសំខាន់នៃការតាមដានស្ថេរភាពនិងជំនឿចិត្តសម្រាប់ក្រុមហ៊ុនទាំងមូល។

ផ្នែកមួយនៃលក្ខខណ្ឌសុវត្ថិភាពនិងសុខភាព ការវាយតម្លៃហានិភ័យ ការកំណត់អត្តសញ្ញាណហានិភ័យ និងដំណើរការត្រួតពិនិត្យត្រូវបានកំណត់នៅក្នុងប្រតិបត្តិការអាជីវកម្មនិងត្រូ ដាក់ឱ្យអនុវត្តហើយកត់ត្រាជា ប្រព័ន្ធ។ ដំណើរការ នេះជួយកំណត់អត្តសញ្ញាណគ្រោះថ្នាក់ដែលអាចកើតមាននៅក្នុងមជ្ឈដ្ឋានការងារ ដើម្បីផ្តល់នូវវិធានការត្រួតពិនិត្យដែលសមស្រប។

យើងបង្កើតវប្បធម៌បង្ការការពារដ៏រឹងមាំ រួមទាំងសុវត្ថិភាព សុខភាព និងសុខុមាលភាពនៅកន្លែងធ្វើការ គុណភាព សុខសុវត្ថិភាព និងបរិស្ថាន ("QHSE") របស់យើងរួមចំណែកនិងអប់រំនិយោជិតជាប្រចាំ។ កម្មវិធីបណ្តុះ បណ្តាល និងចំណេះដឹងបានធ្វើឡើងដើម្បីផ្តល់ជូនដល់និយោជិតនិងអ្នកម៉ៅការម៉ៅការបន្ត(បើចាំបាច់) នូវព័ត៌មានពាក់ព័ន្ធនិងថ្មីៗដើម្បីបំពេញកាតព្វកិច្ចផ្នែកសុវត្ថិភាពនិងសុខភាព។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

### សុខុមាលភាពអតិថិជន និងការជ្រើសរើសអ្នកផ្គត់ផ្គង់ និងអ្នកម៉ៅការបន្ត

សកម្មភាពអាជីវកម្មរបស់ **ថផខ** តម្រូវឲ្យគណៈគ្រប់គ្រងត្រូវធ្វើការដោយផ្ទាល់ឬដោយប្រយោលជាមួយអតិថិជនដែលភាគច្រើនជាអ្នកដែលអាចយល់ច្រើនផ្នែក។ អភិបាលប្រតិបត្តិ ត្រូវធ្វើការជាមួយបុគ្គលិកជនខ្ពស់នៃប្រភេទអតិថិជននោះដោយផ្ទាល់ដើម្បីធានាថាការទំនាក់ទំនងផ្លូវការនិងតម្លាភាពក្នុងការដោះស្រាយតម្រូវការអតិថិជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ជាតិ។

ម្យ៉ាងវិញទៀត ក្នុងនាមជាអ្នកម៉ៅការ EPCC **ផថខ** បានដាក់ចេញនូវគោលនយោបាយលទ្ធកម្មរបស់សម្ព័ន្ធក្រុមហ៊ុនដើម្បីធានាដល់ការជ្រើសរើសអ្នកផ្គត់ផ្គង់ និងអ្នកម៉ៅការបន្តដែលត្រូវអនុវត្តដោយផ្អែកលើរយៈពេល កំណត់ដោយអនុលោមតាមច្បាប់បទបញ្ញត្តិគ្រប់គ្រងពន្ធនិងប្រតិបត្តិការភាគីពាក់ព័ន្ធ។

### ការប្រឆាំងអំពើពុករលួយ

គោលនយោបាយប្រឆាំងអំពើពុករលួយនិងសូកប៉ាន់នៃសម្ព័ន្ធក្រុមហ៊ុនបានចែងថាពុំមានការអនុគ្រោះដែលឈានទៅរកអំពើសូកប៉ាន់ឬពុករលួយឡើយ។ អំពើសូកប៉ាន់និងពុករលួយគ្រប់ទម្រង់ដែលទាក់ទង នឹងសកម្មភាពអាជីវកម្មត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹង។ ដំណើរការអភិបាលកិច្ចសម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ ក្នុងមុខងារអាជីវកម្មដែលមានការត្រួតពិនិត្យ និងតុល្យភាពគ្រប់គ្រាន់ដើម្បីបណ្តុះបណ្តាលសុច្ចរិតភាពការងារ ។ និយោជិតមិនត្រូវផ្តល់ដោយផ្ទាល់ ឬតាមរយៈភាគីខាងក្រៅនូវការសន្យា ការផ្តល់ សិទ្ធិអនុញ្ញាត សំណើ ឬទទួលយកផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុឬប្រយោជន៍ផ្សេងដទៃទៀតដើម្បីទទួលបានការរក្សាអាជីវកម្មឬផលប្រយោជន៍ផ្ទាល់ខ្លួនដែលប្រព្រឹត្តិមិនត្រឹមត្រូវដល់ការធ្វើអាជីវកម្មឡើយ។ ការឧស្សាហ៍ព្យាយាមសមស្រប នឹងត្រូវអនុវត្តនៅពេល ផថខ រួមចំណែកជាមួយភាគីទីបី ដូចជាភ្នាក់ងារ អ្នកចែកចាយ ឬដៃគូបណ្តាក់ទុន សម្រាប់ការរៀបចំអាជីវកម្មដើម្បីធានាបានថាពួកគេនឹងមិនប្រព្រឹត្តអំពើពុករលួយ និងតាមដានការអនុវត្តរបស់ ពួកគេជាប្រចាំដើម្បីធានាបាននូវការអនុលោមភាពបន្ត។ **ផថខ** នឹងប្តេជ្ញាអនុវត្តសកម្មភាពប្រកបដោយវិជ្ជាជីវៈ យុត្តិធម៌ សុច្ចរិតភាព និងសមធម៌នូវរាល់ទំនាក់ទំនងអាជីវកម្មគ្រប់ទីកន្លែងដែលយើងដំណើរការអនុវត្តនិងពង្រឹងប្រព័ន្ធប្រកបដោយប្រសិទ្ធភាពដើម្បីការពារឬប្រឆាំងការសូកប៉ាន់និងអំពើពុករលួយ។

### ការការពារបរិស្ថាន

ផថខ ប្តេជ្ញាការពារបរិស្ថាន និងគោរពតាមច្បាប់/បទបញ្ញត្តិបរិស្ថានជាធរមាន។ ដោយផ្អែកលើឯកសារយោងនៃសម្ព័ន្ធក្រុមហ៊ុន **ផថខ** បានអនុវត្តការកំណត់អត្តសញ្ញាណនិងការវាយតម្លៃផលប៉ះពាល់បរិស្ថាន ("EAIA") ដើម្បីកំណត់និងវាយតម្លៃស្ថានភាពនិងផលប៉ះពាល់បរិស្ថានទាក់ទងនឹងសកម្មភាពអង្គភាពផលិតផល និងសេវាកម្មរៀងៗខ្លួន។

អំឡុងពេលវាយតម្លៃនៃផលប៉ះពាល់គម្រោង ផថខ នឹងពិចារណាលើច្បាប់និងបទបញ្ញត្តិបរិស្ថាន ពាក់ព័ន្ធ ផលវិបាក បញ្ហាធ្ងន់ធ្ងរ និងលទ្ធភាពនៃការកកើតបញ្ហា។ ការវាយតម្លៃពីផលប៉ះពាល់សំខាន់ៗត្រូវបានវាយ តម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបានកំណត់។ ជាឧទាហរណ៍ទំហំនៃភាពធ្ងន់ធ្ងរ/ហានិភ័យរយៈពេលប៉ះពាល់លទ្ធភាពកកើត។ល។ លទ្ធផលនៃការវាយតម្លៃ **ផថខ** នឹងរៀបចំផែនការសកម្មភាពនិងការត្រួតពិនិត្យឲ្យមានប្រសិទ្ធភាពដើម្បីកាត់បន្ថយផលប៉ះពាល់សំខាន់ៗនោះ។

### ទំនាក់ទំនងក្នុងសហគមន៍

ផថខ ជឿជាក់ថាការទទួលបាននូវបរិក្ខារអគ្គិសនីមានសារៈសំខាន់ណាស់ក្នុងការបំបែកវដ្តភាពក្រីក្រនៅប្រទេស កម្ពុជា។ ស្របតាមរដ្ឋាភិបាលកម្ពុជាកំពុងខិតខំប្រឹងប្រែងឥតឈប់ឈរដើម្បីបង្កើតហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីក្នុងការផ្តល់លទ្ធភាពប្រើប្រាស់អគ្គិសនីដល់សហគមន៍ជនបទ។ PESTECH បានដើរតួយ៉ាងសំខាន់ក្នុងការនាំយកហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនីមកកាន់សហគមន៍នៃប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០១២។

ច្រើនឆ្នាំមកនេះ ផថខបានបញ្ចប់គម្រោងសំខាន់ៗជាច្រើនដោយជោគជ័យរួមទាំងគម្រោងបញ្ជូន ភ្នំពេញ-កំពង់ចាម គម្រោងប្រព័ន្ធបញ្ជូន ២៣0kV កំពង់ចាម-ក្រចេះ និងគម្រោងប្រព័ន្ធបញ្ជូន ២៣0kV និង ៥00 kV ភ្នំពេញ-ព្រះសីហនុ។

ការបញ្ចប់គម្រោងខាងលើនេះបានផ្តល់ឱ្យមានការតភ្ជាប់ចរន្តអគ្គិសនីទៅតាមតំបន់ជនបទដែលមានប្រជាជនរស់នៅ។ ខណៈពេលដែលការបរិច្ចាគប្រាក់ត្រូវបានឱ្យតម្លៃយើងជឿថាស្នូលសំខាន់ពិតប្រាកដនៃការទទួលខុសត្រូវសង្គមគឺស្ថិតនៅពីក្រោយមូលហេតុដែលមានអត្ថន័យសម្រាប់អាជីវកម្មរបស់យើង។ មតិយោបល់ ដែលយើងប្រមូលបានតាមរយៈការចូលរួមជាមួយអ្នកភូមិអំពីរបៀបតភ្ជាប់អគ្គិសនីបាននាំមកនូវការផ្លាស់ប្តូរយ៉ាងធំដល់ជីវិតរបស់ពួកគេគឺជាសេចក្តីប្រាថ្នា និងការលើកទឹកចិត្ត។ **ផថខ** សម្លឹងមើលការពង្រីកបុព្វហេតុល្អទៅកាន់សហគមន៍កាន់តែជាច្រើននៅជុំវិញតំបន់ខណៈពេលការធ្វើអាជីវកម្មរបស់យើងប្រកបដោយនិរន្តរភាព។

# របាយការណ៍អភិបាលកិច្ចប្រចាំឆ្នាំ

អំឡុងពេលនៃជំងឺរាតត្បាត ពុំបានបញ្ឈប់ **ផថខ** ក្នុងការបន្តសកម្មភាពអនិវត្តកម្មវិធី CSR របស់ខ្លួនដែលផ្ដោតលើគោលការណ៍ (៤) យ៉ាងរួមមាន មូលដ្ឋានថែរក្សារសហគមន៍ ការអភិវឌ្ឍន៍ ការស្ដារឡើងវិញ និងបរិស្ថានដូចខាងក្រោម៖

| ល.រ | អ្នកទទួលផលប្រយោជន៍ | ចំនួន | គោលបំណង CSR |
|---|---|---|---|
| ១ | កាកបាទក្រហមកម្ពុជា | ៣៥ ០០០.០០ ដុល្លារអាមេរិក | បម្រើសកម្មភាពសប្បុរសធម៌ក្នុងការជួយដល់ប្រជាពលរដ្ឋដែលកំពុងជួបគ្រោះធម្មជាតិ និងគ្រោះផ្សេងៗ។ |

### ផ្នែកទី ៦ - ការបង្ហាញព័ត៌មាន និងតម្លាភាព

### ពិពណ៌នាអំពីយន្តការនៃការបង្ហាញព័ត៌មានដោយរៀបរាប់ពីមធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

ក្រុមប្រឹក្សាភិបាលដែលមានជំនួយពីបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវដូចខាងក្រោម៖

ក) ត្រូវកំណត់ថាតើព័ត៌មានណាជាព័ត៌មានដែលមានលក្ខណៈជាសារវ័ន្ត យោងតាមច្បាប់និងបទប្បញ្ញត្តិរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (**ផ.ម.ក**) និងនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក**)
ខ) ត្រូវធានាថាព័ត៌មានទាន់ពេលដែលមានលក្ខខណៈជាសារវ័ន្តគឺត្រូវបង្ហាញទាន់ពេលដល់វិនិយោគិនសាធារណៈយោងតាមច្បាប់និងបទប្បញ្ញត្តិរបស់ (**ផ.ម.ក**) និង (**ន.ម.ក**)
គ) ត្រូវឆ្លើយតបទាន់ពេលពាក់ព័ន្ធនឹងពាក្យចចាមអារ៉ាម ឬការរាយការណ៍និងសកម្មភាពទីផ្សារដែលខុសប្រក្រតី។

បន្ទាប់ពីបានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាភិបាល បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន អាចផ្តល់ព័ត៌មានទៅសារព័ត៌មាន សមាគមវិនិយោគិន និងបុគ្គលខាងក្រៅ រួមទាំងព័ត៌មានដែលត្រូវផ្សព្វផ្សាយនៅលើគេហទំព័ររបស់ក្រុមហ៊ុននៅផ្នែកទំនាក់ទំនងវិនិយោគិន។

### ទំនាក់ទំនងវិនិយោគិន

អភិបាលប្រតិបត្តិ លោក Charles Tan មានភារកិច្ចត្រួតពិនិត្យសកម្មភាពអភិវឌ្ឍន៍សាជីវកម្មសម្រាប់ **ផថខ** ដែលពាក់ព័ន្ធនឹងទំនាក់ទំនងវិនិយោគិន។ លោកបានរួមចំណែកជានិច្ចជាមួយអ្នកវិភាគ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីលើកកម្ពស់សក្តានុពលកំណើនសាជីវកម្មរបស់ ផថខ ព្រមទាំងធ្វើ បច្ចុប្បន្នភាពជាប្រចាំជាមួយការអភិវឌ្ឍន៍ថ្មីៗរបស់ក្រុមហ៊ុន។

គេហទំព័រ **ផថខ** www.pestech.com.kh មានតួនាទីជាបណ្តាញទំនាក់ទំនងសំខាន់សម្រាប់ភាគហ៊ុនិក វិនិយោគិនសាធារណៈ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការទទួលបានព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពព័ត៌មានពាក់ព័ន្ធនឹងសកម្មភាពរបស់ក្រុមហ៊ុន លទ្ធផលហិរញ្ញវត្ថុ ការអភិវឌ្ឍយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន និងបញ្ហាផ្សេងទៀតដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ។

www.pestech.com.kh

**Office Address**

10th Floor, Building No. 35, Mao Tse Toung Boulevard,
Phum 09, Sangkat Boeung Keng Kang I, Khan Boeung Keng Kang,
Phnom Penh, Kingdom of Cambodia

**Our Projects/Products Reach:**

Australia | Brunei | Cambodia | China | Ghana | Indonesia | Iraq | Kyrgyzstan | Malaysia | Mali | Myanmar
Papua New Guinea | Philippines | Singapore | South Africa | Sri Lanka | Tanzania | Thailand | Vietnam